ENJOY READING

បើចង់ស្រលាញ់ អូនគិតថ្លៃប៉ុន្មាន

តំលៃ ១១០០០៛

Amazing Shelf

www.amazingshelf.blogspot.com

Credits go to

Publisher .... Obsok Publisher
Scanner .... Ewil
Editor .... Ewil
Page-checker .... Ewil

OBSOK
LOVE SERIES

បើចង់ស្រលាញ់ អូនគិតថ្លៃប៉ុន្មាន

ផ្ដើមរឿង

"ម៉ាថុងអ៊ីល! មានស្ដាប់អត់ហ្នឹង!"

"ហឺ..ហឺ?"

"មមើស្អី ពួកយើងកំពុងនិយាយជាមួយឯង!"

មើលទៅខ្ញុំដូចជាធ្វើខ្លួនគ្មានមាយាទហើយ ទៀតហើយ ខ្ញុំមមើមមាយទៀតហើយ ។

"ឯងកើតអីអត់នេះ ច្រើនថ្ងៃហើយដែលខ្ញុំឃើញឯងមមើ ធ្វើដូចមនុស្សមានស្នេហា" សេសីជីន កម្លាយខសង្កេតដែលជាអ្វីដែលក្មេងស្រីដូចជាយើងចាប់អារម្មណ៍បំផុត ធ្វើឲ្យមិត្តក្នុងក្រុមនាំគ្នាងាកមកមើលមុខខ្ញុំភ្លាម "នេះឯងប្រហែលជាមិនបានមានស្នេហាទេមែនទេ"

"អា...អាច្កួត និយាយស្អីនេះ"

"ហេ៎ វាធ្វើបែបនេះប្រែថាមានស្នេហាហើយ អ្ហ៎ា ដូរប្រធានបទពី...ចាប់មនុស្សប្រុសបែបណាឲ្យយើងមើលទៅមានបារមី មកចាប់អារម្មណ៍អ្នកដែល ម៉ាថុងអ៊ីល លួចចូលចិត្តល្អជាង គ្រាប់ភ្លៀងជាថៃថ្លៃ ភពអង្គារជាមុខដូរម៉េន មិនខានទេ!"

មិត្តភក្តិនៅជុំវិញខ្លួនខ្ញុំនាំគ្នាស្រែកគ្រឹតដោយគ្មានអារម្មណ៍ថាខ្មាសអៀនអ្នកណា មនុស្សម្នានៅក្នុងហាងបាយនាំគ្នាងាកមកមើលពួកយើង ហើយធ្វើមុខខ្លាដាក់...សុំទោសជងអ្នករាល់គ្នា ដែលមិត្តភក្តិខ្ញុំក្លាយជាបែបនេះ ។

"ស្អីដែលធ្វើឲ្យពួកឯងគិតថាខ្ញុំ...កំពុងលួចចូលចិត្តអ្នកណា..."

"ព្រោះឯងធ្វើសម្លេងញ៉ាវ" សេសីជីន ។

"គ្រាន់តែប៉ុណ្ណឹង!"

"មនុស្សដូចឯងមិនធ្លាប់ធ្វើឫកចម្លែកៗក្រៅពីរភើបភ្ញាក់ផ្អើលស្អីច្បាស់ៗនោះទេ ហើយវ័យរបស់យើងពេលនេះគឺជាវ័យដែលត្រូវចាប់អារម្មណ៍ភេទប្រុស!"

"ភេទដូចគ្នា" ខ្ញុំ ។

"នោះណ៎ ឯងព្រមទទួលហើយ"

"អត់ទេ"

"និយាយ"

ការដាក់សម្ពាធរបស់មិត្តភក្តិដែលអង្គុយឡោមព័ទ្ធនៅត្រង់នោះធ្វើឲ្យខ្ញុំដកដង្ហើមធំចេញមកពួហៀក ហ៎...សូម្បីតែខ្ញុំខ្លួនឯងនៅមិនប្រាកដចិត្តផងថាដែលគិតតែអង្គុយខ្វល់ចិត្តរាល់ថ្ងៃនេះគឺជារឿងអ្វី ។

"ខ្ញុំមិនប្រាកដចិត្ត តែនឹងនិយាយឲ្យស្តាប់ថាកំពុងគិតអី"

"*O*" គ្រប់គ្នា ។

"គឺ...កាលពីច្រើនថ្ងៃមុនខ្ញុំជួបប្រុសចម្លែកម្នាក់"

"ឃើញទេ ខ្ញុំប្រាប់ហើយថាជាមនុស្សប្រុស!" សេសីជីន ។

"ឯងតាំងចិត្តស្តាប់មែនទែនអត់នេះ"

"អូខេ លែងកាត់ហើយ និយាយទៅ!!!"

សម្រេចថាខ្ញុំសុំនិយាយបែបសង្ខេបៗទៅចុះ នឹងបានកាត់បទសន្ទនាដ៏គ្មានប្រយោជន៍របស់មិត្តភក្តិចេញ ។

ខ្ញុំឈ្មោះ ម៉ាថុងអ៊ីល អាយុ១៧ឆ្នាំ ជាកូនស្រីទោល (កុំក្រៅរឿងបានទេ) អូខេ! ចូលសាច់រឿងក៏បាន ពេលនេះខ្ញុំកំពុងនឹកដល់ប្រុសម្នាក់ដែលបានសាងភាពជាប់ចិត្តចម្លែកដល់ខ្ញុំ...

នៅក្នុងពេលនោះជាវេលាព្រឹក មានភ្លៀងធ្លាក់ប្រុយៗ ធ្វើឲ្យថ្នល់ទទឹកជោក ល្ហូតដល់ខ្លាចថាខ្លួនឯងនឹងរអិលដួលបោកក្បាល វាចំជាថ្ងៃដែលបរិយាកាសមើលទៅកណ្តោចកណ្តែងអស់ទាស់តែម្តង ដែលខ្ញុំមិនចូលចិត្តឡើយ...តែអំឡុងពេលដែលចាំឡានក្រុងនោះ ក៏ក្រលេកទៅឃើញអ៊ំស្រីម្នាក់ព្យាយាមដើរឆ្លងថ្នល់ត្រង់ចំណុចដែលគ្មានគំនូសស មានឡានរថយន្តច្រើនកំពុងតែរិះគន់គាត់ សូម្បីតែខ្ញុំ...

ហើយភាពជាតួឯកស្រីរបស់ខ្ញុំក៏បណ្តាលឲ្យខ្លួនឯងសម្រេចចិត្ត

ដើរទៅជួយអ៊ំស្រី តែថា...

ប្រឺន~

សម្លេងស៊ីភ្លេឡានលាន់ដូចសម្រែកសេះទាំងហ្វូងឮនៅជិត មិនចាច់មើលក៏ស្រមៃបានថាឡាននេះកំពុងតម្រង់មកដែរ ហើយមិនដល់មួយចម្រៀកនាទីផង អ្វីដែលស្រមៃទុកក៏មកដល់ ឡាននាំចូលពណ៌ក្រហមដូចឈាមស្ទុះចូលមកដោយល្បឿនលឿន ។

ងឹត!!!

សម្លេងកង់ឡានអូសនឹងថ្នល់យ៉ាងវែងដូចសម្លេងស្រែករបស់ស្រីៗរោគចិត្ត ប្តឹងថាអ្នកបើកជាន់ហ្វ្រាំងកប់ជើង អ៊ំស្រីដែលកំពុងឆ្លងថ្នល់ក៏ស្រែកចាចចេញមកដោយសម្លេងមនុស្សចាស់ ។

'អ្ហា!!!'

'អ៊ំស្រី ធ្វើអីផស់អ៊ំហ្នឹង!'

ប៉ាំង!

សម្រែករបស់អ្នកបើកឡានហៅខ្សែភ្នែករាប់សិបគូនៅចំណតឡានក្រុងឲ្យងាកមកមើល ឫកពាមុតមាំប្រាកដប្រជាបូកនឹងសម្លេងដែលពោរពេញទៅដោយអំណាចនោះធ្វើឲ្យអ៊ំស្រីដែលស្រែករន្ធត់ចិត្តទៅជាបិទមាត់ជិតភ្លាម ។

'ថ្នល់ក៏រអិល ស្ពានអាកាសនៅលើក្បាលសោះ ម៉េចក៏ម៉ោឆ្លងផ្លូវនេះ បើខ្ញុំបើកបុក តើគិតម៉េច ហើយកូនចៅទៅណាអស់!'

'អ៊ំ...អ៊ំ...អ៊ំ'

'សំណាងហើយឡាននេះមានប្រព័ន្ធគ្រប់គ្រងហ្វ្រាំងបានល្អ មិនអីចឹងអ៊ំនឹងយ៉ាប់ហើយ លើកក្រោយកុំធ្វើអីចឹងទៀត យល់ទេ'

'អ៊ំយល់ហើយ'

'ជើងមិនល្អហើយមានសិទ្ធមិនបាច់ឆ្លងស្ពានអាកាសឬក៏ម៉េច'

សម្លេងរករឿងរបស់ប្រុសម្នាក់នោះធ្វើឲ្យភ្លើងឆេះពេញរាងកាយខ្ញុំ ផ្លូវរអិលយ៉ាងនេះ ខ្លួនឯងហ្នឹងហើយខុសដែលបើកឡានលឿនដល់ថ្នាក់នេះ នៅមកបន្ទោសមនុស្សចាស់ជើងមិនល្អទៀត ហ៊ឺយ!

'ហើយអ្នកនៅត្រង់នោះគ្មានអ្នកណាចង់ជួយអ៊ំទេឬក៏ម៉េច នេះ

ដាទសមនុស្សអាត្មានិយមឬក៏អ្វី ឃើញចាស់ៗដើងមិនមាំដើរច្លងផ្លូវ ហើយមិនគិតនឹងជួយ'

'*o*' គ្រប់គ្នាដែលឈរនៅចំណតឡាន រួមទាំងខ្ញុំផងទៅជាកាំង ដូចរូបចម្លាក់ ។

'ជាអ្នកក្រក៏ខុសទៅហើយ នៅអាត្មានិយមទៀត!'

'ហេ៎ ឯងនិយាយឈ្លើយបែបនេះ ឯងជាអ្នកណាពីយ'

'ជាអ្នកណាក៏បានដែលមានជាងពួកឯងហ្នឹងហើយ'

ពេលនិយាយចប់ គេក៏កៀកដៃអ៊ំស្រីជើងមិនស្ទូវមាំ ហើយសួរដោយសម្លេងមាំ...

'អ៊ំចង់ច្លងថ្នល់មែនទេ តោងដៃខ្ញុំឲ្យជាប់ទៅគឺបានហើយ លើកមុខលើកក្រោយកុំធ្វើបែបនេះទៀត បើខ្លួនឯងច្លងស្ពានអាកាសមិនកើត...'

'ចង់នាំអ៊ំច្លងឬ'

'អ៊ំក៏ដេកក្នុងផ្ទះទៅ'

' '

...

'ចង់បានអីក៏ឲ្យកូនចៅទៅទិញឲ្យ មិនមែនចេញម៉ោធ្វើអីដោយខ្លួនឯងយ៉ាងនេះទេ កុំប្រាប់ណាថាចាស់ប៉ុណ្ណឹងហើយនៅគ្មានកូនចៅប្តីសីទៀត'

'មា...មាន'

'អឺ ប្រាប់ឲ្យពួកនោះម៉ោជួយម៉ោ ចេញម៉ោខ្លួនឯងធ្វើអី ឬបើចាំបាច់ត្រូវចេញម៉ោ ក៏សុំឲ្យកូនចៅជូនម៉ោទៅ'

គេរអ៊ូពេញតែផ្លូវដែលនាំអ៊ំស្រីច្លងថ្នល់ ពេលជូនដល់ចិញ្ចើមផ្លូវម្ខាងទៀតបានហើយ ខ្លួនឯងក៏ច្លងស្ពានអាកាសត្រលប់មកវិញ ហើយសម្លឹងមកចំណតឡានក្រុងដែលមានអ្នកខ្លះដែលឈរមុននេះចេញដំណើរទៅបាត់ហើយ ។

'មើលអី'

គ្រប់គ្នាគេចខ្សែភ្នែក លើកលែងតែខ្ញុំដែលមើលគ្នាទាំងមីងមាំងមិនដឹងថាចង់ជេរ ឬចង់សរសើរ ហើយព្រោះមានតែខ្ញុំម្នាក់ដែល

មើល ទើបគេប្រសព្វភ្នែកជាមួយ ហើយធ្វើមុខស្អុយ ។
'មិនដែលឃើញអ្នកមានជួយសង្គមទេឬយ៉ាងម៉េច'
'=O='
នោះហើយគឺជារូបភាពចុងក្រោយដែលខ្ញុំដូចជាជាប់ចិត្តលាយ ខឹង ដែលគេយកការឌឺដងសង្គមទាំងអស់មកទម្លាក់លើខ្ញុំដែលហ៊ានប្រសព្វភ្នែកគេតែម្នាក់ឯង ។

ត្រលប់ចូលមករកការសន្ទនារវាងខ្ញុំនិងក្រុមមិត្តភក្តិវិញ
"ហើតយគេសង្ហាទេឯង" សីជីន ។
"គឺ...មើលទៅល្អទេដឹង ស ខ្ពស់ ហើយក៏ព្រោះមានឡានកាលីបមួយគ្រឿងនោះដែរទើបកាន់តែធ្វើឲ្យគេមើលទៅសង្ហា"
"បានឮថាជាឡានទាំចូល ប្រែថាច្បាស់ជាមានហើយ ខ្ញុំចង់ជួបដល់ហើយ បើពេលនោះអ្នកឈរនៅត្រង់ចំណតឡានក្រុងជាខ្ញុំ ខ្ញុំនឹងស្ទុះទៅសុំស្គាល់និងសុំលេខទូរសព្ទគេហើយ!"
"ឯងឆ្កួតទេអ៊្ហូស ហ៊ានពេកហើយ"
"កុំទៅស្ដាប់អី សេសីជីន ហ៊ានតាំងពីដើមហើយ ចុងអ៊ីល ឯងក៏ដឹងថានាងប្រមក់ហ្នឹងចាប់អារម្មណ៍តែប្រុសមាន។"
"ប្រាកដហើយ ប្រុសមាន។ធ្វើឲ្យយើងមិនចាច់ចាញ់ប្រៀបច្រើនពេលទៅញ៉ាំបាយ មើលកុន ស្ដាប់ភ្លេង ពេលមានបុណ្យសំខាន់។យើងក៏បានទទួលកាដូមានតម្លៃ ទោះជាយើងឲ្យគេវិញត្រឹមតែគុកគី ដូចបុរសអ្នកមានចុងក្រោយរបស់ខ្ញុំ គឺមសាំយ៉ុង តាំងពីសេពគប់គ្នាម៉ោខ្ញុំសឹងតែមិនចាច់ចេញលុយអស់ម៉ារ៉ុនពេលទៅញ៉ាំបាយជាមួយគេ"
"គេមិនគិតថាឯងទៅបោកគេទេឬ" ខ្ញុំសួរ ។
"ទោះជាដឹងថាបោកក៏គេនៅតែពេញចិត្តហ្នឹង នៅខណៈដែលគេឲ្យអី។ខ្ញុំ ខ្ញុំក៏ចាំប្រណិបត្តិវិញ ចាត់ទុកជាការដោះដូរ ហើយថ្ងៃនេះគេណាត់ខ្ញុំឲ្យទៅលេងបាររបស់គេទៀតផង"
"ទៅលេងបារ? យើងទើប១៧ហ្នឹង"
"គឺជាបាររបស់គេ ពួកយើងចូលបាន ដូច្នេះហើយពួកឯងត្រូវតែ

ទៅ សាំយ៉ុង ឲ្យខ្ញុំបបួលពួកឯងទៅដែរ"

"ខ្ញុំសុំមិ..."

"មិនបាន ឯងមិនដែលទៅដើរលេងជាមួយមិត្តភក្តិទេ លើកនេះបើឯងបដិសេធ ខ្ញុំកាត់កាលចោល"

លេងគ្នាយ៉ាងនេះផង...

"មិនចង់ជឿសោះថាពួកឯងម៉ោបានពិតមែន មិនបានសង្ឃឹមទេនេះ តែក៏អរគុណ"

ស៊ីជីន ដែលតែងខ្លួនស្អាតលើសវ័យបន្តិច ធ្វើឲ្យខ្ញុំនិងបក្ខពួកដែលត្រូវអញ្ជើញមកដោយមើលទៅជាក្មេងមិនទាន់គ្រប់អាយុ ពាក្យថាបារនៅក្នុងខួរក្បាលខ្ញុំវាជាអាណាចក្រមួយដែលក្មេងអាយុស្រករខ្ញុំមិនគួរសូម្បីតែនិយាយពាក្យថា បារ ចេញពីមាត់ ថែមទាំងត្រូវកុហកម៉ាក់ថាមកធ្វើរបាយការណ៍នៅផ្ទះមិត្តភក្តិទៀត ហើយ...សុំលើកនេះតែម្តងទេ តែម្តងពិតមែន ។

យល់ដល់ដែលប្រាប់ថាមានប្រុសសង្ហាច្រើន (អន់ចរិតភ្លាម) ។

ទីនេះតុបតែងបានកាលីបដល់ថ្នាក់គួរឲ្យសង្ស័យ បារធំដល់ថ្នាក់នេះ ម៉េចក៏គ្មានមនុស្ស?

"មនុស្សទៅណាអស់ហើយ"

"ថ្ងៃនេះគេបិទហាង"

"អ្ហ៎ា បិទហាង? ចុះឲ្យយើងចូលម៉ោធ្វើអី"

"បិទហាងដើម្បីឲ្យមានតែពួកយើងហ្នឹងអ្ហ៎"

"អ្ហ៎ អីចឹងទេអ្ហ៎"

ហែសូមែនៗ ជាអ្នកមានគឺវាល្អអីចឹង គិតចង់បើកក៏បើក ចង់ធ្វើអីក៏ធ្វើ អ្នកមានធ្វើអីក៏មិនគួរឲ្យស្អប់ ខ្ញុំចង់ឃើញសង្សាររបស់ ស៊ីជីនដល់ហើយ ថាវាយ៉ាងម៉េច តែបានឮថាវ័យស្រករៗគ្នា អាចនឹងមានដោយសារប៉ាម៉ាក់ទេដឹង ។

"សាំយ៉ុង ខាងនេះ!"

ស៊ីជីន គ្រវីដៃហៅ សាំយ៉ុង ដែលបានឮញឹកញាប់ថាជាឈ្មោះ

សង្សារនាងបច្ចុប្បន្ន អ្នកដែលត្រូវហៅមើលមកដោយឫកពាទឹងទីង និងងក់ក្បាលញញឹមដាក់ ។

"តស់ទៅ"

សរុបទៅ អ្នកណាហៅអ្នកណានេះ ខ្ញុំច្របូកច្របល់អស់ហើយ!

គឺមិនដឹងទេថាគ្រប់គ្នាមានអារម្មណ៍យ៉ាងម៉េច តែពេលនេះខ្ញុំមានអារម្មណ៍តឹងថប់ខ្លាំងណាស់ ព្រោះ គីមសាំយ៉ុង របស់មិត្តនារីធ្វើឱ្យខ្ញុំមានអារម្មណ៍ថាខ្លួនឯងដូចកំពុងត្រូវដាក់សម្ពាធចម្លែក។ គេធ្វើខ្លួនមើលទៅមានអំណាច បញ្ហានេះបញ្ហានោះ មិនថា ស៊ីជីននិយាយអីគឺគ្រាន់តែងក់ក្បាល មិនញញឹម មិនសើច ហើយក៏មិនបានធ្វើឫកពាដូចជាយល់ស្រប ទំនងថាមិត្តខ្ញុំប៉ះចោចតែម្នាក់ឯង ។

"ហើយពួកនេះជាមិត្តរបស់អូន ម្នាក់នោះឈ្មោះទំពាំងចាយជូរម្យៅ និងម្នាក់នេះ ម៉ាចុងអ៊ីល"

"អ្ហឺ...អ្នកដែលអូនចូលចិត្តនិយាយញឹកញាប់ហ្នឹស"

ហឺ? និយាយដល់ខ្ញុំញឹកញាប់ឬ? ល្អមៗបានហើយ...សេស៊ីជីនខ្ញុំនៅតែខ្ញុំសុខៗ យកខ្ញុំមកនិយាយឱ្យសង្សារខ្លួនឯងស្តាប់ធ្វើអី!

"ចុះថ្ងៃនេះបងមោតែម្នាក់ឯងទេហ្អេស ក្រែងថាមានមិត្តភក្តិមោជាមួយដែរហ្អ៎"

មកតែម្នាក់ឯង ខ្ញុំក៏គ្មានតឹងសឹងដកដង្ហើមមិនចេញទៅហើយនេះលេងនាំមិត្តភក្តិមកទៀតឬ ខ្ញុំប្រហែលជាត្រូវរកថង់ O_2 មកដកមុននឹងអស់ខ្យល់ដង្ហើមហើយ ខ្ញុំមិនគួរណាមកទេ ត្រលប់ទៅផ្ទះក៏ល្អពូម៉ាក់ប្រាប់ថាមានរឿងចង់និយាយជាមួយផង មិនឃើញសប្បាយអីសោះ អ្ហា!

"មិនឃើញឯងប្រាប់ថានឹងនាំមិត្តភក្តិមោច្រើនអីចឹងទេ"

សម្លេងប្រហែលៗនោះធ្វើឱ្យខ្ញុំដែលកំពុងគិតចង់ទៅផ្ទះគិតតែអង្គុយធ្វើខ្លួនឡើងរឹងកំព្រឹស វាចំជាដូចសម្លេង...សម្លេងដែលខ្ញុំគិតតែនឹកដល់រហូត ។

"បើប្រាប់ ឯងប្រហែលមិនមោទេ អង្គុយសិនមោ"

ហើយភ្លាមនោះពេលម្ចាស់សម្លេងមហាប្រហែលៗនោះអង្គុយ

ចុះ ខ្ញុំក៏ងើយមុខទៅប្រសព្វនឹងភ្នែកគេល្មម មុខបែបនេះ ខ្សែភ្នែកបែបនេះ សម្លេងបែបនេះ វា...វា!!!

"អ្នកមាន"

"ហឺ?" អ្នកដែលទើបអង្គុយចុះងើយមុខមើលខ្ញុំដោយខ្សែភ្នែកមិនពេញចិត្តយ៉ាងខ្លាំង "មែន ខ្ញុំមាន មើលដឹងងាយមែន"

វាជាអ្នកណាទៅរួចបើមិនមែនជាអាប្រុសម្នាក់នោះ ហេតុអីក៏ជែនដីនេះមូលម្ល៉េះ?

"ឯងនិយាយអី" សឺជីន ក្តិចដៃខ្ញុំហួតដល់ត្រូវវាសដៃគេចហើយស៊ុតមាត់ "រឿងខ្លះឯងគួរតែបិទមាត់ទៅ មិនបាច់ហើបក៏បាន"

"មិនមែនអីចឹងទេ វា...ណេ្ហីយ ខ្ញុំសុំទៅបន្ទប់ទឹកសិន"

មិនបានទេ ខ្ញុំត្រូវទៅតាំងគោលជំហរសិន ថ្ងៃនេះទើបតែនិយាយដល់ គិតដល់មាន មាន់ក៏មកដល់ (ពាក្យស្លោកនេះប្រើបានរហូត) ។

សា!!! @ amazingshelf.blogspot.com

ខ្ញុំបើកទឹកលាងមុខដោយត្រូវការភ្ញាក់ពីសុបិន ហេតុអីក៏បេះដូងខ្ញុំលោតញាប់យ៉ាងនេះ នេះខ្ញុំញាប់ញ័រដែលបានជួបគេឬនេះ!

"ជែនដីមូលឬអត់ មនុស្សយើងបានជួបគ្នាម្តងហើយមិនគួរណាជួបទៀតទេ"

"ឯងនិយាយជាមួយអ្នកណា"

"ហឿក! ឯងផុសមោ៉ពីអង្កាល់!"

សឺជីន ញញឹមស្ញេញបញ្ចេញធ្មេញសក្បុស ហើយប្រញាប់ធ្វើមុខចង់ដឹងចង់ឮភ្លាម ។

"ម៉េចក៏ចាំបាច់ភ្ញាក់ដល់ថ្នាក់ហ្នឹង ឯងជួបស្នេហ៍តំបូងឬ"

"និយាយច្កួតស៊ី!"

"ខ្ញុំឃើញឯងធ្វើមុខដូចជួបខ្មោចពេលឃើញ កូអឹន ហ្នឹងអ្ហ៎ា ម៉េចអ្ហ៎ ឯងចូលចិត្តគេអ្ហ៎ស ឃើញភ្លាមស្រលាញ់ភ្លែតមែនទេ"

"ច្កួត!"

"កុំអីចឹងអ្ហី ខ្ញុំជាមិត្តឯង ឯងប្រាប់ខ្ញុំបានគ្រប់រឿង ម្យ៉ាងទៀត... កូអឹន ក៏សង្ហាណាស់ដែរ ខ្ញុំឃើញម៉េចនៅលោះព្រលឹង"

"ឯងទើបនឹងជួបគេឬ"

"មែន! នេះជាលើកតំបូងហើយដែល សាំយ៉ុង ណាត់ខ្ញុំមកជួបមិត្តរបស់គេ"

"ពួកគេមើលទៅថ្មើងៗម៉េចក៏មិនដឹង"

"អ្នកមានគឺអីចឹង ធ្វើខ្លួនជាអ្នកប្រុស ចូលចិត្តឲ្យគេឯងលើកទូលទើបជាប់និស្ស័យថ្មើងថ្មៃមកប្រើជាមួយអ្នកដទៃ ណ្ហើយៗ គេមិនមែនជាមនុស្សអាក្រក់អីទេ"

"ឯងស្គាល់ គីមសាំយ៉ុង ប៉ុណ្ណាបានជាប្រាកដចិត្តដល់ថ្នាក់នោះ ខ្ញុំមិនឃើញមានអារម្មណ៍ថាគេចូលចិត្តឯងត្រង់ណាផង"

"ឆ្កួត គេចូលចិត្តខ្ញុំសឹងស្លាប់ទៅហើយ"

"តាមដែលឃើញ គឺឯងទេវិញទេដែលចូលចិត្តគេ"

"បើមិនចូលចិត្ត គេណាត់ខ្ញុំម៉ោជួបមិត្តគេធ្វើអី ទើបខ្ញុំត្រូវរកមិត្តមកឲ្យជួបមិត្តគេដែរទៅ បើឯងចូលចិត្ត កូអឺន ខ្ញុំនឹងណែនាំឲ្យ យកទេ"

"មិនបាច់!"

"ចុះមុខក្រហមធ្វើអី"

"ឈប់លេងសើចហើយ ទៅរកសង្សារឯងទៅ"

"ទៅជាមួយគ្នាទៅ"

"ឯងទៅមុនចុះ សុំស្រូបខ្យល់អាកាសបន្តិចទៀតសិន"

"អូខេៗ ចាប់ទៅណ៎ា កុំគេចទៅផ្ទះមុន"

សឺជីន ចេញទៅតាមដែលខ្ញុំសុំ ហើយខ្ញុំក៏ឈរនៅក្នុងបន្ទប់ទឹកមួយសន្ទុះទៀតដើម្បីធ្វើចិត្ត ដូនកាលត្រង់នោះអាចនឹងផឹកពេកទើបខ្ញុំមើលខុស ថែមទាំងសម្លេងភ្លេងក៏ឮខ្លាំងទៀត ទើបខ្ញុំស្តាប់ខុស គិតថាជាសម្លេងប្រុសម្នាក់នោះ សារថ្មី លើកនេះពេលចេញទៅត្រូវប្រើសតិនិងសម្លឹងគេឲ្យច្បាស់។

តស់!

គ្រែក!

ខ្ញុំដើរចេញពីបន្ទប់ទឹកស្រី ហើយក៏រហ័សចូលមកវិញ ហេតុអីអ្នកគឺអាប្រុសម្នាក់នោះ គីមសាំយ៉ុង មកឈរនិយាយគ្នានៅមុខបន្ទប់ទឹក

ប្រុសដែលនៅទល់មុខគ្នាល្មម ឆ្កួតអើយ ម៉េចចាំបាច់មកឈរត្រង់នេះ ហើយខ្ញុំចេញទៅបានយ៉ាងម៉េចនេះ?

"នេះឬស្រីដែលឯងបណ្ដើរ មិនឃើញគួរឱ្យចាប់អារម្មណ៍ដូចរសនិយមរបស់ឯងទាបពេកហើយ"

គូអីន និយាយ ព្រមទាំងឱបដៃ ពេបមាត់ញញើមចម្អក នេះពួកគេកំពុងនិយាយដើមមិត្តខ្ញុំឬអត់?

"បណ្ដោះកួយសិនទៅ ម្យ៉ាងទៀតនាងប្រមក់នោះក៏ប៉ិនយកចិត្តយកថ្លើមដែរ បណ្ដើរហើយមិនគួរឱ្យស្អប់ប៉ុន្មានទេ"

"តែគួរឱ្យស្អប់ត្រង់ដែលសម្ដែងចេញមកពេកថាចូលចិត្តលុយឯងមើលមិត្តនាងទៅ ពេលឃើញខ្ញុំក៏និយាយថា អ្នកមាន គួរឱ្យមើលងាយខ្លាំងណាស់"

និយាយដល់ខ្ញុំទេតើ!

ហើយប្ញកពាមើលងាយមើលថោក សម្លេងបែបនេះ គឺអាឆ្កួតនោះច្បាស់ណាស់ អាអ្នកមានជួយសង្គម អាក្រក់អាក្រីនោះអ្នែង អ្ហ៊ាមកឈរនិន្ទាមនុស្សស្រីបែបនេះ សុភាពបុរសខ្លាំងណាស់ ចង់ចេញទៅធ្វើកូដកម្មមែនទែន ។

"តែខ្ញុំបានឮ សេសីដីន និយាយថា...នាងប្រមក់នោះមិនចូលចិត្តអ្នកណាទេ"

"មិនចូលចិត្តអ្នកណា ឬ គ្មានអ្នកណាយក"

អ្ហ៊ាៗៗ!!!

"មិនចូលចិត្តអ្នកណា ដូចគ្នានឹងមានអ្នកណាម៉ោចែចង់ក៏មិនលេងជាមួយស្អីទំនង់នោះ"

"ម៉ោប្រាប់ខ្ញុំធ្វើអី"

"ឯងជាមនុស្សប្រភេទនោះហ្នឹងអ្ហ៊ អ្នកណាម៉ោចែចង់ក៏មិនលេងជាមួយ ឬមិនអីចឹងគឺបោកគេថាលេងជាមួយ ហើយចុងក្រោយក៏ទាត់គេចោលធ្វើព្រងើយ"

"គឺពួកអស់នោះគ្មានតម្លៃ ចូលចិត្តធ្វើខ្លួនឱ្យខ្ញុំមើលងាយ ពេលដឹងថាខ្ញុំជាអ្នកណាក៏នាំគ្នាម៉ោលោមពីមុខលោមពីក្រោយយកនោះ

យកនេះ ឯងទៅរិញទេដែលចម្លែក ដឹងថាស្រីចូលម៉ោព្រោះចង់បាន លុយហើយនៅសេពគប់កើតទៀត អាមោឃ!"

"គេហៅប្រើលុយទិញក្ដីសុខ ការបានឱ្យលុយទៅមនុស្សឃ្លានលុយ ពេលឃើញពួកនោះក្លាយជាទាសករលុយហើយខ្ញុំមានអារម្មណ៍ថាខ្លួនឯងជាស្ដេច ឯងគួរតែធ្វើខ្លួនឱ្យមានអារម្មណ៍បែបនោះទៅ"

"ខ្ញុំនិងឯងគិតមិនដូចគ្នាទេ"

"ណ្ហើយៗ យើងកុំប្រកែកគ្នាពីរឿងនេះ និយាយរឿងមនុស្សស្រីឈ្មោះ ម៉ាចុងអ៊ីល វិញ"

"ឈ្មោះអាក្រក់ស្ដាប់ណាស់"

ឈ្មោះអាក្រក់ស្ដាប់ពីអង្កាល់ អ្ហ៎ាៗ (តាំងពីមកឈរត្រង់នេះមិនដឹងជាត្រីតប៉ុន្មានលើកហើយទេ)។

"សម្រេចថាមិនចាប់ចាប់អារម្មណ៍ថាស្រីម្នាក់នោះឈ្មោះអីទេ"

"ម៉េចក៏ឯងចាប់អារម្មណ៍នាងម្ល៉េះ មិនឃើញមានត្រង់ណាគួរឱ្យចាប់អារម្មណ៍ទេ"

"អីចឹងយើងម៉ោធ្វើឱ្យគួរឱ្យចាប់អារម្មណ៍ទៅ"

"ម៉េច"

"ខ្ញុំនឹងភ្នាល់ជាមួយឯង"

"ថា?"

"គឺស្រេចលើឯង ឯងភ្នាល់អី ខ្ញុំជ្រើសរើសជួយទាំងអស់"

"ខ្ញុំមិនយល់"

"ម៉ោះភ្នាល់គ្នា ឯងថាឯងអាចបែចង់ ម៉ាចុងអ៊ីល បានទេ"

"ភ្នាល់ច្ចុតៗ ហើយម្យ៉ាង...ខ្ញុំជឿជាក់ខ្លួនឯងណាស់ មនុស្សដូចខ្ញុំសុំត្រឹមតែហាមាត់ ស្រីក៏មករក មិនចាំបាច់ភ្នាល់ទេ"

"ប្រែថាឯងជឿជាក់ថានឹងបែចង់នាងបាន បើនាងដឹងថាឯងជាអ្នកណា"

"ខ្ញុំជឿជាក់ថាញ៉ែបាន តែខ្ញុំមិនភ្នាល់ទេ វាគ្មានបានការ"

"ឯងខ្លាចចាញ់អ្ហ៎ស"

"ថាម៉េច!"

គីមសាំយ៉ុង យកសោឡានរបស់ខ្លួនមកគ្រវីដាក់មុខ កូអ៉ឹន ដោយការផ្ចាញ់ផ្ចាល ។

"ហ៊ីញ៉ែបាន ឯងបានស្ប៉តថ្មីដែលចាំឲ្យខ្ញុំបើក"

"ឯងចង់ចាញ់មែនផ្អូស"

"បើឯងចាញ់ ត្រូវឲ្យឡានឯងម៉ោខ្ញុំវិញ អូខេទេ"

"ខ្ញុំជឿជាក់ថាមិនចាញ់"

"អ៊ីចឹងយល់ព្រម ខ្ញុំភ្នាល់ថាឯងញ៉ែមិនបាន!"

"អ៊ីចឹងចាំមើលទៅ!"

ខ្ញុំដែលឈរស្តាប់បានតែខាំធ្មេញក្រត។ មើលប្រុសពីរនាក់នោះដោយការគុំគួន ពិសេសគឺ កូអ៉ឹន ដែលធ្វើឫកពាមានការជឿជាក់ពេកហើយ ។

"អ៊ីចឹងចាំមើលទៅ!"

១

ខ្ញុំត្រឡប់មកអង្គុយនៅកន្លែងដើមធ្វើដូចគ្មានអីកើតឡើង គ្រប់គ្នាងាកមករាក់ទាក់ ហើយនិយាយគ្នាបន្ត មានតែ កូអឹន ប៉ុណ្ណោះដែលមើលមកខ្ញុំដោយការចាប់អារម្មណ៍ ។

"ផឹកអីបន្តិចទៅ"

"ខ្ញុំមិនផឹកស្រា"

"ខ្ញុំក៏មិនផឹក ដែលហុចឲ្យវាជាតែបៃតងទេ"

"មានតែបៃតងនៅក្នុងបារដែរ"

"ខ្ញុំយកម៉ោ"

មានមនុស្សបែបនេះនៅលើលោកនេះដែរឬ ស្លាយតែបៃតងចូលបារ តែ...នៅក្នុងពេលដែលគេហុចមកឲ្យ ខ្ញុំក៏គួរតែទទួលបន្តិចទៅ ទោះយ៉ាងណាក៏វាល្អជាងស្រាដែលពួកម៉ាកខ្ញុំកំពុងផឹកដែរ មិនដឹងជាប្រញាប់ធំទៅណា មិនឃើញចូរាញ់អីផង (ធ្លាប់សាកតិចៗ) ។

"ទៅយូរម៉េះ ជុះអាចម៍ឬ"

ព្រួត!

តែបៃតងដែលទើបនឹងដាក់ចូលមាត់ក៏ត្រូវព្រួសដាក់មុខ កូអឹន ដោយអាការៈឈ្លក់ គ្រប់គ្នាងាកមកមើលគេដោយការភ្ញាក់ផ្អើលសឹងតែឈប់ដកដង្ហើម ។

"ហ៎ា គ្មានមាយាទដល់ហើយ ម៉ាថុងអ៊ីល ឯងព្រួសទឹកដាក់មុខកូអឹន" សឺជីន ថា ។

"មិនអីទេ គឺគ្រាន់តែព្រួសទឹក លើកលែងតែម៉ោប្រហែលចង់ជេរបន្តិច" កូអឹន យកកន្សែងជូតមុខមកជូត ហើយសម្លក់មុខខ្ញុំថ្មែរ អីយ៉ា...នឹង

ជីងណាស់ណាំ បើខឹងក៏សម្ដែងចេញមក!

"គឺគេនិយាយដល់អ្វីដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើល"

"គេនិយាយអី"

"ដុះអាចម៍"

"គ្រាន់តែដុះអាចម៍ហ្នឹង"

"វាមិនត្រឹមតែដុះអាចម៍ វាគឺជាអ្វីដែលមនុស្សប្រុសមិនសមគួរនឹងនិយាយ"

"តាមតែវាទៅ ខ្ញុំប្រហែលជាសួរត្រង់ៗមែន តែឲ្យនិយាយថាទៅបត់ជើងធំ វាក៏មើលទៅមិនច្បាស់លាស់"

"ភាពច្បាស់លាស់របស់លោកយកទៅកប់ទុកនៅកន្លែងជ្រៅៗក៏បាន យល់ល្អមិនគួរសួរដោយពាក្យថាចូលបន្ទប់ទឹកធ្វើអី ដឹងត្រឹមតែថាចូលបន្ទប់ទឹកទៅបានហើយ!"

"គឺសួរឲ្យមានមាយាទ ឃើញទៅយូរ"

"ខ្ញុំទៅផ្ទះល្អដាង មិនសប្បាយទេ" ខ្ញុំកាត់បទ ត្រៀមខ្លួន សឺជីនធ្វើមុខច្លេច្លាដោយការអាការៈមឹងមាំង ហាមាត់សួរ តែ កូអឹន លឿនដាង គេងើបឈរកាត់មុខ សឺជីន ហើយនិយាយដោយសម្លេងចេញបញ្ញាដ៏មានអំណាច ។

"នាងទៅមិនទាន់បានទេ!"

"មានអីធ្ងន់ធ្ងរណាស់នេះ ហើយម៉េចក៏ខ្ញុំទៅមិនបាន"

"ខឹកៗ" គីមសាំយ៉ុង អង្គុយមើលហេតុការណ៍ ហើយក៏សើចតែម្នាក់ឯង ពេល កូអឹន ងាកទៅសម្លក់ គេក៏នៅស្ងៀម ហើយត្រីកូនសោឡានលេង ព្រមទាំងហួចឲ្យរំភើយទៀត ។

"ទៅមិនបានគឺមិនបានហើយ អ្ហ៎...ខ្ញុំធ្លាប់ជួបនាងនៅណាទេ"

គេចាំខ្ញុំមិនបានមែន ខាតពេលមែននៅខណៈដែលខ្ញុំនឹកដល់គេទោះជាមួយភ្លែតក៏ដោយ តែវាមកមួយភ្លែតរាល់តែថ្ងៃ តែអាប៉ិច្ឆតនេះចាំមិនបានអីបន្តិច ។

"អ្នកមានដូចលោកមិនធ្លាប់ជួបអ្នកក្រដូចខ្ញុំទេ"

"ខ្ញុំក៏ថាអីចឹងដែរ ព្រោះខ្ញុំមាន"

បញ្ឈឺហើយមិនព្រើសម្បុរទៀតពីយ!

"ហៅ ហើយចង់ទៅណា ខ្ញុំនិយាយមិនទាន់ចប់ទេ"

ខ្ញុំដើរចេញមកក្រៅ ចិស! នេះបើគ្មានឡានស្ប៉តជាដើមក្នាល់ គឺមិនចាប់អារម្មណ៍និយាយជាមួយខ្ញុំទេដឹង ឈឺចិត្តដល់-ក ចង់តែស្រែក អ្ហ៊ាៗ!

"ឈប់!"

"កុំម៉ោស្រែកដាក់ខ្ញុំ"

"ខ្ញុំប្រាប់ឲ្យនាងឈប់ តែនាងក៏មិនស្តាប់ នេះចង់ទៅណា"

"ទៅផ្ទះ"

"គ្មានមាយាទ អ្នកផ្សេងគេនៅខាងក្នុង នៅសុខៗនាងក៏ដើរចេញម៉ោបែបនេះ តិចពិធីរលំអស់ទៅ ម្យ៉ាងទៀតអ្នកដែលត្រូវមួម៉ៅ ហើយចេញពីទីនេះគួរតែជាខ្ញុំ ដែលត្រូវព្រួសទឹកដាក់មុខទើបត្រូវ"

"បើលោកចង់រក្សាមាយាទណាស់ ខ្ញុំនឹងនៅ"

"ល្អ"

"ហើយលោកក៏ទៅផ្ទះ ព្រោះបើលោកនៅ ខ្ញុំនឹងទៅ!"

"ស្អីគេ!"

ដូចត្រូវដែកដុតភ្លើងយកមកដាក់លើមុខ ខ្ញុំមានអារម្មណ៍ថាខឹងឡើងស្លឹកពេញរាងកាយទៅហើយ គេចាត់ទុកខ្ញុំជាស្អីនេះ!

"បានឮហើយកុំម៉ោធ្វើពើជាមិនបានឮ ខ្ញុំមិនចូលចិត្តនិយាយច្រំដែល នាងមិនដឹងទេថាអ្នកនាងត្រូវតែនិយាយតិច ទើបមើលទៅគួរឲ្យគោរព"

"អ្នកមានគ្មានខួរក្បាលបែបនេះគ្រប់គ្នាអីអត់នេះ"

"ថាម៉េច"

"បានឮហើយកុំម៉ោធ្វើពើជាមិនបានឮ មិនដឹងឬយ៉ាងម៉េចថាធ្វើបែបនេះអ្នកក្រនឹងជេរបានថារញ៉េរញ៉ៃ រឿងច្រើន"

"នេះនាងជេរខ្ញុំ!"

"អឺ លុយលោកអាចទិញអ្នកផ្សេងបាន តែមិនមែនខ្ញុំ រកលុយបានដោយខ្លួនឯងហើយនៅក៏មិនដឹង ចាយលុយដូចក្រដាស អាក្រក់ ដក

ក្បាលទៅលាដៃសុំលុយម៉ែឪទិញស្ពឺផ្សេងទៅល្អជាង"

ហ៊ឹប!

ក្រដាសខ្នាតធំជាងលុយបន្តិចហើរមកបុកមុខខ្ញុំដោយកម្លាំងគ្រវែងរបស់អ្នកនៅចំពោះមុខ ពេលវាធ្លាក់ទៅនៅលើដីទើបខ្ញុំដឹងថាជាឆែកដែលមានហត្ថលេខារួចស្រេច លើកលែងតែចំនួនលុយ ។

"នាងចង់បានប៉ុន្មាន ដាក់លេខទៅ ហើយមិនបាច់និយាយច្រើនទេ ខ្ញុំមិនជឿទេថានៅលើលោកនេះមានស្ពឺដែលលុយទិញមិនបាន"

"មាន! វាមានរបស់ដែលលុយទិញមិនបាន"

ខ្ញុំឱនរើសឆែកនោះ ហើយហែកដាក់មុខគេឡើងកាលីប (ពិតជាកាលីបមែន) កូអឺន មើលទង្វើរបស់ខ្ញុំដោយភាពស្រឡាំងកាំង ។

"មិនធ្លាប់មានអ្នកណាបានទទួលសំណើបែបនេះទេ នាងមោយណាស់ដែលមិនទទួលរបស់នេះ"

"ខ្ញុំមិនត្រូវការធ្វើជាគ្រាប់អុកលេងហ្គេមស្នេហ៍របស់អ្នកណាទេ ពួកលោកចង់ទៅដូរឡាន ឬ ដូរស្ពឺក៏ទៅរកអ្នកផ្សេងទៅ កុំម៉ោរញ៉េរញ៉ៃជាមួយខ្ញុំ"

"នាងនិយាយដូចដឹង"

"គឺដឹង ខ្ញុំបានឮទាំងអស់ គិតចង់ថែចង់ខ្ញុំដោយការយកលុយម៉ោបោកដើម្បីមិនឱ្យខ្លួនឯងខាតឡានកាលីប...ពុទ្ធោ ហ្គេមអ្នកមានចំជាល្ងីល្ងើមែន បើគ្មានលុយនៅក្នុងលក្ខខណ្ឌ លេងមិនកើតឬម៉េច"

"ពួកខ្ញុំចង់លេងហ្គេមយ៉ាងម៉េចគឺមិនទាក់ទងនឹងនាងទេ"

"វាច្បាស់ជាមិនទាក់ទងហើយ បើលោកមិនយកខ្ញុំទៅចូលរួម"

"គ្រាន់តែយកលុយវាងាប់ឬយ៉ាងម៉េច"

"ងាប់! កិត្តិយសសម្រាប់ខ្ញុំគឺសំខាន់ស្មើជីវិត លុយដែលលោកមិនបានរកដោយខ្លួនឯងបែបនេះ ទិញខ្ញុំមិនបានទេពីយ!"

"នាងពីយដាក់ខ្ញុំឬ គិតថាខ្លួនឯងជាអ្នកណា"

"ព្រៃ"

"នាងឈ្មោះ ព្រៃ ឬ"

"ខ្ញុំលានអណ្តាត!"

"មនុស្សស្អី ឈ្មោះ លានអណ្ដាត"

"អ្ហ៎ា ឈប់និយាយជាមួយហើយ"

ពេលត្រៀមនឹងដើរចេញ គេក៏ស្រវាចាប់ដៃខ្ញុំ ហើយទាញទៅរកធ្វើឲ្យដើមទ្រូងយើងបុកគ្នា ធ្មេញគេទង្គិចនឹងថ្ងាសខ្ញុំលាន់ប៉ឹក ។

"អ៊ូយ! ប្រុសឆ្កួត ខ្ញុំឈឺ"

"ចុះខ្ញុំមិនឈឺទេអ្ហ៎ស្រីឆ្កួត ធ្មេញមុខខ្ញុំរបូតចេញមកទាំងក្រាស់ហើយនេះ មិនដឹងជារបោករហាន់ទៅណា មានមាយាទបន្តិចក៏មិនបាន មនុស្សនិយាយមិនទាន់ចប់ផង"

"ត្រូវនិយាយគ្នាទៀតអ្ហ៎ស ខ្ញុំហែកហៀកចោលហើយ ហើយក៏ដឹងពីអ្វីដែលលោកចង់ធ្វើដែរ"

"ខ្ញុំធ្លាប់ជួបនាងមែន តែគិតមិនឃើញថានៅណា...អ្ហ៎? ឈប់សិន តាមធម្មតាខ្ញុំមិនដែលភ្លេចទេ បើជួបអ្នកណាហើយគឺជាប់ចិត្ត"

"ស្អី"

"ខ្ញុំ...ខ្ញុំមានន័យដល់អ្នកដែលធ្វើឲ្យខ្ញុំចង់ចាំបាន ម៉េចចាំបាច់សួរនាងគ្មានសិទ្ធិសួរទេ"

"គ្រាន់តែខ្ញុំនិយាយថាស្អី ប៉ុណ្ណឹង?"

"តទៅខ្ញុំគឺជាអ្នកសួរតែម្នាក់គត់"

"គ្មានតទៅទេ ព្រោះខ្ញុំមិនព្រមជួបលោកទៀតឡើយ!"

"នាងគិតថាគេចផុតឬយ៉ាងម៉េច ខ្ញុំមានលុយច្រើន តាមរកងាយឃើញ មិនដល់មួយថ្ងៃផង"

"យី អាអ្នកមាន"

"ដឹងច្បាស់គឺល្អហើយ ស្រីអ្នកក្រ...តែថានាងគិតថាខ្លួនឯងជាអ្នកណា"

"ខ្ញុំចង់គិតថាខ្លួនឯងជាអ្នកណា មានទាក់ទងអីនឹងលោក!"

"អ្ហ៎ នេះខ្ញុំនិយាយជាមួយនាងស្រួលៗណ៎ា"

"សួរថាខ្ញុំជាអ្នកណា វាស្រួលត្រង់ណា"

"ខ្ញុំកំពុងសួរឈ្មោះនាង" កូអឺន ធ្វើមាត់អេចអួចអឹមអៀន "បើខ្ញុំសួរថានាងគិតថាខ្លួនឯងជាអ្នកណា គឺមានន័យថា...នាងឈ្មោះអី"

"ចុះម៉េចមិនសួរតាំងពីតំបូងថាឈ្មោះអី ហើយមិនស្គាល់ឈ្មោះខ្ញុំទេឬយ៉ាងម៉េច ដល់ថ្នាក់ភ្ញាល់ដាក់ឡានស្ប៉ត តែមិនស្គាល់ឈ្មោះចំណាប់ខ្មាំងនេះ"

"កាលនោះខ្ញុំមិនបានតាំងចិត្តស្តាប់ តែពេលនេះខ្ញុំតាំងចិត្ត នាងឈ្មោះស្អី"

"មិនប្រាប់...ខ្ញុំមានន័យថា ខ្ញុំមិនប្រាប់ឈ្មោះ មិនមែនឈ្មោះថា 'មិនប្រាប់' ទេ"

"ប៉ាំងអាចមិមែនទេ"

"ចុងអ៊ុល! ផ្អំ...លោកបោកឲ្យខ្ញុំប្រាប់ទេតើ"

"មែន ខ្ញុំអាចចាំបានព្រាលៗ គ្រាន់តែចង់ឲ្យនាងណែនាំខ្លួនជាផ្លូវការតែប៉ុណ្ណោះ ខ្ញុំឈ្មោះ កូអឹន"

"មិនចង់ចាំ!"

"មិនទេ ពេលនេះនាងចាំបានហើយ"

"ហឹស លំអៀងទៅរកខ្លួនឯងទៅ ចង់គិតអីក៏គិតទៅ"

"យើងច្បាស់ជាបានជួបគ្នាទៀត"

"បើគិតថាធ្វើបានក៏សាកមើលទៅ"

ខ្ញុំនិយាយចប់ក៏ដាក់មេដាយទៅហៅតាក់ស៊ី តែមិនឃើញថាគេរត់តាមមកទេ ក្រៅពីឈរជ្រងហោប៉ៅមើលខ្ញុំឡើងឡានទាល់តែបាត់ពីភ្នែក គិតថាខ្លួនឯងជាអ្នកណាដែលមនុស្សដូចខ្ញុំត្រូវអង្គុយចាំឈ្មោះទេ...ខ្ញុំមិនចាំទេ ។

ខ្ញុំនឹងមិនចាំថាគេឈ្មោះ...កូអឹន!!!

អ្ហា...ចាំបានហើយតើ!

នៅផ្ទះ...

ខ្ញុំធ្វើដំណើរពីបារមកដល់ផ្ទះប្រើពេលអស់២០នាទី នាឡិកាពេលនេះប្រាប់ថាម៉ោង១១យប់ហើយ ពេលវេលាដែលក្មេងតូចដូចខ្ញុំគួរតែចូលដេកតាំងពីយូរ ហើយអ្វីដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលជាងនេះ គឺភ្លើងនៅជាន់ក្រោមបើកភ្លឺចិញ្ចាច ដោយមានម៉ាក់មុខសុទ្ធតែឡេ

និងគ្រសក់ ដើរមករកដោយទឹកមុខមិនពេញចិត្តយ៉ាងខ្លាំង ។

"ម៉េចម៉ាផ្ទះយប់ម្ល៉េះ"

"ខ្ញុំប្រាប់ហើយតើថាម៉ោវិញយប់ជ្រៅ ម៉ាក់ក៏អនុញ្ញាតដែរ"

"អនុញ្ញាតក៏ពិតមែន តែចាំបាច់ត្រូវទៀងពេលវេលាដែរ"

"នេះខ្ញុំម៉ោមុនពេលដែលសុំហើយ តែម៉េចក៏ម៉ាក់មិនទាន់ចូលសម្រាន្តទៀត" ខ្ញុំដើរទៅរកទូទឹកកក ហើយចាក់ទឹកផឹក ម៉ាក់ដើរមកហិតនៅលើខ្លួនខ្ញុំ ហើយដកដង្ហើមធំ "កើតអីម៉ាក់"

"ឯងមិនបានផឹកស្រាទេ"

"ប្រាកដហើយ ខ្ញុំជាក្មេងល្អ ទុកចិត្តបាន"

"ប្រែថាម៉ាក់ចិញ្ចឹមបានល្អ តាមពិតទៅម៉ាក់រង់ចាំឯង មានរឿងចង់និយាយជាមួយ"

"ហឺ?"

ម៉ាក់ឡើងទៅខាងលើ ហើយចុះមកវិញយ៉ាងលឿន ដោយមានឯកសណ្ឋានសិស្សថ្មីដែលខុសពីឯកសណ្ឋានសិស្សចាស់របស់ខ្ញុំដាច់ស្រឡះ ។

"ម៉ាក់តែងខុសផ្លែយដែលឬ"

"មិនមែនទេ នេះជាឯកសណ្ឋានសិស្សថ្មីរបស់ឯង" ម៉ាក់តបព្រមទាំងយកវាទៅសំដិលនឹងកៅអី ។

"ឯកសណ្ឋានសិស្សថ្មីស្អីគេម៉ាក់ សាលារៀនខ្ញុំមិនឃើញប្រាប់ថាឲ្យដូរឯកសណ្ឋានផង"

"សាលាមិនប្រាប់ តែម៉ាក់ប្រាប់...ម៉ាក់ដូរសាលាឲ្យឯងហើយ"

"ហ៊ា?"

"មិនឃើញមានអីត្រូវភ្ញាក់ផ្អើលដល់ម្លឹងទេ គ្រាន់តែដូរសាលាចូលពាក់កណ្ដាលឆមាសគួរតែតាមទាន់ ថ្ងៃចន្ទក្រោយ" ម៉ាក់និយាយបណ្ដើរផ្ទះអាចម៍ក្រចកបណ្ដើរដោយមិនចាប់អារម្មណ៍ថាខ្ញុំស្រែកអស់សម្លេងដល់ថ្នាក់ណា ។

"ឈប់សិនម៉ាក់ ម៉េចចាំបាច់ដូរសាលា នេះទើបពាក់កណ្ដាលឆមាស ខ្ញុំវង្វេងអស់ហើយ អធិប្បាយឲ្យបានវែងផងមើល៍"

"ឯងច្បាស់ជាបានពាក្យអធិប្បាយ តែមិនមែនពេលនេះ...យកតាមម៉ាក់ប្រាប់ទៅ ថ្ងៃចន្ទឯងត្រូវរៀននៅសាលាថ្មី ធ្វើខ្លួនឱ្យទម្លាប់ផង ទីនោះសុទ្ធតែកូនអ្នកមាន"

"មាន? នេះម៉ាក់ឱ្យខ្ញុំទៅរៀនសាលាណា"

"អន្តរជាតិ"

"O_O ម៉ាក់គិតស្អីហ្នឹង បានឮថាផ្ទះយើងជួលគេមិនអីចឹង"

"ប្រាប់ឱ្យទៅរៀនក៏ទៅទៅ"

"តែខ្ញុំមិនទាន់បានលាមិត្តភក្តិផង"

"បោលទៅមិត្តចាស់ តិចទៀតនឹងមានមិត្តថ្មីហើយ សង្គមថ្មីគឺអស់បញ្ហាហើយ ហើយមិនបាច់ម៉ោតែអីទៀតទេ ម៉ាក់ទៅបិទម៉ាសមុខបន្ត ខ្លាចមិនស្អាត អ្ហ៎ កុំភ្លេចយកខោអាវទៅលផង នេះម៉ាក់កុម្ម៉ង់ឱ្យកាត់ដោយការវាស់តាមខ្សែភ្នែក មិនដឹងថាឯងលាក់មាឌឬអត់"

ម៉ាក់ដើរឡើងទៅខាងលើដោយប្ញកពាសប្បាយចិត្តសប្បាយថ្លើមទុកខ្ញុំឱ្យនៅជាមួយឯកសណ្ឋានសិស្សថ្មី ស្អីនេះ នៅសុខៗម៉ាក់ក៏ប្រាប់ឱ្យខ្ញុំទៅរៀននៅសាលាថ្មីនៅថ្ងៃចន្ទ នេះជាថ្ងៃអីហើយ...

ជួបតែរឿងច្កួតៗ!!!

២

ម៉ោង ៣ :០០ ទាបភ្លឺ

នេះវាម៉ោងប៉ុន្មានហើយនេះ៎ ពេលាថ្មើរនេះនៅមានអ្នកតេមកមកទៀតតត!

"ហាឡូ"

(ខ្ញុំប្រាប់ហើយថាលុយនឹងធ្វើបានគ្រប់យ៉ាង)

"ហឺ? អ្នកណា"

(នាងព្រហើនណាស់ដែលចាំឈ្មោះខ្ញុំមិនបាន នាងមិនដឹងឬយ៉ាងម៉េចថាខ្ញុំជាអ្នកណា)

"ច្រតអត់នេះ៎"

ខ្ញុំដាក់ទូរសព្ទចុះ ហើយដេកបន្ត តែមើលទៅទូរសព្ទដៃរបស់ខ្ញុំ វាដូចជាមិនស្រលាញ់ម្ចាស់សោះហើយ បេះស្រែកដូចក្មេងទារបៅដោះម៉ែទៅកើត អ្ហ៊ាៗ!

"ស្អីទៀតហើយ មនុស្សដេកពួន បេះតេម៉ោទៅកើត"

(ហ៊ានតំឡើងសម្លេងដាក់ខ្ញុំផង នាងកុំប្រាប់ណាថាចាំខ្ញុំមិនបានពិតមែន គ្មានមនុស្សណានៅលើលោកនេះចាំខ្ញុំមិនបានទេ គ្រាន់តែមិនបានប៉ះពាល់...)

"អាច្កុត!"

(បើនាងដាក់ទូរសព្ទចុះ ខ្ញុំនឹងតាមទៅដល់ផ្ទះ ខ្ញុំដឹងហើយថានាងនៅណា)

ភាពងុយដេករបស់ខ្ញុំត្រូវធាក់ឲ្យខ្ទាតចេញពីខួរក្បាល ល្មមៗបានហើយ អាច្កុតនេះជាអ្នកណា ព្រហើនណាស់ មកគំរាមនៅម៉ោង

បីទាបភ្លឺ ក្ដៅក្រហាយហើយពើយ!

"បើខ្លាំងមែនក៏ម៉ោម៉ា កុំបានតែនិយាយ ហើយនេះជីវិតគ្មានអីធ្វើទេឬយ៉ាងម៉េច បានជាម៉ោរំខានអ្នកភូមិទាំងយប់ទាំងអាធ្រាត្រ ឯងធ្វើឲ្យខ្ញុំក្ដៅក្រហាយហើយពើយ ប្រាប់ឈ្មោះប្រាប់ត្រកូលម៉ោល្អជាង ថាឯងជាអ្នកណា!"

(កុំដ្គីនខ្ញុំ ខ្ញុំច្បាស់ជាទៅ)

"អឺ បើខ្លាំងក៏ម៉ោម៉ោ ខ្ញុំចាំ"

(ហើយនាងនឹងបានដឹងថាខ្ញុំជាអ្នកណា)

អ្នកចុងខ្សែក៏ដាក់ចុះដោយមិននិយាយពាក្យលាមួយម៉ាត់ នេះខ្ញុំនិយាយទូរសព្ទជាមួយពួករោគចិត្តនៅម៉ោងបីទាបភ្លឺឬនេះ តែថាវាជាអ្នកណា?

១០នាទីកន្លងផុតទៅ...

ទ្រូត~

ទូរសព្ទដៃរបស់ខ្ញុំបញ្ចេញសម្លេងម្ដងទៀត ខ្ញុំកំពុងតែភ្លើតភ្លើននៅក្នុងសុបិនថា ស៊ីវ៉ន កំពុងឱនមកបើបក៏ទៅជាភ្ញាក់ព្រើត លេះដួងសឹងតែឈប់ដើរ មើលទៅទូរសព្ទដៃដោយអស់ការអត់ធ្មត់ សរសៃអត់ធ្មត់ចុងក្រោយដាច់ហើយ ភឹង!!!

"ឯងចង់ងាប់ឬយ៉ាងម៉េច មិនចេះដេកពួន គិតចង់រំខានខ្ញុំពេញម៉ាយបីអ្អី"

(មនុស្សឆ្កួតស្អីមិនចង់ឲ្យគេគេទៅ តែមិនព្រមបិទទូរសព្ទ!)

"ខ្ញុំទៅវិញទេដែលត្រូវជេរឯង នេះម៉ោងពាភ្លឺហើយពើយ"

(ខ្ញុំម៉ោហើយ)

"ម៉ោណា"

(ម៉ោនៅមុខផ្ទះនាង អើតក្បាលចេញក្រៅបង្អួចម៉ោ ថាខ្ញុំម្នាក់នេះជាអ្នកណា នឹងបានចាំបាន!)

កុំនិយាយលេងសើច! ខ្ញុំហ័សវាវទៅរកបង្អួច បើកវាំងននមើលក៏ឃើញថាមានមនុស្សដើរនិយាយទូរសព្ទទៅមកនៅមុខផ្ទះ ម៉េចក៏

មុខដូចជាប្រហែលៗម្ល៉េះ ។
"រោគចិត្ត"
(ខ្ញុំរោគចិត្តត្រង់ណា នាងផ្ញើនឲ្យម៉ោ ខ្ញុំក៏ម៉ោ ហើយព្រោះនាងធ្វើឲ្យឡានស្ប៉ត ខ្ញុំត្រូវបាត់!)
"កូអា!"
(ខ្ញុំឈ្មោះ កូអ៊ីន កូអាស្គី ឬនាងហៅខុស 0_0 មិនធ្លាប់មានអ្នកណាហៅឈ្មោះដ៏សែនពិរោះខ្លង់ខ្លស់ដូចទេវតារបស់ខ្ញុំខុសទេ)
"ម៉េ...ម៉េចក៏លោកម៉ោនៅទីនេះបាន"
(គឺប្រាប់ហើយតើ នាងផ្ញើនឲ្យខ្ញុំម៉ោ)
"ប្រែថាដែលនិយាយគ្នាម៉ោរហូតគឺលោកអីចឹងឬ លោកទៅបានលេខខ្ញុំពីណា"
(ខ្ញុំមាន)
"សួរថាបានលេខម៉ោពីណា វាទាក់ទងអីនឹងឋាន:)
(ខ្ញុំទិញលេខនាងពីមិត្តនាងម៉ាលេខ ១០ម៉ឺន)
"មានមែន"
(លេបមុខម៉ោនិយាយជាមួយខ្ញុំភ្លាម!)
"ទេ! រឿងស្អី លោកចង់ម៉ោ តែខ្ញុំមិនចង់ជួបមុខ"
ដឹកដាក់...ដឹកដាក់...
បេះដូងរបស់ខ្ញុំកំពុងតែចង់ផ្ទុះចេញមកក្រៅ តំបូងដែលគិតថាជាមនុស្សរោគចិត្តគឺព្រមទទួលថាខឹង តែពេលដឹងថាជាគេ អារម្មណ៍ខ្ញុំក៏ផ្លាស់ប្តូរ មិនត្រឹមតែមិនខឹងទេ នៅសប្បាយចិត្តទៀត ដូចយល់សប្តិអីចឹង យល់សប្តិល្អជាងពេលឃើញ ស៊ីវ៉ន ធ្វើមាត់ស្រួចហើយឱនមករកទៅទៀត ។
(បើនាងមិនចុះម៉ោ ខ្ញុំនឹងឡើងរបងទៅ នាងគិតថាខ្ញុំមិនហ៊ានឬយ៉ាងម៉េច នាងថាំងអាចម៍!)
"ខ្លាចហើយ!"
ខ្ញុំហ័សរត់ចុះទៅរក មិនទេ ត្រូវប្រាប់ថាហោះទៅច្រើនជាងទើបត្រូវ តាមពិតខ្ញុំកុហករឿងមិនចង់ជួបមុខ គ្រាន់តែដឹងថាជាគេក៏ធ្វើអី

មិនត្រូវដោយចិត្តរំភើបទៅហើយខ្ញុំ ។

"ម៉ោហើយ" កូអឹន ឱបដៃមើលខ្ញុំតាំងពីក្បាលដល់ចុងជើង និង មើលមកខាងលើម្ដងទៀត មុននឹងញាក់ចិញ្ចើម "ឈុតដេកជស់នាង មើលទៅមិនថ្លៃទេ"

"វ៉ាយ កុំមើល" ខ្ញុំរហ័សលើកដៃបិទដើមទ្រូង ភ្លេចទៅថាឈុតដេករបស់ខ្លួនស្ដើងបន្តិចហើយ ថែមទាំងមិនបានពាក់អាវក្នុងទៀត ណ្ហើយ ងងឹតៗ គេមើលមិនឃើញទេ ។

"ធ្វើជាអៀន យឺតបន្តិចហើយទេដឹង ខ្ញុំឃើញអស់ហើយ"

"ប្រុសឆ្កួត!"

"មុខមាត់ក៏អីចឹងៗ រាងក៏អីចឹងៗ ព្រហើនណាស់ដែលចាំឈ្មោះខ្ញុំមិនបាន ដឹងទេថាអ្នកណាក៏ចាំខ្ញុំបានដែរ ខ្ញុំទៅវិញទេដែលជាអ្នកចាំឈ្មោះនាងមិនបាន"

ខ្ញុំចាំបាន តែមិនសម្ដែងចេញ គួរឱ្យជ្រេញមែនអាប្រុសឆ្កួត មកដល់ទីនេះដើម្បីប្រាប់ឱ្យខ្ញុំចាំឈ្មោះរបស់គេឱ្យបាន គ្មានបានការមែន!

"លើកនេះនាងចាំខ្ញុំបានហើយនៅ"

"មិនបាន"

"មិនយុត្តិធម៌ ខ្ញុំចាំឈ្មោះនាងបានហើយ!"

ពេលគេស្រែកចេញមកបែបនោះ ខ្ញុំក៏ឈានថយក្រោយដោយភាពស្រឡាំងកាំង តែ កូអឹន បែរជាធ្វើមុខភ្ញាក់ផ្អើលរហ័សគ្រវីដៃ ។

"ខ្ញុំមិនបានគំហកនាង កុំខ្លាច ហ៊ើយ! ខ្ញុំគឺជាមនុស្សនិយាយខ្លាំងៗបែបនេះហើយ នាងគួរតែចាំវាទុក បើខ្ញុំនិយាយខ្លាំងៗគឺខ្ញុំត្រូវការបញ្ជាក់ មិនមែនគំហកទេ"

"មិ...មិនបាច់អធិប្បាយក៏បាន"

"ម៉េចចាំបាច់អាក់អួល នាងខ្លាចខ្ញុំផ្អើស ខ្ញុំមិនត្រូវការឱ្យនាងខ្លាចខ្ញុំទេ"

"ស្អីលោកឯងហ្នឹង ចូលសាច់រឿងល្អជាង ម៉ោទីនេះធ្វើអី មិនបាច់ប្រាប់ថាព្រោះខ្ញុំផ្អឹនទេ យកហេតុផលបែបច្បាស់លាស់"

"មិនដឹង"

"O_o"

"ពេលនាងផ្ដឹន ទើបខ្ញុំម៉ោ គ្រាន់តែចង់ឲ្យនាងដឹងថាខ្ញុំធ្វើបានគ្រប់យ៉ាងទើប...ម៉ោ"

"ហេតុផលប៉ុណ្ណឹងឬ"

"ម៉េច គិតថាខ្ញុំចង់ឃើញនាងឬយ៉ាងម៉េច គិតថាខ្លួនឯងជាអ្នកណា ធ្វើជាហែកហៀក ធ្វើជាដើរគេច ហើយក៏ស្រែកជេរប្រេតៗ គិតថាខ្ញុំចាប់អារម្មណ៍នាងឆ្កួស"

"អីចឹងក៏ទៅវិញទៅ"

"គឺចាប់អារម្មណ៍នាងហ្នឹងអ្ហា"

"o_O"

"លើកនេះចាំខ្ញុំបានហើយមែនទេ ខ្ញុំឈ្មោះ កូអ៊ីន ចំនែកនាង..."

"ថុងអ៊ុល"

"ខ្ញុំចាំបាន ហើយលេខដែលគេទៅកុំភ្លេចសេវជង នាងត្រូវតែជាអ្នកគេទៅខ្ញុំមុន យល់ទេ"

"=O="

"ទៅហើយ"

"ឈប់សិន"

កូអ៊ីន រហ័សងាកមក ខ្ញុំឃើញស្នាមញញឹមនៅលើមុខគេមួយភ្លែត មុននឹងដូរមកជានឹងធឹងដូចដើម ។

"ស្អី"

"ឡានស្ប៉តត្រូវបែអួសព្រោះចាញ់ភ្នាល់ បើអីចឹងជិះអីម៉ោ"

"ខ្ញុំមានឡានសាគួមួយទៀត"

"=O="

ទៅបារម្ភពីវា...ធ្វើអី?

បន្ទាប់ពីប្រាកដចិត្តហើយថា កូអ៊ីន ទៅវិញ ខ្ញុំក៏ឡើងទៅបន្ទប់ដេកដោយអារម្មណ៍ចង់ស្រែក មិនដឹងដូចគ្នាថាស្រែកសប្បាយចិត្ត ឬមិនចូលចិត្ត វាច្របូកច្របល់អស់ហើយ គ្រប់យ៉ាងសម្រាប់ខ្ញុំនៅពេល

នេះវាជាអ្វីដែលលើសពីការស្មាន ។

បុរសនៅក្នុងពេលនោះលេចមុខមករកខ្ញុំនៅក្នុងពេលនេះ ថែមទាំងធ្វើឫកពាដូចជាចង់ថែចង់ រំភើបណាស់នេះ តែចង់ឱ្យច្បាស់ត្រូវតែទៅ សេសីជីន មិត្តជើងល្អសិន ល្មមៗបានហើយ លក់លេខទូរសព្ទដៃខ្ញុំឬ មិត្តថោកទាប ។

ទ្រូត~

"នេះឯងជាមាន់ខេអេហ្វស៊ីឬ កំពុងនឹកដល់ក៏គេមៅ៉ា តែគេមៅ៉ាគឺល្អហើយ ខ្ញុំមានរឿងចង់និយាយជាមួយច្រើនណាស់"

(ហឺៗៗ)

នៅសុខៗ សីជីន ក៏ប្រកសម្លេងរញ្ជួយចិត្តចូលមក ធ្វើឱ្យខ្ញុំទៅជាកាន់កាំងរញ្ជួយចិត្តតាមនាងដែរ តែថានាងកើតអី?

"ឯងកើតអី"

(ខ្ញុំត្រូវគេបោះបង់ហើយ...ឯង...ខ្ញុំត្រូវបោះបង់ហើយ)

"អ្នកណាបោះបង់ឯង គឺមសាំយ៉ុង ឬ"

(ហឺៗ ម៉ែន គេបោះបង់ខ្ញុំហើយបណ្តើរស្រីថ្មីឡើងឡានស្ប៉តថ្មីគេធ្វើដាក់ខ្ញុំបែបនេះបានយ៉ាងម៉េច)

"អ្នកមានគឺអីចឹង គិតថាស្រីជារបស់លេង ឯងគួរតែធ្វើចិត្តព្រមទទួលទៅ ឯងក៏សុខចិត្តឱ្យគេលេងតើ ព្រោះគេមានលុយ"

(តែខ្ញុំចូលចិត្តគេមែនទែនហើយ គេធ្វើដាក់ខ្ញុំបែបនេះមិនបានទេ ធ្វើដូចខ្ញុំជាក្រដាសប្រើហើយបោះចោល ធ្វើដូចខ្ញុំលក់ខ្លួន!)

"ហ៊ឺៗ ស្អីធ្វើឱ្យឯងនិយាយស្តីមើលងាយខ្លួនឯងដល់ថ្នាក់នេះ គេធ្វើអីឯង"

(គេឱ្យហ៊្សែកខ្ញុំមួយសន្លឹក ហើយប្រាប់ឱ្យខ្ញុំដកក្បាលចេញទៅ)

"ខ្ញុំនឹងទៅសម្លាប់វា វាចាត់ទុកហ៊្សែកជាក្រដាសកិតអាចម៍ឬយ៉ាងម៉េច អាងអីក៏សរសេរហ៊្សែកគប់មុខអ្នកដទៃ"

(ខ្ញុំមិនទាន់បានប្រាប់ឯងម៉ាម៉ាត់ទេថាគេគប់មុខខ្ញុំ តែគេគប់មុខខ្ញុំមែន ហឺៗ)

"ចុះម៉េចក៏ឯងមិនគប់មុខវាវិញទៅ"

(ស្តាយT^T)

"អា...ឯងនៅណា ខ្ញុំនឹងទៅរក ចុះសង្សារឯងនៅហ្នឹងទេ"

(នៅ)

"អី ប្រាប់វាទៅថាតិចទៀតជួបគ្នា!"

ខ្ញុំយល់ពីអារម្មណ៍របស់មិត្តបានច្បាស់ អាការដែលត្រូវគេមើលងាយថាយើងជារបស់ដែលអាចទិញដោយលុយបាន វាគួរឲ្យឈឺចិត្តប៉ុណ្ណា នេះខ្ញុំដល់ថ្នាក់លបចេញពីផ្ទះនៅម៉ោង៤ទាបភ្លឺដើម្បីមករកសីជីន នៅខាងក្រៅ ។ សីជីន ឈរនៅមុខខុនដូកាលីបមួយដោយគិតតែយំ ទឹកភ្នែកឲ្យរហាម ។

"សីជីន!"

"ឯងមកហើយ ហឺៗ គេនៅខាងលើជាមួយស្រីផ្សេង ហឺៗៗ គេច្បាស់ជាធ្វើអីគ្នាមិនខានទេ"

"ហើយឯងមកឈរនៅមុខខុនដូវាធ្វើអី ម៉េចក៏មិនទៅផ្ទះ"

"ខ្ញុំចង់ឃើញដោយផ្ទាល់ភ្នែកថាពេលព្រឹកគេចេញមកជាមួយគ្នានៅម៉ោងប៉ុន្មាន"

"ឯងនេះច្បាស់ជាឆ្កួតហើយ មកឈរចាំទាំងដែលខ្លួនឯងទើបនឹងត្រូវទាត់ចោលនេះ ណាហ៊ែ្យក ឲ្យមើលបន្តិចមើល៍ វាឲ្យប៉ុន្មានទើបស្តាយមិនហ៊ានគប់ដាក់មុខវាវិញ"

"នេះអ្ហី ថ្លៃបែកគ្នា"

ខ្ញុំយកហ៊ែ្យកពី សីជីន មកមើល ហើយបើកភ្នែកធំៗ÷

"ហេ៎ គេសុំបែកពីឯងដោយតម្លៃប៉ុណ្ណឹងឬ"

"អីចឹងហើយទើបខ្ញុំមិនហ៊ានគប់ទៅវិញ ធ្វើសង្សារមិនដល់មួយខែផង ខ្ញុំបានដល់ទៅ ៥០លានវ៉ុន ស្តាយ"

"ឯងយកលុយគេហើយ ចុះមកអង្គុយយំធ្វើអី"

"វាអាប់យស!"

"តែឯងលក់វាព្រោះហ៊ែ្យកមាសន្លឹកនេះទៅហើយ ថែមទាំងយកលេខទូរសព្ទខ្ញុំទៅលក់មកលេខ ១០ម៉ឺន"

"ឯងដឹងលំអិតដល់ហើយ គឺ កូអឺន បន្ទាប់ហ្នឹងណាំ"

"បន្ទាប់បែបណាឲ្យម៉ាលេខដល់ទៅ ១០ម៉ឺន!"

"គឺវាសមាមាត្រហ្នឹង សប្បាយចិត្តដល់ហើយដែលប្រទេសកូរ៉េមានបែបនេះ ហ៊ិៗ"

"នៅម៉ោហ៊ិៗទៀត ឯងខូចចិត្តមែនអត់ហ្នឹង"

"មែន ឯងនៅចាំជាមួយខ្ញុំទេ"

"មិនចាំ"

"ចិត្តអាក្រក់"

"ខ្ញុំនឹងសម្រុកឡើងទៅ"

"លេងមែនទែនអ្ហ៎"

"តែខ្លាចសន្តិសុខមិនឲ្យឡើង"

"ច្បាស់ជាឲ្យបើមានខ្ញុំ"

"នេះឯងធ្លាប់ម៉ោទីនេះឆ្អែស ឬថាឯង..."

"ហ៎ៗ កុំគិតច្រើន ខ្ញុំម៉ោលេងធម្មតាៗទេ"

"ខ្ញុំមិនចង់ស្ដាប់ទេថាឯងធ្លាប់ធ្វើអីខ្លះ ខ្ញុំចង់ទៅតទល់ជាមួយវានាំខ្ញុំទៅភ្លាម"

"អឺ...អឺ!"

សឺជីន នាំខ្ញុំឡើងមកជាន់ដែលសង្សារនាងនៅបានយ៉ាងស្រួលដោយសន្តិសុខមិនជំទាស់អីបន្តិច ថែមទាំងញញឹមពព្រាយដាក់ហាក់ដូចជាស្គាល់គ្នាយូរយារទៀត ខ្ញុំបម្រុងសួរថា នាងធ្លាប់មកប៉ុន្មានដងហើយ តើមើលម្ចាស់ខ្លួនចុះ ធ្វើជាយំហឺៗ មិនទុកចន្លោះប្រហោងឲ្យខ្ញុំសួរសូម្បីតែបន្តិច ។

"ដល់ហើយ បន្ទប់នេះ"

"នៅជាន់លើបំផុតឬនេះ សង្សារឯងមានណាស់"

"ខុនដូនេះជារបស់គេ"

អូខេ មាន ចប់!

"បន្ទប់នេះមែនទេ ឯងឈរក្រោយខ្នងខ្ញុំ ត្រង់នេះមានវន្ធសោ បើវាឃើញមុខឯង ខ្លាចមិនព្រមបើកទ្វារ"

"អ្វី"

មើលទៅ សេសីជីន ស្ដាប់សម្ដីខ្ញុំគ្រប់យ៉ាង ទើបព្រមមកឈរពួន ក្រោយខ្នងខ្ញុំតាមសម្រួល ពេលគ្រប់យ៉ាងទៅតាមការគិតហើយ ខ្ញុំក៏ គោះទ្វារបន្ទប់ហៅអ្នកនៅខាងក្នុង ។

"ម៉ោហើយ...អ៊ុយ នាងជាអ្នកណា"

ស្រីតូចមុខស្អាត ថ្ពាល់ក្រហម ភ្នែកធំៗ មើលស្ថានភាពដូចទើប ងូតទឹករួច ព្រោះធុំក្លិនសាប៊ូ មនុស្សឆ្កួតស្អីចេញមកទទួលភ្ញៀវដោយ ឈុតងូតទឹក មិនខ្មាសខ្មោចមែន ។

"ខ្ញុំម៉ោរក គីមសាំយ៉ុង"

"នាងជាអ្នកណា"

"ខ្ញុំចង់និយាយជាមួយគេ"

"មានការអី"

សាំយ៉ុង រុំតែកន្សែងពោះគោ បង្ហាញឱ្យឃើញល្វែងលើពេញទៅ ដោយដំណក់ទឹកនិងក្លិនសាប៊ូ ខ្ញុំដៅហេតុការណ៍បានថាពីរនាក់នេះ ទើបនឹងងូតទឹកហើយ ។

ក៏កកក ងូតទឹកហើយព្រមគ្នា ពួកគេងូតទឹកជាមួយគ្នាឬ?

"លោកគឺ គីមសាំយ៉ុង"

"អ៊ុំ នាងហ្នឹងអ្ហ៎ ឈ្មោះ ម៉ាថុងជី"

"ម៉ាថុងអ៊ីល"

"ចុះម៉េចក៏នាងម៉ោនៅត្រង់នេះ...អ៊ុំ អ្ហ៎ មិត្តនាងក៏នៅដែរ ងរង៉ក់ មិនព្រមឈប់ឬ ឱ្យហៀកហើយតើ"

ខ្វាក!!!

ខ្ញុំហែកហៀក ហើយគប់ដាក់មុខ គីមសាំយ៉ុង នៅកណ្ដាល សម្លេងស្រែក...របស់ សេសីជីន ស្រីឆ្កួត ខូចហ្វមអស់!

"ឯងធ្វើអីហ្នឹង"

"ស្ងាត់ទៅ ខ្ញុំចាត់ការឱ្យឯងហ្នឹងអ្វី" ខ្ញុំងាកទៅរក គីមសាំយ៉ុង "លោកធ្វើបែបនេះដាក់មិត្តខ្ញុំមិនបាន មនុស្សយើងមិនអាចទិញគ្នា បានដោយលុយទេ គិតចង់សេពគប់ក៏សេព គិតចង់បែកក៏ឱ្យលុយ

លោកធ្វើមិនត្រូវ"

"តែមិត្តនាងទទួលលុយទៅហើយ"

"តែខ្ញុំហែកហៀកនោះចោលហើយ បើចង់បែកក៏ប្រាប់តាមសម្រួលទៅ កុំមើលថោកគ្នាបែបនេះ មនុស្សពើយ នេះជាមនុស្ស!" ខ្ញុំយកដៃចុចសាច់ដើមទ្រូងម៉ាទ់ៗរបស់ សាំយ៉ុង ហើយរហ័សដកមកវិញហាក់ដូចជាត្រូវខ្សែភ្លើងឆក់ ទន់មែន ដើមទ្រូងធំជាងខ្ញុំទៀត ។

"ហើយចង់ឱ្យធ្វើម៉េច យើងបែកគ្នាទៅ បុណ្ណឹងបានទេ"

"មិនបាន លោកត្រូវក្រាបសុំទោសមិត្តខ្ញុំដែលធ្វើឱ្យនាងខូចចិត្តដោយនាងមិនបានខុស"

"ត្រូវក្រាបឬ ច្កួតអត់ហ្នឹង មនុស្សយើងសេពគប់គ្នាគឺសេព បែកគ្នាគឺបែក ខ្ញុំមិនបានសេពគប់ដើម្បីបូជាទេ"

"អីចឹងក៏ដឹងផងទៅថាមិត្តខ្ញុំមិនមែនអ្នកសុំទាន គិតចង់បែកក៏ឱ្យលុយ អ៊ុំយ មួម៉ៅពើយ សុំម្ដងទៅចុះ!"

"នាងចង់ធ្វើអី អ៊ឹា!!!"

ថាហើយ ខ្ញុំក៏ទាត់បំប្រលោះជើង គីមសាំយ៉ុង មុននឹងដើរចេញមកឡើងឡូយ...ដោយមិនដឹងថានឹងមានរឿងរញ៉េរញ៉ៃតាមមកច្រើនទៀត ។

៣

"ឯងច្បាស់ជាឆ្កួតហើយ ឯងហែកហ៊្វេកតម្លៃ ៥០លានវ៉ុនរបស់ខ្ញុំឱ្យមានតម្លៃស្មើសូន្យក្នុងពេលមិនប៉ុន្មានទាទី ហ៎ៗ" ស៊ីជីន យំឡេឡូហើយឡូឡាមិនឈប់។

"នេះឯងយំខូចចិត្តដែលត្រូវទាត់ចោល ឬស្តាយលុយទេ"

"ស្តាយលុយ!"

ត្រង់មែនទែន!

"ខ្ញុំខំទៅទាមទារយសឱ្យហើយ នៅម៉ោជេរទៀត លើកក្រោយបើមានបញ្ហាគឺមិនចាប់ម៉ោរកខ្ញុំទេ"

"អឺ ខ្ញុំមិនប្រាប់ទេ សង្សារក៏បង់ លុយក៏បាត់ ឈឺចិត្តណាស់ ខ្ញុំមិនចង់ឃើញមុខឯងទៀតទេ"

"ឯងបែបលែងបានឃើញមុខខ្ញុំហើយ"

"មានន័យថាម៉េច" ស៊ីជីន ដែលឡេឡូពីដំបូងទៅជាបានសតិផាកមកនិយាយជាមួយខ្ញុំដោយការតាំងចិត្តតាំងថ្លើម "អាដែលឯងប្រាប់ថាខ្ញុំលែងបានឃើញមុខឯងនេះ នេះឯងប្រហែលមិនបានគួចចិត្តនឹងខ្ញុំដល់ថ្នាក់សម្លាប់ខ្លួនទេមែនទេ ខ្ញុំចេះតែថាព្រោះស្តាយលុយ តែខ្ញុំមិនបានដេញឯងឱ្យទៅងាប់ទេ"

"ខ្ញុំដូរសាលា"

"ឆ្កួត!"

"មិនជឿក៏ទៅសួរម៉ាក់ខ្ញុំទៅ ឯកសណ្ឋានសិស្សសាលាថ្មីត្រូវរៀបចំរួចរាល់អស់ហើយ ថ្ងៃចន្ទនេះខ្ញុំត្រូវដូរទៅសាលាថ្មីហើយ"

"តែនេះទើបពាក់កណ្តាលឆមាស ចុះកន្លែងចាស់ ស្អីនេះ ឯងដូរ

សាលាម៉េចក៏ទើបនឹងប្រាប់ខ្ញុំ"

"ខ្ញុំក៏ទើបនឹងដឹងពីម៉ាក់នៅថ្ងៃនេះដូចគ្នា មិនទេ ត្រូវប្រាប់ថាពីម្សិល ព្រោះនេះជាថ្ងៃថ្មី"

"ហេ៎ បើឯងទៅហើយ ចុះខ្ញុំអង្គុយរៀនជាមួយអ្នកណា"

"ខ្ញុំច្រើនជាងដែលត្រូវខូចចិត្ត ឯងគ្មានខ្ញុំ តែនៅមានមិត្តផ្សេងទៀត តែខ្ញុំ...គ្មានអ្នកណាទេ ថែមទាំងសង្គមថ្មីបែបនោះ ខ្ញុំនឹងត្រូវជួបនឹងអ្វីខ្លះក៏មិនដឹង"

គ្រាន់តែគិត...ក៏ព្រឺទៅហើយ!

ហើយពេលវេលានៃភាពព្រឺរន្ធត់ក៏មកដល់យ៉ាងលឿនដូចចោកប្រាស់អីចឹង ពេលថ្ងៃចន្ទមកដល់ រាងកាយរបស់ខ្ញុំក៏ត្រូវគ្រងដោយឯកសណ្ឋានសិស្សថ្មីដែលម៉ាក់រៀបចំឲ្យល្មមម៉ាច់តែម្តង ។

"នេះគឺកាបូបសិស្សថ្មីតម្លៃថ្លៃដែលម៉ាក់យកមកស៊ើរីប្រែស៍"

កាបូបស្បែកល្អ មានយីហោ ត្រូវញាក់នៅក្នុងដៃខ្ញុំដោយមិនទាន់មានសៀវភៅមួយក្បាល ។

"នេះម៉ាក់ត្រូវឆ្នោតឬ រង្វាន់លេខមួយមែនទេម៉ាក់"

"ស្អី ម៉ាក់មានរបស់ល្អៗឲ្យឯងប្រើខ្លះចាំបាច់ត្រូវឆ្នោតដែរអ្ហ៎"

"ម៉ាក់ដឹងទេថាថ្លៃសាលានេះទម្រាំតែរៀនចប់គឺថ្លៃជាងផ្ទះមួយខ្នងដែលយើងស្នាក់ទៅទៀត"

"យើងលែងនៅហើយ"

"អ្ហ៎?"

"ព្រោះម៉ាក់លក់វាហើយ"

"ហ៎ា!!!" ខ្ញុំស្រែកលាន់ បំពង់សម្លេងសឹងតែបែកជាចម្រៀក ។

"ម៉េចចាំបាច់ធ្វើមុខភ្ញាក់ផ្អើលដល់ថ្នាក់នោះ ទៅរៀនបានហើយ"

"តែថា..."

"ចាំម៉ោវិញសឹមនិយាយគ្នា នៅមានរឿងឲ្យភ្ញាក់ផ្អើលច្រើនជាងនេះទៀត!"

ម៉ាក់រុញខ្ញុំទៅមុខផ្ទះដោយមានតាក់ស៊ីមកចតពីមុខល្មម នោះ

ទើបធ្វើឱ្យខ្ញុំកាន់តែច្របល់ នេះខ្ញុំកំពុងច្របល់ ឬចូលទៅនៅ 4D ។

"មានតាក់ស៊ីម៉ោយកខ្ញុំទៅសាលាថ្មីដែរឬនេះ!"

"អត់ធ្មត់បន្តិចទៅកូន"

"អត់ធ្មត់អី ជិះតាក់ស៊ីទៅសាលាជំនួសឡានក្រុងនេះ វាម៉េចឱ្យប្រាកដទៅ វ៉ាយ!"

ម៉ាក់ញាត់ខ្ញុំចូលទៅបាំងក្រោយ ហើយឱ្យថ្លៃតាក់ស៊ី ព្រមទាំងធ្វើឫកពាកាលីបពេញបន្ទុក ។

"មិនបាច់អាប់ទេ"

"ម៉ាក់!"

ប្រឹន~

អ្នកបើកតាក់ស៊ីម្នាក់នេះក៏ស្ដាប់សម្ដីម៉ាក់ខ្ញុំបានល្អណាស់ គ្រាន់តែប្រាប់ថាមិនបាច់អាប់ ខ្ញុំទៅដាអង្គុយឱបកាបូបគ្មានសៀវភៅដោយភាពខ្លាចរអានឹងល្បឿនរបស់ឡាន ហើយពេលមកដល់សាលាថ្មី ខ្ញុំក៏ភ្លេចអារម្មណ៍ប្រយ័ត្នប្រយែងទៅហើយ ។

វ៉ាវ នេះឬសាលាថ្មីរបស់ខ្ញុំ?

មិនដឹងទេថាអ្នកកសាងសាលានេះចំណាយអស់ប៉ុណ្ណា តែចាន់តម្លៃតាមខ្សែភ្នែក...គឺមហាសាលតែម្ដង សិស្សម្នាក់ៗគឺខុសពីសិស្សនៅសាលាចាស់ខ្ញុំដាច់ឱ្យស្រឡះ គ្រប់គ្នាមើលទៅសប្បាយៗ គឺមិនបានប្រាប់ថាមិនមានរបៀប តែនៅទីនេះគេឱ្យធ្វើម៉ូតសក់ម៉េចក៏បានពណ៌អីក៏បាន ស្អីក៏បាន គ្រាន់តែស្រាតមកមិនបានប៉ុណ្ណោះ ។

ញ័រជើង ខណៈដែលអ្នកណាម្នាក់រត់កាត់ទ្វារសាលាចូលមក មានតែខ្ញុំប៉ុណ្ណោះដែលដើរដូចពាក់ហ្វ៊ែរជប៉ុនទិជឈានតាមចង្វាក់នៃការលោតរបស់បេះដូង ទាំងដែលអ្នកផ្សេងមិនបានមើលខ្ញុំផង តែភាពភ័យខ្លាចដែលមានចំពោះមជ្ឈដ្ឋានថ្មី ធ្វើឱ្យមានអារម្មណ៍ដោយខ្លួនឯងថាត្រូវសម្លឹងមើលដូចកំពុងដើរនៅលើព្រំក្រហមហូលីវូតថតរូបខ្ញុំទៅ សុំហត្ថលេខាខ្ញុំទៅ!!!

"មិនពិត!"

សម្លេងស្រែករបស់អ្នកណាម្នាក់ធ្វើឱ្យខ្ញុំងើយមុខពីការឈ្ងោកមើលដី ហើយមើលទៅតាមប្រភពសម្លេង ។

"ម៉េចក៏នាងម៉ោនៅទីនេះបាន ខ្ញុំមិនធ្លាប់ឃើញនាងទេ!"

"ចុះម៉េចក៏លោកម៉ោនៅទីនេះបាន...កូអឺន" ទម្រាំតែថ្លុំឈ្មោះគេចេញមកបាន ខ្ញុំសឹងតែឈ្លក់ខ្យល់ដង្ហើម ហើយសន្លប់នៅលើផ្លូវដើរ តែហេតុអីក៏ខ្ញុំត្រូវចម្លែកចិត្តដែរ វាប្រាកដណាស់ទៅហើយដែលគេ...

"លោករៀននៅទីនេះ?"

"មែន អ្នកដែលត្រូវធ្វើមុខចម្លែកចិត្តគឺជាខ្ញុំទៅវិញទេ ម៉េចក៏អ្នកក្រដូចនាងម៉ោរៀនទីនេះបាន"

ចាំបាច់និយាយពាក្យថា ក្រ នៅចំពោះមុខគ្រប់គ្នាដែរឬក៏អ្វី!

"ឱ្យតែមានលុយគឺមានសិទ្ធិរៀនបានទាំងអស់ហ្នឹង"

"ម៉េចក៏នាងចាំបាច់ធ្វើសម្លេងដូចខឹងខ្ញុំអីចឹង ហេ៎ កុំដើរគេច"

អាពីតំបូងដែលគ្មានអ្នកណាមើល ហើយគិតថាមានអ្នកមើលគឺខ្ញុំគិតដោយខ្លួនឯង តែពេលនេះមានអ្នកមើលមែនទែន សឹងតែគ្រប់ខ្សែភ្នែកដែលខ្ញុំដើរកាត់ វាស្អីទៅនេះ មើលខ្ញុំធ្វើអី...ឬថាព្រោះ កូអឺនដើរតាមខ្ញុំ ច្បាស់ជាអីចឹងហើយ ។

"ខ្ញុំប្រាប់ឱ្យឈប់ អ៊ូយ! ចង់ឈប់ម៉េចក៏មិនប្រាប់មុន"

"ចង់យ៉ាងម៉េច ចង់ឱ្យឈប់ ឬឱ្យដើរ ឈប់ក៏រអ៊ូ មិនឈប់ក៏រអ៊ូមើលណ៎ មនុស្សម្នាមើលខ្ញុំហើយ"

"គឺនាងដើរគេចខ្ញុំ!"

"ចុះលោកមានការស្អីណាស់ណាទៅ"

"នាងមិនទាន់ប្រាប់ទេថាម៉ោទីនេះធ្វើអី...នាងមិនបានប្រូទេមែនទេថារៀននៅទីនេះ"

"មើលតាំងពីក្បាលដល់ចុងជើង ឯកសណ្ឋានសិស្សដែលខ្ញុំពាក់នៅមើល៎ មិនដូចសិស្សសាលានេះទៀតឬ"

"យ៉ាងហោចណាស់ក៏នាងមិនបានពាក់ឈុតក្នុងរបស់សាលានេះដែរ"

"ហើយវាមានផលិតចេញម៉ោទេ!"

"បើនាងចង់ឱ្យមាន ខ្ញុំនឹងប្រាប់ចា៎"

"ចា៎លោកជាម្ចាស់សាលានេះឬ!" ខ្ញុំលោតគេចចេញពីគេបែប Over action "លោកជាតួឯកប្រុស F4 ឬយ៉ាងម៉េច"

"ម៉េចក៏មនុស្សចូលចិត្តនិយាយបែបនេះ ព្រោះតែអីចឹងហើយទើបខ្ញុំមិនចង់មានមិត្តភក្តិច្រើន ខ្លាចគេថាតាំងជាក្រុមបែបតួកុន គឺដូចថា ខ្ញុំមិនត្រឹមតែមានទេ គឺសង្ហាទៀត"

ហត់ចិត្តនឹងអាម្សៀនេះណាស់ តាំងពីតំបូងដល់ថ្ងៃនេះ!

"អីចឹងប្រែថាលោកមិនសូវមានអ្នករាប់អាន"

"អ្នកណាប្រាប់ មានតែអ្នកចង់រាប់អានខ្ញុំ តែខ្ញុំរើសមនុស្ស មានមិត្តគឺត្រូវមើលចំនួនផង"

"ហេតុអី"

"បើមាន១៣ នឹងមើលទៅដូច Super Junior បើមាន៩ដូច Girls' Generation បើមាន៥ដូច ដុងបាំងស៊ីនគិ ពេកហើយ ហើយបើមាន៤ គឺជា F4 បើមាន៣គឺជា D2B ទើបខ្ញុំជ្រើសរើសរាប់អាន គឺមសាំយ៉ុងតែម្នាក់បានហើយ"

"ស្មើនឹងមានគ្នាពីរនាក់"

"មែន"

"អ្ហ៎ ជារ៉េបទីហ្វ៊ីងអ៊្ហ៊ីង"

"ច្រូត!!!"

"ខ្ញុំនិយាយខុសត្រង់ណា!"

"អីចឹង M2M"

"មិនមែន"

"Cinderella man"

"មិនមែន"

"ចុះជាស្អី"

"កាងហូសេ ចាងស៊ុបិយ៉ុក"

យ៉ាប់ជាងខ្ញុំដាក់ឱ្យទៅទៀត!

"លេងសើចទេ ខ្ញុំគឺខ្ញុំ ខ្ញុំគឺ កូអីន អ្នកដែលមានបុគ្គលិកលក្ខណៈ

ជារបស់ខ្លួនឯង ថែមទាំងមានមុខមាត់សង្ហានិងមានបរិគល្អទៀត តែ ថានាងរៀននៅបន្ទប់ណា ថ្នាក់ណា"

"គឺតាមតារាងដែលម៉ាក់ឲ្យ...លោកដណ្ដើមយកបាត់ហើយ!"

"បន្ទប់បី រ៉ាយ...ល្ងង់ ប្រែថាលទ្ធផលរៀនសូត្រយ៉ាប់ហើយទើបត្រូវនៅថ្នាក់នេះ ហ៊ូៗ"

"លោកត្រូវការផ្សារភ្ជាប់ស្អីឲ្យប្រាកដទៅ យកតារាងខ្ញុំទៅហើយម៉ោនិយាយស្ដីបែបនេះទៀត ឲ្យម៉ោវិញ!"

"ទេ!" គូអឹន មិនព្រមឲ្យកាលវិភាគមកខ្ញុំ ថែមទាំងដណ្ដើមយកកាបូបសិស្សខ្ញុំទៅកាន់ទៀត "ចាំខ្ញុំនាំទៅបន្ទប់តាមតារាងនេះ នាងនឹងបានស្គាល់សាលារបស់ខ្ញុំដែរ"

"ខ្ញុំមិនបានសុំ"

"មិនពេញចិត្តក៏ឈប់រៀនទៅ"

"អីចឹងខ្ញុំឈប់ក៏បាន"

"ល្ងង់បន្តិចទៅ!"

"ថ្លុកស្អីនេះ"

"តស់ទៅ"

"ពីយ!!!"

គូអឹន នាំខ្ញុំដើរមើលសាលារៀនមួយជុំវិញ ចង្អុលនេះចង្អុលនោះហាក់ដូចខ្លួនឯងស្គាល់ច្បាស់ បន្ទប់ខ្លះសម្រាប់ដាក់របស់សោះ គេបែរជាប្រាប់ថាជាបន្ទប់របស់មេផ្ទះ (ស្គាល់សាលារបស់ខ្លួនបានល្អមែន) តែថាខ្ញុំត្រូវការរកបន្ទប់រៀនខ្លួនឯង គេនាំដើរជុំវិញសាលាធ្វើអីហើយពេលដើរក៏មានអ្នកមើលហើយងាកទៅខ្សឹបខ្សៀវគ្នា សង្ស័យតែថ្លុកហើយ ឃើញមនុស្សស្អាតសង្ហាមិនបាន (ហ៊ានផង)។

"ពេលណា"

"ស្អី"

"នឹងនាំខ្ញុំទៅបន្ទប់រៀន លោកនាំខ្ញុំដើរទៅដើរមកមួយជុំហើយ"

"ដូរបន្ទប់ទៅ"

"ស្អី"

"ទៅរៀនបន្ទប់ជាមួយខ្ញុំ មិនត្រឹមតែមានតែអ្នកពូកែ ថែមទាំងមានខ្ញុំដែលមុខមាត់សង្ហាទៀតផង"

"បើបន្ទប់នោះគ្មានលោក ខ្ញុំក៏ដូរទៅដែរ"

"មានន័យថាម៉េច"

"កាំងហ្វូសេ រៀននៅទីនេះដែរ ម៉េច...ខ្ញុំដៅត្រូវទេ?"

"កាំងហ្វូសេ ណា?"

"បើលោកជា ចាង់ស៊ីប៊ីយ៉ុក គីមសាំងយ៉ុង គឺ កាំងហ្វូសេ នោះអ្វីរត់ហុយដីសំពោងម៉ោហើយ"

"ម៉េចក៏នាងមិនភ្លេចរឿងនេះ ប្រាប់ហើយតើថានិយាយលេង!"

គីមសាំយ៉ុង រត់មករកយើងដោយទឹកមុខភ្ញាក់ផ្អើល បន្ទាប់មកក៏ឈរដង្ហក់ ហើយសម្លឹងមុខខ្ញុំយ៉ាងយូរ ។

"អ្នកដែលឯងដើរតាមគឺស្រីម្នាក់នេះទេអ្ហ៎ស!" សាំយ៉ុង ។

"ខ្ញុំធ្វើឲ្យលោកភ្ញាក់ផ្អើលដល់ថ្នាក់រត់មករកផងអ្ហ៎" ខ្ញុំមើលគេតាំងពីក្បាលដល់ចុងជើង នៅមិនភ្លេច អាស្រោតល្វែងលើថ្ងៃនោះ វាដូចរូបភាព3D ដែលចាំមកលងខ្សែភ្នែកខ្ញុំពេលដែលមើលមុខគេ ។

"អ្នកណារត់ម៉ោរកនាង ខ្ញុំម៉ោរកមិត្តភក្តិ ឮម្នាក់ៗនិយាយថាកូអ៊ីន ដើរតាមសិស្សថ្មីទើបចង់ម៉ោឃើញផ្ទាល់ភ្នែកថាជាអ្នកណាបានជាធ្វើឲ្យកូនម្ចាស់សាលាដែលមិនធ្លាប់ចាប់អារម្មណ៍អ្នកណាសូម្បីមិត្តភក្តិ មកដើរតាមបែបនេះ"

"ស្អីគេ ខ្ញុំចាប់អារម្មណ៍មិត្តភក្តិ ហើយខ្ញុំក៏មិនបានដើរតាមស្រីម្នាក់នេះដែរ ខ្ញុំឲ្យនាងដើរតាមខ្ញុំទៅវិញទេ ឯងមិនឃើញទេអ្ហ៎ស..." កូអ៊ីន ថា ព្រមទាំងយកដៃអង្អែលសក់ខ្លួនឯងពេលខ្ញុំងាកទៅមើល ។

"នាងនៅបន្ទប់ណា"

"ប៊ី"

"បន្ទប់ជាមួយគ្នា"

"វ៉ាយ ល្ងង់!!!" ខ្ញុំ ។

"ថាម៉េច ថាបន្ទប់ខ្ញុំល្ងង់ នាងក៏ល្ងង់ដែរអីចឹង"

"ខ្ញុំយកពាក្យនេះមកពីមិត្តលោកទេ កូអ៊ីន ប្រាប់អីចឹង"

"ខ្ញុំនិយាយពីអង្គាល់...ទៅៗ ទៅរៀនទៅ ចាំខ្ញុំនាំមិត្តទាំងពីរទៅបន្ទប់ ទាំងនឹងខ្ញុំវាម៉េចហ្នឹង យើងជួបគ្នាបីដងហើយ"

"បីដងហើយវាម៉េច"

"ទាំងមិនដឹងឬ" កូអ៊ីន ។

"ម៉េចនឹងដឹងទៅ"

"ល្ងង់!"

ទៀតហើយ!

ខ្ញុំត្រលប់មកផ្ទះដោយភាពល្អិតល្ហៃ ម៉ាក់រហ័សមកសួរនាំរឿងសាលាថ្មីដោយសម្លេងឡាៗហាក់ដូចខ្លួនឯងទៅរៀនជំនួសខ្ញុំអ៊ីចឹង ។

"ម៉េចម៉ាដែរ មជ្ឈដ្ឋានយ៉ាងម៉េចដែរ មិត្តភក្តិល្អៗទេ ហើយវាហៃសូសមដូចគេល្បីទេ"

"សមដូចគេល្បី មជ្ឈដ្ឋានល្អ ហៃសូដែលមិនអាចចាន់បាន តែមិត្តភក្តិល្អទេ ខ្ញុំមិនដឹងទេ"

ព្រោះតាមដែលឃើញ គ្រប់គ្នាគឺមើលទៅខុសគ្នា អ្នកដែលធ្លាប់ចាប់ក្រុមធ្វើការជាមួយគ្នាគឺជ្រើសរើសក្រុមដើម អ្នកណាធ្លាប់អង្គុយជាមួយគ្នាក៏អង្គុយជាប់គ្នាដូចដើម ខ្ញុំដែលជាសិស្សថ្មី ទើបចូលទៅថ្ងៃនេះ ក៏កណ្តាចកណ្តែងឯកា...

ឯកាពីអង្គាល់?

គឺអាម្សៀ កូអ៊ីន ហ្នឹងហើយដែលធ្វើឱ្យខ្ញុំត្រូវត្រលប់មកផ្ទះវិញដោយការឃាតនៀយបែបនេះ គ្មានមិត្តណាហ៊ាននិយាយជាមួយខ្ញុំព្រោះអាម្សៀនោះគិតតែតាមខ្ញុំស្អិត បន្ទប់ខ្លួនឯងមិនទៅរៀន បែរជាមកអង្គុយជាមួយខ្ញុំ ដេញប៉ុណ្ណាក៏មិនទៅ ហ៊ឺុយ!

"ចុះនេះម៉ាក់កំពុងធ្វើអី ម៉េចក៏របស់របរត្រូវរាយប៉ាយបែបនេះ...កុំប្រាប់ណាំថាគេមកទារបំណុលទៀតហើយ ឥឡូវនេះវាដល់ថ្នាក់រឹករបស់របរហើយឬ!"

ខ្ញុំឡូឡា របស់របរត្រូវគ្រវាត់គ្រវែងពេញផ្ទះ...តែក៏មិនដូចការរឹកកាយប៉ុន្មានទេ ដូចត្រូវរៀបចំឱ្យទៅជាអីចឹង គ្មានអ្វីខូចខាត ថែម

ទាំងផ្នែកខ្លះនៅដាក់ឱ្យមានរបៀបទៀត ។

"ម្ចាស់បំណុលមិនមោទៀតទេ ព្រោះម៉ាក់សងអស់ហើយ"

"ស្អីគេ ម៉ាក់ត្រូវឆ្នោតពិតមែនឬនេះ"

"លើសពីត្រូវឆ្នោតទៅទៀត"

"បើមិនមែន ចុះម៉េចក៏ម៉ាក់..."

"វ៉ាលីខោអាវមានតែប៉ុណ្ណឹងមែនទេ អ្ហ៎ា...នេះជា ចុងអុិល មែនទេ សួស្តី"

នៅស្រុះៗ អាប្រុសណាក៏មិនដឹង ធ្វើឫកពាដូចជាស្គាល់ខ្ញុំ យកវ៉ាលីខោអាវទាំងអស់របស់ខ្ញុំនិងម៉ាក់ដាក់ចុះ ហើយចូលមកឱបខ្ញុំ ហាក់ដូចជាស្គាល់គ្នាជាង១០លានឆ្នាំមុនអីចឹង ។

"សួ...សួស្តី" ខ្ញុំរហ័សថយចេញពីគាត់ដោយការហួងហែងសាច់ឈាម គឺខ្ញុំជាស្រីជាក្រមុំហ្នឹងណា៎ "អ្នកណាគេ...ម៉ាក់"

"ម៉េចក៏គ្មានមាយាទអីចឹង រាក់ទាក់លោកប៉ាឱ្យសមទំនងទៅ"

"លោកប៉ា...ស្អីគេម៉ាក់ លោកប៉ាឬ!"

មានអារម្មណ៍ថាដូចត្រូវភ្លើងឆក់ពេញរាងកាយ ពេលដៅហេតុការណ៍ចេញថាបុរសដែលចូលមកឱបខ្ញុំ ហើយញញឹមដូចតួឯកប្រុសឃោសនាថ្នាំដុសធ្មេញនេះជាអ្នកណា...ម៉ាក់បិទបាំងខ្ញុំបានយ៉ាងម៉េចអស់រយៈពេលយ៉ាងយូរ ហើយពេលចង់ប្រាប់ក៏ប្រាប់បែបនេះឬ?

"នេះអូនមិនធ្លាប់ប្រាប់កូនទេឆ្អើស"

"គឺចង់សើប្រាយស៍" ម៉ាក់ងាកមកធ្វើមុខក្រញូក្រញូវដាក់ខ្ញុំ "ឈប់ធ្វើមុខដូចខ្មោចលងទៅបង"

"អ៊ាហ៎ា"

"ស្វាមីថ្មីរបស់ម៉ាក់ និងជាអ្នកដែលក្លាយជាប៉ាថ្មីរបស់កូនចាប់ពីពេលនេះទៅ"

៤

ប៉ាំងៗ!

"ម៉ាថុងអ៊ីល! បេញម៉ោនិយាយគ្នាឲ្យដឹងរឿងភ្លាម ម៉េចក៏គ្មានមាយាទអីចឹង បេញម៉ោ!"

មិនថាម៉ាក់គោះទ្វារបន្ទប់ខ្លាំងៗដាក់ថ្នាក់អ្នកជិតខាងចេញមកស្រែកដេរប៉ុណ្ណា (ករជ្រុល) ខ្ញុំក៏មិនចេញទៅតាមបញ្ជារបស់គាត់ដាច់ខាត ខ្លួនឯងគិតចង់ធ្វើអីក៏មិនប្រឹក្សាជាមួយកូនស្រីទោលម្នាក់នេះទេឬយ៉ាងម៉េច នៅសុខៗក៏មកប្រាប់ថាមានប្ដីថ្មី ហើយខ្ញុំកំពុងតែមានប៉ាថ្មី។

"មិនអីទេអូន បងថាអូនក៏ខុសដែរដែលមិនព្រមប្រាប់រឿងនេះឲ្យកូនដឹងមុន"

"អូនខ្លាចប្រាប់ទៅកូនឡូឡាអីចឹង"

"ទៅនិយាយគ្នានៅខាងក្រោមទៅ"

សម្លេងម៉ាក់និងប៉ាថ្មីរបស់ខ្ញុំក៏ឮតិចទៅៗរហូតដល់បាត់ ដៅថាពួកគាត់បែបចុះទៅខាងក្រោមអស់ហើយ ខ្ញុំគួរធ្វើយ៉ាងម៉េចល្អ ខ្ញុំសម្ងំនៅក្នុងបន្ទប់ពេញមួយថ្ងៃមិនបានទេ តែបើចេញទៅ ម៉ាក់ច្បាស់ជាអូសទៅបង្កើតភាពស្និទ្ធស្នាលនឹងគ្រួសារថ្មីដែលកំពុងតែកើតឡើងមិនខាន អីចឹងតើថាម៉េចក៏នៅសុខៗម៉ាក់មានលុយបញ្ជូនខ្ញុំទៅរៀននៅសាលាថ្លៃ ថែមទាំងឲ្យជិះតាក់ស៊ីទៅរៀនទៀត។

គុកៗ

"ថុងអ៊ីល...ជួយចេញម៉ោនិយាយជាមួយខ្ញុំបន្តិចបានទេ"

លោកប៉ាថ្មីគោះទ្វារ ព្រមទាំងនិយាយស្ដីសុភាពទន់ភ្លន់រហូតដល់

ខ្ញុំមានអារម្មណ៍ថារអៀសចិត្ត ហើយខ្ញុំក៏ចិត្តទន់ព្រមដើរទៅបើកទ្វារឲ្យគេតាមសម្រួលដោយកាយវិការប្រយ័ត្នប្រយែង អីយ៉ា...តីព័ត៌មានផ្សាយឡើងគគោក ឪពុកចុងរំលោភកូនដើម ថែមទាំងខ្ញុំក៏ស្អាតទៀត (ហ៊ានផង) ។

"អ៊ំសប្បាយចិត្តដែលក្មួយបើកទ្វារឲ្យ"

ថាទៅ...មុខមាត់អ៊ំប្រុសម្នាក់នេះដូចប្រហែលៗ ដូចធ្លាប់ឃើញនៅឯណាអីចឹង ។

"អ៊ំសុំនិយាយជាមួយបានទេ"

"តីបើកទ្វារឲ្យហើយតើ"

"អីចឹងយើងនិយាយគ្នាខាងក្នុង"

"បើកទ្វារនិយាយ"

គាត់ធ្វើមុខចម្លែកចិត្តបន្តិច មុននឹងញញឹមបែបយល់ដឹង ហើយគ្រវីដៃ÷

"ហ៎ៗ អ៊ំមិនធ្វើអីគួរឲ្យស្អប់បែបនោះទេ យើងបើកទ្វារនិយាយគ្នាក៏បាន អ៊ំម៉ោក្នុងផ្លូវល្អទេ"

ដោយសម្លេងដែលពេញទៅដោយភាពប្រាកដប្រជា ទើបខ្ញុំងក់ក្បាល ដូចជាការអនុញ្ញាតឲ្យគាត់ចូលមកក្នុងទឹកដីអីចឹង ។

"អ៊ំមានឈ្មោះអីដែរ ខ្ញុំនឹងបានហៅត្រូវ"

"ចុងកូម៉ា ហៅថាអ៊ំ អច្ឆរិយៈ ក៏បាន"

"ខ្ញុំដូចធ្លាប់ឃើញអ៊ំនៅឯណា ប្រហែលៗមុខណាស់...ចុងកូម៉ាហៅ អច្ឆរិយៈ"

"យ៉េស!"

"មិនពិត!" ខ្ញុំលោតថយក្រោយ យកដៃក្តោបទ្រូងខាងឆ្វេងខ្លួនឯងដោយខ្លាចថាបេះដូងនឹងធ្លាយចេញមកក្រៅដូចរូបភាពនៅលើអេក្រង់ធីវីអិលស៊ីឌី "កុំប្រាប់ណាំថាអ៊ំគឺអ្នកដែលត្រូវបុះទស្សនាវដ្តីញឹកញាប់ ហើយក៏ទើបធ្វើកម្មវិធីបោះសួតកាលពីថ្មីៗនេះ"

"មែន តីអ៊ំ"

អីចឹងតើបានជាប្រហែលៗយ៉ាងនេះ តាំងពីតំបូងដែលឃើញ ខ្ញុំក៏

មើលដឹងតាមរយៈពន្លឺនៃមាសប្រាក់ដែលចាំងចែងតាមខ្លួនប្រាណរបស់គាត់ អ៊ំប្រុសមើលទៅជុំវិញខ្លួន ហើយញញឹម ។

"ក្មួយនៅផ្ទះមួយនេះតាំងពីកំណើតឬ"

"គឺតាមដែលមានការចងចាំបាន"

"បើទៅនៅជាមួយអ៊ំ អ៊ំនឹងឱ្យបន្ទប់ធំជាង...៥ដង"

"ចង់ឱ្យបើកហាងទំនិញឬ គ្រាន់តែគេងបាន ខ្ញុំសប្បាយចិត្តពេកទៅហើយ"

"អ៊ំមិនបានចង់មានន័យថាអីចឹងទេ"

"ខ្ញុំមិនបានខឹងទេ ហោះៗ កុំធ្វើមុខបែបនោះអ្ហី"

ឫកពារគមាត់រហ័សចិត្តរហ័សរបស់ខ្ញុំធ្វើប្តីថ្មីរបស់ម៉ាក់ភាន់កាំងទៅហើយ តែមើលទៅគាត់ក៏មិនមែនជាមនុស្សអាក្រក់អី គួរតែទុកចិត្តបាន ។

"ចុះអ៊ំនិងម៉ាក់ស្គាល់គ្នាបានយ៉ាងម៉េច ព្រោះសង្គមអ្នកទាំងពីរមិនគួរណាមកជួបប្រសព្វគ្នាបានទេ"

"វាជាព្រហ្មលិខិត"

"ហឺ?"

"ពេលម៉ាក់របស់ក្មួយកំពុងឆ្លងថ្នល់ អ៊ំបើឡានមិនប្រយ័ត្ន រ៉ះនឹងបុកគាត់ទៅហើយ សំណាងល្អដែលជាន់ហ្វ្រាំងទាន់ តែដោយការភិតភ័យ ម៉ាក់ក្មួយក៏សន្លប់ យើងក៏បានជួបគ្នាតាំងពីពេលនោះមក" ទឹកមុខរបស់គាត់មើលទៅភ្លឺស្វាង ដល់ថ្នាក់ធ្វើឱ្យខ្ញុំព្រឺរោម ។

មនុស្សចាស់ក៏មានស្នេហាបានណ៎ា (ហេតុអីក៏មានមិនបាន) ។

"ពេលកាន់តែបាននិយាយជាមួយ ស្គាល់គ្នា អ៊ំគិតថាម៉ាក់ក្មួយចំជាមនុស្សចិត្តល្អខ្លាំងណាស់"

"ម៉ាក់ខ្ញុំនេះ" ខ្ញុំសួរដោយសម្លេងហាក់ដូចហ្គីតាដូរសម្លេង "អ្វីដែលធ្វើឱ្យអ៊ំមានអារម្មណ៍បែបនោះ"

"គាត់ស្រលាញ់អ៊ំដោយមិនចង់បានផលអ្វី"

ម៉ោង ៩:៤៦ យប់ នៅថ្ងៃតែមួយ

ការពិតគឺ...

"បើមិនធ្វើបែបនោះលោក ចុង នឹងគិតថាម៉ាក់ជាមនុស្សឃើញតែលុយ ដែលការពិតទៅឯងក៏ដឹងថាម៉ាក់ជាមនុស្សមុខលុយប៉ុណ្ណា លុយសំខាន់ជាងអ្វីៗទាំងអស់ គ្មានលុយ យើងនឹងស្លាប់!"

ខ្ញុំចំហមាត់ម្ហូបៗ បន្ទាប់ពីលើកចិត្តនិយាយជាមួយម៉ាក់ ដែលពេលនេះខោអាវទាំងអស់របស់យើង អ៊ំ អច្ឆរិយៈ យកទៅអស់ហើយ ។

ដឹងស្រាប់ហើយ មនុស្សដូចម៉ាក់ខ្ញុំឬចិត្តល្អ!

អ៊ុយ...មិនបាននិន្នាទេ តែខ្ញុំស្គាល់ម៉ាក់ច្បាស់ជាងអ្នកណាៗទាំងអស់នៅលើលោកនេះ ថ្នាក់ឆ្អឹងត្រីដែលយកសាច់ញុាំអស់ហើយក៏មិនឱ្យឆ្មាប៉ះផង ព្រោះខ្លាចត្រីមិនបានទៅដល់សុគតិភព រាប់ស្អីនឹងត្រូវឡានបុកហើយមិនទាមទារថ្លៃជម្ងឺចិត្ត ដែលស្ដាប់យ៉ាងណាក៏មិនមែនជាម៉ាក់ខ្ញុំ មិនមែនទេ!!!

"អីចឹងរឿងដែលគាត់វិះនឹងបើកឡានបុក គាត់ប្រាប់ថាម៉ាក់មិនសូម្បីតែទាមទារថ្លៃខូចខាតនោះ"

"បើកាលនោះទារ ថ្មើរនេះក៏មិនបានទៅនៅជាមួយគេដែរ"

"ល្បិចខ្លស់!"

"អ្នកមានតែងតែខ្លាចយើងទៅដណ្ដើមរបស់គេ ដែលបើយើងចង់បានរបស់គេ យើងត្រូវតែធ្វើជាមិនចង់បាន ពេលបានទទួលការទុកចិត្តទុកថ្លើមហើយ គេនឹងឱ្យយើងដោយខ្លួនឯង ហើយវាក៏មិនមែនជម្មតាៗដែរ...មហាសាល!"

"នេះស្មើនឹងម៉ាក់បោកគាត់ហើយ...ម៉ាក់ធ្វើបានយ៉ាងម៉េច!"

"អាយុប៉ុណ្ណឹងហើយគឺត្រូវតែរកទីពឹងពាក់"

"ចុះស្នេហា ម៉ាក់មិនធ្លាប់មានស្នេហាឱ្យគាត់ទេអ៊្ហស"

"រស់នៅក្នុងពិភពនិទានច្រើនពេកអត់ ម៉ាក់ផុតវ័យដែលរវើរវាយពីរឿងស្នេហាយូរហើយ ចូលគេងទៅ ស្អែកពេលចេញពីសាលា មានអ្នកបើកឡានទៅយក"

"ទទួលហើយយ៉ាងម៉េច"

"ទទួលហើយក៏នាំទៅផ្ទះថ្មី"

នៅក្នុងរយៈពេលមិនប៉ុន្មានថ្ងៃ ជីវិតដ៏សែនទីទាល់ក្ររបស់ខ្ញុំក៏ប្តូរផ្លាស់ក្លាយមកជាកូនចុងរបស់សេដ្ឋី បានរៀនសាលាថ្មី មានមិត្តភក្តិថ្មី មានសង្គមថ្មី ថែមទាំងមានឡានចាំជូនទៅ យកមកទៀតផង តែហេតុអីទៅណា៎ ទាំងដែលគ្រប់យ៉ាងវាល្អដល់ថ្នាក់នេះ ខ្ញុំបែរជាគ្មានក្តីសុខ?

"ដកដង្ហើមធំធ្វើអី"

"ហៀក! លោកធ្វើឱ្យខ្ញុំលោះព្រលឹង!"

កូអឹន លោតផ្លោះជើងម៉ា ហើយដាក់បង្គុយក្បែរខ្ញុំ ទៀតហើយ ...គ្រប់ខ្សែភ្នែកសម្លឹងមើលមកខាងនេះទៀតហើយ ។

"ម៉េចក៏ថ្ងៃនេះមិនទៅញ៉ាំបាយ"

"លោកជាពោះវៀនធំរបស់ខ្ញុំឬយ៉ាងម៉េច ម៉េចក៏ចាំបាច់មកខ្វល់ដែរថាខ្ញុំញ៉ាំ ឬ មិនញ៉ាំ ម្យ៉ាងទៀត...ថយចេញទៅបានទេ រាល់ពេលដែលលោកចូលមកជិត មានខ្សែភ្នែកចម្លែកៗមើលមកជានិច្ច"

"នោះគឺមកពីខ្ញុំឆ្លាត សង្ហា និងជាចរិតរបស់អ្នកនៅទីនេះ នាងគួរតែមានមោទនភាពដែលមានប្រុសសង្ហា ឡូយ ពូកែ កាលីប អ៊ីបៗដូចខ្ញុំចាប់អារម្មណ៍រាប់អាន ធ្វើបុណ្យប៉ុន្មានជាតិក៏មិនបានអីចឹងដែរ"

"ប៉ុនិយាយមែនទែន អីផ្សេងអាចនឹងយល់ តែអ៊ីបៗនេះជាស្អីឈឺពោះអីអីសឬ"

"ម៉េចក៏ការសន្ទនារបស់យើងទៅមិនផុតពីរបស់បែបនោះអីចឹង"

"គឺលោកចាប់ផ្តើមមុនមិនមែនឬ"

ខ្លួនឯងហៅខ្ញុំ ថាំងអាចម៍ សោះ និយាយប៉ុណ្ណឹងធ្វើងងឯណា!

"តែថានាងមានសង្សារទៅ"

"ហ៎ា!" ពេលជួបសំនួរដែលមិនគិតថានឹងបានជួប ខ្ញុំក៏ចំហមាត់ម្លបៗ អ្នកសួរត្របៀកក្រហមដោយមិនដឹងខ្លួន "សួរធ្វើអី"

"វាជាអាថ៌កំបាំងឬយ៉ាងម៉េច"

"យើងស្គាល់គ្នាប៉ុណ្ណាទើបដល់ថ្នាក់ម៉ោសួរស្អីបែបនេះ" ខ្ញុំយកបាតដៃទាំងពីរដាក់លើថ្ពាល់ខ្លួនឯងដោយមានអារម្មណ៍ថាក្តៅកាយៗ "ចង់ដឹងធ្វើអី"

"សួរប៉ុណ្ណឹងធ្វើងងឯណា ខ្ញុំមិនបានចាប់អារម្មណ៍នឹងនាងជា

ពិសេសទេ ឆ្លើយម៉ោថាមានទៅ"

"មិនឆ្លើយ មិនប្រាប់ លោកមិនធ្លាប់និយាយរឿងផ្ទាល់ខ្លួនឱ្យខ្ញុំស្តាប់ផង"

"ចុះនាងធ្លាប់សួរខ្ញុំទេ! ខ្ញុំគ្មាន"

"មិនទាន់បានសួរផង!"

"មិនអីទេ ខ្ញុំក្រៅពីសង្ហាហើយនៅចិត្តទូលាយទៀត ចំណែកនាងមិនឆ្លើយក៏មិនបាច់ឆ្លើយដែរ ដឹងត្រឹមតែថាខ្ញុំគ្មានទៅបានហើយ"

តាមពិតគេតាំងចិត្តមកធ្វើអីឱ្យប្រាកដទៅ!

"ចុះនាងមិនសប្បាយចិត្តអី មិនឃើញញាំចាយ ថែមទាំងអង្គុយដកដង្ហើមធំម៉ាគំនរទៀត មានបញ្ហាអីអាចប្រាប់ខ្ញុំបាន ព្រោះយើងជួបគ្នាបីដងហើយ មិនរាប់លើកនេះទេ រាប់ជាពិសេសពេលចៃដន្យ...ខ្ញុំចាត់ទុកថាយើងស្និទ្ធស្នាលគ្នាហើយ"

"ហើយលេខបីវាសំខាន់ស្អីណាស់ណាទៅ ហេតុអីជួបគ្នាបីដងប្រែថាស្និទ្ធស្នាលគ្នា"

"ខ្ញុំមានជំនឿថា..." កូអឹន គ្រហែម ព្រមទាំងងើបអង្គុយត្រង់ខ្លួន "ការដែលមនុស្សយើងបានជួបគ្នាដោយចៃដន្យដល់ទៅបីដង វាជាអ្វីដែលដូច...ព្រហ្មលិខិត"

"អ៊ុ ព្រឺសម្បុរណាស់"

ពេលនេះខ្ញុំចាប់ផ្តើមមិនមែនជាខ្លួនឯងហើយ គេមកអង្គុយនិយាយស្អីនេះ៎ ព្រហ្មលិខិត...ពាក្យបែបនេះចេញពីមាត់មនុស្សប្រុសដូចជាគេបានយ៉ាងម៉េច អៀនដល់ក ។

"ខ្ញុំមិនគួរនិយាយទេ លែងខ្វល់នឹងនាងហើយ!"

"អ្ហ៎ា លែងចង់ស្តាប់បញ្ហារបស់ខ្ញុំហើយអ្ហ៎"

"ចាំលើកក្រោយទៅ"

កូអឹន ងើបឈរ ត្រៀមនឹងដើរគេច មុខគេពេលនេះក្រហាមដូចភ្លើងអីចឹង ការដែលនិយាយពាក្យរ៉ូមែនទិក តែលួចព្រឺបែបនោះចេញមកបាន វាត្រូវតែអាស្រ័យភាពក្លាហាន...

"ឈប់សិន"

"ស្អី" គេងាកមកសម្លក់ធ្វើដូចធុញទ្រាន់ ។

"ខ្ញុំមិនទាន់មានសង្សារទេ"

"អឺ...អ៊ឹម ល្អ"

ហើយគេក៏រត់ចេញទៅដោយមិនងាកមកមើលទៀត...ស្អីហ្នឹង គ្រាន់តែប៉ុណ្ណឹងនេះ!

ហើយពេលវេលាដ៏សំខាន់ក៏មកដល់ ពេលឡានធំវែងហាក់ដូចពស់ថ្លាន់ព័ន្ធកន្ទុយគ្នា៣០ក្បាលមកចតនៅសាលា ខ្ញុំព្រិចភ្នែកមើលឡានលីមូមួយនោះដោយភាពភាន់ភាំង ចាប់អារម្មណ៍ ស្អាតអស់ទាស់ ធ្លាប់ឃើញតែក្នុងរឿង នេះមាននៅក្នុងជីវិតពិតដែរឬនេះ!

"និ...នេះឡានឬ"

"បាទ អ្នកនាង"

"អ្នកនាងឬ!"

ខ្ញុំភ្ញាក់ព្រើតពេលអ៊ំតៃកុងឡានហៅខ្ញុំថាអីចឹង ជួយផង ព្រឺរោមពេញខ្លួនហើយ ស្មានថាឱ្យឃើញតែក្នុងកុន ។

"ខ្ញុំចង់ក្អួត ហៅខ្ញុំថា ឋុងអ៊ុល ធម្មតាៗទៅបានហើយ"

"មិនស្រួលខ្លួនឬ"

"ខ្ញុំទ្រាំនឹងពាក្យថា អ្នកនាង មិនបាន"

"តែយើងក៏ហៅកូនៗរបស់លោកប្រុសថា អ្នកប្រុស អ្នកនាង គ្រប់គ្នាហ្នឹង"

"លោកប្រុស? អ៊ំអច្ឆរិយៈ ឬ គាត់មានកូនដែរ"

"បាទមាន និយាយដើមក៏មកដល់"

គូអ៊ីន ដើរមករកខ្ញុំដោយបូកពាចម្លែកចិត្ត តៃកុងឡានឱនគោរពគេ ហើយហៅ÷

"អ្នកប្រុស"

"ថាម៉េច!" ខ្ញុំស្រែកខ្លាំងៗឡើង គូអ៊ីន សើច ។

"វាចឹងនាង ខ្មោចចូលឬក៏ម៉េច ហើយម៉ោឈរធ្វើអីត្រង់នេះ នេះជាឡានអ្នកផ្ទះខ្ញុំ ឬចង់ឱ្យខ្ញុំជូនទៅ វ៉ាយ...នាងមិនបេះខ្មាសមែន ចង់

ឲ្យជូន សួរម្ចាស់ឡានហើយនៅ"

"ម្ចាស់ឡាន...លោកជាម្ចាស់ឡាន ចៅហ្វាយរបស់តៃកុងម្នាក់នេះឬ"

"មែនហើយ ម៉េចចាំបាច់ធ្វើមុខដូចខ្មោចលង់អីចឹង ស្អីក៏ស្អីទៅ" កូអ៊ីន ធ្វើមុខមិនចាប់អារម្មណ៍ថាខ្ញុំសួរស្អី នៅសុខៗក៏រុញខ្ញុំចូលឡានមួយនេះ "ថ្ងៃនេះខ្ញុំជូននាងទៅផ្ទះ"

"តិ...តែ...តែ!"

ល្បែងទាន់ហើយ ស្ងប់តែតៃកុងក៏មើលខ្ញុំដោយខ្សែភ្នែកចម្លែក តែថាមិនបាននិយាយអ្វីច្រើនក្រៅពីបិទទ្វារឲ្យតាមតួនាទី ។ ពេលឡើងឡានបានហើយ ក៏មានអារម្មណ៍ថាអាប់អួសឹងតែដកដង្ហើមមិនចេញ ចាប់ផ្ដើមដឹងពីជោគជតាកម្មអ្វីម្យ៉ាងដែលនឹងកើតឡើងនៅក្នុងពេលមិនប៉ុន្មាននាទីខាងមុខពេលទៅដល់ផ្ទះ ។

"នាងចង់ចូលញ៉ាំអីសិនទេ ខ្ញុំស្គាល់ហាងថ្នាញ់ៗនិងថ្លៃណាស់ចាំខ្ញុំបាវ ព្រោះខ្ញុំសង្ហានិងមានណាស់"

"មិនអីទេ ដូរជា...នាំខ្ញុំទៅផ្ទះលោកល្អជាង"

"ស្អី"

"សម្រេចថាតៃកុងនាំខ្ញុំទៅណា ខ្ញុំក៏ទៅហ្នឹង"

"នាងជាស្រីដែលមុខក្រាស់បំផុត នេះចូលចិត្តខ្ញុំដល់ថ្នាក់តាមទៅផ្ទះឬនេះ"

"មិនចង់ទៅឬ"

"ចង់ គ្រិៗ"

សើចបានគួរឲ្យស្អប់ខ្លាំងណាស់!

កូអ៊ីន យកដៃបិទមាត់ ហើយញញឹមម្នាក់ឯងដូចកំពុងគិតអីនៅក្នុងចិត្ត កាយវិការរបស់គេធ្វើឲ្យខ្ញុំមានអារម្មណ៍ថារសើប អាប៉ិច្ចតនេះកំពុងគិតអី គំនិតរបស់យើងវាច្បាស់ជាផ្ទុយគ្នា ខណៈដែលគេមានក្ដីសុខ ខ្ញុំបែរជាមានទុក្ខមហាសាលដោយភាពភ័យខ្លាចថាអ្វីដែលគិតវាជាការពិត ។

"នេះគឺផ្ទះខ្ញុំ"

"មិនពិត!"

"ពិត!"

នេះគេហៅថាផ្ទះឬ! គឺបានឮខ្លះថាគេមានខ្លាំងណាស់ ហើយអ៊ំអច្ឆរិយៈ ជាមហាសេដ្ឋីជាប់លំដាប់ថ្នាក់របស់កូរ៉េ តែថាអ្នកដែលមានខ្លាំងណាស់ចាំបាច់នៅផ្ទះធំដល់ម្លឹងដែរឬយ៉ាងម៉េច?

"ផ្ទះលោកនៅប៉ុន្មាននាក់"

"ខ្ញុំ ប៉ា និងប្អូនស្រីម្នាក់ ក្រៅពីនោះគឺអ្នកបម្រើ"

"ពាក់ឯកសណ្ឋានដូចក្នុងកុនអត់"

"ពាក់ ឯកសណ្ឋានរបស់យើងថ្លៃម៉ូតដោយអ្នកច្នៃម៉ូតល្បីឈ្មោះដើម្បីឱ្យផ្ទះខ្ញុំមើលទៅល្អមានលំដាប់ ហើយបន្ទប់គេងខ្ញុំក៏ធំដែរ"

"ខ្ញុំសួររឿងខោអាវអ្នកបម្រើ ទាក់ទងអីទឹងបន្ទប់គេង"

"គ្រិៗៗ"

ពេលនេះគេប្រហែលជាសើចសម ព្រោះមិនទាន់ដឹងថាការពិតជាអ្វី ពេលឡានចតជាប់ជណ្តើរផ្ទះ អ្នកបម្រើច្រើននាក់ចេញមកឈរស្វាគមន៍យ៉ាងមហោឡារិក ។

"ម៉េចក៏អ្នកបម្រើម៉ោឈរច្រើនម្លេះ" កូអ៊ីន រអ៊ូរទាំម្នាក់ឯង មុននឹងបើកទ្វារចុះពីឡាន ហើយរត់មកបើកទ្វារឱ្យខ្ញុំ "នេះគឺផ្ទះខ្ញុំ សូមស្វាគមន៍"

"អឺ...អ៊ឹម"

"ចូលទៅក្នុងផ្ទះជាមួ..."

កូអ៊ីន និយាយមិនទាន់ចប់ផងក៏ត្រូវច្នក់ពេលអ៊ំប្រុសនិងម៉ាក់ខ្ញុំដើរចេញពីក្នុងផ្ទះ គេមើលម៉ាក់ខ្ញុំបែបមឹងមាំង តែកាន់តែច្ងល់គឺពេលប៉ារបស់គេដើរមករកខ្ញុំ ហើយឱបដោយក្តីស្រលាញ់ ។

"សូមស្វាគមន៍កូនសម្លាញ់ថ្មីរបស់អ៊ំ"

"ស្អីគេ" កូអ៊ីន ជ្រែកសម្លេង ហើយធ្វើភ្នែកព្រិចៗមើលប៉ាខ្លួនឯងបែបមិនយល់ "ប៉ាស្គាល់ ម៉ាជុងអ៊ុល ដែរឬ"

"ស្គាល់ ឯងជិះឡានជាមួយគ្នា ស្គាល់គ្នាខ្លះហើយនៅ"

"យើងស្គាល់គ្នាយូរហើយ ហើយថ្ងៃនេះខ្ញុំនាំនាងម៉ោលេង"

អុំប្រុសសើចក្អាកក្អាយ ហើយខោកក្បាលកូនប្រុសបែបមិនប្រកែប្រកាន់÷

"ម៉ោលេងស្អីឯង ពេលនេះ ចុងអ៊ីល ម៉ោនៅផ្ទះយើងក្នុងឋានៈជាកូនស្រីរបស់ប៉ា ហើយជាប្អូនស្រីរបស់ឯង"

"ថាម៉េច!"

កូអ៊ីន ងាកមកមើលមុខខ្ញុំដោយខ្សែភ្នែកមិនអាចចាប់ន័យបាននោះហើយដែលធ្វើឲ្យខ្ញុំដឹងព្រាលៗថា...នឹងមានរឿងតាមមកមិនចេះចប់មិនចេះហើយ ។

៥

"នេះចាក់ចង់រៀបការមិនគិតនឹងប្រាប់ខ្ញុំមួយម៉ាត់ទេឬម៉េច!"

គូអ៊ីន ពេលដឹងរឿងគ្រប់យ៉ាងហើយក៏ឡូឡាភ្លាម ខ្ញុំបានតែអង្គុយបន្ទឹមខ្លួនក្បែរម៉ាក់មិនហ៊ានងើយមុខមើលគេ មនុស្សនៅក្នុងលោកមានឡើងគគោក ម៉េចក៏ខ្ញុំត្រូវមកចៃដន្យជួបគេញឹកញាប់បែបនេះ!

"ព្រោះចាក់ដឹងថាបើប្រាប់ ឯងនឹងមានអាការៈបែបនេះ"

"មានច្បាស់ហើយ ចាក់ធ្វើអីមិនប្រឹក្សាជាមួយខ្ញុំទេ មិនគិតនឹងសួរយោបល់ស្អី ថែមទាំង...ម៉េចចាំបាច់ជាស្រីម្នាក់នេះ!"

គូអ៊ីន មើលមកម៉ាក់និងខ្ញុំដោយខ្សែភ្នែកពេញទៅដោយភាពអួអាប់និងសែនឈឺចាប់ ខ្ញុំដឹងច្បាស់ថាពេលនេះគេមានអារម្មណ៍យ៉ាងម៉េច ព្រោះមុននេះខ្ញុំក៏បានជួបវាដែរ។

"ចាក់ចង់រៀបការរស់នៅជាមួយអ្នកណាចាំបាច់ប្រឹក្សាជាមួយឯងសិនឬយ៉ាងម៉េច ចាក់ជាចាក់ឯង"

"តែខ្ញុំជាកូនចាក់ មិនគិតនឹងប្រាប់ស្អីទេក៏អ្វី"

"ប្រាប់ទៅក៏រឿងច្រើន"

"កាន់តែមិនប្រាប់ហ្នឹងហើយដែលវារឿងច្រើន ចាំមើលទៅ ថាវាយ៉ាងម៉េចបន្ត"

"ឯងចង់មានន័យថាម៉េច ចុងគូអ៊ីន ម៉ោវិញភ្លាម"

គូអ៊ីន ស្ទុះចេញទៅក្រៅ បន្ទាប់ពីនោះមិនយូរប៉ុន្មាន ក៏ឮសម្លេងបញ្ឆេះឡាននៅក្នុងផ្ទះរបស់គេ ហើយក៏ដូចដែលដឹង...គេបើកឡានចេញទៅបាត់ហើយ។

"ប្រហែលមិនមែនម៉ាក់តែម្នាក់ទេដែលមិនប្រាប់ អ៊ំប្រុសក៏មិន

ប្រាប់កូនប្រុសគាត់ដែរ"

ខ្ញុំនិយាយដោយអារម្មណ៍ចង់រិះគន់ តាមរយៈការសន្ទនាមុនមិញ ធ្វើឲ្យខ្ញុំអាចដឹងថា អ៊ំប្រុសសឹងតែមិនផ្តល់ភាពសំខាន់ចំពោះអារម្មណ៍កូនប្រុសសូម្បីតែបន្តិច...ដូចម៉ាក់អ៊ីចឹង កូនគ្មានសិទ្ធិធ្វើអ្វីទាំងអស់។

"បើអ៊ំប្រាប់គឺវាតែងតែអ៊ីចឹង អ៊ំមិនអាចដៅស្ថានការណ៍បានថាកូអឺន ចង់ធ្វើអ្វីខ្លះ ណេ្ហីយៗ អ៊ំត្រៀមបន្ទប់ឲ្យក្មួយរួចហើយ"

ខ្ញុំចង់និយាយ តែពេលងាកទៅឃើញម៉ាក់ធ្វើមុខដូចហាមប្រាមមិនឲ្យបញ្ចេញយោបល់អី ទើបខ្ញុំបិទមាត់ភ្លាម ។

"ចាំ"

អ៊ំប្រុសនាំខ្ញុំឡើងទៅមើលបន្ទប់ដេក តំបូងមិនចង់ឃើញប៉ុន្មានទេ តែពេលបានឃើញ ខ្ញុំសឹងតែស្រែកចាចចេញមកដោយចិត្តរំភើបកើតចេញពីពោះម៉ាក់ពោះចាយូរឆ្នាំហើយមិនធ្លាប់គិតថាខ្លួនឯងនឹងមានបន្ទប់ដេកដូចព្រះនាងនៅក្នុងនិទានទេ គ្រប់យ៉ាងពេញទៅដោយពណ៌ផ្កាឈូកនិងល្បាយពណ៌សហោះហើរទៅមក ។

"អ៊ំឲ្យ អ៊ុនជីវៀ មកតុបតែងថ្មីជាពិសេស"

"ក្នុងពេលមួយថ្ងៃឬ"

"អត់ទេ អ៊ំត្រៀមទុកមួយរយៈហើយ ក៏លួចកង្វល់ដូចគ្នាថាក្មេងស្រីនឹងចូលចិត្តម៉ូតនេះគ្រប់គ្នាអត់ តែមើលតាមរយៈចរិតឬកពាក្មួយទៅ អ៊ំថាមិនគួរណាមានបញ្ហាអីទេ សាកចូលមើលទៅ វាធំទូលាយជាងបន្ទប់ក្មួយច្រើនណាស់"

"មិនអាចចូលទៅក៏អាចដៅបានដែរ" ខ្ញុំលបលេបទឹកមាត់លាន់អឿកដោយភាពមិនគួរឲ្យជឿនឹងជោគជតាខ្លួនឯង ពីម្សិលខ្ញុំដេកនៅក្នុងទ្រុងឆ្កែ (ពេកហើយ) តែថ្ងៃនេះមានបន្ទប់ព្រះនាងជារបស់ខ្លួនឯងហើយ "អ៊ំមិនគួរណាចាំបាច់លំបាកទេ"

"អ៊ំចង់ឲ្យក្មួយមើលឃើញទឹកចិត្ត យើងនឹងបានរស់នៅជាមួយគ្នាដោយមានក្តីសុខ"

"ចាំ"

ពេលអ៊ំប្រុសបណ្ដោយឱ្យនៅម្នាក់ឯង ខ្ញុំក៏ដើរពិនិត្យមើលបន្ទប់របស់ខ្លួនដោយអារម្មណ៍សុខសាន្តលើគំនរទុក្ខទោម្នេញរបស់ខ្លួន ពេលនឹកទៅដល់ទឹកមុខរបស់ កូអឺន ដែលមើលមកខ្ញុំពេលនោះហើយ វាក៏ធ្វើឱ្យមានអារម្មណ៍មិនល្អ គេបើកឡានចេញទៅយ៉ាងនោះនឹងកើតអីឬអត់ ដែលសំខាន់...មានប័ណ្ណបើកបរហើយនៅ (នេះជារឿងដែលគួរឱ្យបារម្ភមែនទេ) ។

ផ្លូង!

ថូផ្កាដែលដាក់នៅកណ្ដាលតុត្រូវធ្លាក់បែក ពេលងាកទៅមើលក៏ឃើញមានស្រមោលមួយលឹបលៗ ។

"អ្នកណា ឈប់ភ្លាម!"

ស្រមោលលឹបលៗនោះអាចជាក្មេង ព្រោះសម្រិបជើងដែលរត់មើលទៅញាប់ពេកហើយ ហើយពេលរត់ដេញតាមមកដល់សួនស្មៅក្រោយផ្ទះ (ផ្ទះធំពេកហើយ) ខ្ញុំក៏លោតទៅសង្គ្រប់ដូចចាប់ចោរ រួចខ្លួនយើងក៏រមៀលទៅរមៀលមកទាល់តែក្លិនក្លរ៉ូភីលនិងកម្ទេចស្មៅជាប់ពេញខ្លួន សក់កន្ទ្រើងកន្ទ្រើង ។

"អ្ហ៎ាៗៗ អ្ហ៎ាៗៗ"

"ឈប់ភ្លាម ឈប់ស្រែកភ្លាម ឈប់!!"

"អ្ហ៎ាៗៗ"

មិនត្រឹមតែមិនឈប់ទេ នាងល្អិតនេះថែមទាំងចាប់ទាញសក់ខ្ញុំឱ្យរបូតរបាញទៀត ហើយខ្វៅកខ្ញុំដូចឆ្មាឆ្កួត ។

"អ៊ូយ ឈប់ភ្លាម ខ្ញុំប្រាប់ឱ្យឈប់!"

ខ្ញុំរុញនាងឱ្យនៅពីក្រោម ហើយចាប់សង្កត់ដៃទាំងពីរនោះជាប់ នាងល្អិតខ្លួនតូចដែលមានអាយុមិនគួរណាដល់១២ឆ្នាំនៅតែស្រែកដោយគ្មានប្ញូកពោថាបំពង់-កនឹងបែកធ្លាយ ។

"កើតអី!"

សម្លេងអ៊ំប្រុសមកដល់មុនរាងកាយ បន្ទាប់ពីនោះក៏មានច្រើននាក់ទៀតមកចាប់បំបែកពួកខ្ញុំ ម៉ាក់ងាកមកមើលខ្ញុំ ហើយចាប់នេះចាប់នោះដោយកាយវិការភិតភ័យ ។

"ម៉េចក៏ឯងមានឈាម ដូចត្រូវថ្មាខ្វៅក"

ពេលម៉ាក់និយាយ ខ្ញុំក៏លើកដៃស្ទាប.ក ហើយក៏ឃើញថាមានឈាមមែន ។

"ក្មេងម្នាក់នេះជាអ្នកណាអ៊ំប្រុស"

"មែនហើយ អ្នកណាគេ" ម៉ាក់ ។

បុរសចំណាស់ធ្វើមុខពិបាកចិត្ត ហើយបញ្ជាឲ្យអ្នកបម្រើបីនាក់តូចដែលនៅតែឡូឡាចេញពីកន្លែងដែលយើងឈរ ។

"មិនបាច់ភ្ញាក់ផ្អើលទេ ខ្ញុំភ្លេចប្រាប់ពីរឿងនេះទៅ"

"អីដែរទៅ" ម៉ាក់ ។

"ក្មេងមិញនេះ...ឈ្មោះ ចុងកូសង់ ជាកូនស្រីរបស់ខ្ញុំ"

អ៊ំប្រុសនាំម៉ាក់និងខ្ញុំមកអង្គុយនិយាយគ្នាជាលក្ខណៈផ្ទាល់ខ្លួនទាក់ទងនឹង ចុងកូសង់ នោះហើយដែលធ្វើឲ្យខ្ញុំនិងម៉ាក់រន្ធត់ចិត្តពេលដឹងថា... ក្មេងស្រីម្នាក់នោះមិនដូចមនុស្សទូទៅ ។

"គេកើតមកខុសប្រក្រតី គ្រប់យ៉ាងមើលទៅដូចធម្មតា មានតែខួរក្បាលទេ គេកើត Autistic"

"អន់បញ្ញាឬ" ម៉ាក់និយាយដាំងចេញមក ហើយរហ័សបិទមាត់ភ្លាមពេលឃើញខ្សែភ្នែកបុរសចំណាស់មើលមកដោយការមិនពេញចិត្ត "សុំទោស ខ្ញុំមិនសូវដឹងរឿងអស់នេះទេ"

"មិនមែនអន់បញ្ញា គេគ្រាន់តែខុសប្រក្រតីខាងខួរក្បាល អាការៈរបស់គេគឺមានពិភពផ្ទាល់ខ្លួន មិនចុះចូលនឹងអ្នកណា គេគ្រាន់តែមិនចេះទំនាក់ទំនងជាមួយអ្នកណាតែប៉ុណ្ណោះ តែអូនមិនបាច់បារម្ភទេ គេមិនធ្វើបាបអ្នកណាឡើយ"

"តែនាងប្រមក់នេះឈាម-កហើយ បងនៅប្រាប់ថាមិនចេះធ្វើបាបអ្នកណាទៀតឬ បងស្រលាញ់កូនបង អូនក៏ស្រលាញ់កូនរបស់អូនដូចគ្នា!"

"មិនអីទេម៉ាក់ ប្អូនមិនបានតាំងចិត្តឡើយ ទោះយ៉ាងឲ្យខ្ញុំសុំទោសជងអ៊ំ ដែលចាប់ប្អូនបែបនោះ ពេលនោះខ្ញុំមិនដឹងថាគួរចាត់ការបែប

ណាពិតមែន ពេលឃើញនាងស្រែក ទើប...ខ្ញុំធ្វើអីមិនត្រូវ"

ខ្ញុំប្រាប់ដោយមានអារម្មណ៍អៀសចិត្តបំផុត តាមពិត...ខ្ញុំរិះនឹងទះកំផ្លៀងនាងទៅហើយ (សារភាពនៅក្នុងចិត្ត) ។

"បងមិនឃើញប្រាប់អូនទេថាមានកូនស្រី មកជួបបែបនេះក៏ភ័យមិនបេះតិចដែរ"

"សុំទោសផង"

"បើគ្មានអីទេខ្ញុំសុំទៅសិនហើយ ចង់សម្រាក"

ខ្ញុំបណ្ដោយឱ្យចាស់ៗនិយាយគ្នាគាត់ ចំណែកខ្លួនឯងក៏ចេញមកដើម្បីទៅរកក្មេងស្រីម្នាក់នោះដោយត្រូវការកែតសម្ព័ន្ធភាព ។ ពេលដឹងថានាងនៅបន្ទប់ណា ខ្ញុំក៏ចូលទៅភ្លាម ហើយក៏ឃើញនាងអង្គុយរៀបបៀតម្រៀបគ្នាដោយមានសមាធិ ។

"កុំទាន់ទៅរំខានគេ" សម្លេងអ្នកមើលថែតឿនពេលឃើញខ្ញុំ ព្រមទាំងញញឹមដាក់ "គេទើបស្ងប់ បណ្ដោយឱ្យអង្គុយលេងម្នាក់ឯងសិនទៅ តែថាអ្នកនាងឈឺណាស់មែនទេ"

"អ៊ុំ មិនអីទេ ខ្ញុំចង់និយាយជាមួយគេដើម្បីស្គាល់គ្នា"

"ឱ្យសុំទោសផងដែលអ្នកនាងតូចធ្វើឱ្យអ្នកនាង..."

"ខ្ញុំ ប៊ុនអ៊ីល"

"អ្នកនាង ប៊ុនអ៊ីល ត្រូវឈឺ គេបែបយល់ថាជាមនុស្សប្លែកមុខទើបមិនចូលចិត្ត តែបើនៅជាមួយឱ្យបានយូរ គេនឹងស៊ាំ"

"អ្នកនាងតូចអាចនឹងមិនចូលចិត្តឱ្យខ្ញុំប៉ះពាល់ទេដឹង អាខ្ញុំក៏មិនដឹង ទៅដល់ប៉ុបក៏លោតសង្គ្រប់ ហេះៗ" ខ្ញុំមើលទៅ កូសង់ ម្ដងទៀតហើយញញឹមដាក់អ្នកមើលថែ "បើអីចឹងខ្ញុំសុំទៅសិនហើយ ចាំម៉ោរកអ្នកនាងតូចម្ដងទៀត"

"ចាំ"

និយាយទៅថ្ងៃនេះជីវិតរបស់ខ្ញុំមានការផ្លាស់ប្ដូរខ្លាំងណាស់ តែដូចថាអីចឹង មនុស្សយើងធ្វើអ្វីតែងតែមានឧបសគ្គ ត្រូវមកនៅផ្ទះថ្មីដែលចាស់ៗទាំងសង់ខាងមានកូនរៀងខ្លួន ទើបលំបាកគឺជារឿងធម្មតា

តែកូនរបស់គាត់មិនគួរជា កូអឹន ទេ ងាប់ហើយ!

ម៉ោងមួយទាបភ្លឺទៅហើយ ខ្ញុំជាក្មេងល្អដែលចូលដេកតាំងពីម៉ោង១០ក៏ត្រូវលោតចុះពីគ្រែព្រះនាង (ចង់ប្រាប់ថាវាជាគ្រែព្រះនាងដែលមើលទៅមានអនាគតខ្លាំងណាស់) ព្រោះសម្លេងទូរសព្ទ ។

"ហាឡូ"

(លើកទូរក្លាម)

"អ្នកណា លើកទូរស័ព្ទថ្មើរនេះ នេះម៉ោង១ហើយ...កូអឹន ឬនេះ"

ពេលខួរក្បាលចាប់ផ្ដើមធ្វើការ នៅសុខៗខ្ញុំក៏ដូចជាដឹងភ្លាមថាជាសម្លេងរបស់គេ ។

(ខ្ញុំប្រាប់ឲ្យលើកទូរ!)

"ទូរអី ទូរផ្ទះឬ មានអ្នកយាមនៅមុខផ្ទះតើ"

(ទ្វារបន្ទប់នាង ពេលនេះខ្ញុំនៅមុខបន្ទប់នាង)

"ហើយលោកមោបន្ទប់ខ្ញុំធ្វើអី"

(បើនាងមិនបើកតាមសម្រួល ខ្ញុំនឹងស្រែកឲ្យបែកផ្ទះ ហើយទម្លាយចូលទៅ រើសទៅ ខ្ញុំរាប់ថយក្រោយហើយ ៥...២...១...)

"លោកធ្វើធ្លាក់លេខឬយ៉ាងម៉េច ពី៥ម៉ោដល់២បានយ៉ាងម៉េច អីខ្ញុំនឹងលើកឲ្យភ្លាមនេះ"

គឺមិនដឹងគេមកស្អីលណា តែវាប្រហែលជាមិនល្អទេលើមកនៅផ្ទះគេថ្ងៃតំបូងក៏មានរឿងទៅហើយនោះ ទើបខ្ញុំរត់ទៅបើកទ្វារដោយគ្មានលក្ខខណ្ឌ ហើយក៏ឃើញថា កូអឹន ឈរនៅមុខបន្ទប់មែន ថែមទាំងមានក្លិនស្រាទៀត ។

"លោកញ៉ាំស្រាឬនេះ អ៊ូយ ម៉េចចាំបាច់រុញ!"

ប៉ុង...

ទ្វារបន្ទប់ត្រូវរុញបិទយ៉ាងខ្លាំង កូអឹន ដើរចូលមកជិតរហូតដល់ខ្ញុំក្លាយជាអ្នកថយក្រោយដោយការភ័យខ្លាច ។

នេះមិនមែនជាស្ថានការណ៍ធម្មតាទេ ខ្ញុំមិនធ្លាប់ឃើញគេគួរឲ្យខ្លាចបែបនេះឡើយ ។

"មា...មានអីក៏ចាប់និយាយម៉ោ នេះយប់ជ្រៅហើយ"

"ខ្ញុំធ្លាប់សង្ស័យថាម៉េចក៏ចាំឲ្យគេមកតុបតែងបន្ទប់ថ្មី តែក៏មិនបានភ្នកចិត្តអី ស្មានថាធ្វើឲ្យ កូសង់ មានពីអង្កាល់...ចាំធ្វើឲ្យនាងទេ ចាំខ្ញុំធ្វើឲ្យកូនថ្មីរបស់គាត់គឺនាង"

"វាគួរឲ្យមហាស្ចារ្យមែន ហោះ។"

នេះគឺអ្វីដែលខ្ញុំតបបានឬនេះ គ្មានពាក្យណាដែលធ្វើឲ្យស្ថាន-ការណ៍ប្រសើរជាងនេះទេឬនេះ?

"ដែលនាងធ្វើជាម៉ោស្គាល់ខ្ញុំ ព្រោះនាងដឹងតាំងពីតំបូងមែនទេ"

"ច្អួតទេអ្នំស!" ការភិតភ័យធ្វើឲ្យខ្ញុំស្រែកដាក់គេវិញ "ខ្ញុំក៏ទើបតែដឹងមិនយូរប៉ុន្មាននេះដែរ ហើយក៏ទើបដឹងថាជូរមកនៅទីនេះ វ៉ាយ!"

ខ្ញុំត្រូវគ្រវែងឲ្យប៊ីងទៅលើគ្រែ កូអ៊ីន ដើរតាមមក ហើយយកអ្វីម្យ៉ាងចេញមក ព្រមទាំងខ្វាំ ហើយគប់ដាក់មុខខ្ញុំ ។

"ដាក់លេខទៅ ចង់បានប៉ុន្មានក៏ដាក់ទៅ ហើយធ្វើតាមតួនាទីរបស់នាង"

"និយាយច្អួតស្អី"

"បៀក្រនោះ ខ្ញុំមិនទាន់ដាក់លេខទេ នាងដាក់ម៉ោ ហើយមានស្អីៗជាមួយខ្ញុំភ្លាមនេះ!"

"ហ៊ា!"

៦

កូអ៊ីន លោតឡើងលើគ្រែ ហើយចាប់ដៃជើងខ្ញុំដាប់ ពេលអាច ដោយបានថាគេកំពុងគិតចង់ធ្វើអី ទើបខ្ញុំព្យាយាមរើបម្រះ តែក៏មិនបាន ផល ។

"កុំធ្វើអីឆ្កួតៗ"

"ម៉េច! ខ្ញុំជាកូនរបស់ប៉ា ខ្ញុំក៏មានលុយចាយដូចគាត់ដែរ នាង បដិសេធធ្វើអី ខំដាក់ផែនការចង់ចាប់ដើម្បីចូលមកជិតខ្ញុំហើយ ពេល ខ្ញុំចាប់ធ្វើឯងរើបម្រះ" @ amazingshelf.blogspot.com

"ខ្ញុំមិនដឹងរឿងពិតមែន អ្ហាៗ យកមុខលោកចេញទៅ ខ្ញុំរសើប!"

គេថើបជញ្ជក់ពេញមុខខ្ញុំយ៉ាងអន្ទះអន្ទែង ការពិតខ្ញុំធ្លាប់គិតថា អាចនឹងមានថាកូរ៉េមនទឹកអ៊ីបែបនេះជាមួយគេនៅពេលណាមួយ តែ ពេលជួបហេតុការណ៍ពិត ខ្ញុំបែរជាធ្វើខ្លួនមិនត្រូវ គិតតែបិទភ្នែកជិត ដោយការភ័យខ្លាច ។ ខណៈដែលខ្ញុំជិតអស់កម្លាំងព្រោះអស់សង្ឃឹម ថានឹងយកឈ្នះកម្លាំងគេបាន សម្លេងគ្រែកនៅត្រង់ទ្វារក៏ឮឡើង ដូច ជារគាំងជួយជីវិតខ្ញុំអីចឹង ។

កូសង់ ឈរនៅមាត់ទ្វារដោយឫកពាមិនយល់ថាមានអ្វីកើត ឡើង កូអ៊ីន ដែលងាកទៅមើលក៏ភាំងមួយស្របក់ ទើបនោះក្លាយជា ចន្លោះដែលគួរតែយករួចខ្លួនបានដោយការយកក្បាលខោកនឹងច្រមុះ មានខ្ទង់របស់គេលាន់ប៉ឹក ។

"អ៊ូយ! ស្រីឆ្កួត ឈប់ភ្លាម!"

ខ្ញុំរត់កាត់មុខ កូសង់ ចុះទៅជាន់ក្រោម ដោយមាន កូអ៊ីន ដេញ តាមពីក្រោយទាំងខ្លួនគេនៅឈឺ តែហើយក៏ត្រូវច្នក់ពេលឃើញម៉ាក់

ឈរនៅត្រង់ដណ្ដើរ។

"កើតអី ម៉េចក៏ធ្វើមុខដូចឃើញខ្មោច"

"ម៉ាក់"

"នេះនាងហ៊ានគេចពីខ្ញុំផងអ្ហ៎ស...អ្ហ៎" កូអឺន ក៏ត្រូវចុកដូចគ្នាពេលឃើញមុខម៉ាក់ "ឲ្យវាអីចឹងទៅ"

"កំពុងនាំគ្នាលេងអីហ្នឹង"

"មិនបានលេងជាមួយអ៊ំទៅគឺបានហើយ!"

សម្លេងរាងគំហកបស់ កូអឺន ធ្វើឲ្យម៉ាក់ញញឹមលែងសមុ ទៅជាខ្វមុខភ្លាម គេមិនត្រឹមតែមិនចាប់អារម្មណ៍នឹងម៉ាក់ទេ ថែមទាំងធ្វើឫកឲ្យឃើញថា មិនធ្លាប់មានម៉ាក់នៅក្នុងខ្សែភ្នែកទៀតផង ដោយការដើរកៀសខ្ញុំមួយទំហឹងរិះតែធ្វើឲ្យខ្ញុំផ្កាប់មុខធ្លាក់ពីលើដណ្ដើរ រួចក៏ដើរចុះទៅក្រោមហៅអ្នកបម្រើ។

"ពូគីម!"

"បាទអ្នកប្រុស"

អ្នកបើកឡានដែលទៅយកខ្ញុំក៏ចេញមុខមកភ្លាម ដូចចុចតេឡេហៅ ហើយទទួលបញ្ជា។

"រកទឹកមន្តម៉ោលាងម៉ុំនេះផង សិយ!"

"=O="

និយាយចប់ កូអឺន ក៏ដើរកាត់មុខម៉ាក់ ហើយធ្វើ ហឺ ចេញមកមុននឹងឡើងមកលើវិញ ខ្ញុំមិនដឹងទេថាអ្នកបើកឡានទៅយកទឹកមន្តមកមែនអត់ តែក៏ឃើញដើរចេញទៅបាត់ ទុកឲ្យខ្ញុំនិងម៉ាក់បានតែឈរមើលមុខគ្នាដោយភាពតានតឹង។

"ព្រៃផ្សៃ"

"ម៉ាក់ តិចៗ បើគេបានឮ តើធ្វើម៉េចទៅ"

"ឮក៏ឮទៅ គឺវាព្រៃផ្សៃមែន ឯងមិនឃើញមាយាទដែលវាធ្វើទេក៏អ្ហី!" ម៉ាក់ដែលលាក់អារម្មណ៍យូរហើយក៏ផ្ទុះឡើង "វាសម្ដែងចេញឱ្យច្បាស់ក្រឡែតថាស្អប់ម៉ាក់ ហើយមើលទៅវាដូចជាមិនចាប់អារម្មណ៍ទេថាឪវាគិតយ៉ាងម៉េចចំពោះម៉ាក់"

"ទោះបន្ទោសគេក៏មិនត្រូវដែរម៉ាក់ នៅសុខៗយើងក៏ចូលម៉ោនៅ អីប្រុសក៏មិនបានប្រាប់គេឲ្យដឹងមុន វាប្រហែលជាទោមិនរួចទេដែល គេព្រមទទួលម៉ាក់ភ្លាមៗ"

"អ៊ូយ! ម៉េចក៏វាយ៉ាប់យ៉ឺនដល់ថ្នាក់នេះ ស្មានថាការជាមួយអ្នក មានហើយរស់នៅបានសុខ ត្រូវម៉ោមានរឿងជាមួយកូនប្រុសដើងល្អ របស់គេទៀត ហើយនេះឯងនិងអាម្សៀនោះធ្វើស្អី ម៉េចក៏ដល់ថ្នាក់រត់ ដេញគ្នា មើលឫកពាទៅបែបមិនមែនលេងសើចទេមែនទេ"

"គេមិនចូលចិត្តម៉ាក់ អីចឹងកូនក៏គេមិនចូលចិត្តដូចគ្នាដែរ"

"ល្មមៗបានហើយ...ស្គាល់ម៉ាក់ស្តើងពេកហើយ!"

"ម៉ាក់ចង់ធ្វើអី"

"ធ្វើគ្រប់វិធីដើម្បីឲ្យវាចេញពីទីនេះ"

"O_O"

មើលទៅដូចជាមាន...រឿងកាន់តែធំហើយ ។

ថ្ងៃបន្ទាប់

ខ្ញុំដេកមិនលក់ព្រោះរវល់តែគិតច្រើនពីរឿងយប់មិញ ទើបព្រឹក ឡើងភ្នែកដូចខ្លាឃ្មុំផែនដា ថែមទាំងព្រឹកនេះត្រូវមកញាប់ញ័រថានឹង មានរឿងអីកើតឡើងខ្លះបើយើងទាំងអស់បានជួបមុខគ្នា ។

ការមករស់នៅផ្ទះថ្មីនេះ ខ្ញុំពិតជាមិនទម្លាប់នោះទេ ព្រោះកាល នៅផ្ទះចាស់ ខ្ញុំចង់ញ៉ាំអីក៏ត្រូវដើរមកធ្វើដោយខ្លួនឯងមុនទៅសាលា តែទីនេះមានច្បាប់រស់នៅរួមគ្នា គឺត្រូវញ៉ាំបាយនៅតុអាហារដោយ មានអ្នករៀបចំឲ្យរួចជាស្រេច ។

"ម៉េចក៏ថ្ងៃនេះ កូអឺន មិនទាន់ចុះម៉ោទៀត"

"ចុះម៉ោហើយលោកប្រុស ហើយក៏ទៅសាលាហើយដែរ"

"ហ៎ា? នេះទើបម៉ោងពាហ្វឹង វាទៅពីអង្កាល់ ម៉េចក៏ខ្ញុំមិនដឹង"

"គេគេចមុខពីខ្ញុំទេដឹង" ម៉ាក់ធ្វើសម្លេងសោកសៅភ្លាម "មើល តាមរយៈពីម្សិលកូនប្រុសបងមិនចូលចិត្តអូនទេ"

អីប្រុសធ្វើមុខតឹងចិត្តភ្លាម ហើយលូកដៃមកចាប់ដៃម៉ាក់ដែល

ដាក់ទៅលើតុ ។

"មិនអីទេ បងនឹងនិយាយជាមួយកូន អីចឹងយើងញ៉ាំទៅ"

ខ្ញុំមើលទៅម៉ាក់ដែលងាកមកប្រសព្វភ្នែក ហើយញញឹមដាក់យ៉ាងឈោរឈៅ តាមពិតខ្ញុំមើលដឹងថាម៉ាក់មិនបានសោកសៅអីនោះទេ តែគ្រាន់តែចង់ដាក់គ្រាប់បែកមួយគ្រាប់ពីរឲ្យវាកើតរឿងប៉ុណ្ណោះ អ្វីដែលម៉ាក់ធ្វើ ធ្វើឲ្យខ្ញុំឆ្អែតបាយទាំងមិនទាន់បានញ៉ាំ ។

"អីចឹងខ្ញុំទៅសាលាសិនហើយ"

"ស្អីគេ ឯងមិនទាន់បានញ៉ាំអីផង"

"ខ្ញុំមិនឃ្លាន សង្ស័យប្លែកកន្លែង យប់មិញគេងមិនសូវលក់ទៀត អីចឹងខ្ញុំទៅសិនហើយ"

ខ្ញុំកាត់ការសន្ទនា ឱនគោរពហើយក៏ដើរចេញមកក្រៅផ្ទះយ៉ាងលឿន ហើយក៏ត្រូវមកជួបនឹងតៃកុងចាំបើកបិទទ្វារឡានឲ្យទៀត ។

មើលទៅជីវិតខ្ញុំដូចជាស៊ាំនឹងភាពមានបានយ៉ាប់ណាស់ ។

នៅសាលា

មានអ្វីកើតឡើង...

ហេតុអីនៅសុខៗក៏មានអារម្មណ៍ថាបរិយាកាសនៅទីនេះដូចជាមានការផ្លាស់ប្តូរ ទាំងដែលផ្ទៃមេឃក៏ស្រឡះល្អ ភ្លៀងក៏មិនធ្លាក់ ថ្ងៃក៏មិនក្តៅ តែហេតុអ្វីក៏ខ្ញុំមានអារម្មណ៍ថាវាមានអ្វីដែលមិនល្អ នៅសុខៗក៏មានអារម្មណ៍ថាវ៉ាត្រជាក់ដល់ឆ្អឹងខ្នង ហើយនោះជាស្អី ដូចជាមានអ្នកណាម្នាក់មើលខ្ញុំ នោះទៀត នោះទៀត មិនទេ...មិនមែនតែម្នាក់ទេ វាច្រើនពេកហើយ ។

"បានឮថាពួកអ្នកក្រចង់ឡើងម៉ោស្មើនឹងពួកយើង"

"ពួកជាន់ទាបយ៉ាងណាក៏នៅតែទាប"

...

"បិទមាត់ទៅ មានស្អីក៏និយាយចេញម៉ោ ខ្ញុំដឹងថានិយាយពីខ្ញុំ!"

ទោះជាពួកនោះធ្វើជាយកដៃបាំងមាត់ តែក៏មានចេតនានិយាយខ្លាំងៗឲ្យខ្ញុំបានឮ ថែមទាំងមិននិយាយតែពីរនាក់ទៀត ពេលនេះគ្រប់

គ្នាមើលមកខ្ញុំហើយ មិនថាដើរទៅខាងណាទេគឺធ្វើដូចគ្នា យកដៃបាំងមាត់ ហើយនិយាយរឿងរបស់ខ្ញុំ មានអីកើតឡើង ម៉េចក៏ពួកនេះដឹងរឿងច្រើនដល់ថ្នាក់នេះ ខ្ញុំមិនទាន់បានប្រាប់អ្នកណាផង?

"នាងនោះម៉ោហើយ ចាប់ថយ ឡូវ៉ាឃើញទៅ!"

"មុខក្រាស់ ត្រូវបកអាក្រាតបែបនេះហើយ អ្នកណាហ៊ានរាប់អាននោះ"

...

គ្រប់គ្នាងាកចេញដូចខ្ញុំកាន់ឈើច្រត់ទេវមន្តដែលអាចញែកទឹកសមុទ្របាន ហើយពេលងាកចេញអស់ ក្រដាសខ្នាត A4 ដែលសរសេរដោយកុំព្យូទ័រក៏បង្ហាញឱ្យឃើញនៅលើក្ដារខៀន ហើយនៅក្នុងនោះមានបិទរូបថតដែលដូចជាយកមកពីលិខិតសុំចូលរៀនដើម្បីអះអាងថាពិតជាខ្ញុំទៀត ។

នាងខ្ញុំឈ្មោះ ម៉ាថុងអ៊ីល ខ្ញុំនិងម៉ាក់គឺជាអ្នកក្រដែលចូលចិត្តលុយទើបដាក់ផែនការបោកប្រាស់មនុស្សប្រុសឱ្យលង់ដោយការបញ្ជូនអ្នកជាម្ដាយមកឈរកណ្ដាលផ្ដល់ឱ្យឡានបុក តែក៏ខ្លាចថាមិនបានសម្រេចទើបប្រើផែនការសាគួគឺការធ្វើជាមកស្និទ្ធស្នាលនឹងកូនប្រុសអ្នកមាន ហើយធ្វើពុតថាវាជាការចៃដន្យ ។ ខ្ញុំចង់មានសង្គមដែលល្អទើបព្យាយាមរុញច្រានខ្លួនឯងដោយការមករៀននៅសាលាថ្លៃៗ ខ្ញុំចង់មានលុយចាយទើបឱ្យម៉ាក់លក់ខ្លួនដូរនឹងលុយរបស់សេដ្ឋី ខ្ញុំចង់ឱ្យខ្លួនឯងមើលទៅល្អ ទើបបោកកូនសេដ្ឋីឱ្យក្លាយជារបស់ខ្លួន ។ 63

"ក្ដូត...ក្ដូត!"

ខ្វាក!

ខ្ញុំទាញក្រដាសនោះចេញពីក្ដារខៀន ហើយហែកមិនឱ្យសល់រូបរាង អ្នកណាជាអ្នកធ្វើបែបនេះ...

"កូអ៊ីន...ច្បាស់ជាអាច្កូតនោះហើយ ចុងកូអ៊ីន!"

ខ្ញុំស្រែកហៅឈ្មោះគេដូចមនុស្សឡប់សតិ ហាក់ដូចជាថាបើ

ហៅហើយគេនឹងផុសចេញមកភ្លាម ។

"មានអ្នកណាឃើញអាចម៍ជ្រៃនោះទេ ខ្ញុំសួរថាមានអ្នកណា..."

ខ្ញុំច្រូក់ ហើយមើលទៅជុំវិញខ្លួន គ្រប់គ្នាសម្លឹងមើលខ្ញុំ ហើយក៏សើចក្អាកក្អាយ ។

"ម៉េចក៏ធ្វើដាក់ខ្ញុំបែបនេះ"

ប៊ីប!

ដុំថ្មដែលមិនដឹងមកពីទិសណាធ្លាក់ចំក្បាលខ្ញុំមួយទំហឹង អ្នកនៅជុំវិញខ្លួនក៏មានអាការៈភ្ញាក់ផ្អើលតិចតួច ហើយក៏សើចបន្ត ។

"សមមុខហើយ ក្រមិនប្រមាណខ្លួន"

"ចង់ចាប់ប្រុស ត្រូវគេចាប់បាន បែកមុខ ពេទ្យមិនដេរឱ្យ"

"ត្រូវប៉ុណ្ណឹងនៅតិចផង"

គ្មានអ្នកណាចាប់អារម្មណ៍មកសាកសួរអាការៈរបស់ខ្ញុំអីបន្តិចទេ ពួកគេបំបែកគ្នាចេញទៅ នៅសល់តែខ្ញុំ ឈាមពណ៌ក្រហមស្រស់ហូរចូលភ្នែក ខ្ញុំយកដៃជូត តែក៏ត្រូវច្រូក់ព្រោះមានអ្នកចាប់ដាប់ ។

"ដៃស្មោកគ្រោកកុំជូត យកកន្សែងនេះទៅ"

"ហឺ?" ខ្ញុំមើលកន្សែង ហើយមើលមុខអ្នកឱ្យដោយមិនចង់ជឿ "គីមសាំយ៉ុង"

"ជូតទៅ"

"ម៉េចក៏លោក..."

"ទោះជាក្នុងក្រដាសនោះជេរខ្លាំងប៉ុណ្ណា...ក៏ខ្ញុំមិនជឿដែរ"

ក្នុងវេលាដែលខ្ញុំមានអារម្មណ៍ថាទន់ខ្សោយបំផុត គ្រាន់តែបានកម្លាំងចិត្តមកពីមនុស្សតែម្នាក់ក៏មានអារម្មណ៍ថា...ខ្លួនឯងមិននៅម្នាក់ឯងទេ ។

៧

គីមសាំយ៉ុង នាំខ្ញុំមកអង្គុយកំបាំងខ្លួននៅជ្រុងមួយក្នុងសួនមួយរបស់សាលា (គឺខ្ញុំជាសិស្សថ្មី មិនដឹងនេះជាកន្លែងណាទេ) គេមើលខ្ញុំហើយឱបដៃយ៉ាងយូរហូតដល់ខ្ញុំតានតឹង ទ្រាំលែងបាន ។

"មើលស្អីណាស់ណា ចង់និយាយអីក៏និយាយម៉ោ"

"ខ្ញុំគ្រាន់តែមិនចង់ជឿ...គឺពេលនេះនាងទៅនៅក្នុងផ្ទះជាមួយ កូអឹន ហើយ?"

"មែន"

"វាគឺជារឿងពិតឬនេះ អីបឹងដែល កូអឹន ប្រាប់ថានាងធ្វើជាម៉េ ជិតដិតនឹងវាព្រោះដឹងរឿង គឺជាការពិត"

"មិនពិត!" ខ្ញុំស្រែកខ្លាំងៗ "ខ្ញុំមិនបានដឹងរឿងអីទេ ម្យ៉ាងទៀតខ្ញុំទៅធ្វើជាដិតដិតនឹងមិត្តរបស់លោកឬយ៉ាងម៉េច លោកក៏ឃើញថាពីតំបូងគេជាអ្នកចូលមករកខ្ញុំមុន ព្រោះពួកលោកស្គាល់គ្នា"

"អានោះគឺពិត"

"ហើយចង់ម៉ោបន្ទោសថាខ្ញុំមានផែនការខ្ពស់គិតចង់ដិតដិតនឹងគេដើម្បីអី ចេះគិតម៉ោទៅកើត បើបាមិនបានក៏ចូលមករកកូន ឆ្កួតៗកាន់តែឆ្កួតហើយ គិតថាខ្លួនឯងអស្ចារ្យប៉ុណ្ណាទៅ"

"គឺមិនអស្ចារ្យប៉ុណ្ណាទេ កូអឹន គ្រាន់តែ...សង្ហា មាន រៀនពូកែតែប៉ុណ្ណឹង"

"សរសើរគ្នាដល់ថ្នាក់នេះម៉េចក៏មិនយកទៅឃោសនាប្រកាសពីភាពល្អរបស់មិត្តតែម្តងទៅ!"

សាំយ៉ុង ធ្វើមុខកាំងមួយសន្ទុះ មុននឹងផ្ទុះសំណើចដោយការចូល

ចិត្ត វាកើតឡប់ស្អីហ្នឹង នេះខ្ញុំកំពុងមួម៉ៅ មកសើចពន្យរកំហឹងខ្ញុំទៀតធ្វើអី!

"ម៉េចក៏នាងជាមនុស្សប៉ិនឌឺម្ល៉េះ"

"..."

"អីចឹងខ្ញុំជឿនាងក៏បាន ថានាងគ្មានចេតនាចូលមករកវាដើម្បីចង់ស្និទ្ធស្នាល ឬ ស្អីក៏ដោយ ចុះនេះនាងគិតធ្វើម៉េច មើលទៅមនុស្សម៉ាសាលាមិនចូលចិត្តនាងទេ"

"ចង់ឲ្យធ្វើម៉េច ខ្ញុំត្រូវទ្រាំទីងវាឲ្យបានតែប៉ុណ្ណឹង ដែលខ្ញុំចម្លែកចិត្តខ្លាំងជាងនេះគឺម៉េចក៏លោកម៉ោជួយខ្ញុំ"

"ខ្ញុំចង់ដឹងប្រកពឲ្យច្បាស់លាស់ បើមិននិយាយជាមួយនាងក៏មិនដឹងដែរថាការពិតវាយ៉ាងម៉េច ទោះ កូអ៊ីន ជាមិត្ត តែខ្ញុំក៏ចង់ស្តាប់ដែរថានាងវាយ៉ាងម៉េចឲ្យប្រាកដទៅ មនុស្សម្នាក់ៗតែងតែមានគំនិតរៀងៗខ្លួន"

"ចុះតាមរយៈការស្តាប់នេះលោកគិតម៉េច"

"នាងសាកដៅទៅ" សាំយ៉ុង ញាក់ចិញ្ចើម ហើយបក់ដៃហៅ "ចេញពីត្រង់នេះទៅ គួរតែចូលរៀនហើយ កណ្តឹងដូចជារោទិ៍ម៉ាសន្ទុះហើយ"

និយាយរួច គេក៏ហុចដៃមកឲ្យ តែខ្ញុំបានត្រឹមតែមើល ហើយវាសចេញដោយការស្អប់ខ្ពើម ។

"អុំ គ្មានមាយាទមែន"

"ខ្ញុំមិនដឹងថាលោកម៉ោធ្វើល្អដើម្បីអី គួរក្បាចម្ងាយល្អជាង"

"តាមចិត្ត"

ខ្ញុំងើបឈរដោយខ្លួនឯង ហើយដើរចេញមក តែក៏ឃើញ កូអ៊ីន ឈរឱបដៃសម្លឹងមកយ៉ាងសោះកក្រោះ ។

"ម៉ោឈរត្រង់នេះយូរទៅ"

សាំយ៉ុង សួរដូចជាគ្មានអ្វីកើតឡើង ថែមទាំងសើចចូលចិត្តទៀតផង មនុស្សឆ្កួតស្អីសើចចេញគ្រប់ស្ថានការណ៍!

"គឺយូរ...យូរណាស់!" កូអ៊ីន ដើរចូលមកជិត ហើយសម្លឹងមិន

ព្រិច "ខ្ញុំចង់ដឹងថាពួកឯងនិយាយស្អីបានជាច្រើនដល់ម្លឹង"

"ហើយវាទាក់ទងអីនឹងលោកដែរ" ខ្ញុំស្រែកដាក់ភ្លាម ធ្វើឱ្យ កូអឹន ងាកមកមើលដោយខ្សែភ្នែកចាបចេះ ។

"ទាក់ទង! នាងកំពុងតែបោកមិត្តខ្ញុំ ដូចដែលចង់ធ្វើដាក់ខ្ញុំអីចឹង"

"អង្គុយលើចង្អេរលើកខ្លួនឯងអត់ហ្នឹង ខ្ញុំនេះអ្នកបោកលោក មុខលោកដូចមនុស្សល្ងង់ណាស់ទៅអ្នកដែលឱ្យគេឯងបោកបានស្រួល"

"បើអ្វីដែលនាងធ្វើមិនមែនជាការបោកប្រាស់ ចុះវាជាស្អី ខ្ញុំមិនជឿទេថាមានភាពចៃដន្យច្រើនបែបនេះនៅលើលោក"

"មិនជឿក៏តាមចិត្ត"

"ចុះនាងនិយាយស្អីជាមួយ សាំយ៉ុង"

"ចង់ដឹងសួរគេទៅ ហ៊ើយ ល្ងីល្ងើបំផុត ម៉េចក៏ខ្ញុំត្រូវម៉ាប្រកែកប្រណាំងជាមួយមនុស្សដូចជាលោកក៏មិនដឹង"

ខ្ញុំដើរចេញមកព្រោះមិនចង់តមាត់តសម្ដី មនុស្សឆ្កួត ប្រើពាក្យថាបោកដាក់ខ្ញុំ? ខ្ញុំនេះ តាំងពីកើតមកមិនធ្លាប់ញ៉ៃប្រុសបានម្នាក់ទេ ខ្ញុំយកបញ្ហាពីណាមកបោកគេទៅ មានតែគេហ្នឹងហើយដែលដើរចូលមករក ហើយធ្វើនេះធ្វើនោះ ធ្វើឱ្យខ្ញុំមិនអាចបំភ្លេចគេបានទៅហើយ ។

ណានៅរឿងដែលគេដើរចាំប្រកាសថាខ្ញុំជាស្រីមិនល្អដើរចាប់ប្រុសអ្នកមានទៀត ម៉េចក៏គេធ្វើបែបនេះ ខ្ញុំត្រូវតែធ្វើអ្វីម្យ៉ាងហើយ!

ការទៅសាលារបស់ខ្ញុំនៅថ្ងៃនេះវាចំជាកន្លងផុតទៅយ៉ាងលំបាក ពេលមិត្តភក្ដិចាប់ក្រុមគ្នាហើយក៏មើលមកខ្ញុំដូចជាសត្វចម្លែកនិងជាផ្នែកលើស រហូតដល់គ្រូត្រូវយកខ្ញុំទៅញាត់ចូលក្នុងក្រុមមួយដោយគេមិនបានពេញចិត្ត មិនត្រឹមតែពេលអង្គុយរៀនទេ សូម្បីពេលញ៉ាំបាយថ្ងៃត្រង់ មិនថាខ្ញុំអង្គុយនៅត្រង់ណាទេ ក៏មានតែអ្នកមើល ថែមទាំងត្រូវមកអង្គុយញ៉ាំបាយតែម្នាក់ឯង ព្រោះគ្មានអ្នកណាចង់ញ៉ាំជាមួយទៀត ហើយនៅមានអ្នកនិន្ទាដែលធ្វើឫកជាបិទសម្លេងខ្សឹបខ្សៀវ តែតាំងចិត្តឱ្យខ្ញុំបានឮ ខ្ញុំទ្រាំលែងបានហើយ ។

"ខ្ញុំត្រូវតែឈប់ពីទីនេះ ខ្ញុំទ្រាំលែងបានហើយ"

"សាលាអ្នកមានគឺមិនមែនចេះតែល្អទេ តែខ្ញុំប្រណែនឯងស៊ីងស្លាប់ទៅហើយ"

បន្ទាប់ពីចេញពីរៀន ខ្ញុំក៏ប្រញាប់តេទៅ ស៊ីជីន ឲ្យមកស្ដាប់ទុក្ខសោកភ្លាម ល្អដល់ហើយមិត្តខ្ញុំ ទោះជាដូរសាលាក៏ដោយ តែក៏នៅតែចេះបារម្ភ ព្រមមកជួបតាមសម្រួល។

"ប្រណែនប្រណ្ឌួយស្អី ហើយមើលទៅ កូអ៊ីន ដូចជាមានឥទ្ធិពលខាងផ្នែកចិត្តសាស្ត្រណាស់ គ្រាន់តែក្រដាសម៉ាសន្លឹកសោះក៏ធ្វើឲ្យមានមនុស្សស្អប់ខ្ញុំម៉ាសាលា សូមបញ្ជាក់គឺម៉ាសាលា សំណាងដែលសង្សារចាស់របស់ឯងម៉ោជួយ តាមពិតគេមិនបានអាក្រក់អីប៉ុន្មានទេ"

"ឯងថាម៉េច ឯងកំពុងតែប្រាប់ថា គីមសាំយ៉ុង ជួយឯងស្អីបែបនោះឬ"

"អឺ ពេលខ្ញុំត្រូវគប់ក្បាលបែក មានតែគេទេនាំទៅបន្ទប់ព្យាបាល និងនិយាយជាមួយ ទោះការនិយាយមើលទៅមិនស៊ីសង្វាក់គ្នាប៉ុន្មានក៏ដោយ"

"នេះគេចាប់អារម្មណ៍ឯងអត់ហ្នឹង"

"និយាយដូចឆ្កួត"

"មនុស្សដូច គីមសាំយ៉ុង មិនធ្លាប់ឃើញអ្នកណានៅក្នុងខ្សែភ្នែកទេ ឯងមិនឃើញទេអ្ហ៎ស ចង់បែកពីខ្ញុំក៏បែក នៅសុខៗម៉ោធ្វើល្អដាក់ឯង វាច្បាស់ជាមានហេតុមានផលហើយ"

"ម៉េច ឯងប្រចណ្ឌអ្ហ៎"

"អត់ទេ និយាយទៅសន្តាន...ខ្ញុំមិនខ្វល់ពីអ្នកដែលបែកគ្នាឡើយ ចង់ខ្វល់គឺនាងមិត្តដែលហែកហៀករបស់ខ្ញុំនោះទេ"

"សួរតាមត្រង់ ឯងចង់យកលុយនោះមែន"

"គឺខ្ញុំមុខលុយហ្នឹងណ៎ា!"

"=O="

"តែមិនយកទេ ដែលឈឺចិត្តគឺពេលនោះខ្ញុំទន់ជ្រាយពេកនឹងជេរដាក់បណ្ដាសានឹងមុខវាមិនបាន ហើយមានអារម្មណ៍យ៉ាប់យ៉ឺនដែលអ្នកហែកហៀកនោះជាឯងមិនមែនខ្ញុំ"

"អី សុំទោសដែលកាលនោះទប់ខ្លួនឯងមិនទាន់"

"តែមកគិតម្តងទៀតក៏ស្តាយដូចគ្នា"

"ចង់យ៉ាងម៉េចឱ្យប្រាកដហ្នឹង"

"ចូលរឿងឯងល្អដាច់ តាមដែលស្តាប់ម៉ោ ភាពថៃដន្យមានច្រើនណាស់ បើជាខ្ញុំក៏សង្ស័យដែរ តែប្រហែលមិនបានសង្ស័យហួសហេតុដូច កូអ៊ីន ធ្វើទេ ឯងធ្លាប់សាកល្បងនិយាយរឿងនេះជាមួយគេឱ្យប្រាកដប្រជាហើយនៅ"

"មនុស្សពាលបែបនោះនិយាយទៅក៏មិនស្តាប់ដែរ"

"គេបែបហ្នឹង"

"ចុះខ្ញុំត្រូវល្ងង់ទេ ចង់គិតអីក៏គិតទៅ តែខ្ញុំប្រហែលជាត្រូវធ្វើអីម្យ៉ាងហើយ បើមិនចេញពីសាលាគឺបែបត្រូវចេញពីផ្ទះនោះ ព្រោះម៉ាក់ក៏មានគ្រួសាររបស់គាត់ហើយដែរ"

"ហើយឯងទៅនៅជាមួយអ្នកណា"

"ខ្ញុំនឹងសាកល្បងទៅរកប៉ា"

"អ៊ឹម...អី នោះ!" ដូចតែបៃតងជាប់ក ឬអ្វីម្យ៉ាងធ្វើឱ្យ សីជីនស្ទាក់ ហើយយកជើងធាក់ខ្ញុំយ៉ាងខ្លាំង "ឯងមើលនោះទៅ ចុងកូអ៊ីម ឬមិនមែន ម៉ោជាមួយអ្នកណា!"

ខ្ញុំមើលទៅខាងក្រៅហាងដែលជាជញ្ជាំងកញ្ចក់ ក៏ឃើញ កូអ៊ីនដើរមុខខ្មួរមកជាមួយមិត្តភក្តិស្រីមុខស្អាតខាបព្រលឹងដែលខ្ញុំចាំបានថានាងគឺជាសិស្សច្បងរៀនចប់នៅឆ្នាំនេះ ។

"សិស្សច្បង ណាយ៉េ"

"មនុស្សថ្លុតស្អីមានឈ្មោះតែពីរព្យាង្គ ហើយជាឈ្មោះមនុស្សជនជាតិកូរ៉េឬ"

"ឯងក៏មានពីរព្យាង្គដែរ"

"មាន ណា ហើយចាំបាច់មាន យ៉េ បើដាក់ យ៉ុង យិន ប៊ី វី ស្អីទៅមិនមានន័យហើយពិរោះជាង មិនសមហេតុផលមែន"

មើលវារ៉ិះគន់!

"តែមុខមាត់ស្អាតណាស់...កុំប្រាប់ណាថាជាស្រីរបស់គេ"

ខ្ញុំមានអារម្មណ៍ថាដូចជាមានអ្វីម្យ៉ាងមកជោគចំកណ្ដាលទ្រូង ធ្វើឲ្យគ្មានអ្វីអធិប្បាយបានក្រៅពីខាំមាត់ ហើយនៅស្ងៀម អាឆ្កួត ខ្លួនឯងមានគូស្នេហ៍ហើយ នៅមកគប់ហ៊ៀកឲ្យខ្ញុំឡើងគ្រែជាមួយទៀត ថោកទាប!

"ចង់ជាស្អីគឺជារឿងរបស់គេ យើងទៅរកប៉ាល្អជាង"

"នេះកើតអីអត់ហ្នឹង ទើបនិយាយគ្នាមិញសោះ...អ្ហ៊ា ខ្ញុំទៅដែរ"

ចង់ដោយការម្ងម៉ៅ តានតឹងចិត្ត ឬ ស្អីក៏ដោយ ធ្វើឲ្យខ្ញុំធ្វើដំណើរមករកប៉ាឲ្យទាល់តែបាន ហើយពេលមកដល់ ក៏ត្រូវជួបនឹងភាពអស់សង្ឃឹម ពេលផ្ទះរបស់ប៉ាបិទជិតឈឹង ។

"ប៉ាឯងមិននៅទេដឹង"

"ប៉ាខ្ញុំមិនបានធ្វើការអីទេក្រៅពីអង្គុយគូររូប ម៉េចក៏ចាំបាច់មិននៅចំថ្ងៃនេះដែរ!"

ខ្ញុំទន្ទ្រាំជើងដោយមិនដឹងថាគួរតែកម្ចាយអារម្មណ៍យ៉ាងណាល្អ ធ្វើឲ្យ ស៊ីជីន មើលដោយការសង្ស័យ ។

"មើលឯងទៅម្ងម៉ៅពេកអត់ហ្នឹង ប៉ាមិននៅ ថ្ងៃក្រោយសឹមមកទៀតក៏បាន"

"ឯងមិនមែនជាខ្ញុំ ឯងមិនយល់ទេ!"

"ម៉េចចាំបាច់ស្រែកដាក់ខ្ញុំ កាលនៅហាងបាយមិញឯងសោកសៅទេ ពេលឃើញ កូអ៊ីន... អ៊ុំ! នេះឯងក្លាយជាបែបនេះព្រោះ កូអ៊ីន អីចឹងឬ រ៉ាវៗ"

"រ៉ាវៗក្បាលឯងស្អី មិនមែនស្អីទាំងអស់"

"ហើយនេះគិតម៉េច ទៅវិញទេ"

"មិនទាន់ចង់ទៅ"

"មិនទៅពេលនេះ តិចទៀតនៅតែត្រូវទៅដដែល ម្យ៉ាងទៀត... ខ្ញុំខ្ជិលនៅជាមួយហើយ ម៉ោអង្គុយចាំប៉ាឯងដែលមិននៅផ្ទះដើម្បីអី"

"តិចទៀតគាត់ម៉ោហើយ"

"បើម៉ោប្រហែលជាបោសស្លឹកឈើដែលជ្រុះពេញមុខផ្ទះអស់ទៅហើយ ខ្ញុំដៅថាគាត់បែបទៅកន្លែងណាឆ្ងាយមួយ អីចេះចុះ ទៅ

សួរអ្នកជិតខាងល្អដាង"

សីដីន ដើរទៅចុចកណ្ដឹងផ្ទះអ្នកជិតខាងមែន (ភាពក្រែងចិត្តវាទៅត្រង់ណាក្នុងរាងកាយ) បន្ទាប់មកក៏រត់លីលាមករកខ្ញុំវិញ ។

"ចាំឯងទៅបរទេស"

"ហ៎ា! បរទេស...ចាំខ្ញុំនេះ"

"អឺ"

"ចាំទៅបរទេសធ្វើអី នៅកូរ៉េមិនទាំងមានអីញ៉ាំគ្រប់ផង"

"សម្រេចថាគាត់ទៅបរទេសចុះ ចប់ ចំណែកឯងទៅផ្ទះវិញបានហើយ ពីរបីថ្ងៃទៀត ឬ អាទិត្យក្រោយចាំម៉ោ ថ្មើរនោះចាំឯងបែបម៉ោវិញហើយ អូខេ?"

"ឯងរហាន់ទៅណា តឿនដល់ហើយ"

"ខ្ញុំមានណាត់ជាមួយមនុស្សប្រុសខ្លះអីខ្លះហ្នឹង"

"ទៀតហើយអ្ហ៎ស លើកនេះអ្នកណាទៀតហើយ"

"គឺមានដូចគ្នា"

"អីចឹងតើ ពេលនិយាយដល់ គឺមសាំយ៉ុង បានជាគ្មានប្រតិកម្មអី"

"ខ្ញុំមិនចាប់អារម្មណ៍ប្រុសដែលបោះបង់ខ្ញុំទេ ម្យ៉ាងទៀតខ្ញុំក៏មិនបានសេគគប់ដោយចិត្ត តែព្រោះលុយ ទៅណាក៏មិនបាច់ចំណាយខ្លួនឯងស្អីបែបនេះ ទីកៗ"

ជឿនាងហើយ តែណ្ហើយ នៅក្នុងពេលដែលចាំមិននៅ ខ្ញុំក៏គួរតែទៅផ្ទះ ។ បន្ទាប់ពី សីដីន ដើរចេញទៅហើយ ខ្ញុំក៏ទៅផ្ទះដោយការជិះឡានក្រុង អ្ហ៎ បើចង់សួរថាថ្ងៃនេះអ្នកបើកឡានទៅណា ជូនអីថ្ងៃនេះខ្ញុំគានតឹងដល់ថ្នាក់សម្ដែងទឹកមុខមិនពេញចិត្ត ដេញគេព្រោងព្រាតឱ្យទៅវិញតាំងពីតំបូងដូចអ្នកមានលុយ (លុយក៏ជារបស់អ្នកជ្យេងដែរ) ហើយចុងក្រោយអ្នកដែលមានលុយក៏ជិះឡានក្រុងទៅភូមិគ្រឹះវិញ ។

ពេលមកដល់ផ្ទះហើយខ្ញុំក៏ត្រៀមខ្លួនដើរលបៗឡើងទៅបន្ទប់ខ្លួនឯង ព្រោះខ្លាចជួបនឹង កូអីន ហើយត្រូវគេឡូឡាដាក់ទៀត តែថា... មុនពេលដើងឈានផុតជណ្ដើរ ខ្ញុំក៏ត្រូវចូកពេលបានឮសម្លេងប្រកែកគ្នាលាន់រញ្ជួយ ។

"ទៅចំពោះមុខចាំធ្វើជាសម្ដែងល្ខោនជាមនុស្សល្អ ពេលចាំមិនទៅក៏សម្ដែងធាតុពិត ហឺស ខ្ញុំមើលមិនខុសមែនហើយក៏សម្រេចចិត្តមិនខុសដែរដែលស្អប់នាង នាងមេមត់!"

"ហើយគិតថាខ្ញុំចូលចិត្តឯងណាស់ទៅអ្ហ៊ឹសអាបិសាច ជាក្មេងជាក្មាងនិយាយស្ដីដូចក្រួចគ្មានទឹក សង្ស័យឪម៉ែមិនដែលប្រដៅទេ"

"ឪខ្ញុំជាអ្នកដែលនាងចាប់ហ្នឹងហើយ"

"មិនថាឪឯងក៏ត្រូវថាម៉ែឯងដែរ អាកូនគ្មានម៉ែប្រដៅ!"

"កុំម៉ោរាលដាលដល់ម៉ាក់ខ្ញុំ!"

"បើរាលដាលហើយចង់ម៉េច ម៉ែឯងមិនមែនម៉ែខ្ញុំ...អ៊ូយ!"

កូអឺន ក្រញាម៉ាក់ឲ្យដួល ហើយបម្រុងស្ទុះទៅថែម តែខ្ញុំដែលលួចមើលក៏ស្ទុះទៅរក យកខ្លួនពាំងម៉ាក់ បាតដៃនោះក៏ទះមកចំមុខខ្ញុំវិញលាន់ផាច់ ។

"ចុងអ៊ីល!" ម៉ាក់ ងើប ចូលមករកខ្ញុំ ហើយចាប់ថ្ពាល់មើល "នេះឯងទះកូនខ្ញុំអ្ហ៊ឹស"

"អ្នក...អ្នកណាប្រើឲ្យម៉ោរវល់!" កូអឺន មើលខ្ញុំដោយធ្វើអ្វីមិនត្រូវ "នាងខុសដែលចូលម៉ោពាំង នាងខុស!"

និយាយចប់ គេក៏ដើរចូលទៅក្នុងបន្ទប់បាត់ ទុកឲ្យខ្ញុំឈរជាមួយម៉ាក់ដោយមិនបានទទួលការសុំទោស ឬ អ្វីមួយម៉ាត់ ។

"ម៉ាក់ត្រូវចាត់ការវាឲ្យបាន"

"ម៉ាក់ចង់ធ្វើអី"

"ម៉ាក់នឹងឲ្យវាចេញពីផ្ទះនេះឲ្យបាន ចាំមើលទៅ!"

៨

មើលទៅរាងកាយខ្ញុំដូចជាសុទ្ធតែរបួស ពីព្រឹកត្រូវក្បាលមួយដុំ ថ្មចេញឈាម ពេលល្ងាចក៏ត្រូវមួយកំផ្លៀងទៀត ខ្ញុំមើលសភាពខ្លួនឯងនៅក្នុងកញ្ចក់ ហើយក៏បានតែដកដង្ហើមធំ នៅមិនបានប៉ុន្មានថ្ងៃផង សភាពរបស់ខ្ញុំក៏បែបនេះទៅហើយ ។

អ្ហ៎ា...

ខ្ញុំសន្សឹមៗក៏ទាញបង់ចេញពីរបួសនៅលើក្បាលដែលមានទឹកខ្ទុះហូរមកតាមបង់នោះដោយមានអារម្មណ៍ថាព្រឺរោម នេះក្បាលខ្ញុំធ្ងន់ធ្ងរដល់ម្លឹងឬនេះ ណានៅមានមុខហើមស្ពុរដូចត្រូវមេឃ្មុំតិច នឹងទៅរៀនដោយសភាពបែបណាទៅខ្ញុំ!

"បើកទ្វារ!"

ហៀក! សម្លេងរបស់ កូអឹន ទេតើ គេមកធ្វើអី ខ្ញុំបានតែឈរផ្ទឹងមិនហ៊ានសូម្បីតែឆ្លើយតប ។

"នេះនាងងាប់ហើយម្ល៉េស បើមិនបើក ខ្ញុំទម្លាយចូលទៅហើយ"

"អ្ហ៎ា ខ្ញុំម៉ោហើយ!!!"

ខ្ញុំស្ទុះទៅបើកទ្វារហាក់ដូចបញ្ហាចាន ពេលប្រឈមមុខជាមួយកូអឹន ហើយក៏ឃើញគេភាំង ។

"មា...មានការអី"

"ក្បាលនាងទៅត្រូវនឹងស្អី"

"ត្រូវនឹងស្អីក៏មិនសំខាន់ដែរ!" មូលហេតុគឺមកពីលោកហ្នឹង អាប្រុសមោយអើយ "ហើយម៉ោនេះមានការអី"

"យកទៅ" កូអឹន ញាត់ប្រអប់ថ្នាំក្នុងដៃខ្ញុំ ហើយរុញច្រានខ្លួនឯង

ឲ្យចូលមកក្នុងទឹកដីរបស់ខ្ញុំ "ងាប់ហើយ នេះជាបន្ទប់ដេកអត់ហ្នឹង គួរចង់ក្អួតណាស់"

"មិនចូលចិត្តហើយដើរចូលម៉ោធ្វើអី"

គេងាកមកលឿនដូចព្យុះ ហើយសម្លឹងមុខខ្ញុំថ្មេរ÷

"ផ្ទះនេះខ្ញុំចង់ចេញចូលកន្លែងណាក៏បានដែរ នាងមានសិទ្ធអីម៉ោសួរ"

"ចាំៗ"

"កុំម៉ោធ្វើសម្លេងផ្គីន"

"នែ៎ បើលោកមិនចូលចិត្ត ឬ ស្អប់ខ្ពើមនឹងនិយាយជាមួយខ្ញុំដល់ថ្នាក់ត្រូវតែំហាកបែបនេះគ្រប់ពេល ខ្ញុំថាលោកចេញទៅល្អជាង បើនៅម្នាក់មួយប៉ុល វាសប្បាយចិត្តជាង"

"ប្រែថាខ្ញុំនៅអីចឹងវាធ្វើឲ្យនាងមិនសប្បាយចិត្តមែនទេ"

"ស្រេចតែគិត"

"បើវាធ្វើឲ្យនាងមិនសប្បាយចិត្ត...ខ្ញុំនឹងដេកនៅទីនេះ"

"ហេ៎"

កូអឹន លោតទៅដេកលើគ្រែ ហើយរមៀលខ្លួនទៅមកធ្វើឲ្យពូកទក់ទីអស់ ខ្ញុំមើលទង្វើរបស់គេដោយមានអារម្មណ៍ថាហត់ចិត្ត មនុស្សបែបនេះក៏មានដែរ កាន់តែមិនចូលចិត្ត កាន់តែបេះបួយ ។

"ស្អីគេ នាងគ្រាន់តែឈរមើលខ្ញុំធម្មតាៗនេ៎ះ ម៉េចមិនធ្វើមុខខឹង ឬមិនអីចឹងគឺស្រែកដូចម៉ាក់នាងចូលចិត្តធ្វើបន្តិចទៅ"

"ខ្ញុំចង់នៅស្ងៀម ហើយបណ្តោយឲ្យលោកច្នួតម្នាក់ឯងទៅ ម៉េចធុញអ្ហ៎ស"

"អី ធុញ ដើរម៉ានេះ"

"ស្អីទៀតហើយ"

ខ្ញុំហ៉ាសរត់ទៅរកគេ ហើយអង្គុយលើគ្រែត្រង់កន្លែងដែលគេទះជាច់ៗ ដូចបញ្ជាឲ្យក្មេងតូចទៅអង្គុយតាម ។ កូអឹន មើលខ្ញុំមួយសន្ទុះហើយក៏លូកដៃមកអង្អែលថ្ពាល់ខ្ញុំថ្នមៗ ។

"ឈឺខ្លាំងហើយមើលទៅ ណានៅក្បាលទៀត ម៉េចក៏នាងចូល

ចិត្តភករឿងដាក់ខ្លួនឯងម្លេះ ចូលចិត្តឈឺខ្លួនឬយ៉ាងម៉េច"

"លោកនិយាយដូចខ្ញុំចង់ណាស់អីចឹង រឿងទាំងអស់ហ្នឹងគឺកើតឡើងមកពីលោកមិនមែនឬ"

"នេះនាងបន្ទោសខ្ញុំអ្ហេស"

"អឺ!"

"មិនលាបឱ្យទេរបួស លាបខ្លួនឯងទៅ!"

នៅសុខៗគេក៏គំហក ហើយងើបដើរចេញទៅដូចក្មេងស្រីមករដូវ ចង់អារម្មណ៍ល្អអារម្មណ៍អាក្រក់ទៅណានេះ តែថា...មិញគេយកថ្នាំមកឱ្យ ឬថាតាំងចិត្តមកលាបថ្នាំឱ្យ!?

មនុស្សឆ្កួត!!! ចង់ធ្វើល្អក៏ធ្វើឱ្យដល់ទីបំផុតទៅមិនបានឬម៉េច!

ឃ្វាំង!!!

ទ្វារបន្ទប់ត្រូវបើកម្តងទៀតដោយមានទឹកមុខខ្វូររបស់គេអើតចូលមក÷

"បើស្អែកខ្ញុំភ្ញាក់ឡើងមិនឃើញនាងលាបរបួសទាំងក្បាលទាំងថ្ពាល់...នាងងាប់!"

បាំង!!!

ដូចជាមានអារម្មណ៍ល្អ តែក៏នៅមានអារម្មណ៍ថាត្រូវគំរាម គេចង់ល្អ ឬចង់អាក្រក់នេះ អាខ្មោចឆ្កួត!

ខ្ញុំភ្ញាក់ឡើងដោយភាពខ្សេះខ្សោះចម្លែក មានអារម្មណ៍ថាស្រៀវស្រាញពេញខ្លួន ពេលដើរក៏មានអារម្មណ៍ថារាងកាយដូចជាអណ្តែតម៉េចក៏មិនដឹង ទើបត្រូវតោងជណ្តើរចុះយឺតៗ ហើយពេលមកដល់ជាន់ក្រោម អ៊ំអច្ឆរិយៈ និងម៉ាក់ក៏មើលមកដោយខ្សែភ្នែកព្រួយបារម្ភ។

"រូបទេ ម៉េចក៏ថ្ងៃនេះមើលទៅខ្សេះខ្សោះម្លេះ"

"ចាំ មិនដឹងទេ សង្ស័យចូលគេងយប់ពេកទេដឹង សុំទោសដែលឱ្យរង់ចាំ"

"មើលមុខកូនទៅបង ហើមដូចគ្រួចទៅហើយ ណានៅក្បាលទៀត ម្សិលមិញត្រូវកូនប្រុសបងប្រានឱ្យបោកនឹងឥដ្ឋ បងត្រូវតែចាត់

ការអីម្យ៉ាងហើយ អូនក៏ចេះស្រលាញ់កូនរបស់អូនដែរ"

"អី ម៉ាក់ ក្បាលខ្ញុំ..."

"ឯងមិនបាច់និយាយអីទាំងអស់ ញាំបាយ!"

ម៉ាក់បិទចន្លោះប្រភេទដែលថាខ្ញុំមិនចាំបាច់អធិប្បាយអ្វីទាំងអស់ តែរឿងទាំងអស់គឺម៉ាក់ជាអ្នកសាង ផាប់ហើយ មើលមុខអំប្រុសចុះ ខឹងឡើងផ្ដុំភ្លើងដុតផ្ទះចេះទៅហើយ ។

"កូអឺន!"

សម្លេងដូចរន្ទះរបស់អំប្រុស ធ្វើឲ្យខ្ញុំស៊ីងតែស្ងាងពីភាពរិល។ កូអឺន ដែលដើរចុះមកតាមក្រោយក៏សម្លឹងមុខឪពុករបស់ខ្លួនដោយការងឿងឆ្ងល់ ។

"បាទ"

"នេះអាក្រក់ហ៊ានដល់ថ្នាក់ធ្វើបាបមនុស្សស្រីមែនទេ"

"ប៉ានិយាយច្បាស់...អ្ហា!"

កូអឺន ត្រូវឪពុកដាល់មុខឡើងដួលនៅក្រោមសម្លេងស្រែករន្ធត់របស់ខ្ញុំនិងស្រីបម្រើដែលឈរជុំវិញ គេមើលឪពុកដោយការតក់ស្លុតហើយសួរដោយសម្លេងញ័រ ។

"ខ្ញុំធ្វើអីខុស!"

"ឯងមិនមែនជាមនុស្សប្រុស ធ្វើបាបសូម្បីតែមនុស្សស្រីដែលគ្មានកម្លាំងស៊ូ ប៉ុងអ៊ីល ខ្លួនតូចតែមួយ នេះឯងរុញនាងឡើងបោកក្បាល ហើយតាមទៅទះកំផ្លៀងទៀត"

"ខ្ញុំនេះអ្ហេស!" កូអឺន មើលមកខ្ញុំ ហើយសើច "រុញនាងឲ្យបោកក្បាល ហើយតាមទៅទះកំផ្លៀងទៀត អ្នកណាប្រាប់ប៉ាទៅ កូនចុងប៉ាប្រាប់ឬយ៉ាងម៉េច"

"ភស្តុតាងឃើញពេញភ្នែក!"

"ប៉ាចង់ជឿយ៉ាងម៉េចគឺស្រេចតែប៉ា និយាយអីទៅក៏ប៉ាមិនស្ដាប់តាំងពីមានប្រពន្ធថ្មី មើលទៅប៉ាមិនស្ដាប់អ្វីទៀតទេ ឈ្លក់នឹងប្រពន្ធ!"

"ឯង!!!"

អំប្រុសចង់ស្ទុះទៅទះកូនប្រុសទៀត តែម៉ាក់ចាប់ដៃជាប់ ហើយ

និយាយដោយសម្លេងស្រទន់÷

"តាមតែគេទៅ កូននៅក្មេង"

"ក្មេងស្អី វាធំអាចមានប្រពន្ធបានទៅហើយ មិនបាន បងត្រូវតែប្រដៅវា"

"បងប្រដៅរួចហើយ តិចកូនៗទៅសាលាយឺត ទៅៗ ប៉ុងអ៊ុល កូអ៊ីន ឡើងឡានទៅ"

ម៉ាក់ញញឹមដាក់ខ្ញុំ និង កូអ៊ីន បែបគួរឲ្យស្រលាញ់ មុននឹងអូស អ៊ំប្រុសទៅល្ហួងលោមនៅតុអាហារបែបគូស្នេហ៍ថ្មោងថ្មី ។ ខ្ញុំចាំបាច់ត្រូវតែយកកាបូប ហើយដើរឡើងឡានតាមបញ្ជាម៉ាក់ ព្រមគ្នានឹង កូអ៊ីន ហើយពេលបាននៅតែពីរនាក់ គេក៏សម្លឹងខ្ញុំបែបចង់អាឃាត ។

"នាងនេះវាមាយា ពុតត្បុតពេញខ្លួន!"

"មិ...មិនមែនបែបនោះទេ"

"ខ្ញុំលែងអាណិតនាងហើយ តទៅនឹងទទួលបានការព្រមានរបស់ខ្ញុំពេញ៨ម៉ោងពេលនៅសាលា ខ្ញុំនឹងធ្វើឲ្យនាងដូចធ្លាក់នរកអីចឹង ចាំមើលទៅ!"

ហេតុ...ហេតុអីគ្រប់យ៉ាងត្រូវធ្លាក់មកលើខ្ញុំ?

ទោះជាមិនដឹងថានរកដែល កូអ៊ីន និយាយនោះគឺជាអ្វី តែគ្រាន់តែខ្ញុំឈានជើងចូលសាលាដែលដូចជាអាណាចក្ររបស់គេ ខ្ញុំក៏ដូចជាធ្លាក់នរកស្រាប់ទៅហើយ ថ្ងៃនេះក៏ដូចថ្ងៃម្សិល ខ្ញុំនៅតែបានទទួលភាពច្នើងឆ្មៃពីគ្រប់គ្នា ម៉េចក៏ធ្វើអីចឹង តានតឹងពេញបន្ទុកហើយ អឹងអើយ~ (នៅនិយាយស្ដីមានក្ដីសុខទៀត) ។

កូអ៊ីន ដែលដើរមុខប្រហែលពីរម៉ែត្រក៏ងាកមក ព្រមទាំងចង្អុលមុខខ្ញុំ÷

"ខ្ញុំនឹងព្រមាននាង"

"ហ៊ាក់...ហ៊ា?"

"អ្នកណាធ្វើឲ្យស្រីម្នាក់នេះមានអារម្មណ៍ថាដូចធ្លាក់នរកទាំងរស់បាន ខ្ញុំនឹងឲ្យរង្វាន់ជាទីគាប់ចិត្ត!"

នៅសុខៗគេក៏ស្រែកបែបនេះចេញមក សិស្សទាំងអស់ងាកមកមើល កូអឺន ហើយក៏ញញឹមពេញចិត្ត ស្អីគេនេះ ម៉េចក៏នាំគ្នាមើលខ្ញុំបែបនេះ ហើយនោះ...គេដើរទៅណា?

"លោកធ្វើថ្នូតស្អីហ្នឹង ចុងកូអឺន ហេ៎!"

គ្រប់គ្នានៅម៉្លុំនេះដើរមកឡោមព័ទ្ធខ្ញុំជារង្វង់ ចំណែក កូអឺន ក៏ចាត់ស្រមោលទៅនៅក្នុងហ្វូងមនុស្សម្នាហាក់ដូចជៀវង ពេលនេះមិនថាជាសិស្សច្បង សិស្សប្អូន ឬសិស្សរួមជំនាន់ គឺនាំគ្នាមើលមកហាក់ដូចចង់ស៊ីសាច់ខ្ញុំទាំងរស់អីចឹង ។

"ច...ចង់ធ្វើអី"

"គឺចង់យករង្វាន់ហ្នឹងអ្ហ៎"

ពេលម្នាក់នៅក្នុងចំណោមនោះនិយាយចប់ គឺដូចជារលកយក្សស៊ូណាមិដែលរត់ដេញតាមខ្ញុំទាំងហ្វូង ខ្ញុំមិនដឹងទេថាអាពួកអស់នេះកំពុងតែគិតអី តែអ្វីដែលខ្ញុំដឹងគឺរត់ឲ្យណាណីតែម្តង ប្រភេទថាបើជើងចាក់គឺនឹងយកដៃរត់ម្តង ។

វីត!

ដៃរបស់អ្នកណាម្នាក់ទាញអាវក្រៅរបស់ខ្ញុំជាប់ នៅចង្វាក់នោះអ៊្ហែងដែលមិនដឹងថាយក្សូចខ្លួនយ៉ាងម៉េចទើបបង្វិលខ្លួនហាក់ដូចកំពុងលេងកុនវាយតប់របស់ ឈិនឡុង ហើយដកដៃចេញពីអាវ មុននឹងរត់ចេញទៅយ៉ាងលឿន បានឮទេនេះសម្លេងកណ្តឹងរោទិ៍ចូលរៀន ពួកឯងបានឮទេ ត្រូវរកកន្លែងលាក់ខ្លួនសិន តែរកម៉េចនឹងបានទៅ គ្មានកន្លែងណាឲ្យខ្ញុំទៅបានទេ នៅក្នុងពេលដែលគេចមិនរួចបែបនេះ អីចឹងមានតែខ្ញុំស៊ូជាមួយហើយ ។

ហ្វឹប!

ខ្ញុំឈប់រត់ ហើយងាកទៅប្រឈមមុខនឹងពួកនោះដែលមានគ្នាជាង៤០នាក់ ព្រមទាំងកាងដៃដោយភាពក្លាហាន ។

"ឈប់!"

គ្រប់គ្នាឈប់តាមសម្រែករបស់ខ្ញុំហាក់ដូចជាបញ្ញាបាន នោះទើបធ្វើឲ្យខ្ញុំមានកម្លាំងចិត្តបន្តិចវិញ ។

"បើចង់ស៊ូជាមួយខ្ញុំគឺមួយទល់មួយ មិនមែនម៉ោទាំងហ្វូងដូចឆ្កែបែបនេះទេ វាគ្មានកិត្តិយស"

"មិនចាប់អារម្មណ៍!"

"អ៊ុយ!"

"យើងចង់បានតែផល មិនចង់បានយុទ្ធសាស្ត្រ ហើយពួកយើង... ព្រួតគ្នាចាប់ស្រីម្នាក់នេះទៅ"

"ហឺ!!! អ្ហា!!!"

មើលទៅការបង្ហាញភាពក្លាហានរបស់ខ្ញុំលែងបានផលហើយ ពួកគេទាំង៤០ឡោមព័ទ្ធជុំជិត មុននឹងចាប់ខ្ញុំលើកឡើងលើ ហើយហៅឱ្យទ្រហឹង ធ្វើមើលតែខ្ញុំជាមេមត់នៅយុគសម័យព្រះរាជា ភីតជីអាឡិបសាន់ដឺ ចច (យុគសម័យស្អីគេអីក៏ច្រើនយ៉ាងនេះ) គ្រប់គ្នាដង្ហែរខ្ញុំធ្វើមើលតែខ្លាចភ្លៀងមិនធ្លាក់ (អាហ្នឹងគឺដង្ហែរឆ្មាញី) តែហើយសម្លេងកង់រំពងនេះក៏ស្ងាត់បន្តិចម្តងៗដោយគ្មានមូលហេតុកើតអី មានអីកើតឡើងឬ?

"ដាក់ស្រីនោះចុះម៉ោ...ខ្ញុំប្រាប់ឱ្យដាក់ចុះ!"

សម្លេងរបស់ គីមសាំយ៉ុង ដែលស្រែកបញ្ជាម្តងទៀត ធ្វើឱ្យរាងកាយរបស់ខ្ញុំត្រូវដាក់មកឱ្យឈរលើលោកនេះបានដូចធម្មតានិងគ្មានស្លាកស្នាមរបួស បានអីចឹងខ្ញុំក៏ស្ទុះទៅពួនក្រោយខ្នងគេភ្លាម ។

"ម៉េចចាំបាច់ធ្វើដាក់គ្នាដល់ថ្នាក់នេះ"

"ចុងកូអឺន ប្រាប់ថាអ្នកណាធ្វើឱ្យស្រីម្នាក់នេះមានអារម្មណ៍ថាដូចធ្លាក់នរកទាំងរស់បាន នឹងឱ្យវង្វាន់ជាទីគាប់ចិត្ត"

"ចុះការដែលលើកនាងឡើងលើវាដូចធ្លាក់នរកម៉េចទៅ"

ពួកនោះមើលមុខគ្នាដោយអាការៈមឹងមាំង ។

"បើចង់ដឹងថានរកវាយ៉ាងម៉េច ខ្ញុំនឹងធ្វើឱ្យមើល!"

សាំយ៉ុង លើកខ្ញុំលីលើស្មាក្រោមសម្លេងចេចចាចរបស់ពួកនោះ ស្អីនេះ៎ គេមិនបានមកជួយខ្ញុំទេឬ ម៉េចក៏គេធ្វើឫកដូចជាចង់បង្ហាញឱ្យគ្រប់គ្នាមើលថានរកវាមានលក្ខណៈយ៉ាងម៉េច ឯងជាបក្សពួកអ្នកណាឱ្យប្រាកដទៅ?

"លែងខ្ញុំទៅអាច្កត សំពត់ខ្ញុំរបើករចាញអស់ហើយ"

"ខ្ញុំនឹងបើកនាងខ្លាំងជាងសំពត់ទៅទៀត"

"មានន័យថាម៉េច"

ប៉ាំង!

សាំយ៉ុង នាំខ្ញុំចូលទៅក្នុងថ្នាក់ដែលពេលនេះមានតែតុក្តារខៀន គ្មានសិស្សបានម្នាក់ បន្ទាប់ពីនោះក៏ចាក់សោលាន់គ្រឹក ហើយដាក់ខ្ញុំទៅលើតុគ្រូ គេធ្វើដូចជាខ្ញុំរាងស្រាលដូចបេបីអីចឹង ។

"កុំធ្វើអីច្កត។ ខ្ញុំស្មានថាលោកល្អជាងគេ"

"នោះប្រែថានាងគិតខុសហើយ ដឹងអត់ថារង្វាន់បានពី កូអឹន គឺមិនដូចអ្នកដទៃឱ្យទេ អ្នកណាៗក៏ចង់បាន នាងមិនបានឮសម្លេងហោកញ្ជ្រៀវនៅខាងក្រៅទេអ្ហ៎ស...ដើម្បីធ្វើឱ្យ កូអឹន ពេញចិត្ត ពួកនោះព្រមធ្វើគ្រប់យ៉ាង"

"ចុ...ចុះលោកចង់ធ្វើអី"

មានតែស្នាមញញឹមដ៏គួរឱ្យខ្លាចប្រាកដនៅចុងមាត់ សាំយ៉ុង គេមិននិយាយអ្វីទាំងអស់ ហើយលូកដៃមកក្របួច-កអាវខ្ញុំ ។

"ធ្វើបែបនេះ"

ខ្វាក!!!

៩

"ឡប់សតិហើយអ្វី លែងខ្ញុំ!"

អាវសឺមីពណ៌សរបស់ខ្ញុំដាច់ចេញពីគ្នា ឡេវលោតប្រសាក់ប្រសាច តែមើលទៅការយំស្រែករបស់ខ្ញុំមិនបានធ្វើឲ្យ សាំយ៉ុង រញ្ជួយចិត្តសូម្បីតែបន្តិច ខ្ញុំទាំងរើកញ្ជ្រោល ទាំងវាយតប់ ស្រែក តែកម្លាំងមនុស្សស្រីដូចជាខ្ញុំម៉េចនឹងអាចស៊ូកម្លាំងមនុស្សប្រុសបានទៅ ។

"បិទមាត់!"

"ឈឺឈប់ធ្វើបែបនេះទៅ!"

"មានបានធ្វើអីឯណា ហែកខោអាវធម្មតា។ នាងនៅឲ្យស្ងៀមមិនបានឬយ៉ាងម៉េច"

សាំយ៉ុង ពាក់កណ្ដាលល្ងង់លោមពាក់កណ្ដាលគំហក ហើយក៏មិនប៉ះពាល់ខ្ញុំទៀត ព្រមទាំងឈានថយក្រោយ ទៅឈរឱបដៃមើលនិងសើចពេញចិត្ត ។

"នាងមានកម្លាំងច្រើនមែន តាំងពីកើតមកខ្ញុំទើបនឹងបានជួបទេសញ្ញេញ"

"ស្អីស វ៉ាយ!" ខ្ញុំរហ័សយកដៃបិទដើមទ្រូងដែលពេលនេះកអាវរំហាធំ ព្រោះដាច់រហែកឃើញដល់អាវតូចរូបស្ត្របឺរី "កុំមើល អាឆ្កួត ៗ ម៉េចក៏ធ្វើបែបនេះ"

"ណ្ហើយ លើកនេះ"

"លើកនេះស្អី"

"ស្រែកឲ្យឮបំផុតតាមដែលនាងធ្វើបានទៅ"

"លោកចង់រំលោភខ្ញុំឬ!"

"អត់ទេ ខ្ញុំចង់ឲ្យនាងមើលអ្វីម្យ៉ាង ធ្វើដូចជាថាខ្ញុំធ្វើបាបរាងកាយនាងបានប៉ុណ្ណាគឺកាន់តែល្អ"

"អាឡប់សតិ អស់អីលេងហើយក៏អ្អី"

"ឬចង់ឲ្យខ្ញុំធ្វើមែនទែន"

"អ្ហ៎ា!!!"

សាំយ៉ុង បម្រុងនឹងចូលមករក ទើបខ្ញុំសម្រេចចិត្តស្រែកដោយមិនដឹងហេតុផលដូចមនុស្សវិកលចរិត អាម្សៀនោះបានតែឈរស៊េចចូលចិត្តដែលឃើញខ្ញុំស្រែកបែបនោះ ។

"នាងបានឮសម្លេងអ្នកនៅខាងក្រៅទេ កញ្ច្រៀវដូចសេះហើយបែបស្រមៃទៅដល់ឋានព្រះច័ន្ទហើយថានាងនិងខ្ញុំនេះនោះគ្នា រឿងនេះច្បាស់ជាល្បីបានយូរ ស្រែកបន្តទៅ កុំឈប់ មិនអីចឹងខ្ញុំនឹងរំលោភនាងមែនទែនហើយ"

"អ្ហ៎ា។។ ឡប់សតិ អាមនុស្សវិកលចរិត អ្ហ៎ា។។"

"បើកទ្វារក្លាម ខ្ញុំប្រាប់ឲ្យបើកទ្វារ!!!"

សម្លេងស្រែកលាន់នៅខាងក្រៅ ធ្វើឲ្យ សាំយ៉ុង ញញឹម ហើយយកមេដៃចង្អុល ព្រមទាំងញាក់ចិញ្ចើមដាក់ ។

"បានឮទេថាជាសម្លេងអ្នកណា ប្រហែលៗទេ"

"គូអ៊ីន"

"យ៉េស"

"ឯងទាំងពីរកំពុងធ្វើអី ខ្ញុំប្រាប់ថាឲ្យចេញម៉ោក្លាម អាសាំយ៉ុងខ្ញុំប្រាប់ថាឲ្យឈប់!"

ប៉ាំង!

សម្លេងដូចជាធាក់ទ្វារនោះ ធ្វើឲ្យខ្ញុំភ្ញាក់ព្រើត ស្រែកដូចបំពង់កបែក តែក៏ខំស្រែកតាម សាំយ៉ុង សម្អុតឲ្យធ្វើ ។

"បើកក្លាម អាសាំយ៉ុង ខ្ញុំនឹងសម្លាប់ឯង បើក!!!"

យ៉ាំង!

ហើយទីបំផុតកម្លាំងធាក់ពីខាងក្រៅក៏ធ្វើឲ្យទ្វាររធ្លាយបាន គូអ៊ីនដង្ហក់ខ្យល់ មើលខ្ញុំដែលអង្គុយលើគ្រែ និង សាំយ៉ុង ដែលឈរឱបដៃ

ទៅមិនឆ្ងាយ ។

"នាងកើតអីអត់ វាធ្វើអីនាងទេ" កូអឹន ស្ទុះមករកខ្ញុំ ហើយពិនិត្យមើលរាងកាយ មុននឹងចូកដៃពេលឃើញអាវសឹមីរបស់ខ្ញុំប្រឡាក់ "នេះវាធ្វើអីនាងខ្លះ វាហែកអាវនាងផ្អើស"

"ឯងចូលមកាត់ចង្វាក់" សាំយ៉ុង ។

"ឯងធ្វើដើម្បីស្អី"

"ដើម្បីរង្វាន់ ហេ៎ៗ អ៊ូយ!"

សាំយ៉ុង ដួលទៅដេកលើឥដ្ឋដោយសារកណ្តាប់ដៃរបស់ កូអឹន សូម្បីតែខ្ញុំក៏ចំហមាត់ធ្លុងនឹងសម្លេងផ្គើងប៉ះនឹងឥដ្ឋដែរ មិត្តរួមសាលាដែលឈរមើលហេតុការណ៍នេះក៏នាំខ្សឹបខ្សៀវគ្នាញញឹមសមចិត្តនឹងការឈឺចាប់របស់អ្នកដទៃ ខ្លះក៏កំពុងពិចារណាពីខ្លួនប្រាណខ្ញុំ នេះផងនោះផង ធ្វើឲ្យចាប់ន័យមិនបានថាអ្នកណានិយាយអ្វីខ្លះ ។

"ថោកទាប ម៉េចក៏ឯងធ្វើបែបនេះទៅរួច"

"គឺឯងប្រាប់ថានឹងឲ្យរង្វាន់ជាទីគាប់ចិត្ត បើឲ្យអ្នកជៀសបាន ឲ្យខ្ញុំល្អជាងឲ្យអ្នកជៀស"

"តែខ្ញុំមិនបានមានន័យថាឲ្យធ្វើបែបនេះទេ"

"អាអ្នកនៅខាងក្រៅគឺគិតចង់ធ្វើបែបនេះតែទាំងអស់ហ្នឹង"

ពេល សាំយ៉ុង បួញមាត់ទៅខាងក្រៅ កូអឹន ក៏ងាកទៅតាម គ្រប់គ្នាចាត់ក្បាលអស់ហាក់ដូចជាមិនធ្លាប់មានរូបរាងនៅត្រង់នេះអីចឹងនៅសល់តែយើងបីនាក់ ។

"បានហើយ ឈប់ទាំងពីរនាក់ហ្នឹងទៅ!"

ខ្ញុំក្តោប-កអាវ ហើយលោតចុះពីតុ ពួកគេមើលមកដោយការសង្ស័យថាខ្ញុំចង់ធ្វើអី ដៃម្ខាងដែលនៅសល់ពេលនេះកំពុងក្តាប់យ៉ាងណែន ហើយក៏លោតក្តាប់ៗជាច្រើនដង ។

"ពួកអ្នកមានសុខតែបែបនេះឬយ៉ាងម៉េច តាំងពីកើតមកពីពោះម៉ែ ខ្ញុំស្មានថាមានតែក្តុងការទូនដែលចូលចិត្តធ្វើបាបអ្នកដែលតូចទាបជាង តែខ្ញុំមិនគិតថាមនុស្សដូចពួកលោកធ្វើបែបនេះបានមែន ឃើញទុក្ខសោករបស់អ្នកដទៃជារឿងកំសាន្ត"

"អី..." កូអ៊ីន ។

"ម្នាក់ធ្វើព្រោះរកកន្លែងកម្លាយអារម្មណ៍មិនបាន" ខ្ញុំងាកមើលទៅ កូអ៊ីន ហើយងាកទៅរក សាំយ៉ុង "ចំណែកម្នាក់ទៀតធ្វើព្រោះតែចង់សប្បាយ តែមិនបានគិតទេថាខ្ញុំក្លាយទៅជាចំណីមាត់អ្នកណា!"

"នាងស៊ីរៀលពេកអត់"

ផាច់!

ខ្ញុំទះកំផ្លៀង សាំយ៉ុង ហើយងាកទៅទះ កូអ៊ីន ដែលនៅជិត នៅពេលាដែលឆ្ងាយពីគ្នាមិនដល់មួយចម្រៀកនាទី ប្រុសទាំងពីរមើលមកខ្ញុំដោយការភ្ញាក់ផ្អើលពេលឃើញខ្ញុំស្រក់ទឹកភ្នែក ។

"ខ្ញុំស្អប់...ស្អប់មនុស្សដូចជាពួកលោកបំផុត!"

ង៉ាប់ហើយ ហេតុអីមនុស្សដូចខ្ញុំ សិស្សដែលធ្លាប់តែស្ងប់ស្ងាត់ត្រូវមកជួបរឿងអ្វីបែបនេះដែរ ខ្ញុំមិនដែលបាននៅសុខស្រួលទេតាំងពីជួបពីរនាក់នេះ ។ ខ្ញុំគេចមកសម្ងំនៅក្នុងបន្ទប់ទឹកនៅអាគារដែលមិនសូវមានមនុស្សឡើងមកប៉ុន្មាន ហើយគិតតែយំដោយមានអារម្មណ៍ថាស្អប់ពីរនាក់នោះដល់ពោះវៀន ខ្ញុំចូលចិត្តគេ ទាំងដែលមិនធ្លាប់ចូលចិត្តអ្នកណា ចុះកូអ៊ីន...គេធ្វើបែបនេះដាក់ខ្ញុំបានយ៉ាងម៉េច គេមិនមែនជាមនុស្សល្អដូចដែលខ្ញុំគិតទេមែនទេ?

គុកៗ

សម្លេងគោះទ្វារពីខាងក្រៅធ្វើឱ្យខ្ញុំភ្ញាក់ព្រើត រហ័សលាក់សម្លេងអណ្ដឹតអណ្ដក ហើយពេលមិនតបក៏មានសម្លេងហៅ៖

"ចេញម៉ោ ខាងក្រៅគ្មានមនុស្សទេ ខ្ញុំដឹងថានាងនៅខាងក្នុង"

"អ្នកណា"

"ចេញសិនម៉ោ"

ខ្ញុំនៅស្ងៀមមួយសន្ទុះធំ ដូចជាចង់សាកចិត្តថាអ្នកនៅខាងក្រៅនឹងរង់ចាំខ្ញុំទេ ហើយសន្សឹមៗបង្អើបទ្វារ សិស្សស្រីដែលខ្ញុំចាំមុខច្បាស់ព្រោះជាតារាប្រចាំសាលាមើលខ្ញុំ ហើយញញឹមយ៉ាងទន់ភ្លន់ដាក់ ។

"មិនបាច់ខ្លាចទេ ខ្ញុំជាមិត្ត"

"យើងស្គាល់គ្នាដែរឬ"

"ខ្ញុំជាមិត្តរបស់ កូអឺន ឈប់ៗ អ៊ូយ!"

ខ្ញុំបម្រុងនឹងរុញបិទទ្វារ តែស្រីម្នាក់នោះក៏លូកដៃមកពាំង ទើបត្រូវកៀបម្រាមដៃយ៉ាងខ្លាំង សម្លេងស្រែករបស់នាងធ្វើឱ្យខ្ញុំភ័យ ។

"ឈឺខ្លាំងអត់"

"ដូចដាច់ដៃអីចឹង"

"លូកម៉ោធ្វើអី ខ្ញុំសោកហើយ នាងចង់រករឿងឱ្យខ្ញុំសៅទៅដល់ណាទៀត"

"គឺនាងចង់បិទទ្វារដាក់មុខខ្ញុំហ្នឹងណា៎ តែនាងក៏ព្រមចេញម៉ោឱ្យទាល់តែបាន"

"ហើយនេះនាងជាអ្នកណា ម៉ោឈឺខ្លួននឹងរឿងខ្ញុំធ្វើអី"

"ថ្ងៃនេះខ្ញុំឃើញហេតុការណ៍ទាំងអស់ហើយក៏អត់បារម្ភមិនបាន" ដៃដែលត្រូវកៀបពេលនេះញ័រឱ្យទទ្រើត តែម្ចាស់ខ្លួនក៏ព្យាយាមយកអ្វីម្យ៉ាងចេញពីកាបូបស្ពាយចេញមក "យកអានេះទៅ"

"ហឺ ស្អីគេ"

"មើលមិនដឹងទេផ្កើសថាវាជាប្រអប់ដាក់ម្ជុល អំបោះនិងខ្សែអាវយកទៅដេរទៅ នាងចង់ដើរហើរដាយបង្ហាញអាវតូចរូបស្ត្រីបឺកបែបនេះមិនបានទេ"

"មនុស្សបែបណាទៅដែលស្ពាយរបស់អស់នេះតាមខ្លួន"

"មនុស្សដែលទៅលួចពីបន្ទប់របស់គ្រូ"

"អី ខ្ញុំចាំបានថានាងជាសិស្សច្បង...ខ្ញុំគួរហៅនាង មិនមែនទេហៅសិស្សច្បងថាអី"

"ហៅខ្ញុំថា ណាយ៉េ មិនចាច់ហៅសិស្សច្បងទេ ស្តាប់ទៅចាស់ម្យ៉ាងទៀតអាយុយើងស្រករគ្នា គ្រាន់តែខ្ញុំចូលរៀនមុនអាយុប៉ុណ្ណោះតែថានាងឈ្មោះអី ម៉ាថាំងអាចមី មែនទេ"

"ម៉ាថុងអ៊ុល!!! រងឥទ្ធិពលរបស់ ចុងកូអឺន មែនទេនេ៎ះ"

"គឺឃើញថាគេចូលចិត្តហៅនាងអីចឹង ហេះៗ"

"គេនិយាយរឿងខ្ញុំឱ្យនាងស្តាប់ដែរឬ មើលទៅជិតដិតគ្នាណា៎" ខ្ញុំនិយាយចេញទៅបែបប្រហើរៗ តែក៏អត់មិនបាននឹងរមួលចិត្តចម្លែកៗ

អាម្សៀនោះយករឿងខ្ញុំទៅនិយាយឱ្យអ្នកណាស្ដាប់ខ្លះនេះ ។

"គឺនិយាយថាមានអ្នកមកនៅជាមួយក្នុងឋានៈជាកូនចុង ហើយក៏ហៅនាងថា ថាំងអាចម៉ី។ ទើបខ្ញុំហៅតាម ក៏ចម្លែកចិត្តដែរ មនុស្សអីឈ្មោះបែបនេះ ណាយ៉េ ថាចម្លែកទៅហើយ តែ ថាំងអាចម៉ី នេះវាចម្លែកជាង តែពេលនាងប្រាប់ថាឈ្មោះ ចុងអ៊ុល ទើបខ្ញុំអាចនឹងយល់បានថា កូអ៊ីន គួរតែនិយាយឱ្យ អ្ហ៊ុំ ភ្លេចឆ្លើយទៅ ខ្ញុំ និង កូអ៊ីន ជិតដិតគ្នាណាស់ ទោះជាខ្ញុំរៀនលើសគេម៉ាថ្នាក់ក៏ដោយ"

"អ្ហឹម"

"មិនសួរទេឬថាហេតុអីក៏ជិតដិតគ្នាម្ល៉េះ"

"គឺប្រហែលជាសង្សារគ្នាទេដឹង ធ្លាប់ឃើញដើរជាមួយគ្នា"

"នាងធ្វើមុខដូចអស់សង្ឃឹម"

"ខ្ញុំទៅអស់សង្ឃឹមស្អី"

"តំឡើងសម្លេងទៀត"

"សរុបទៅខ្ញុំអរគុណសម្រាប់របស់អស់នេះ បើមានឱកាស ខ្ញុំនឹងតបស្នងវិញ"

"សោះកក្រោះអីយ៉ាងនេះ"

ខ្ញុំច្រូក់នឹងសម្ដីលេងបន្លំមែនរបស់នាង ។

"អី មិនមែនបែបនោះទេ"

"ខ្ញុំចង់ធ្វើជាមិត្តនាងពិតមែន"

"ហ៊ឺ? ហេតុអី"

"ខ្ញុំចង់ធ្វើជាមិត្តនឹងអ្នកដែល កូអ៊ីន លង់ស្នេហ៍ វាមិនងាយនឹងរកបានទេ"

"O_O"

មិនដឹងទេថាសិស្សច្បង ណាយ៉េ ម្នាក់នេះត្រូវការជ្សារក្តាប់ស្អីទេ តែវាដូចជាថាធ្វើឱ្យខ្ញុំមានអារម្មណ៍មិនតិចឡើយ ពេលនាងចេញទៅ ខ្ញុំក៏អង្គុយដេរឡេវអាវដែលមានពណ៌ចម្រុះដូចស្ករគ្រាប់មិនស៊ីនឹងអាវ តែទោះដេររួចក៏ដោយ ក៏ខ្ញុំសម្ងំនៅក្នុងនោះរហូតដល់ម៉ោងចេញទៅផ្ទះ ស្មើនឹងថាថ្ងៃនេះខ្ញុំគេចសាលាបែបមិនគិតពីជីវិត ។

ខ្ញុំហ័សចេញពីសាលាភ្លាមពេលឮសម្លេងកណ្តឹង ហើយក៏រត់ទៅឡើងតាក់ស៊ី ហើយប្រាប់គោលដៅ ហ៊ូ...មិនថានៅទីណាក៏មានក្តីសុខដាងនៅក្នុងសាលានោះដែរ នរកឱ្យច្បាស់ក្រឡែត ចុងកូអីន ធ្វើឱ្យទីនោះក្លាយជានរកសម្រាប់ខ្ញុំ ។

"ត្រង់នេះហើយ"

ខ្ញុំប្រាប់អ៊ំអ្នកបើកឱ្យចតឡាន ហើយកន្លែងដែលខ្ញុំមកគឺជាកន្លែងដែលខ្ញុំមកពីម្សិល...ផ្ទះរបស់ប៉ា ទាំងដឹងហើយថាប៉ាមិននៅ តែខ្ញុំក៏តែចង់មក វាប្រហែលធ្វើឱ្យកក់ក្តៅចិត្តច្រើនទេដឹង ព្រោះយ៉ាងហោចណាស់ទីនេះមើលទៅគឺជារបស់ខ្ញុំច្រើនជាងផ្ទះរបស់ កូអីន ។

"នែ៎"

"ហឿក!!!"

ពេលបានឮសម្លេងបែបនោះនៅក្រោយខ្នង ខ្ញុំក៏ភ្ញាក់ព្រើតបែបអូពីដោយការលោតទៅខាងមុខមួយម៉ែត្រ ។

"ម៉េចចាំបាច់ធ្វើមុខបែបនោះ ខ្ញុំធ្វើឱ្យនាងលោះព្រលឹងអ្ហ៎ស"

គឺមសាំយ៉ុង ដែលមិនដឹងផុសមកពីណាធ្វើឱ្យខ្ញុំរិះតែស្រែក ។

"អាភេគចិត្ត នេះតាមម៉ោរំលោភខ្ញុំដល់ទីនេះឬ!"

"ស្ងួត! នាងឡប់ទេអ្ហ៎ស តិចៗបានទេ តិចគេឯងយល់ច្រឡំទៅ"

"យល់ច្រឡំខ្មោចលងស្អី ថ្ងៃនេះលោកធ្វើអីចឹងមែន" ព្រោះទោះជាខ្ញុំភ្លេច តែឡេវចម្រុះពណ៌នៅតែជាស់តឿនការចងចាំ ។

"ខ្ញុំធ្វើបែបនោះ តែមិនបានតាំងចិត្តថាធ្វើមែនទែនទេ"

"ឯងគួរហើយបានគិត គំរក់...មិនបាច់ឈានម៉ោទេ ម៉ែនឹងស្រែកហើយបើហ៊ានចូលម៉ោ"

សាំយ៉ុង ឈប់ស្ងៀម ហើយមើលខ្ញុំដោយទឹកមុខហត់នឿយចិត្តមុននឹងញាក់ស្មាព្រមចុះចាញ់ ។

"អូខេ មិនដើរចូលទៅក៏បាន តែស្តាប់ខ្ញុំនិយាយឱ្យចប់សិនទៅ ថ្ងៃនេះខ្ញុំមិនបានធ្វើអីនាងបែបនោះមែន បើគិតចង់ធ្វើមែន ខ្ញុំហែកអាវនាងហើយដើរទៅឈរឱបដៃមើលធ្វើអី"

"ដើម្បីភាពឡប់សតិ"

"ម៉ោដល់ថ្មើរនេះហើយនៅតែមិនយល់ទៀតផ្អុស ខ្ញុំធ្វើទៅដើម្បីធ្វើបាប គូអ៊ីន ប៉ុណ្ណោះ នាងមិនឃើញទេអ្ហី ពេលនាងនៅជាមួយខ្ញុំ វាក៏ទម្លាយទ្វារចូលមកដូចមនុស្សឆ្កួត ខ្ញុំគ្រាន់តែសប្បាយនឹងការបានធ្វើបាបមនុស្សមាត់រឹងដល់ថ្នាក់មាត់ខ្លួនឯងមានរបួសព្រោះត្រូវវាដាល់ នាងមិនឃើញទេអ្ហ៎"

"សមមុខហើយ"

"នាងបំភ្លេច...ណ្ហីយ នាងមិនបានមើលឃើញខ្ញុំជាមនុស្សល្អស្រាប់ទៅហើយ តែថានាងម៉ោធ្វើអីទីនេះ ថ្ងៃនេះខ្ញុំមិនបានឃើញនាងទៅញ៉ាំបាយនៅកន្លែងទិនទេ"

គេសង្កេតដល់ថ្នាក់នោះផង...

"រឿងផស់ខ្ញុំ"

"ហេ៎ ខ្ញុំបារម្ភ"

"ស្អី បារម្ភ? ខ្ញុំទៅរកអ៊ីម៉ូទិខននៅឯណាមកក្អួតដាក់លោកនេះ"

"នាងក៏ធ្វើស្អីលក្អួតឱ្យឃើញទៅហើយ ម៉េចចាំបាច់ធ្វើអីឱ្យយ៉ាប់យ៉ឺនដែរ ម៉េចក៏ខ្ញុំនិយាយអី នាងតែងតែធ្វើឱ្យវាស្តាប់ទៅយ៉ាប់បានទាំងអស់អីចឹង តែថាមិនទាន់ឆ្លើយតបទេថាម៉ោទីនេះធ្វើអី អ្ហ៎ ឆ្លើយឱ្យត្រឹមត្រូវម៉ោ ឈឺឡាតែគណាស់ពេលនាងធ្វើជារឿងច្រើន"

"ខ្ញុំមានធុរៈ" ខ្ញុំខាំមាត់ មើលទៅផ្ទះ "នេះជាផ្ទះប៉ាខ្ញុំ"

"ខ្ញុំស្មានថាប៉ានាងស្លាប់បាត់ហើយ"

"ណ្ហើយ!"

"អ្ហា៎ គឺឃើញម៉ាក់នាងរៀបការជាមួយប៉ា គូអ៊ីន ហ្នឹងណ៎ា"

"មនុស្សយើងរៀបការថ្មីបាន មិនចាំបាច់ភាគីម្ខាងទៀតបែកឋានទេ គឺ...ប៉ាម៉ាក់ខ្ញុំមានការចាំបាច់ត្រូវលែងលះគ្នា ប៉ាទៅម្ខាង ម៉ាក់ទៅម្ខាង អ្ហ៎ ម៉េចក៏ខ្ញុំត្រូវនិយាយស្អីបែបនេះដែរ អ៊ុនសាយដីពេកហើយ"

"ចុះនាងម៉ោទីនេះធ្វើអី"

"..."

"ចង់ម៉ោនៅជាមួយប៉ាឬ"

ខ្ញុំងាកខ្វាប់ទៅមើល សាំយ៉ុង ដោយមានអារម្មណ៍ថាខឹងដែលគេ

ដៅស្ថានការណ៍បានត្រូវ ព្រោះហើនណាស់ដែលដៅត្រូវ អ្ហា!!! (ពាល ដោយគ្មានហេតុផល)

"វាជាវិធីតែមួយដែលខ្ញុំអាចចេញពីផ្ទះ កូអឺន បាន"

"នាងចេញពីផ្ទះនោះបាន តែមិនបានមានន័យថាចេញពីសាលា នោះបានដែរ"

"បើចេញពីផ្ទះនោះបាន ខ្ញុំក៏ប្រហែលជាអាចគិតរកផ្លូវធ្វើអីផ្សេង បានងាយជាងនោះ"

"ចុះឯណាប៉ានាង"

"មិននៅ"

"នាងម៉ោទាំងដែលដឹងថាប៉ាមិននៅ ហើយម៉ោរកស្អី"

"ខ្ញុំម៉ោដេកចាំទាល់តែប៉ាម៉ោពីបរទេសវិញ"

"តែមើលទៅផ្ទះដូចចាក់សោ ចូលទៅម៉េច" សាំយ៉ុង អើតមើល ទ្វារផ្ទះ "វិធីតែមួយដែលនាងធ្វើបានគឺដេកហាលមូសនៅមុខផ្ទះ មិន អីចឹងគឺគាស់ទ្វារ"

"ខ្ញុំគ្មានផ្លូវផ្សេងទេឬយ៉ាងម៉េច"

តាមពិតដឹងហើយថាទោះជាមកក៏ជួយអីមិនបាន ផ្ទះក៏ចាក់សោ មនុស្សក៏មិននៅ តែខ្ញុំគិតថាទោះយ៉ាងណាក៏ល្អជាងទៅផ្ទះជួប កូអឺន ជួបសង្គ្រាមរវាងម៉ាក់និងគេទៀត បើបែបនោះ ខ្ញុំដេកនៅមុខផ្ទះប៉ាឲ្យ មូសខាំឲ្យគ្រុនឈាមងាប់នៅល្អជាង ។

"មាន"

"ស្អី"

"ទៅនៅជាមួយខ្ញុំ"

១០

ខ្ញុំមើលមុខ សាំយ៉ុង ដោយខ្សែភ្នែកចម្លែកៗ និងគិតទៅដល់សម្ដីរបស់ សេដីន ហើយមើលទៅគេបែបដឹងហើយថាខ្ញុំច្បាស់ជាគិតអីចម្លែកៗ ទើបរហ័សគ្រវីដៃគ្រវីជើងដូចប៉ូលិសចរាចរណ៍ផ្លូវថ្មើរជើងមុខសាលា ។

"ទេៗៗ កុំយល់ច្រឡំនឹងខ្ញុំអ្ហី"

"..."

"ព្រោះថ្ងៃនេះខ្ញុំមានអារម្មណ៍ថាខ្លួនឯងប្រហែលជាធ្វើឲ្យនាងពិបាកចិត្តពេកហើយ ខ្ញុំគួរតែជួយអីម្យ៉ាងដល់នាង"

"អរគុណ តែមិនអីទេ"

"ចុះនេះនាងចង់ទៅណា"

"ទៅផ្ទះ"

"ក្រែងប្រាប់ថាដេកនៅទីនេះភ្អើស"

"លោកជឿគ្រប់សម្ដីអ្នកដទៃឬយ៉ាងម៉េច ឱព្រាន"

"ខ្ញុំជាមនុស្សស្មោះត្រង់ អីចឹងនាងចង់ទៅណា ខ្ញុំជូន"

"មិនបាច់ ខ្ញុំទៅផ្ទះ...របស់ កូអីន"

"ទៅយ៉ាងម៉េច"

"ឡានក្រុង"

"ខ្ញុំជូនទៅ"

"មិនបាច់!"

"អីចឹងមិនជូនទៅក៏បាន"

ស្អីទ៊េះ ព្រមចុះចាញ់! ល្អួចខឹងតិចតួចដែលមិនព្រមតាប៉ែបន្ត

(នេះជាអ្វីដែលនាងត្រូវការរម្លេស) តែណ្ហ៍យ គេមិនបានជិតជិតអីនឹងខ្ញុំបន្តិចទេ ចង់ឲ្យគេជូនទៅបានយ៉ាងម៉េច ថែមទាំងថ្ងៃនេះទើបនឹងមានរឿងជាមួយគ្នាផង ។ ខ្ញុំមើលមុខ សាំយ៉ុង ហើយក៏ងក់ក្បាលដាក់ មុននឹងដើរមកមាត់ច្រក ឡើងឡានក្រុង តែថា...

"លោកឡើងមោធ្វើអី"

"ខ្ញុំចង់ជិះឡានក្រុងសាកមើល"

"ធ្លាតឬយ៉ាងម៉េចនេះ មានឡានល្អៗមិនទៅជិះ ចុះឡានលោកទៅណាហើយ"

"បើកតាមក្រោយឡានក្រុង"

ខ្ញុំមើលតាមការប្រាប់របស់គេ ហើយក៏ចាប់ផ្ដើមមានអារម្មណ៍ថាក្ដៅរងាៗចម្លែក គឺមិនចង់គិតលើកជើងខ្លួនឯងទេ តែគេធ្វើបែបនេះដើម្បីអី?

"លោកចូលចិត្តខ្ញុំឬ"

"ស្អីគេ!"

សម្លេងស្រែករបស់ សាំយ៉ុង ធ្វើឲ្យមនុស្សពេញមួយឡានងាកមកមើល កាន់តែយើងឈរបែបនេះផង អាច្ឆុត...គិតថានេះជាបន្ទប់ដេកឯកជនឬយ៉ាងម៉េច ។

"គឺ...មិនដឹងទេ សួរលេង"

"នាងសួរសំនួរដែលគ្មានការគួររាសបែបនេះបានយ៉ាងម៉េច"

"ខ្ញុំសួរព្រោះខ្ញុំគិតរួចហើយ តែបើលោកមិនគិតក៏ល្អដែរ"

"ម៉េច វាល្អយ៉ាងម៉េច"

"លោកនឹងមិនអស់សង្ឃឹម ដែលលង់ស្រលាញ់ខ្ញុំហើយ ខ្ញុំមិនស្រលាញ់វិញ"

ខ្ញុំតបឡើងកាលីប ហើយពើងថ្ងូងដាក់ បន្ទាប់ពីនោះយើងក៏នៅស្ងៀមរហូតមកដល់ចំណតដែលខ្ញុំត្រូវចុះ សាំយ៉ុង ចុះមកដែរ ហើយដើរតាមខ្ញុំទៀត ។

"ស្អីនេះ ដើរតាមធ្វើអី"

"អ្នកណាដើរតាមនាង ខ្ញុំមកលេងផ្ទះមិត្តខ្ញុំ គ្រាន់តែមកស្រប

ពេលជាមួយនាងប៉ុណ្ណោះ...មិនចាច់ទេ មិនចាច់មើលមុខបែបនេះទេ ហើយមិនចាច់គិតអីចម្លែកៗទេ"

"តាមពិតដែលខ្ញុំសួរ ព្រោះមានគេប្រាប់ខ្ញុំថាមនុស្សដូចលោកគឺមិនចាប់អារម្មណ៍ ឬ យកចិត្តទុកដាក់លើអ្នកណាអ្វីបែបនេះទេ"

"ហើយម៉េច"

"ទើបខ្ញុំសួរត្រង់ៗទៅថាលោកចូលចិត្តខ្ញុំឬអត់តែប៉ុណ្ណោះ អ្ហ៎ ខ្ញុំនិយាយជាមួយលោកធ្វើអី ទៅឈរឱ្យឆ្ងាយទៅ បើម៉ាក់ឃើញថាមានមនុស្សប្រុសជូនដល់មុខផ្ទះ ខ្ញុំច្បាស់ជាត្រូវជេរហើយ"

"បាទ ស្រីពីរជីន"

"គឺពីរជីនមែន"

"O_O ចេះម៉ោនិយាយលេង"

"ម៉េចចាំបាច់ធ្វើមុខបែបនោះ"

"នាងមិនធ្លាប់...មិនដែល?"

"ម៉េចចាំបាច់ធ្វើមុខដូចខ្មោចអីចឹង អ្ហ៎ ប្រហែលបំផ្លាញស្រីអស់ច្រើនហើយទើបមិនគិតថាមាននៅសល់ ហឺស លោកឯងនេះចំជាគួរឱ្យខ្ពើមមែន ហើយម៉ោឈរធ្វើអី មិនចូលផ្ទះទេអ្ហ៎ស"

"នាងបបួលខ្ញុំចូលក្នុងផ្ទះឬ"

"អ្ហ៎ា គឺលោកប្រាប់ថាម៉ោលេងផ្ទះមិត្តភក្តិនោះអ្វី"

"អឺ...មែន កុំល្អជាង វាល្ងាចណាស់ហើយ ម្យ៉ាងទៀតអ្នកបើកឡានខ្ញុំក៏បើកតាមយូរដែរ អាណិត"

"ប្រាប់ខ្ញុំធ្វើអី ទៅប្រាប់អ្នកបើកឡានស្អីផសលោកទៅ"

ខ្ញុំដើរចូលទ្វារធំទៅដោយមិនចាប់អារម្មណ៍គេសូម្បីតែបន្តិច ធ្វើឱ្យ សាំយ៉ុង ត្រូវឈរគោងទ្វារដូចស្វាហៅឱ្យខ្ញុំងាកទៅរក ។

"ន៎ែ..."

"នៅមិនទៅទៀត"

"សុបិនល្អ"

"អ៊ី! វ្វក"

ខ្ញុំហាក់សដេញគេ ហើយរត់ប្រួចចូលទៅក្នុងផ្ទះ ទោះមាត់និយាយ

ថារូក តែលេះដូងលោតញាប់ ឬកពាដូច សេដឺន ប្រាប់...ប្រុសម្នាក់ នេះកំពុងតែមានចិត្តចំពោះខ្ញុំ ខ្ញុំទៅវាយស្នេហ៍ ឬ ធ្វើអ្វីឲ្យគេជាប់ចិត្ត ទៅនេះ ចង់ប្រាប់ថាលើកជើងខ្លួនឯងក៏មិនមែន តែអាការៈវាសម្ដែងឲ្យ ច្បាស់ក្រឡែតដល់ថ្នាក់នេះ ឲ្យគិតជាអីផ្សេងបានយ៉ាងម៉េច ។

"អ៊ូយ...អ៊ុយ!"

ខ្ញុំឈ្ងោកមុខរត់ចូលមក ទើបមិនដឹងថាមានអ្នកពាំងផ្លូវ កូអ៊ីន ឈរឱបដៃ មើលមុខខ្ញុំដោយមានចេតនាចង់ករឿង ។

"ម៉េចទើបម៉ោដល់"

"រឿងផស់ខ្ញុំ" ខ្ញុំដើរគេច ហើយចូលទៅក្នុងផ្ទះ តែអាម្សៀនេះនៅតែដើរតាមមិនឈប់ ។

"ហើយពេញម៉ាថ្ងៃនេះនាងបាត់ទៅណា ម៉េចក៏មិនទៅញុំាបាយនៅកង់ទីន នាងដឹងទេថាខ្ញុំដើររកនាងសព្វកន្លែង ន៎ែ ខ្ញុំកំពុងនិយាយ"

"កុំម៉ោទះក្បាលអង្អែលខ្នងមើល៍!" ខ្ញុំវាសដៃគេចេញពីស្មា "ខ្លួនឯងជាអ្នកបញ្ជាពួកនោះឲ្យធ្វើបាបគេសោះហ្នឹង នៅមានមុខម៉ោសួរនេះសួរនោះទៀត ចង់ឃើញខ្ញុំឈឺចាប់ណាស់មែនទេ ទើបចាំផ្អាក់ផ្លូវសួរ ថ្ងៃនេះខ្ញុំមិនត្រូវ តឹមសាំយ៉ុង ធ្វើស្អីទេ!"

"មែនហ្អេស ខ្ញុំក៏គិតថាអីចឹង..."

"តែបើថ្ងៃនេះមិនបានគេ ខ្ញុំច្បាស់ជាត្រូវអ្នកផ្សេងធ្វើ ព្រោះតែលោកម្នាក់គត់" ទឹកភ្នែកខ្ញុំស្រក់ចុះមក ធ្វើឲ្យ កូអ៊ីន ភាំង ។

"ហ៎ា។ កុំយំ វាគ្មានអីកើតឡើងបន្តិចណាទេ ខ្ញុំលុបបញ្ហាហើយ ម្យ៉ាងទៀត...គិតថាយើងរួបគ្នាទៅបានហើយ ខ្ញុំត្រូវចាំទះកំផ្លៀង នាងមិនត្រូវស្អីផង"

"លោកនិយាយងាយៗបានយ៉ាងម៉េចថាខ្ញុំមិនត្រូវ ត្រូវឲ្យត្រូវសិនទើបមានកំហុសមែនទេ"

"ន៎ែ កុំរឿងច្រើនមើល៍ ប្រុសសង្ហាមានស្នេហ៍មកនិយាយជាមួយ គឺបាត់ទុកថាមានសំណាងហើយ"

"ពីយ!"

"ស្រែកធ្វើអី មិនគួរឲ្យស្រលាញ់ទេ ន៎ែ ម៉ោវិញ យើងនិយាយគ្នា

មិនទាន់ចប់ទេ នាងមិនទាន់ប្រាប់ទេថានាងទៅណាម៉េចម៉ោះវិញល្ងាចម្ល៉េះ ហេ៎!!"

ខ្ញុំរត់គេចពី កូអ៊ីន ឡើងទៅខាងលើ ព្រោះគ្មានអារម្មណ៍សូម្បីតែបន្តិចថាចង់មើលមុខគេ តែពេលឡើងមកដល់ក៏ងាកភ្នែកទៅឃើញទ្វារបន្ទប់របស់ កូសង់ បង្អើប ជើងដែលបម្រុងនឹងចូលបន្ទប់ខ្លួនឯងក៏ដូរទិសដៅទៅរកបន្ទប់នោះវិញ ។

នៅខាងក្នុង កូសង់ កំពុងអង្គុយរៀបគ្រាប់ឡុកឡាក់ ដែលមើលយ៉ាងណាក៏មិនអាចចេញជារូបរាងបានដែរបើគ្មានកាវ បន្ទប់ដែលហប់ស្អុះស្អាប់ ធ្វើឲ្យខ្ញុំអត់នឹងរអ៊ូមិនបាន ។

"ម៉េចក៏មិនបើកអ៊ែរ ឬ កង្ហារ"

អ្នកមើលថែងាកមកញញឹមដាក់÷

"បើបើក គ្រាប់ឡុកឡាក់អាចនឹងដួល ហើយអ្នកនាងតូចក៏ត្រូវអង្គុយរៀបបែបនេះជារៀយៗ"

"ខ្ញុំចង់ដូចជាគេដល់ហើយ មិនចាច់មានរឿងទុក្ខចិត្ត"

"គេក៏មានរឿងទុក្ខសោកដែរ គ្រាន់តែយើងមិនដឹងប៉ុណ្ណោះ តែថាអ្នកនាង ថុងអ៊ុល កើតអីឬអត់ មុខមាត់មិនសូវស្រស់ថ្លា"

"គឺធុញថប់រឿងរៀននិងរឿងទូទៅ"

"មានអីចង់បន្ទូរគឺប្រាប់អ្នកនាងតូចបាន គេមានទាទីចាំស្តាប់... ពេលខ្ញុំមិនសប្បាយចិត្តក៏និយាយឲ្យគេស្តាប់ដែរ"

ខ្ញុំអង្គុយមើល កូសង់ ដែលនៅតែរៀបគ្រាប់ឡុកឡាក់ហើយដួលព្រមទាំងញញឹម មុននឹងលូកដៃទៅអង្អែលសក់នាងតិចៗ តែក៏ត្រូវវាសចេញដោយការធុញទ្រាន់ ហើយនាងក៏រៀបគ្រាប់ឡុកឡាក់បន្ត ។

"មើលទៅនាងដូចមិនចូលចិត្តទេ"

"ព្យាយាមបន្តិចទៅ តិចទៀតអ្នកនាងតូចនឹងចូលចិត្តអ្នកនាងហើយ"

"ខ្ញុំចូលចិត្ត កូសង់ នាងមិនពិសពុល ខ្ញុំមានអារម្មណ៍ថាចូលចិត្តនាង"

"អីចឹងខ្ញុំសុំចូលបន្ទប់ទឹកមួយភ្លែត ជួរមើលគេផង"

អ្នកមើលថែដើរចេញទៅ ទុកឱ្យខ្ញុំនៅជាមួយ កូសង់ ដែលមិនសូម្បីតែងាកមកមើលខ្ញុំ ទើបខ្ញុំត្រូវខិតទៅជិត ហើយនិយាយជាមួយដោយការត្រូវការចង់សម្ព័ន្ធភាព ។

"ខ្ញុំសុំលេងផងបានទេ"

"..."

"បើនៅក្នុងផ្ទះនាងមិនលេងជាមួយ ខ្ញុំក៏គ្មានអ្នកណាទៀតដែរ"

មើលទៅ កូសង់ ដូចជាធូរក់បន្តិច ហើយធ្វើការបន្ត ។

"ពេលនេះខ្ញុំធុញថប់ណាស់"

ប៊ឹប!

មានអារម្មណ៍ថាដូចជាត្រូវខ្លាឃ្មុំមាឌធំឱបជាប់ពីក្រោយ ពេលងាកទៅមើលក៏ឃើញថាជា កូអ៊ីន គេខ្មោចចូលឬក៏ម៉េចហ្នឹង!

"ធ្វើស្អី ស្មានថាលោកទៅបាត់ពីមុខពីមាត់ទៅហើយ"

"គឺមិនចង់ឱ្យនាងអផ្សុក ទើបម៉ោលេងជាមួយ"

"ខ្ញុំមិនបានសុំ!"

ខ្ញុំព្យាយាមរើបម្រះ តែ កូអ៊ីន នៅតែឱបណែនដូចចង់យកឈ្នះ កូសង់ ដែលនៅក្នុងហេតុការណ៍មិនសូម្បីតែមើលយើង តែខ្ញុំបែរជាមានអារម្មណ៍ថាខ្មាសដែលត្រូវធ្វើបែបនេះនៅនឹងមុខក្មេង ។

"សុំទោស"

"ហឺ?"

"ជួនកាលខ្ញុំក៏ធ្វើខ្លួនដូចក្មេងពេកទាល់តែមិនដឹងថាព្រំដែនរបស់ភាពសក្តិសមនៅត្រង់ណា បើធ្វើឱ្យនាងត្រូវក្តៅក្រហាយខ្លះ..."

"មិនមែនខ្លះទេ គឺច្រើនតែម្តង!" ខ្ញុំព្យាយាមរើ "លែងទៅ!"

ប៉ឹក!

គ្រាប់ឡូកឡាក់មួយឈុតត្រូវគប់ដាក់យើងចំៗ កូសង់ មើលមុខយើងដោយក់ហឹង ខ្ញុំក៏ចំហមាត់ឆ្ងល់ព្រោះមិនយល់ ។

"អីគេ" ខ្ញុំ ។

"គេខឹងដែលនាងឯងរើក់មិនជានាទីងបងប្រុសគេ"

កូសង់ មើលមុខយើងម្តងទៀត ហើយរៀបចំរបស់លេងម្តងទៀត

កូអឺន ព្រមលែង ហើយទាញខ្ញុំឱ្យដើប ។

"ទៅយើង"

"អឺ...អឺ"

ខ្ញុំព្រមតាមគេចេញទៅខាងក្រៅយ៉ាងងាយ ហើយលួចមើលកូសង់ ម្ដងទៀត ក៏ឃើញថានាងរៀបរបស់លេងជាថ្មី គួរឱ្យអាណិត មិញរៀបបានជារូបជារាងហើយក៏ត្រូវរលំរលាយ ព្រោះតែ...

"ម៉េចមើលមុខខ្ញុំបែបនោះ ខ្ញុំមិនបានធ្វើខុស ព្រោះមិនត្រឹមតែមិនខុស ខ្ញុំនៅមានមុខស្អាតទៀត"

"អឺ លោកវាល្អទាំងអស់ហ្នឹង សុំឱ្យលង់នឹងខ្លួនឯងបន្តទៀតទៅ"

"ហើយចង់ទៅណា"

"ទៅបន្ទប់"

"ឈប់"

"ដីទៀតហើយ!"

លឿនជាងពាក្យថាលឿន រហ័សជាងពាក្យថារហ័ស កូអឺនទាញខ្ញុំទៅថើប ហើយរុញចេញភ្លាមបែបមិនឱ្យតាំងជំហរ ។

"សុបិនល្អ"

"..."

ឈប់សិន...មិញគេធ្វើអី?

១១

ព្រោះស្នាមថើបនោះធ្វើឲ្យខ្ញុំដេកមិនលក់ពេញ១យប់ លុះព្រឹកឡើងមុខដូចខ្មោចតែសាក តែវាបែរជាផ្ទុយពី កូអ៊ីន គេមិនត្រឹមតែគ្មានអារម្មណ៍អីទេ ថែមទាំងធ្វើសោះកក្រោះនៅចំពោះមុខម៉ាក់ដូចដើម ដោយការមិនចូលញ៉ាំបាយជុំគ្នា តែរាងគ្រាន់បន្តិចដែលគេនៅចាំខ្ញុំដើម្បីទៅរៀនព្រមគ្នា ហើយពេលយើងឡើងឡាន ភាពស្ងៀមស្ងាត់ក៏កើតឡើងភ្លាម ថាទៅគេមិនគួរនៅចាំទេ ធ្វើដូចដើមមិនបានឬក៏ម៉េច ដឹងទេថាខ្ញុំធ្វើខ្លួនមិនត្រូវ។

ប៉ាច់!

ជើងដ៏វែងដូចកន្ទុយដាយណូស័រត្រូវដាក់នៅលើភ្លៅខ្ញុំដោយមិនឲ្យសួរឲ្យសម្លេង ខ្ញុំងាកទៅមើលមុខគេ ហើយផ្អើបមាត់ណែន។

"ធ្ងន់"

"រួយ"

"រួចហើយត្រូវយកមកដាក់លើដែរឬយ៉ាងម៉េច"

"គឺជើងវាវែង ដាក់ទៅណាក៏មិនបាន ត្រូវដាក់លើភ្លៅនាងហ្នឹងហើយ ប្របាច់ផង"

"ឃើញខ្ញុំជាស្អី ម៉ោប្រើបែបនេះ"

"ត្រូវឲ្យបរិយាយទេថាយើងជាស្អីនឹងគ្នា"

"ក៏បម៉ោ ក្រៅពីខ្ញុំជាកូនចុងប៉ាលោកហើយ លោកក៏ជាកូនចុងម៉ាក់ខ្ញុំដែរ យើងចង់ជាស្អីនឹងគ្នាបានទៀត"

"យើងជាស្អីនឹងគ្នាក៏បានដែលអាចទាញមកថើបបានគ្រប់វេលា អ៊ុំប អ៊ូ អ៊ី"

ខ្ញុំហ៊ាសយកដៃសង្គ្រប់មាត់ កូអ៊ីន ពេលគេនិយាយដល់រឿងយប់មិញ នេះនៅក្នុងឡាន អីតែកុងច្បាស់ជាឮមិនខាន ហើយឱ្យខ្ញុំយកមុខទៅទុកនៅឯណាទេះ!

"ម៉េចចាំបាច់និយាយរឿងនេះដែរ"

"គឺនាងប្រាប់ឱ្យបរិយាយ"

"លោកជាអ្នកចាប់ផ្តើម ខ្ញុំមិនបានតបស្នងអីបន្តិចទេ"

"បើមិនចូលចិត្ត នាងមុខជាជេរហើយ"

"=O="

"ដល់សាលាហើយ"

កូអ៊ីន និយាយកាត់ចោក ហើយចុះពីឡានយ៉ាងលឿន ដែលខ្ញុំក៏ធ្វើអីមិនបាន ទើបត្រូវចុះទៅដែរដោយគ្មានលក្ខខណ្ឌ ។ ពេលចូលមកដល់ គ្រប់គ្នាក៏សម្លឹងមើលខ្ញុំដូចពីម្សិលមិនខុស ហាក់ដូចជានៅក្នុងខួរក្បាលកំពុងគិតថាធ្វើម៉េចចំពោះខ្លួនខ្ញុំដើម្បីឱ្យបានរង្វាន់ ឬមិនអីចឹងគឺ ប្រហែលគិតថាកើតអ្វីចំពោះខ្ញុំ និង សាំយ៉ុង នៅក្នុងបន្ទប់អ៊ុំយ ខ្ញុំមិនចង់គិតទេ ខ្ញុំលែងចង់មករៀននៅទីនេះហើយ ។

ប៊ឹប!

"O_O" ខ្ញុំ ។

(-_-)(-_-)(-_-) គ្រប់ខ្សែភ្នែក ។

កូអ៊ីន វាសដៃមកកៀក-កខ្ញុំ ហើយដើរទៅមុខព្រមគ្នាដោយមិនចាប់អារម្មណ៍អ្នកណា ចំណែកខ្ញុំបែរជាធ្វើអីមិនត្រូវ បានតែព្រិចភ្នែកព្រិចៗ ហើយសម្លឹងមុខគេនិងពួកនោះទៅមក ។

"ធ្វើ...ច្កុតស្អីហ្នឹង"

"កែខៃអ្វីដែលបានធ្វើពីម្សិល បើធ្វើបែបនេះ គ្មានអ្នកណាហ៊ានធ្វើអីនាងទេ"

"លោកជាមនុស្សបែបណាឱ្យប្រាកដទៅ ខ្ញុំដៅមិនត្រូវទេ"

"ខ្ញុំគ្រាន់តែជាមនុស្សស្មោះត្រង់ចំពោះអារម្មណ៍ខ្លួនឯង ខ្ញុំមិនត្រឹមតែមើលទៅឡូយ ថែមទាំងមានមុខមាត់ស្អាតនិងនិយាយស្តីយកជាការទៀតផង"

យោសនាខ្លួនឯងទៀត!

"ហេ៎"

សាំយ៉ុង គ្រវីដៃរាក់ទាក់តាំងពីចម្ងាយ ហើយដើរមកឈប់ពីមុខយើង គេមើលដៃដែល កូអឺន កៀក-កខ្ញុំដោយខ្សែភ្នែកពេញទៅដោយស្នាមញញឹមអុជអាល ។

"ម៉េច" កូអឺន ទាញខ្ញុំចូលទៅជិតទៀត "ឯងម៉ោតាំងពីព្រឹកតែម្ដងហើយណ៎"

"ខ្ញុំម៉ោថ្មើរហ្នឹងតាំងពីដើម ឯងទេវិញទេដែលមិនធ្លាប់សង្កេតអ្នកនៅជុំវិញខ្លួន...មើលទៅរវាងអ្នកទាំងពីរដូចជាមានអីប្រែប្រួល"

"វាត្រូវតែអីចឹង អ្នកផ្ទះតែមួយ មានពេលវេលារួមគ្នា គឺត្រូវតែនិយាយគ្នាខ្លះ ធ្វើអី...គ្នាខ្លះ អូ៎យ! ម៉េចចាំចាប់ក្តិច"

"ខ្ញុំទៅរៀន ឈប់និយាយអីច្ឆុតៗទៅ"

"ធ្វើជាអៀន អិអឺ" @ amazingshelf.blogspot.com

ខ្ញុំហ៊ាសរត់ចេញមក ទុកឲ្យមិត្តទាំងពីរនិយាយគ្នា ម៉េចក៏ចាំចាប់ធ្វើបែបនេះ កាលពីម្សិលនៅធ្វើខ្លួនជាខ្មោចកំណាច ឬពីម្សិលអាចជាថ្ងៃពេញបូរណ៍ទើបវិញ្ញាណអាក្រក់កាឡាខ្លួន អ៊ូយ ខ្ញុំមិនចង់រស់នឹងមនុស្សបែបនេះទេ ចង់អាក្រក់ក៏ធ្វើឲ្យខ្លើមដូចអាចម៍ ចង់ល្អក៏ធ្វើឲ្យ...ញាប់ញ័រ ។

ខ្មាសមាត់!

តែមើលទៅទង្វើរបស់ កូអឺន នៅថ្ងៃនេះដូចជាផ្ដល់ផលល្អចំពោះខ្ញុំ ព្រោះពេលចូលដល់ថ្នាក់ គ្រប់គ្នាក៏មកនិយាយលេងនិងធ្វើដូចថាជាមិត្តភក្តិនឹងគ្នាយូរឆ្នាំហើយ ខ្លះបបួលឲ្យចូលក្រុមធ្វើរបាយការណ៍ហេហាចាំជីងកូ ហើយពេលគិតថាជិតដិតនឹងខ្ញុំបានសមល្មមហើយក៏ហ៊ាសហ្មួនជួយគ្នាជីកឫកជីកគល់ដល់ប្រវត្តិបុគ្គល ។

"នៅផ្ទះជាមួយ កូអឺន ម៉េចម៉ាដែរ"

"ពេលនៅផ្ទះគេចូលចិត្តធ្វើអីជាពិសេស"

"ផ្ទះគេមានឡានម៉ានគ្រឿង"

"បន្ទប់គេធំគេម៉េចដែរ"

តាមពិតនេះមិនមែនជាប្រវត្តិរបស់ខ្ញុំទេ ហេតុអីក៏ កូអឺន ក្លាយជាមនុស្សជាទីពេញនិយមរបស់យុវវ័យសម័យថ្មីអីយ៉ាងនេះ ពេលវេលាកន្លងផុតទៅពីរម៉ោងក៏ដល់ពេលសម្រាកថ្ងៃត្រង់ ហើយពេលវេលានៃខ្សែភ្នែកគ្រប់ទិសចាញ់ផ្ដោះមកខ្ញុំក៏មកដល់ដែរ ព្រោះពេលចុះទៅដល់កង់ទីន ហើយអង្គុយបុកភ្លាម កូអឺន ក៏ចូលមកអង្គុយក្បែរភ្លែត ។

"ហេឡូ"

"ពេលណាទើបឈប់ធ្វើស្អីបែបនេះទៅ"

"មិនឈប់ ព្រោះខ្ញុំថើបនាងហើយ"

"បើមិនឈប់និយាយរឿងនេះ ខ្ញុំនឹងគេចទៅឱ្យឆ្ងាយ"

"ម៉េចនឹងអាចគេចបាន មានកន្លែងទៅឬក៏ម៉េច"

"នាងប្រមក់នេះមានកន្លែងទៅ" សាំយ៉ុង ដែលនៅសុខៗក៏ផុសមក ហើយអង្គុយទល់មុខយើងក៏តបដោយទឹកមុខស្ញេញស្ញាញ ឈប់សិន...មុននេះគេបានឮអីឬអត់ មិនគួរទេ~ "កុំមើលងាយ"

"ម៉េចក៏ឯងដឹង"

"ខ្ញុំបានទៅជាមួយ"

"ស្អីគេ!"

កូអឺន ស្រែកលាន់ ហើយទះតុចាយហាក់ដូចជាគេកំពុងកាត់ក្ដីប្រហារជីវិតអ្វីបែបនោះ កង់ទីនទាំងមូលស្ងាត់ឱ្យជ្រងំ មានតែ សាំយ៉ុង ប៉ុណ្ណោះដែលញញឹមសមនិងញាក់ចិញ្ចើមដាក់ខ្ញុំ ។

"នេះអ្នកទាំងពីរ...ស្អី យ៉ាងម៉េច ពីអង្កាល់ ម៉េចក៏ខ្ញុំមិនឃើញដឹងរឿងអីចឹង"

"រឿងខ្លះអ្នកផ្ទះតែមួយ ប្រើពេលវេលាជាមួយគ្នា ធ្វើអ្វីរួមគ្នា ក៏មិនចេះតែដឹងរឿងជាមួយគ្នារហូតដែរ"

"គីមសាំយ៉ុង!"

"ពួកលោកល្មមៗបានហើយ ខ្ញុំចង់ញ៉ាំបាយយ៉ាងស្ងៀមស្ងាត់មិនបានឬយ៉ាងម៉េច"

"ចុះនេះនៅស្ងៀមមិនគ្រប់ទៀតឬក៏អ្វី កង់ទីនមួយទាំងមូលគ្មានអ្នកណានិយាយសូម្បីតែម្នាក់!" កូអឺន ងាកមកគំហក ធ្វើឱ្យខ្ញុំភាំង ។

"តែត្រង់នេះនៅមានលោកនិយាយ មិនអីទេ នៅក្នុងពេលដែលលោកមិនស្ងាត់ ខ្ញុំទៅរកកន្លែងស្ងាត់ដោយខ្លួនឯង"

ខ្ញុំលើកចាន ហើយដើរចេញពីគ្រប់ខ្សែភ្នែកដែលតាមមើលបែបស្ងាត់ស្ងៀម ហើយពីរនាក់នោះកំពុងតែធ្វើថ្លតអី ប្រកួតកលយុទ្ធតាមរបៀបកូនប្រុសឬយ៉ាងម៉េច ខ្ញុំឈឺឡាតែតអស់ហើយ ។

"ឈប់ភ្លាម"

"នៅតាមម៉ោទៀតតតត"

"ខ្ញុំប្រាប់ថាឱ្យឈប់"

កូអ៊ីន ស្រែកដេញតាមក្រោយ ខ្ញុំដែលធ្វើអីមិនត្រូវក៏រត់គេចដោយកាន់ចានបាយជាប់ តែកាន់តែរត់គេច កាន់តែត្រូវស្រែកដេញតាម ។

"ឈប់!"

ដោយសារជើងវែងជាង គេក៏រត់មកស្កាត់ផ្លូវ ហើយចង្អុលមុខដូចបញ្ជា នោះហើយដែលធ្វើឱ្យខ្ញុំច្នក់ចាន តែដែលគួរឱ្យមហាស្ចារ្យជាងគឺចានមិនបានកម្ពប់បាយសូម្បីតែមួយគ្រាប់ ។

"យើងមានរឿងត្រូវនិយាយគ្នា"

"ចង់ញ៉ាំបាយ"

ផ្លូង!

កូអ៊ីន វាសចានដែលខ្ញុំខំថ្នាក់ថ្នមមិនឱ្យបាត់សូម្បីបាយមួយគ្រាប់ឱ្យធ្លាក់ទៅលើដី កម្ពត់ខ្ចាត់ខ្ចាយពេញនោះ ឬកពាររឿងរបស់គេ ធ្វើឱ្យខ្ញុំខ្លាចក៏ខ្លាច ខឹងក៏ខឹង ។

"ថ្លតស្អីទៀតហើយ បន្តិចក៏ល្អ បន្តិចក៏អាក្រក់ ចង់យ៉ាងម៉េច"

"នាង និង សាំយ៉ុង ទៅជិតដិតគ្នាពីអង្កាល់"

"ហើយវាជារឿងស្អីផស់លោកដែរ នៅក្នុងពេលដែលមនុស្សម៉ាសាលានេះបោះបង់ខ្ញុំចោលព្រោះតែបញ្ហារបស់លោក សាំយ៉ុង ម្នាក់គត់ដែលមិនខ្លាចអីក៏មកនិយាយជាមួយ នោះហើយដែលធ្វើឱ្យយើងជិតដិតគ្នា"

ងាប់ហើយ! ហ៊ាននិយាយផង ទាំងដែលត្រូវចាប់លីលើស្មា ទាំង

ចាប់ហែកអាវ នៅហៅថាជិតដិតគ្នាបានទៀត ។

"ប្រែថាថ្ងៃនោះនៅក្នុងថ្នាក់វាធ្វើអីនាងរួចហើយ"

"នែ៎!" ខ្ញុំស្រែក ហើយបានតែខាំមាត់ដោយព្យាយាមទប់មិនជេរ "អី ចង់គិតអីក៏គិតទៅ ខ្ញុំនិយាយអីក៏លោកមិនជឿស្រាប់ទៅហើយ"

"ខ្ញុំបញ្ជាឲ្យនាងនិយាយ"

"មិននិយាយ បានហើយ អាគ្រាន់តែខ្ញុំទៅនៅផ្ទះលោក ហើយត្រូវលោកធ្វើបាប ត្រូវលោកចាប់បង្ខំគឺខ្ញុំអត់ផ្លូវណាស់ទៅហើយ"

"បើទ្រាំលែងបានហើយ ចង់ធ្វើអី"

"ខ្ញុំនឹងទៅ"

"ទៅណា"

"សាំយ៉ុង បបួលខ្ញុំទៅនៅជាមួយ"

"ថាម៉េច"

"គឺបានឮហើយតើ លើកនេះជឿនៅថាខ្ញុំមានកន្លែងទៅ ទោះជាម៉ាក់នៅផ្ទះជាមួយលោកក៏គ្មានអីរារាំងការទៅនៅជាមួយ សាំយ៉ុងរបស់ខ្ញុំបានដែរ ស្តាប់ឲ្យច្បាស់ ខ្ញុំមានកន្លែងទៅហើយ!"

កូអ៊ីន ក្តាប់ដៃ ហើយចាប់ក្របួច-កអាវខ្ញុំទាញទៅជិត ពេលនេះខ្ញុំមើលមុខគេបែបស៊ូងាប់ (ងាប់គ្មានដីកប់ទៀតផង) ។

"ម៉េច ចង់ដាល់មុខខ្ញុំឬម៉េច ឬ ចង់ថើបទៀត អញ្ចឹង! លោកមានកម្លាំងច្រើនជាង ចង់ធ្វើអីក៏ធ្វើទៅ ខ្ញុំធុញនឹងរត់តាមអារម្មណ៍ឡើងចុះៗដូចសីតុណ្ហភាពរបស់លោកហើយ ម៉េចក៏ម៉េចទៅ"

ទោះជាខ្ញុំចូលចិត្តគេយ៉ាងណា តែបើគេទៅជាបែបនេះក៏វាហួសពីទទួលបានដូចគ្នា សង្ស័យតែស៊ីកណ្តាប់ដៃមែនហើយខ្ញុំ ។

"បើឃើញវាល្អជាងណាស់ក៏ទៅចុះ"

កូអ៊ីន ព្រលែងដៃ ហើយដើរថយក្រោយ ។

"ស្អីគេ គ្រង់អីចឹងធ្វើជាឯងមិនរករឿង"

"ខ្ញុំវាអន់ចរិតពិតមែន"

"នែ៎ កុំម៉ោធ្វើបែបនេះ វាមិនបានផលទេ"

ល្បិចខ្ពស់ណាស់ គិតមកធ្វើឲ្យខ្ញុំគិតថាខ្លួនឯងខុសឬម៉េច ហឺស!

"ខ្ញុំមិនធ្វើអីទាំងអស់ តែខ្ញុំក៏មិនបានដេញឱ្យនាងទៅនៅកន្លែងផ្សេងដែរ សរុបទៅថាខ្ញុំមិនតាមចែបចែប្រនាងទៀតទេ"

"បើមិនចែបចែប្រ ចុះកន្លងម៉ោហៅថាស្អី"

"ហៅថាចូលចិត្តនាងហ្នឹងអ្ហី"

"O_O"

ពេលនិយាយចប់ គេក៏ដើរចេញទៅ ទុកពាក្យស័ក្តិសិដ្ឋឱ្យខ្ញុំកាំងបោលដោយគ្មានទំនួលខុសត្រូវ សុខៗក៏មកនិយាយបែបនេះ...បន្ទាប់ពីឈ្លោះគ្នាហើយនេ៎ះ មិនយុត្តិធម៌ទេ ។

"ចុះបាយរបស់ខ្ញុំ"

នេះគឺជាអ្វីចុងក្រោយដែលខ្ញុំគិតបាននៅវិនាទីនោះ ។

១២

សម្ដីរបស់ កូអ៊ីន ធ្វើឲ្យខ្ញុំស្ងៀមស្ងាត់អស់ពេញមួយថ្ងៃ មេរៀនស្អី ក៏មិនចូលខួរ គិតតែអង្គុយទឹកដល់ទឹកមុខឈឺចាប់របស់គេពេល និយាយ ហើយក៏ដើរបែរខ្នងដាក់ខ្ញុំយ៉ាងកាលីប ។

'ហៅថាចូលចិត្តនាងហ្នឹងអ្ហី'

គ្រាន់តែសម្ដីប៉ុណ្ណឹងក៏ធ្វើឲ្យបេះដូងខ្ញុំលោតខុសចង្វាក់ទៅហើយ ធ្លាប់ឮទេថាអាការៈរបស់ស្នេហាគឺជាអ្វីកើតឡើងដោយសារខួរក្បាល បញ្ជា តែហេតុអ្វីក៏ខួរក្បាលបញ្ជាហើយក៏គ្រប់គ្រងអារម្មណ៍មិនបាន អីចឹង បេះដូងលោតខុសចង្វាក់ទៀតហើយ...អ្នកជឿងបានឮទេនេះ គួរ ឲ្យអៀនខ្លាំងណាស់ តែក៏រំភើប មិនបាន ខ្ញុំបណ្ដោយឲ្យរឿងបែបនេះ កន្លងផុតទៅមិនបានទេ នៅក្នុងពេលដែលគេចុះទុនមកនិយាយហើយ ខ្ញុំក៏គួរតែឈ្លៀវឆ្លាឲ្យចប់ ខ្ញុំគួរតែនិយាយអីជាមួយគេទៅណ៎!

ខណៈដែលខ្ញុំតាំងចិត្តទៅរក កូអ៊ីន ដល់ថ្នាក់ ជើងក៏ត្រូវច្រកពេល ឃើញគេឈរនិយាយជាមួយសិស្សច្បង ណាយេ៉ នៅមុខថ្នាក់ ឫកពា ប៉ះដៃប៉ះជើងគ្នាជិតដិតបែបនោះ ធ្វើឲ្យខ្ញុំត្រូវឈរកៀនជញ្ជាំងដោយ មិនដឹងថាហេតុអីបានជាធ្វើបែបនេះ ។

"បេតនាមិនល្អ"

"សាំយ៉ុង"

ខ្ញុំរហ័សឈរត្រង់ខ្លួនជាស្ទីលគោរពទង់ជាតិ នេះខ្ញុំត្រូវជួបនឹងអា ខ្មោចនេះរហូតឬយ៉ាងម៉េច!

"ម៉ោលួចមើលធ្វើអី មានផែនការក្បត់ឬ"

"ឡប់ ខ្ញុំមិនបានលួច គឺគ្រាន់តែ...មិនដឹងថាលេចមុខទៅធ្វើអី"

"ឈរត្រង់នេះហើយវាបានឮទេ នាងគួររកកន្លែងដែលល្អចមើល និងល្អចស្ដាប់ឲ្យបានច្បាស់ជាងនេះ"

"មិនឈរក៏បាន!"

"ចង់ទៅណា មិនទៅមើលបន្តទេឬថាគូដណ្ដឹងគេធ្វើអីគ្នា"

ក្បាលសីងតែរបូតចេញពីស្មារពេលបានឮពាក្យថា គូដណ្ដឹង នេះជាពាក្យដែលខ្ញុំមិនធ្លាប់ស្រមៃថានឹងបានឮនៅក្នុងជីវិតពិត ក្រៅពីនៅក្នុងកុនដែលអាយុប៉ុណ្ណេះមានគូដណ្ដឹង ខ្លួនខ្ញុំស្លឹកអស់ហើយ ។

"ពីរនាក់នោះជាគូដណ្ដឹងនឹងគ្នាឬ"

"នាងថាគេសមគ្នាទេ"

"ម៉េចក៏ខ្ញុំមិនឃើញដឹងរឿង"

"គឺនាងមិនដែលសួរ ម្យ៉ាងទៀតរឿងរបស់ កូអីន មិនសំខាន់ដល់ថ្នាក់ឲ្យនាងសួររឿងផ្ទាល់ខ្លួនដល់ម្លឹងទេដឹង តែក៏...នៅផ្ទះជាមួយគ្នាហើយមិនដឹងវាដូចជាមិនសម ផ្កា ចង់ទៅណា"

ខ្ញុំដើរចេញមក មានអារម្មណ៍ដូចត្រូវទះកំផ្លៀង នេះខ្ញុំមិនដឹងរឿងដូច សាំយ៉ុង ថាមែនហ្នឹង ថែមទាំងមកអង្គុយយល់សប្ដិខ្យល់ថាខ្ញុំនឹងបានទៅនិយាយជាមួយគេច្បាស់លាស់និងមានអារម្មណ៍រ៉ូមែនទិករួមគ្នាពេលដែលប្រាប់គេថា ខ្ញុំក៏ចូលចិត្តគេដែរ អ្វីបែបនេះ ហើយអាដែលគេនិយាយចោលកាលពីពេលនោះវាជាការនិយាយលេងសើចឬគិតចង់និយាយក៏និយាយអីចឹងឬ ។

ដោយសារថ្ងៃនេះអារម្មណ៍មិនល្អ ទើបខ្ញុំណាត់ សីជីន ចេញមកដើរលេងនៅផ្សារទំនើប នាងប្រមក់នេះពេលដឹងរឿងទាំងអស់ក៏បើកភ្នែកធំៗ ភ្ញាក់ផ្អើល រន្ធត់ ។

"និយាយលេងទេអី កូអីន ប្រាប់ថាចូលចិត្តឯង"

"អឺ"

"ហើយខ្លួនឯងក៏មានគូដណ្ដឹង!"

"អឺ"

"ពួកអ្នកមាននេះគិតចង់លេងកំប្លែងដាក់អ្នកក្រដូចយើងឲ្យដល់ជាតិមុខឬយ៉ាងម៉េចនេះ អាម្សៀ តឹមសាំយ៉ុង ក៏ម្នាក់ដែរ ដែលមកធ្វើ

លេងសើចដាក់ខ្ញុំ សំណាងហើយដែលខ្ញុំមិនប្រាកដប្រជា មិនអ៊ីចឹងមុខដាខូចចិត្តងាប់មិនខាន ឬថាការញៀវស្រីសខ្សាំពិនុជាហ្គេមម៉ូតថ្មីដែលពួកអ្នកមានលេង ដូចជា ចុងកូអ៊ីន ចាញ់ឡានម៉ាគ្រឿងព្រោះតែញៀងង៉មិនបានសម្រេច"

កាន់តែគិត កាន់តែឈឺ ឬខ្ញុំមានគំនិតទុតិដ្ឋិនិយមដូច ស៊ីដីន គេអាចគ្រាន់តែនិយាយដើម្បីឲ្យខ្ញុំរំដើបរំជួល រៀនមិនចូលក៏ថាបានលេងល្បែងបានល្អបំផុត មកធ្វើមុខឈឺចាប់ឲ្យខ្ញុំឈឺចាប់ពេញ១ថ្ងៃ។

"ខ្ញុំចង់សងសឹកគេណាស់ តែខ្ញុំគ្មានអីល្អគ្រប់គ្រាន់ទៅសងសឹកបាន គេទាំងមានជាង ផ្ទះដែលខ្ញុំនៅក៏ជាផ្ទះគេ សាលាដែលខ្ញុំរៀនក៏ជារបស់គេ"

"តែយកមិត្តរបស់គេម៉ោសងសឹកក៏បាន"

"ឯងនិយាយដល់អី"

"គីមសាយ៉ុង នោះអ្វី"

"ទាក់ទងអីនឹងអាម្សៀនោះ"

"តាមស្តាប់ឯងនិយាយ មើលទៅគេដូចជាចាប់អារម្មណ៍នឹងឯងឯងសាកគិតលេងៗទៅមើល៍ បើឯងសងសឹកគេដោយការយកមិត្តគេទៅបណ្តើរនឹងមុខគេ គេនឹងឈឺ អាម៉ាស់មុខជាងចាញ់ឡានស្ព័តមួយនោះទៅទៀត ថែមទាំងឯងបានសមចិត្តដែរ"

"អ្នកដែលនិយាយដល់គឺសង្សារចាស់ផស់ឯងណា៎"

"អ៊ុយ! ខ្ញុំមិនស៊ីរៀសទេ ឯងគិតច្រើនជំនួសខ្ញុំធ្វើអីទៅ ការដែលបានធ្វើឲ្យមនុស្សប្រុសឈឺចាប់គឺចាត់ទុកថាជាការប្រគល់ក្តីសុខឲ្យខ្ញុំហើយ លេងទៅឯង ម៉ាចាស់ដៃទៅ"

"ខ្ញុំធ្វើបែបនេះបានពីអង្កាល់ ម្យ៉ាងទៀត...ខ្ញុំគិតដោយខ្លួនឯងទេថាគេអាចនឹងចូលចិត្តខ្ញុំ បើគេមិនបានចូលចិត្តគឺអាម៉ាស់មុខទទេ អត់ទេ មិនលេងទេ ខ្ញុំខ្លាចអាម៉ាស់មុខជាងស្អីទាំងអស់នៅលើលោកនេះ"

"ឯងនេះមិនជឿខ្សែភ្នែកឥន្ទ្រីយរបស់ខ្ញុំ...អ៊ុយ ខ្សែភ្នែកធ្វើការ"

"វាបីឯង"

"នោះជាម៉ាក់ឯងតើ"

ខ្ញុំងាកទៅមើលតាមសម្ដីរបស់ សីដីន ហើយក៏ត្រូវស្រឡាំងកាំង ពេលឃើញថាម៉ាក់ខ្លួនឯងអង្គុយនៅក្នុងហាងអាហារអ៊ីរ៉ុបនៅទល់មុខ ជាមួយបុរសម្នាក់ មើលឫកពាដូចជាជិតដិតគ្នា រហូតដល់ខ្ញុំត្រូវមើល ម្ដងទៀតព្រោះមិនច្បាស់ថាអ៊ំប្រុស អច្ឆរិយៈ ឬអត់ ។

"ម្នាក់ហ្នឹងមែនជាទេជាប៉ា កូអ៊ីន"

"មិនមែនទេ"

"ម៉ាក់ឯងមានមិត្តច្រើនណាស់ណាំ មើលឫកពាដូចជាជិតដិត គ្នា មិនទៅរាក់ទាក់បន្តិចទេអ្ហ៎ស"

សីដីន សួរបែបមិនដឹងខ្យល់អី ព្រោះមិនធ្លាប់ឃើញមុខប៉ា កូអ៊ីន តែខ្ញុំបែរជាឈរស្ងៀម ហើយមើលកាយវិការរបស់ម៉ាក់និងប្រុសម្នាក់ នោះដោយការសង្ស័យ ។

"មិនទេ"

"ហេតុអី"

"បណ្ដោយទៅ គាត់នៅជាមួយមិត្តគាត់ ខ្ញុំនៅជាមួយមិត្តខ្ញុំ"

"អី មែន ខ្ញុំក៏ធ្វើអីមិនត្រូវដែរពេលនៅមុខមនុស្សចាស់ អីចឹងទៅ រកញ៉ាំអីទៅយើង"

ខ្ញុំញញឹមនឿយណាយ ហើយដើរតាម សីដីន តែមិនភ្លេចងាក ទៅមើលម៉ាក់ម្ដងទៀតដោយអារម្មណ៍មិនសូវស្រួល...អ្នកណាគេទៅ ប្រុសម្នាក់នោះជាអ្នកណា?

នៅផ្ទះ...

ហេតុការណ៍ពីព្រឹកគិតថាអាក្រក់ហើយ ពេលល្ងាចដែលត្រូវ ត្រលប់មកផ្ទះជួបមុខគ្នាក៏កាន់តែអាក្រក់ ខ្ញុំ និង កូអ៊ីន មិនមើលមុខ គ្នា មិននិយាយគ្នាពេលអង្គុយញ៉ាំបាយ មានតែម៉ាក់ និង អ៊ំប្រុសដែល និយាយគ្នាពីនេះពីនោះ ។

"ខ្ញុំចង់ទៅដើរលេងនៅបរទេសមើលម្ដង បែបល្អមិនស្មើរទេ"

"អូនមិនធ្លាប់ទៅបរទេសទេអ្ហ៎ស"

"មិនទេ អីយ៉ា...បងក៏ដឹងថាអូនត្រូវរកលុយចិញ្ចឹមកូន សង្ឃឹម

លុយតែប៉ុន្មានសិបរ៉ុនម៉េចនឹងអាចទិញសំបុត្រយន្តហោះបានទៅ"

"បើអូនចង់ ចាំបងជូន"

"មែនអេ្ហ៎ស អស្ចារ្យខ្លាំងណាស់"

ម៉ាក់សប្បាយចិត្ត ហើយងាកមកសួរខ្ញុំឱ្យពព្រាយ÷

"ទៅជាមួយម៉ាក់ទេ តាំងពីកើតម៉ោមិនធ្លាប់ជិះយន្តហោះផង"

"ហឺស" កូអ៊ីន ទម្លាក់ស្លាបព្រាក្នុងចាន ហើយងើបដើរចេញទៅបែបមិនក្រែងចិត្ត "ថោក"

ត្រឹមពាក្យមួយម៉ាត់ខ្លីៗ តែក៏ចាក់ដោតចិត្តខ្ញុំយ៉ាងខ្លាំង ខ្ញុំមានអារម្មណ៍ខ្មាសអៀនណាស់ដែលត្រូវគេប្រមាថដោយពាក្យបែបនោះ ទោះជាដឹងថាគេមិនបាននិយាយដាក់ក៏ដោយ ។

"អាកូនចង្រៃ ម៉ោវិញភ្លាម ឯងថាឱ្យអ្នកណាថោក!" អ៊ំប្រុស ។

ម៉ាក់តាមមើល កូអ៊ីន ហើយក្ដាប់ដៃណែនដោយកំហឹង តែមុខនៅតែប្រឹងញញឹមដាក់អ៊ំប្រុស ធ្វើជាម្ដាយចុងពេញទៅដោយក្ដីមេត្តាសឹងតែមានរស្មីចែងចាំងភ្លឹបភ្លែតលើក្បាលដូចទេពធីតាទៅហើយ ។

"មិនអីទេបង អូនស៊ាំទៅហើយ"

"ឱ្យបងសុំទោសផង ចាំបងទៅនិយាយជាមួយវាឱ្យ"

អ៊ំប្រុសងើប ដើរទៅតាម កូអ៊ីន ខ្ញុំមើលតាមពីក្រោយដោយការព្រួយបារម្ភពី កូអ៊ីន ដោយប្រាប់មិនត្រូវ តែខ្ញុំគិតឃើញថាពេលនេះជាឱកាសល្អហើយដែលខ្ញុំបាននិយាយជាមួយម៉ាក់ ។

"បើមានកាំភ្លើងម៉ាក់នឹងបាញ់បំបែកក្បាលវាហើយ!"

"រឿងនោះបណ្ដោយឱ្យប៉ាគេចាត់ការទៅ"

"នេះឯងកើតអីម្នាក់ទៀតហើយ វាជាសត្រូវរបស់ម៉ាក់ តែឯងធ្វើព្រងើយកន្តើយ ធ្វើដូចអ្វីដែលវាធ្វើគឺជារឿងត្រឹមត្រូវ"

"យើងម៉ោក្រោយគេ"

"ហើយវាម៉េច ម៉ាក់រៀបការជាមួយឪវាណាំ"

"គេក៏មើលដឹងថាម៉ាក់មិនបានស្រលាញ់ប៉ាគេមែនទែនដែរ"

"ឯងនិយាយស្អី" ម៉ាក់បញ្ចេញចង្កូមប្រកេទដែលថាបើអាចពន្លាត់ស្បែកក្បាលខ្ញុំបាន គាត់ធ្វើទៅហើយ "បើប្ដីម៉ាក់បានឮ គេនឹង

មានអារម្មណ៍យ៉ាងម៉េច"

"ថ្ងៃនេះម៉ាក់ទៅណា"

"ស្អី គឺម៉ាក់ទៅសបភីងតាមប្រភេទអ្នកមាន ចូតកាតប៉ុន្មានដង ក៏មិនលេះអស់ដែរ"

"អីចឹងខ្ញុំសួរម៉ាក់មួយទៀត ថ្ងៃនេះម៉ាក់ទៅជាមួយអ្នកណា"

ពេលជួបសំនួរថ្មី ម៉ាក់ក្លាយជាគោដំបៅខ្ទង់ក្បាលដោយអាការៈរអើល។ ហើយតបដោយសម្លេងរអាក់រអួល៖

"ឯ...ឯងចង់មានន័យថាម៉េច ម៉ាក់ទៅតែម្នាក់ឯងទេ"

"ថ្ងៃនេះខ្ញុំឃើញម៉ាក់អង្គុយពិសាចាយជាមួយមនុស្សប្រុស អ៊ុំប!"

ម៉ាក់ហាសលូកដៃមកបិទមាត់ខ្ញុំ ហើយទាញច្រងស្តាំដោយឬកពាប្រយ័ត្នប្រយែង៖

"ឈប់និយាយក្លាម ឈប់! មិនថាឯងបានឃើញស្អីទេថ្ងៃនេះ ខ្ញុំបញ្ជាឲ្យឯងបិទមាត់ ហើយហាមគិតដល់វាទៀត"

ខ្ញុំទាញដៃម៉ាក់ចេញ ហើយមើលមុខបែបរករឿង៖

"អីចឹងប្រែថាវាច្បាស់ជាមានអីច្រើនជាងទៅពិសាចាយហើយមែនទេ ទើបម៉ាក់ខ្លាចយ៉ាងនេះ"

"បើមិនឈប់និយាយ ម៉ាក់នឹងទះមាត់ឯង!"

ចង្វាក់ដែលម៉ាក់យារដៃឡើង កូអឹន ក៏រត់ចុះជណ្តើរដោយមានអាវក្រៅបម្រុងចេញទៅក្រៅ មើលមកខ្ញុំនិងម៉ាក់បែបមិនយល់ ចេញពីកំពុងរត់ដូចគេចពីអ្នកណា មកជាឈប់ច្រឹងសម្លឹងមុខម៉ាក់ ។

"ចង់ធ្វើអី"

"ម៉ែកូនទូន្មានគ្នា" ម៉ាក់ ។

"តែខ្ញុំឃើញនាងយារដៃទះកំផ្លៀង"

"យើងនិយាយគ្នាមិនទាន់ចប់ទេ កូអឹន...អ្ហា មានអីទៀតអត់"

អាប្រុសដែលរត់តាមមកក៏ឈប់ស្ងៀម មើលមកគ្រប់គ្នាដោយការសង្ស័យ ។

"នាងកើតអីអត់" កូអឹន សួរខ្ញុំ ។

"អត់ទេ"

"ប្រាកដ?"

"អ្ហឹម"

"តាមចិត្ត!"

កូអ៊ីន មើលខ្ញុំម្តងទៀត ហើយដើរចេញទៅក្រៅផ្ទះយ៉ាងលឿន ដោយមានអ៊ំប្រុសតាមទៅជាប់ៗ ឯម៉ាក់ក៏ងាកមករកខ្ញុំ ហើយចង្អុលមុខជាការគំរាម÷

"ម៉ាក់បញ្ជា ហាមនិយាយរឿងនេះទៀត មិនថាម៉ាក់ទៅណាជាមួយអ្នកណា ឯងជាកូន គ្មានសិទ្ធិសួរអីទាំងអស់"

"ចុះខ្ញុំមានសិទ្ធិធ្វើអីខ្លះ"

"ក្រៅពីងាប់ គឺគ្មានសិទ្ធិធ្វើអីទាំងអស់"

"អីចឹងខ្ញុំក៏ចង់ងាប់ដែរ មានឪក៏ដូចជាគ្មាន មានម៉ែក៏ដូចជាអត់"

"ចុះម៉ាក់មិនមែនជាម៉ាក់របស់ឯងទេឬយ៉ាងម៉េច ចង់ទៅណាឈប់ភ្លាម!"

ខ្ញុំរត់ចេញមកក្រៅ ពេលឃើញ កូអ៊ីន បញ្ឆេះឡាន ក៏រត់ទៅពាំងមុខ ធ្វើឱ្យគេជាន់ហ្វ្រាំងឡើងផ្កាប់មុខខ្លួនឯង ។

"ធ្វើច្កួតស្អីនាង"

"សុំទៅដែរ"

"ហ៊ា?"

"ខ្ញុំសុំទៅដែរ!"

កូអ៊ីន មើលមុខខ្ញុំប្រហែលពីវិនាទី ហើយងក់ក្បាល÷

"អីចឹងចាប់ឡើងម៉ោ"

"ឈប់ទាំងពីរនាក់ភ្លាម អាអ៊ីន ប៉ាប្រាប់ថាឱ្យឈប់!"

ពេលខ្ញុំលោតឡើងឡានបាន កូអ៊ីន ក៏បើកចេញទៅយ៉ាងលឿនបែបមិនគិតពីជីវិត មិនថាអ៊ំប្រុសបញ្ជាឱ្យមនុស្សទៅពាំងផ្លូវយ៉ាងណា តែគ្រប់គ្នាក៏រត់ព្រាតព្រោះខ្លាចងាប់ជាងខ្លាចបញ្ជា ។

"ប្រាប់ម៉ោថានាងចង់ទៅណា"

"ទៅណាក៏បាន...ទៅងាប់កាន់តែល្អ"

១៣

យើងជិះឡានចេញមកដោយមិនដឹងថាទៅណា ទើប កូអ៊ីន ចតឡានអែបផ្លូវ ហើយនាំដើរឡើងស្ពានយោលទៅមើលទឹកអាងក្នុងសួនសាធារណៈ ។

"គ្រាន់បើខ្លះទេ"

"ហឹ? គ្រាន់ទេដឹង"

"ម៉េចក៏ម៉ាក់នាងចង់ទះនាង"

"វាជារឿងធម្មតាដែលឪម៉ែប្រដៅកូន"

"សម្រាប់ខ្ញុំមិនមែនរឿងធម្មតាទេ នាងធំធាត់ដោយការចិញ្ចឹមបែបណា តាមដែលចាំបាន ម៉ាក់មិនដែលវ៉ៃខ្ញុំម៉ាចាប់ទេ មិនថាខ្ញុំខូចប៉ុណ្ណា"

"មនុស្សយើងកើតនៅកន្លែងខុសគ្នា ចិញ្ចឹមបែណាក៏ដោយ ធំឡើងក្លាយជាមនុស្សល្អទៅគឺគ្រប់គ្រាន់ហើយ តែថាលោកក៏មានរឿងតានតឹងដែរមិនមែនឬ មិនបាច់ចាប់អារម្មណ៍ខ្ញុំទេ"

"ខ្ញុំមិនបានតានតឹង គ្រាន់តែមិនចង់នៅផ្ទះមើលមុខម៉ាក់នាង"

"ពេលណាដែលលោកមិនឃើញមុខម៉ាក់ គឺមានន័យថាលោកក៏មិនឃើញមុខខ្ញុំដែរ"

ខ្ញុំនិយាយតាមការពិតដែលវាអាចនឹងត្រូវកើតឡើង ហើយខ្ញុំក៏មានប្រផ្នូលថានៅផ្ទះគេមិនបានយូរទៀតទេ ព្រោះម៉ាក់ចាប់ផ្ដើមធ្វើខ្លួនផ្ដេសផ្ដាស ការដែលម៉ាក់មិនព្រមប្រាប់ខ្ញុំឲ្យច្បាស់ថាប្រុសម្នាក់នោះជាអ្នកណា ទើបខ្ញុំប្រាប់បានថាវាជារឿងខុសប្រក្រតីនិងមានរឿងមិនល្អកើតឡើងដែលកំពុងខ្លាចនេះហើយ ។

"ចាំខ្ញុំមិនចិត្តអាក្រក់ទេ ទោះម៉ាក់នាងមិនទៅ នាងក៏នៅបាន"

"និយាយលេងច្រើនមែន ខ្ញុំមិនមែនជាកូនគាត់ផង"

"គាត់ដេញនាងធ្វើអី ម៉ាក់នាងស្លាប់ដោយខ្លួនឯង"

"ម៉ាក់ខ្ញុំមិនទាន់ស្លាប់ទេ!"

"អ្ហា នាងមិនបាននិយាយពីអនាគតថាបើម៉ាក់នាងស្លាប់ទៅ នាងនឹងនៅយ៉ាងម៉េចទេឬ អីចឹងនាងចង់មានន័យដល់អី"

មានអារម្មណ៍ថាដូចត្រូវព្រិលធ្លាក់ចូលមាត់ ហើយរលាយជន់ទឹកពេញនោះ ធ្វើឱ្យខ្ញុំអាក់អួល ទើបច្នៃច្នាប្តូររឿង ។

"ថាតែលោកទៅ ព្រមនិយាយគ្នាស្រួលបួលហើយអ្ហ៎ស"

ពេលនិយាយចប់ ក៏សឹងតែយកដៃទះមុខខ្លួនឯង ព្រោះមើលទៅកូអឹន ដូចទើបនឹងដឹងខ្លួន ទើបថយក្រោយពីជំហានបែបតាំងជំហរ។

"អី សុំទោស ខ្ញុំគ្រាន់តែនិយាយលេងទេ"

"រឿងថ្ងៃនេះ"

"អាំហ៊ាំ"

ដូរពីការទះមុខមកបើបដៃខ្លួនឯងថ្នមៗវិញល្អជាង ការដែលបាននិយាយជាមួយគេពីរឿងនេះ ធ្វើឱ្យខ្ញុំសឹងតែភ្លេចរឿងម៉ាក់អស់រលីង ក៏ល្អដូចគ្នា និយាយទៅ ខ្ញុំនឹងបានដឹងថាគេមានអារម្មណ៍យ៉ាងម៉េច ទើបពេលនេះខ្ញុំសម្លឹងមុខគេដោយពន្លឺភ្នែកភ្លឹបភ្លែត ។

"ខ្ញុំចង់ឱ្យនាងបំភ្លេចវាទៅ"

"ហ៊ឺ?"

"ខ្ញុំនិយាយលេងទេ ហាៗ" កូអឹន វាយដៃខ្ញុំតិចៗ ហើយសើចដូចមនុស្សឆ្កួត "ខ្ញុំឃើញមុខនាងពេលបានឮថាខ្ញុំចូលចិត្តឡើងស្លេ ថ្នាក់ខ្ញុំធ្វើជាបែរខ្លួនដើរចេញហើយក៏នាងនៅតែឈរធ្មឹងដដែល សង្ស័យតែស្លុតណាស់ហើយមើលទៅ"

"និយាយលេង...ឬ"

ដូចជាមានដុំអ្វីម្យ៉ាងមកបុកទ្រូង-ក ក៏មិនបានមានសង្ឃឹមនិងបានត្រៀមចិត្តទុកហើយ តែមិនគិតថា...វាជារឿងកំប្លែងសម្រាប់គេនោះទេ ។

"នេះនាងបែបមិនបានគិតថាខ្ញុំច្រាកដប្រដាស្អីបែបនោះទេ មែនទេ ហេ៎ នាងខ្លប់ទេអ្វី ខ្ញុំនៅផ្ទះជាមួយនាង ឪម៉ែយើងនៅជាមួយគ្នា បើខ្ញុំនិងនាងស្រលាញ់គ្នាគឺច្បាស់ជាក្តៅក្រហាយហើយ ម្យ៉ាងទៀត ខ្ញុំក៏មានគូដណ្តឹងដែរ"

"សិស្សច្បង ណាយ៉េ ឬ"

"នាងដឹងដែរ អ្ហ៎...ប្រហែលជា សាំយ៉ុង ប្រាប់ហើយ"

"អ្ហឹម មុននេះខ្ញុំក៏ធ្លាប់ឃើញលោកទៅណាមកណាជាមួយនាងដែរ ពេលដឹងថាជាគូដណ្តឹងទើបមិនចម្លែកចិត្ត តែរន្ធត់ចិត្តដែលមកដឹងនៅពេលក្រោយអ្វីបែបនេះ"

"អីប៊ីងយើងឈ្លោះគ្នានៅត្រង់នេះចុះ តទៅនិយាយគ្នាដូចធម្មតា មិនធ្វើឬកពាខឹងរមាំងរមោក ព្រោះយើងត្រូវនៅជាមួយគ្នាយូរទៀត ខ្ញុំមិនបានចូលចិត្តនាងទេ អូខេ?"

"..."

"ម៉េចមិនឆ្លើយស្អីអីប៊ីង ឬនាងមិនអូខេ នាងចូលចិត្តខ្ញុំ?"

មែន!!! នេះគឺជាចម្លើយដែលលាន់នៅក្នុងចិត្តខ្ញុំប៉ុណ្ណោះ ។

"ម៉េចក៏នាងមិនឆ្លើយ"

ប៉ុក!

ខ្ញុំក្តាប់ដៃណែន ហើយដាល់ដៃគេមិនជាខ្លាំងប៉ុន្មាន ព្រមទាំងញញឹម÷

"លោកធ្វើឲ្យខ្ញុំស៊ីរៀសពេញម៉ាថ្ងៃ"

"..."

"គឺគិតហើយថាមនុស្សដូចលោកម៉េចនឹងអាចមកចូលចិត្តខ្ញុំទៅព្រោះមិនត្រឹមតែមានទេ ថែមទាំងមុខមាត់ស្អាតទៀត"

"វាជាពាក្យស្លោកប្រចាំខ្លួនរបស់ខ្ញុំទេ!"

"ម្យ៉ាងទៀតយើងនៅផ្ទះជាមួយគ្នា ឪម៉ែយើងក៏រៀបការជាមួយគ្នា បើយើងចូលចិត្តគ្នា ស្រលាញ់គ្នាមែន ហើយថ្ងៃមួយយើងក៏លែងគ្នា គ្រប់គ្នានឹងពិបាកចិត្ត ឪម៉ែយើងច្បាស់ជាមិនព្រមទេ"

"អ្ហឹម" កូអ៊ីន តបខ្លីៗ ហើយងាកទៅផ្សេង "យល់អីប៊ីងដែរ"

"បានឮអីចឹងហើយក៏ធូរទ្រូង ចាប់ពីពេលនេះទៅយើងជាមិត្តនឹងគ្នា ជាបងប្អូន យើងមិនត្រូវឈ្លោះគ្នាទេ"

ខ្ញុំលូកដៃទៅសេកហោនដី កូអ៊ីន មើលមុខខ្ញុំ ហើយក៏វាសចេញតិចៗ ព្រមទាំងអេះ~កបែបខ្មាសៗ ឬធ្វើអីមិនត្រូវទំនងនោះ ។

"ម៉េចចាំបាច់ធ្វើពិធីដែរ គឺគ្រាន់តែដឹងថាយើងជាមិត្តនឹងគ្នាទៅបានហើយ តែធ្វើល្អដាក់នាងមិនបានមានន័យថាខ្ញុំនឹងធ្វើល្អដាក់ម៉ាក់នាងទេ"

"អ៊ឹម ខ្ញុំយល់"

"អីចឹងយើងនៅទីនេះម៉ាសន្ទុះទៀតទៅ ចាំទៅផ្ទះ"

កូអ៊ីន ដើរទៅម្ខាងទៀតយ៉ាងលឿន ទុកឲ្យខ្ញុំនៅម្នាក់ឯង ពេលប្រាកដចិត្តថាគេដើរទៅឆ្ងាយហើយ ខ្ញុំក៏យំហ៊ូដូចមនុស្សឆ្កួត អាមនុស្សអាក្រក់ មកធ្វើឲ្យខ្ញុំមានសង្ឃឹមធ្វើអី គិតចង់និយាយអីក៏និយាយបានអីចឹងឬ!

"ខ្ញុំនឹងមិនស្រលាញ់លោកទៀតទេ ចុងកូអ៊ីន មិនស្រលាញ់ទេ!"

ទោះជាត្រលប់មកដល់ផ្ទះហើយក៏ដោយ ក៏ខ្ញុំនៅតែយំមិនឈប់នៅក្នុងយប់ដ៏សែនយោរយៅនេះ ។

ការខូចចិត្តដែលមិនអាចកាត់បន្ថយបាន ធ្វើឲ្យខ្ញុំក្លាយជាមនុស្សស្ងាត់ស្ងៀម គ្មានអ្វីទុក្ខចិត្តជាងការដែលខ្លួនឯងខូចចិត្តតែត្រូវបង្ខំចិត្តញញឹមចេញ ហើយនោះហើយដែលកាន់តែបង្ខំឲ្យខ្ញុំចង់ចេញពីផ្ទះនេះឲ្យបានចាប់ តែថា...ប៉ានៅតែមិនទាន់មកវិញ ។

"ញ៉ាំនំទេនាង"

នៅសុខៗអ៊ំស្រីអ្នកជិតខាងក៏ចេញមកដោយកាន់នំមកជាមួយផង ទឹកចិត្តរបស់អ៊ំស្រីធ្វើឲ្យខ្ញុំរំភើប ទើបឱនគោរពជាការអរគុណ ។

"ចាំ មិនអីទេ មិនឃើញចាំបាច់លំបាកទេអ៊ំស្រី"

"ខ្ញុំឃើញនាងម៉ោទីនេះរាល់ថ្ងៃ តើទៅប៉ាមិនចូលឬ"

"ខ្ញុំគ្មានលេខប៉ាទេ តែថាអ៊ំស្រីប្រាកដហើយផ្អើសថាប៉ាមិនបានដូរផ្ទះទៅណា"

"ប្រាកដណាស់ មុនទៅគេបានផ្ដាំខ្ញុំឱ្យមើលផ្ទះ ពេលនោះខ្ញុំគួរតែសួរគេបន្តិចថាម៉ោពេលណា ញ៉ាំតាមសប្បាយចុះ"

"ចាំ"

ពេលអ៊ំស្រីចូលទៅក្នុងផ្ទះវិញ ខ្ញុំក៏ដើរទៅរក សាំយ៉ុង ដែលឈរពួនទៅក្រោយបង្គោលភ្លើង ធ្វើមើលតែខ្លួនគេតូចប៉ុនអាចម៍សុច ។

"យកទៅញ៉ាំទៅ ឃើញមកពួនត្រង់នេះម៉ាសន្ធុះហើយ"

សាំយ៉ុង ចេញពីក្រោយបង្គោលភ្លើងយឺតៗ តែក៏នៅធ្វើមុខជាប់គ្មានអារម្មណ៍អ្វី ។

"អរគុណ"

"កើតរោគចិត្តឬ" ខ្ញុំមើលគេ ហើយជ្រិមភ្នែក "ទំនេរណាស់ឬក៏ម៉េច បានជាម៉ោដើរតាមខ្ញុំត្រុកៗ ព្រមជិះឡានក្រុង ហើយក៏ម៉ោពួននៅម្ដុំនេះ ឱ្យអ្នកមាន"

"ណាគេតាមនាង អត់ទេ!"

"ធ្វើសម្លេងបែបនេះ ច្បាស់ជាតាមហើយ ខ្ញុំថាលោកគួរតែទៅរកស្ដីធ្វើដែលរាល្អជាងនេះទៅ កុំម៉ោរវល់នឹងខ្ញុំ"

"នែ៎" សាំយ៉ុង ចាប់ចង្កាខ្ញុំបង្វែរទៅមក "មួយរយៈនេះមើលទៅនាងដូចជាសោកសៅណាស់ កើតអីអត់"

"អត់ទេ"

"មានន័យជានិច្ចអាពាក្យថា អត់ទេ នេ៎ះ ហើយក៏មិនមែនមានតែនាងដែលមានអាការៈបែបនេះ កូអ៊ីន ក៏មើលទៅស្ងៀមៗអីចឹងដែរឈ្លោះគ្នាស្អីទៀតហើយ"

"ចុះម៉េចក៏លោកមិនដើរតាម កូអ៊ីន ម៉ោដើរតាមខ្ញុំដែលមិនមែនសូម្បីតែមិត្តភក្តិធ្វើអី"

"ព្រោះអាម្សៀនោះមានអ្នកចាំដើរតាមហើយ"

សម្ដីមិនបានតាំងចិត្តរបស់ សាំយ៉ុង ធ្វើឱ្យខ្ញុំមានអារម្មណ៍ថាបុកហាក់ដូចជាមានកាំបិតជាង ១០០មកចាក់ចំបេះដូង មានអារម្មណ៍ថាទន់ជើងភ្លាម ធ្វើឱ្យ សាំយ៉ុង ស្ទុះចូលមកទប់ តែត្រូវខ្ញុំវាសចេញ ។

"មិនបាច់ ខ្ញុំមិនអីទេ"

"ម៉េចក៏នាងធ្វើឫកបែបនោះ វាមិនឃើញចម្លែកត្រង់ណាដែល កូអីន ទៅណាមកណាជាមួយ ណាយ៉ែ ទេ ពួកគេជាគូដណ្ដឹងនឹងគ្នា"

"បានហើយ!"

"នាងចូលចិត្តវា"

"ខ្ញុំប្រាប់ថាបានហើយ!"

"មានរឿងកើតឡើងរវាងអ្នកទាំងពីរមែនទេ ទើបដល់ថ្នាក់មានសភាពយ៉ាប់បែបនេះ"

"បើមិនឈប់ អីចឹងខ្ញុំនឹងដើរចេញ"

ខ្ញុំដើរគេច តែ សាំយ៉ុង នៅតែដើរតាមមករករឿងមិនឈប់។

"កូអីន ចាប់អារម្មណ៍នាងវាមិនចម្លែកទេ តែនាងចាប់អារម្មណ៍វាផ្ទេះវាខុសពីការគិតរបស់ខ្ញុំខ្លាំងណាស់ តាំងពីអង្កាល់ វាកើតឡើងបានយ៉ាងម៉េច"

"វាកើតឡើងតាំងពីតំបូង គ្រាន់តែជួបគេលើកតំបូងក៏លង់ស្នេហ៍គេទៅហើយ"

"..."

"ការបានជួបគេម្ដងទៀត សម្រាប់ខ្ញុំគឺដូចព្រហ្មលិខិត ព្រោះភាពចៃដន្យជួបគ្នាញឹកពេក ធ្វើឲ្យខ្ញុំជឿថា ជួនកាលយើងអាចមានរាសីត្រូវគ្នា ហើយថ្ងៃមុនគេប្រាប់ថាចូលចិត្តខ្ញុំ គេប្រាប់ថាចូលចិត្តខ្ញុំបានឮទេ"

"..."

"តែហើយគេបែរជាក្រឡាស់សម្ដីថាគេលេងសើច ដែលនិយាយទៅនោះគឺគេគ្រាន់តែចង់បោកបុំណ្ណោះថាខ្ញុំនឹងមានអាការៈបែបម៉េច ចាំម៉ាក់យើងរៀបការជាមួយគ្នា មជ្ឈដ្ឋានមិនសមប្រកបចំពោះយើងទេ គេក៏មានគូដណ្ដឹង ដូច្នោះហើយយើងធ្វើជាមិត្តនឹងគ្នាបន្តទៅ គេនិយាយចេញមកបានយ៉ាងម៉េច ជាមិត្ត!"

"ជុងអ៊ីល" សាំយ៉ុង ហៅឈ្មោះជាផ្លូវការរបស់ខ្ញុំជាលើកតំបូង។

"ខ្ញុំឈឺ គេមិនដឹងឡើយថាខ្ញុំឈឺ"

"ខ្ញុំដឹងតើ"

"ហើយនឹងមានន័យអ្វីទៅ!"

មិនទាន់បានតាំងខ្លួន សាំយ៉ុង ទាញខ្ញុំទៅឱប ធ្វើឱ្យមុខខ្ញុំជ្រុបនឹងដើមទ្រូងរបស់គេសឹងតែដកដង្ហើមមិនចេញ មិនថាខំរើយ៉ាងណាក៏គេនៅតែឱបខ្ញុំណែនដៃដដែល មិនព្រមលែង រហូតដល់ខ្ញុំហត់នឿយនឹងការជំទាស់ ។

"គឺមិនដឹងទេ ជួនកាលរបស់ដែលអ្នកផ្សេងមើលឃើញថាគ្មានតម្លៃ ទើបវាជាអ្វីដែលយើងចង់ធ្វើ ដូចជាការឱបនាងជាប់បែបនេះនិងយល់ពីនាង"

ជាគេទៀតហើយដែលចាំនៅជាមួយខ្ញុំនៅក្នុងពេលបែបនេះ ទើបខ្ញុំឱបគេវិញ ហើយយំដូចកូនក្មេង ។

"លោកចូលចិត្តខ្ញុំ"

"..."

"ចាំមើលលោកនឹងខូចចិត្ត"

"គិតទៅថាខ្ញុំធ្វើឱ្យស្រីផ្សេងខូចចិត្តអស់ម៉ាគំនរទៅបានហើយ"

១៤

រឿងមកបញ្ចប់បែបនេះបានយ៉ាងម៉េច សាំយ៉ុង និង ខ្ញុំអង្គុយញ៉ាំការ៉េមជាមួយគ្នាបន្ទាប់ពីខ្ញុំយំសសឹកក្នុងដើមទ្រូងរបស់គេ ពេលមកនឹកដល់អ្វីដែលកើតឡើងហើយ...ភាពខ្មាសអៀនក៏ជ្រែកចូលមកគ្រប់រន្ធរោមរហូតដល់មិនហ៊ានប្រសព្វភ្នែកគេ ក្រៅពីធ្វើជាដួសការ៉េមដែលរលាយសល់តែទឹកមកញ៉ាំបន្លប់ ។

"នាំមកញ៉ាំអាយស្ក្រីមឱ្យចិត្តត្រជាក់ហើយម៉េចធ្វើឱ្យបរិយាកាសកាន់តែយ៉ាប់" សាំយ៉ុង សួរដោយស្នាមញញឹមដូចដឹងថាខ្ញុំកំពុងគិតអ្វីទើបខ្ញុំដើបអង្គុយត្រង់ខ្លួន ។

"ខ្ញុំធ្វើអី គ្រាន់តែដួសអាយស្ក្រីមលេង គឺវាគ្មានអីឱ្យនិយាយ ម៉េចក៏លោកមិនបបួលខ្ញុំនិយាយ"

"អីចឹងខ្ញុំបបួលនិយាយក៏បាន យកប្រធានបទ...យើងសេពគប់គ្នាទៅល្អទេ"

"លោកចង់ងាប់ក្អេស!"

"គឺនាងឱ្យខ្ញុំបបួលនិយាយតើ"

គេសើចដោយការចូលចិត្តពេលឃើញខ្ញុំប្រយ័ត្នប្រយែងជាងមុនងាប់ហើយ! ខ្ញុំខុសខ្លួនឯងដែលឱ្យគេចេញប្រធានបទសន្ទនា គឺអ្នកណាទៅគិតទៅថាមានអ្នកហ៊ាននិយាយ ហ៊ានបាន ហ៊ានអត់ ហ៊ាន ...គ្រប់យ៉ាងអ្វីបែបនេះ ។

"ម៉េចក៏ចូលចិត្តខ្ញុំ"

មើលទៅវាដូចជាសំនួរដែល សាំយ៉ុង មិនបានត្រៀមចិត្តទុកឆ្លើយ ព្រោះខ្ញុំឃើញភ្នែកពណ៌ខ្មៅរបស់គេរីកធំដោយការភ្ញាក់ផ្អើល

(សង្កេតដល់ថ្នាក់នោះផង) តែព្រោះគេជាមនុស្សដែលប៉ិនលាក់អាការៈបានល្អមហាសាលជាង កូអីន ទើបរហ័សបន្លប់ដោយការញាក់ស្មា ហើយយកចង្កាកើយដៃ សម្លឹងមុខខ្ញុំ ។

"ព្រោះតាំងពីស៊ុស្រីបាន..."

"ហឺ?"

"អឺ...ខ្ញុំមានន័យដល់តាំងពីបានសេពគប់ស្រីៗម៉េា មិនធ្លាប់មានអ្នកណាធ្វើឫកពាស្អប់ខ្ពើមមិនចង់រាប់អានខ្ញុំជាមិត្ត ឬ ដើរគេចខ្ញុំរាល់ពេលដែលជួបមុខដូចជានាងទេ"

"ហេតុផលតូចតាចសម្បើមណាស់ ព្រោះមើលតាមរយៈការធ្វើខ្លួនជាពួករោគចិត្តដើរតាមខ្ញុំទៅផ្ទះរាល់ថ្ងៃ ម៉េាចាំនៅត្រង់បង្គោលភ្លើងដែលមានថ្កៅឈរនោមស្អីបែបនេះ មិនគួរណាធ្វើអីបានដល់ថ្នាក់នេះទេ"

"ខ្ញុំធ្លាប់ជួបតែស្រីចិត្តងាយ ហើយនាងគួរឲ្យចាប់អារម្មណ៍"

គិតថាញាក់ភ្នែកហើយមើលទៅសង្ហាឬយ៉ាងម៉េច...អឺ! មើលទៅសង្ហាពិតមែន!

"ខ្ញុំគួរឲ្យចាប់អារម្មណ៍យ៉ាងម៉េច"

"នាងគឺជាអ្នកដែលខ្ញុំជួបដោយមិនបានស្រមៃដល់ ទោះមិនស្មើនឹង កូអីន ក៏ដោយ តែដូចជាថា...នាងម៉េាជួបខ្ញុំនៅក្នុងបារ ហើយខ្ញុំក៏បែជន្យជួបនាងនៅសាលា ហើយកាន់តែជាងនោះ នាងម៉េាក្លាយជាបងប្អូនឪពុកម្ដាយទីទៃនឹងមិត្តជិតដិតរបស់ខ្ញុំទៀត"

"មិនឃើញបែជន្យត្រង់ណាផង អាតំបូងទៅបារនោះគឺមកពីមិត្តកក្កិបបួលទៅ អាទីពីរខ្ញុំត្រូវបញ្ជូនឲ្យទៅរៀននៅទីនេះស្រាប់ទៅហើយ ហើយក៏មិនបានតាំងចិត្តទៅជួបលោកទៀតផង"

"មិនថានាងមើលឃើញថាម៉េច តែខ្ញុំចាត់ទុកវាជាហេតុការណ៍ល្អៗដែលធ្វើឲ្យខ្ញុំបានជួបនាង បានស្គាល់នាង បានឃើញនាងនៅផ្នែកដែលរឹងមាំបំផុតនិងផ្នែកដែលទន់ជ្រាយបំផុត ធម្មតាខ្ញុំសេពគប់ស្រីតែមួយចាវ ខ្ញុំមិនដែលស្គាល់អ្នកណាបានច្រើនដូចស្គាល់នាងទេ"

"និយាយដល់ថ្នាក់នេះម៉េចមិនសុំរៀបការតែម្ដងទៅ"

"យកចិញ្ចៀនពេជ្របុ៉ន្មានការ៉ាត់"

"សុំទៅគិតមើលសិន"

"ប្រែថានឹងរៀបការជាមួយខ្ញុំមែនទែនផ្អេស"

"ម៉េចក៏លោកចូលចិត្តធ្វើឱ្យខ្ញុំធ្លាក់ទៅនិយាយរឿងផ្សេងជារឿយៗ ស្រីអស់នោះលង់ស្នេហ៍លោកបានយ៉ាងម៉េចនេះ ខ្ញុំមិនយល់សោះ"

"ស្រីអស់នោះលង់ស្នេហ៍ខ្ញុំ ព្រោះរូបសម្បត្តិនិងទ្រព្យសម្បត្តិដែលខ្ញុំមាន តែនាង...មិនចូលចិត្តអ្វីដែលខ្ញុំមានសូម្បីម្យ៉ាងទេ ទើបវាធ្វើឱ្យខ្ញុំមានអារម្មណ៍ថាចុះចាញ់ទេដឹង"

"លោកនេះធ្វើខ្លួនដូចបុរសនៅក្នុងកាទូនអីចឹង"

"ទោះខ្ញុំមិនធ្លាប់អាន តែខ្ញុំក៏ដៅថាខ្ញុំប្រហែលជាបុរសដែលស្រីៗជាច្រើនលង់ស្នេហ៍អ្វីបែបនោះ"

"ហ៊ានដង"

"ទោះយ៉ាងណាក៏បានជានិយាយម៉ោដល់នេះទៅហើយ" សាំយ៉ុងដើបអង្គុយត្រង់ខ្លួន ហើយចាប់ផ្តើមមានបូកកង្វល់ជាលើកតំបូង ទោះគេគិតថាបិទបាំងបានយ៉ាងល្អ "បើអីចឹងខ្ញុំសួរនាងត្រង់ៗទៅចុះ"

"ស្អិ...ស្អី"

"សាកល្បងសេពគប់ខ្ញុំមើលទេ"

ខ្ញុំសោប់រសល់ហាក់ដូចជាប្រើសំឡីអនាម័យគ្មានស្លាប ហើយខ្លាចវាជ្រាបប្រឡាក់ផ្នែកខាង។ ទើបប្រែខ្លួនដេកចំហៀង ខាងនេះម្តងខាងនោះម្តង ហើយមានអារម្មណ៍ថាហេតុអីក៏ធ្វើខ្លួនដូចតួឃោសនាសំឡីអនាម័យបែរខ្លួនទៅមក ហើយភ្ញាក់ឡើងដោយទឹកមុខស្រស់ស្រាយ (ចង់ឃោសនាសំឡីអនាម័យទៅដល់ណា) ដូររឿងក៏បាន (ល្អ) ខូចចិត្តដោយសារប្រុសម្នាក់ ហើយត្រូវប្រុសម្នាក់ទៀតសុំសេពគប់។

ព្រួសច្រាស!

នេះគឺជាមូលហេតុដែលធ្វើឱ្យខ្ញុំដេកមិនលក់ ទើបងើបមកអង្គុយឈឺឡាតែតអីយ៉ាងនេះ អារំដើបរំជួលក៏រំដើបហើយ តែមានអារម្មណ៍ថាវាមិនត្រឹមត្រូវ ដូចជាកំពុងបោកគេប្រើដើម្បីធ្វើឱ្យអារម្មណ៍ខ្លួនឯង

ធូរស្បើយបន្ទាប់ពីរងកាយវាយប្រហារ។

'ខ្ញុំមិនបានបង្ខំអីនាងទេ គឺសាកល្បងសេពគប់គ្នាទៅមើល៍ នាងមិនចាំបាច់ខ្វល់ទេ'

'ម៉េចចាំបាច់ធ្វើបែបនេះ លោកសេពគប់ដោយមិនសង្ឃឹមអីពីស្រីម្នាក់នោះទេឬ'

'ខ្ញុំសាកល្បងសេពគប់នាងជានារីទីមួយនោះអ្ហី'

'ហើយបើឧបមាសេពទៅ តែក៏នៅតែមានអារម្មណ៍ថាលោកគឺមិនមែន'

'យើងបែកគ្នាបានគ្រប់ពេល មិនមែនថានាងជាអ្នកប្រាប់ថាបែកគ្នាបានតែម្នាក់ឯងទេ បើខ្ញុំមានអារម្មណ៍ថានាងគឺមិនមែន ខ្ញុំនឹងសុំបែក យុត្តិធម៌ទេ'

'ប្រាកដចិត្តហើយថាត្រូវការបែបនេះ បើមិនមែនក៏បែក ហើយយើងក៏ខឹងគ្នាឬអត់ពេលដល់ពេលនោះ'

'ខ្ញុំជាមនុស្សចិត្តទូលាយ ខ្លាចតែនាងទេ ឧបមាថាមានចិត្តបំពោះខ្ញុំ ហើយខ្ញុំមានអារម្មណ៍ថាមិនមែន នាងហ្នឹងហើយដែលត្រូវយ៉ាប់'

'ចាត់ទុកថាយើងឃ្លៀវគ្នាហើយ អ្ហ៎ ហាមធ្វើអីជ្រុលជ្រួលមកលើខ្ញុំដូចដែលធ្លាប់ធ្វើដាក់ស្រីផ្សេង'

'ខ្លាចតែនាងហ្នឹងហើយដែលហាក់មករកខ្ញុំ'

អ្ហា៎!!! រឿងវាក្លាយជាបែបនេះបានយ៉ាងម៉េច គ្រាន់តែគេចូលមកក្នុងពេលវេលាដែលខ្ញុំសោកសៅបំផុត គ្រប់យ៉ាងរវាងយើងក៏ផ្លាស់ប្តូរ គេបែរក្លាយជាអ្នកដែលមកឈរក្បែរខ្ញុំដោយលក្ខខណ្ឌដ៏ចម្លែក ចង់ថាយុត្តិធម៌ក៏យុត្តិ ចង់ថាមិនល្អក៏មិន ហើយម្យ៉ាងទៀត សាំយ៉ុង ក៏ធ្លាប់ជាសង្សារ សេសីជីន ដែរ។

មិនត្រឹមត្រូវ វាមិនត្រឹមត្រូវ!

(អ៊ូយ ឯង ទៅគិតច្រើនឲ្យបានស្អីម៉ោ នេះឯងគេម៉ោខ្ញុំម៉ោងពាក្លីដើម្បីប្រាប់ថាឯងមិនសប្បាយចិត្តដែល គឹមសាំយ៉ុង សុំសេពគប់ន៎េះ ចាំនិយាយស្អែកក៏បានដែរទេដឹង)

"វាមិនត្រឹមត្រូវ ទោះយ៉ាងក៏គេធ្លាប់ជាសង្សារឯង"

(គេមិនមែនជាសង្សារខ្ញុំ គេគ្រាន់តែជាមនុស្សប្រុសដែលខ្ញុំធ្លាប់បណ្ដើរដើម្បីបាននូវអ្វីដែលខ្ញុំចង់បាន បើចង់ខឹងគឺខឹងដែលអ្នកបាននេះបាននោះគឺជាឯង មិនមែនខ្ញុំ កុំស៊ីរៀសអី)

"មានមនុស្សដូចឯងនៅលោកនេះបានយ៉ាងម៉េច ឯងមិនដឹងទេ ផ្អើសថាជាមិត្តនឹងគ្នាមិនគួរយកសង្សារចាស់របស់មិត្តមកធ្វើសង្សារខ្លួនឯងស្អីបែបនោះ គ្រាន់តែសង្សារចាស់របស់មិត្តមកចែចង់ក៏មានអារម្មណ៍ថាយ៉ាប់ទៅហើយ"

(នោះគឺអ្នកផ្សេង នេះជាខ្ញុំ ហើយយើងគ្រាន់តែបណ្ដើរគ្នាដើម្បីយកប្រយោជន៍ពីគ្នាប៉ុណ្ណោះ ឯងកុំឡូឡាពេកមើល៍ បើឯងខ្លាច ខ្ញុំនឹងខឹងមែនទែនហើយ...ឯងហាមឱ្យវាសុំបែកមុនទៅបានហើយ ព្រោះវាធ្លាប់សុំបែកពីខ្ញុំមុន ដូច្នេះឯងត្រូវតែបោលវាមុន អូខេ?)

"ឯងនេះចិត្តរឹងលំដាប់អេ"

(ខ្ញុំនិងឯងគឺខុសគ្នា មនុស្សប្រុសសម្រាប់ខ្ញុំគឺជារបស់លេង ខ្ញុំធ្វើខ្លួនទន់ជ្រាយមិនបានទេ អីចឹងខ្ញុំដេកសិនហើយ មិនបាច់មិនសប្បាយចិត្តរឿងប៉ុណ្ណឹងទេ សាំយ៉ុង និង ខ្ញុំមិនធ្លាប់មានស្អីៗគ្នា គ្មានអីទាក់ទើ)

"មិនធ្លាប់មានឬ តែឯងធ្លាប់ទៅខុនដូគេ"

(ខ្ញុំធ្លាប់ទៅ ព្រោះវាធ្លាប់មានជាតទី ឃើញខ្ញុំហាច់ហើរអីចឹង ខ្ញុំក៏ស្រលាញ់ខ្លួនស្រលាញ់ប្រាណដែរ ម្យ៉ាងទៀតខ្ញុំស្រលាញ់ឯងច្រើនជាងស្រលាញ់ប្រុសម្នាក់នោះឡើងម៉ាគំនរ បើចង់ឱ្យគៀនគឺមានតែ១គត់...កុំទុកចិត្តមនុស្សប្រុស!)

នោះគឺជាពាក្យគៀនចុងក្រោយ មុននឹង សីដីន ដាក់ទូរសព្ទចុះដោយការងោកងុយ មានមិត្តដែលចេះគិតច្រើនវាគឺអូខេ តែ...យ៉ាងណាក៏ដោយ សម្រាប់ខ្ញុំវានៅតែជារឿងមិនត្រឹមត្រូវ។

មិនបាន ខ្ញុំនឹងទៅសុំបញ្ចប់គ្រប់យ៉ាងនៅថ្ងៃស្អែក ។

ខ្ញុំដើរត្រុកៗតាមរក សាំយ៉ុង ពេញសាលា ហើយក៏សម្រេចចិត្តមកជួបគេនៅថ្នាក់នៅកណ្ដាលភាពចម្លែកចិត្តរបស់គ្រប់គ្នា សាំយ៉ុងដែលកំពុងអង្គុយនិយាយលេងជាមួយមិត្តភក្ដិពេលងាកមកឃើញខ្ញុំក៏

ញញឹមមានមន្តស្នេហ៍ដាក់ ហៅខ្សែភ្នែកគ្រប់គ្នាឲ្យងាកមកមើលខ្ញុំដោយការចាប់អារម្មណ៍ចង់ដឹងចង់ឮ ។

"ម៉េចអូនសំឡាញ់"

មួយប្រយោគខ្លីៗ ដែលគ្មានសូម្បីតែប្រធាន មានត្រឹមកម្មបទថាអូនសំឡាញ់ ប៉ុណ្ណឹងក៏ហៅសម្លេងហ៊ោបានភ្លាម ខ្ញុំមានអារម្មណ៍ថាមុខខ្លួនឯងក្រហមងាំងដូចស្វាយ អឺ មិនមែនទេ ស្វាយពណ៌ខៀវទេតើដូចប៉េងប៉ោះ ឈាមច្រាសច្រាលពេកហើយ ។

"ខ្ញុំមានរឿងនិយាយជាមួយ តែមិនមែនទីនេះ"

"បានតើ"

នេះមិនមែនជាការដើរ សម្រាប់ខ្ញុំជាការរត់ ព្រោះខ្សែភ្នែកគ្រប់គ្នាធ្វើឲ្យមិនសប្បាយចិត្តអីយ៉ាងនេះក៏មិនដឹង សាំយ៉ុង ដើរតាមដោយអារម្មណ៍ល្អ ការដើរ រត់ លោត ហាក់ដូចជាមានចង្វាក់ភ្លេងតាមរណ្ដំចុងជួនគ្រប់ជំហាន ។

"ចាំបាច់ដើរទៅឆ្ងាយដែរអ្ហ៎ និយាយត្រង់នេះក៏បានទេដឹង"

"មានភ្នែកមនុស្សច្រើនពេក"

"ម៉េចចាំបាច់កង្វល់ ឬ យើរខ្សែភ្នែកអ្នកដទៃ ពីមុននាងទាំងត្រូវធ្វើបាប ទាំងត្រូវស្អប់ មិនឃើញយើរផង"

ពេលគេនិយាយឲ្យខ្ញុំភ្ញាក់ខ្លួនបាន វាក៏ធ្វើឲ្យខ្ញុំបញ្ឈប់ជើង ហើយសម្រេចចិត្តឈរនិយាយនៅចំណុចនេះ ទោះមិនមែនជាកន្លែងដែលខ្ញុំចង់និយាយ តែក៏មានមនុស្សតិចជាងនៅមុខថ្នាក់គេដែរ ។

"ខ្ញុំគិតមើលហើយ រឿងរវាងយើង"

"នេះយកទៅគិតពេញម៉ោយប់ឬនេះ នាងធ្វើឲ្យខ្ញុំរំភើប" សាំយ៉ុងលូកដៃមកលេងសក់ តែត្រូវខ្ញុំវាសចេញ "ហួងហែងខ្លួនមែន ប៊ូៗ"

"ម៉ោប៊ូបាស្អី មិនទាន់ស្អីផងប្រើដៃជើងទៅហើយ"

"ឬនាងចង់ឲ្យខ្ញុំប្រើអីផ្សេង ក៏បាន"

"ចូលរឿង!" ខ្ញុំសោប់រសល់ដូចត្រូវភ្លើងរោលគូថ "ខ្ញុំគិតថារឿងរបស់យើង..."

មិនទាន់បាននិយាយអីផង ក៏ក្រលេកទៅឃើញ គូអឺន និង សិស្ស

ច្បង់ឈរនិយាយគ្នាក្អាកក្អាយ ចាប់ដៃចាប់ជើងគ្នា មិនមែនទេ គ្រប់យ៉ាងដែលជាភាសាកាយវិការរបស់ពួកគេធ្វើឱ្យខ្ញុំល្ហល្ហេវចិត្ត ។

"រឿងរបស់យើងវាម៉េច"

"វាជាអ្វីដែល..."

ហើយមើលទៅ កូអ៊ីន ដូចជាដឹងថាមានអ្នកមើល ទើបងាកមកក៏ប្រទះនឹងភ្នែកខ្ញុំល្មម តំបូង កូអ៊ីន មើលបែបមិនចាប់អារម្មណ៍ តែហើយក៏រហ័សងាកមកវិញពេលឃើញថា សាំយ៉ុង ក្រសោបមុខខ្ញុំបង្វែរទៅរកឱ្យចាប់អារម្មណ៍គេតែម្នាក់ ។

"អ្វីដែលខ្ញុំត្រូវការនៅពេលនេះគឺសមាធិរបស់នាង ហៅខ្ញុំចេញមកនិយាយគ្នា តែមិនចូលសាច់រឿង រវល់តែចាប់អារម្មណ៍ស្អី"

ពេល សាំយ៉ុង ងាកទៅ ខ្ញុំក៏សង្គ្រប់មុខគេឱ្យងាកមករកខ្ញុំវិញ ។

"គ្មានអីទេ គឺរឿងដែលខ្ញុំចង់និយាយ វាក៏មិនបានសំខាន់អីដែរ"

"ថីនាងហ្នឹង វាច្បាស់ជាសំខាន់ មិនអីចឹងនាងធ្វើមុខតានតឹងទៅធ្វើស្អី" សាំយ៉ុង សើច "ថាទៅយប់មិញខ្ញុំក៏ដេកមិនលក់ដែរ ចម្លែកមែនដែលខ្ញុំក្លាយជាបែបនេះបាន"

"មែន...ឬ"

"ដួនកាលបើខ្ញុំសាកល្បងសេពគប់គ្នាឱ្យប្រាកដប្រជា ខ្ញុំអាចនឹងក្លាយជា គីមសាំយ៉ុង ថ្មីដែលមានស្នេហ៍ស្មោះក៏ថាបាន"

"អ៊ឹម" ខ្ញុំដៀងទៅមើល កូអ៊ីន ម្តងទៀត តែពេលនេះគេនិងសិស្សច្បងមិននៅត្រង់នោះទៀតទេ ។

"ស្អី នាងឆ្លើយតែប៉ុណ្ណឹងទេឬ តែថានាងមើលស្អីណាស់ណាទៅនេះ" គេងាកទៅមើលដោយខ្ញុំមិនហាមឃាត់ "មិនឃើញមានស្អីផង"

"គ្មានស្អីទេ"

"ខ្ញុំនិយាយអស់ហើយ ពេលនេះនាងចង់និយាយអីក៏និយាយម៉ោ"

ខ្ញុំញញឹដាក់គេដោយការហាត់នឿយ÷

"ខ្ញុំគ្រាន់តែចង់មកប្រាប់ថាខ្ញុំសម្រេចចិត្តមិនខុសទេ"

"ខ្ញុំសន្យាថានឹងមិនធ្វើឱ្យនាងអស់សង្ឃឹម"

តែហេតុអី...ក៏ខ្ញុំមានអារម្មណ៍ថាអស់សង្ឃឹមអីយ៉ាងនេះ... ។

១៥

មួយអាទិត្យបានកន្លងផុតទៅយ៉ាងលឿនដូចកុហក តាមពិតទៅ តាំងពីថ្ងៃនោះ ខ្ញុំ និង សាំយ៉ុង មិនបានធ្វើអីគ្នាច្រើន (កុំគិតជ្រៅ) ក្រៅពីការជួបគ្នានៅសាលា ហើយគេក៏មកផ្ទះប៉ាជាមួយខ្ញុំ ហើយ ពេលប៉ាខ្ញុំនៅតែមិនទាន់មកផ្ទះវិញ មិនដឹងថាស្លាប់រស់យ៉ាងណាខ្លះ ភាពខ្វល់ខ្វាយដែលខ្ញុំមានក៏ត្រូវ សាំយ៉ុង ដែលនៅក្បែរជួយកម្ចាត់វាចេញ ។

‘ខ្វល់ធ្វើអី គាត់ទៅបរទេស មិនបានទៅជេដូទេ ទៅតាមខេត្តក៏នៅយូរជាងនេះ ពេលដល់ពេលានឹងមកហើយ’

‘ចុះបើប៉ាខ្ញុំកើតអីនោះ’

‘ប៉ានាងមិនអីទេ ទើបប៉ុន្មានថ្ងៃសោះ’

សាំយ៉ុង ចាប់ដៃខ្ញុំណែនដូចជាត្រូវការល្បួងលោមនៅក្នុងពេលដែលខ្ញុំកំពុងបែកសតិ ណាបារម្ភពីប៉ា ណានៅកាត់ចិត្តពី កូអ៊ីន មិនបាន គឺមានគេនេះហើយដែលនៅកំដរ ហើយថ្ងៃមុននេះក៏ដូចគ្នា...

‘ថ្ងៃសៅរ៍យើងទៅដេត’

‘ដេតឬ ខ្ញុំមិនចេះធ្វើស្អីបែបនោះទេ’

‘ចាំខ្ញុំបង្រៀន’

ណ្ហើយ ចូលមកបច្ចុប្បន្នវិញ Grammar ថា Present Simple ពេលនេះខ្ញុំកំពុងតែខ្វល់ចិត្តពេកណាស់ទាក់ទងនឹងខ្លួនឯងថាតែងខ្លួនយ៉ាងណាសម្រាប់ការដេតលើកតំបូង ហើយក៏មកអង្គុយខូចចិត្តដែលខ្លួនឯងមិនធ្លាប់ចាប់អារម្មណ៍នឹងការតុបតែងខ្លួន បុងក្រោយក៏ស្លៀក

ឈុតសេកសម័យអនុវិទ្យាល័យ ដែលវាសែនកពង្វាស់ អ៊ឺា តែវាក៏គួរឲ្យស្រលាញ់ ឬ ព្រោះខាងស្លៀកវាយូរ ។

ពេលតែងខ្លួនរួចហើយក៏ត្រៀមខ្លួនចេញដំណើរ តែពេលចុះមកដល់ជាន់ក្រោមក៏ជួប កូអឺន ឈរឱបដៃសម្លឹងមុខខ្ញុំដូចជាថាកំពុងរង់ចាំការស្តេចយាងរបស់ព្រះនាងតូច (ហ៊ានជង់) គេមើលតាំងពីក្បាលដល់ចុងជើង ហើយភាំងមួយសន្ទុះ មុននឹងរហ័សធ្វើសម្លេងរាបស្មើ ។

"ទៅណា"

"ដើរលេង"

"សាំយ៉ុង ឬ"

"អឺម"

"ហើយចាំបាច់ស្លៀកពាក់ឈុតខ្លីកំបិតបែបនេះដែរឬក៏ម៉េច"

"វាជាឈុតតែមួយដែលខ្ញុំពាក់ហើយស្អាត" ប្រាកដណាស់ថាខ្ញុំមិនព្រមប្រាប់ការពិតដាច់ខាតថាទូខោអាវមានតែឈុតនេះមួយ "និងម្យ៉ាងទៀត ពីតំបូងវាក៏មិនបានខ្លីបែបនេះដែរ"

"អាកាសធាតុប្រែប្រួលទើបវារួញឬយ៉ាងម៉េច"

ឡប់សតិទេអ្ហ៎ អាកាសធាតុប្រែប្រួលវាប្រើបានតែជាមួយមនុស្សបើខោអាវរួញបានព្រោះអាកាសធាតុ ថ្មើរនេះគ្រប់គ្នាបែបជាស្លៀកលីអូម៉ាកថ្មីដែលវារីបរួញរបស់របរអស់ទៅហើយ ហឹស!

"ថាអីចឹងក៏បាន"

"ម៉ោវិញម៉ោងម៉ាន"

"រវល់អីដែរ"

"យ៉ាងហោចណាស់ក៏ខ្ញុំជាបងប្រុសនាង!"

មើលទៅពាក្យនេះដូចជាចាក់ដោតបេះដូងខ្ញុំយ៉ាងខ្លាំងដល់ថ្នាក់ងាកខ្វាប់ទៅសម្លឹងគេដោយចង់រករឿង ។

"ខ្ញុំកើតម៉ោជាកូនទោល គ្មានបងប្រុស មិនបាច់ម៉ោរវល់"

"អ៎! មិនរវល់ក៏បាន មិនឲ្យធ្វើជាបងប្រុសក៏បាន"

"ល្អ!"

សម្លេងបើកទ្វាររបង ធ្វើឲ្យយើងឈប់ខាំគ្នា ហើយងាកទៅចាប់

អារម្មណ៍ឡានដែលបរចូលមក អតីតស្ប៉តដ៏កាលីបរបស់ កូអ៊ីន ត្រូវចតដោយថ្មីដែលរបស់ សាំយ៉ុង ដែលមកដោយឈុតសប្បាយៗ ផាយៗ តែមើលទៅថ្លៃមានកម្រិត ក្មេងថ្នាក់នេះ បើកឡានថ្លៃថ្នាក់នេះ ថែមទាំងមានមុខមាត់ស្អាតថ្នាក់នេះបានយ៉ាងម៉េច យកស្អីមកគិត!

"រួចរាល់ហើយនៅ ហេ៎ កូអ៊ីន ថ្ងៃនេះម៉េចក៏ភ្ញាក់ពីព្រឹកម៉េះ"

"ខ្ញុំភ្ញាក់ថ្មើរនេះរាល់តែថ្ងៃហ្នឹង"

"មិនទេ ធម្មតាថ្ងៃឈប់បែបនេះឯងដេកស្លាបដូចក្ដែផ្ងារពោះនៅលើគ្រែតើ"

"រឿងផស់ខ្ញុំ"

"ហ៎ាន៎ែ"

"ស្អី"

"ឯងម៉ោចាំមើលថាថ្ងៃនេះខ្ញុំនិងប្អូនស្រីក្លែងក្លាយរបស់ឯងទៅដេតជាមួយមែនទែនដូចដែលខ្ញុំបានប្រាប់ឬអត់មែនទេ" សាំយ៉ុង ធ្វើមុខពព្រើម "ម៉េចចាំបាច់ធ្វើមុខអស់សង្ឃឹមដល់ថ្នាក់នោះដែរ"

"ខ្ញុំមិនបានអស់សង្ឃឹមទេ ឯងចង់ទៅណា ជាមួយអ្នកណា មិនទាក់ទងនឹងខ្ញុំស្រាប់ទៅហើយ"

កូអ៊ីន បម្រុងនឹងដើរចេញ តែ សាំយ៉ុង ហៅមុន÷

"អី ភ្លេចប្រាប់"

"ស្អីទៀត!"

"ស្ប៉តផស់ឯងបើកហើយស្រួលខ្លួនណាស់ នេះជាលើកតំបូងដែលខ្ញុំយកវាទៅដេតជាមួយស្រីជាផ្លូវការ កាលីបអស់ទាស់"

"ហឺយ!"

កូអ៊ីន ដើរឡើងទៅដាន់លើបាត់ ទុកឲ្យខ្ញុំ និង សាំយ៉ុង នៅតែពីរនាក់បែបនេះ នៅសុខៗខ្ញុំក៏មានអារម្មណ៍ថាអស់សង្ឃឹមនិងសមបិត្តព្រមគ្នាយ៉ាងចម្លែកដូចផ្លែកមួយនៅក្នុងខ្លួនក៏ល្ងួចដឹងថាគេមិនពេញចិត្តដែលខ្ញុំទៅដេតជាមួយ សាំយ៉ុង ទើបធ្វើឲ្យខ្ញុំញញឹមបានខ្លះ ។

"ថ្ងៃនេះតែងខ្លួនគួរឲ្យស្រលាញ់អីយ៉ាងនេះ"

"កុំនិយាយបែបនេះ ខ្ញុំមានឈុតតែមួយទេទុករកស៊ី"

"ប្រែថាស្អី"

"ប្រែថាមិនថាពិធីអី បុណ្យស្អី ឈុតនេះគឺជាឈុតដែលខ្ញុំស្លៀកទៅចូលរួមគ្រប់ឱកាស"

"ប្រែថាការទៅជាមួយខ្ញុំលើកនេះគឺជាឱកាសដ៏សុទ្ធសែនវិសេស តែការបានសាកល្បងសោពគប់ខ្ញុំ វាអាចនឹងពិសេសញឹកញាប់បន្តិច ខ្ញុំថា...យើងគួរទៅសបភីងសិន"

"សបភីង? តែខ្ញុំអត់បានសុំលុយម៉ាក់ផង"

"តួនាទីរបស់សង្សារប្រុសគឺនាំសង្សារស្រីទៅសបភីង ហើយការសបភីងត្រូវប្រើលុយរបស់សង្សារប្រុស"

"ចង់ត្រូវខ្ញុំជេរម៉ែមនទេ"

"បណ្ដោយឱ្យថ្ងៃនេះជាថ្ងៃដែលខ្ញុំបានប្រើលុយខ្លះទៅ ខ្ញុំដឹងថាវាទិញនាងមិនបាន តែខ្ញុំចង់ធ្វើអីល្អៗខ្លះ ហើយអ្វីដែលខ្ញុំធ្វើបានល្អបំផុតគឺការប្រើលុយ អូខេ?"

ជាហេតុផលដែលមើលទៅគ្មានហេតុផល តែក៏មានហេតុផលចំពោះខ្លួនឯងបែបមាំងៗ Infinity ល្អពេកហើយ តែណ្ហើយ ថ្ងៃនេះខ្ញុំគួរតែធ្វើខ្លួនសប្បាយៗ ហើយទុកឱ្យ សាំយ៉ុង នាំផ្លូវក្នុងឋានៈដែលគេមានបទពិសោធន៍ខាងផ្នែកនេះ ។ ក៏ព្រមទទួលស្គាល់ថាការជិះឡានជាមួយគេមើលទៅកាលើបមិនល្អមទេ តាមផ្លូវដែលបើកកាត់គឺមានតែអ្នកងាកមើលឡើងចង់គេច-កទៅហើយ តែគួរឱ្យឈឺចិត្តត្រង់ពេលដែលខ្ញុំចុះពីឡាន គ្រប់គ្នាក៏ធ្វើមាត់វៀចវេចដូចថ្កែស៊ីថ្លើម ធ្វើមាត់វៀចវេចធ្វើអី ខ្ញុំចុះពីឡានហើយធ្វើឱ្យពួកនាងអស់សង្ឃឹមដល់ថ្នាក់នោះឬ!

"លើកក្រោយបើចង់នាំខ្ញុំទៅណា លោកគួរយកកង់ម៉ោទទួល"

"វ៉ាវ៉ា យើងរីកចម្រើនហើយ នាងដល់ថ្នាក់ដាក់ផែនការថាមានលើកក្រោយផង"

"វាជាអនាគត ខ្ញុំនិយាយបង្ការ"

"ទៅចាប់អារម្មណ៍នឹងខ្សែភ្នែកពួកនោះធ្វើអី ពពួកដែលចូលចិត្តកាត់ក្ដីមនុស្សតាមរយៈវត្ថុ"

ស្ដាប់មើលទៅមានន័យល្អ!

"ដូច្នេះ ខ្ញុំនឹងនាំនាងទៅទិញវត្ថុដែលមនុស្សចូលចិត្តកាត់ស្លឹឲ្យនាងពាក់ល្អជាង"

"អ្ហ៎ា!"

ហើយតាភាងពេលវេលារបស់ខ្ញុំនៅថ្ងៃនេះក៏ក្លាយទៅជាធុរៈរបស់ សាំយ៉ុង គេនាំខ្ញុំទៅរើសខោអាវម៉ូតនេះម៉ូតនោះក្នុងតម្លៃដែលមិនអាចឲ្យខ្ញុំលូកដៃយកបាន ទោះជាចង់បដិសេធ តែគេមិនព្រមញាត់អាវនេះអាវនោះឲ្យខ្ញុំ ហើយរុញចូលបន្ទប់ល ព្រមទាំងបញ្ជាឲ្យចេញមកបង្ហាញខ្លួនដូចនៅក្នុងកុនពេលឈុតរៀបការ (ពេកហើយ) យើងលអស់ជាង១០ឈុតហើយ ។

"ចង់បានមួយណា យកមោលចុះ"

"ចាំ"

ម្ចាស់ហាងនេះចិត្តល្អ ប្រាប់ដោយស្នាមញញឹម លឡើងរញ៉េរញៃពេញហាងហើយនៅញញឹមបានទៀត ចិត្តធូន់មែន ។

"មិនចាប់ក្រែងចិត្តទេ ហាងនេះជាសាខារបស់ម៉ាក់ខ្ញុំ"

"អីចឹងតើបានជាមើលទៅគេក្រែងចិត្តក្រែងអីយ៉ាងនេះ លោកចង់មានដើម្បីអ្នកណា"

"ដើម្បីនាងហ្នឹងអ្ហី"

"=O="

"អីចឹងលសិនទៅ ខ្ញុំទៅមើលខោអាវខ្លួនឯងខ្លះ ឃើញនាងពាក់ហើយក៏ប្រណែន ខ្លាចមើលទៅស្អាតមិនសមនឹងនាង នឹងមិនហ៊ានដើរជាមួយ"

សាំយ៉ុង ដើរទៅបាត់នៅប្រកដែលជាផ្នែកខោអាវប្រុស ទុកឲ្យខ្ញុំនៅលខោអាវតែម្នាក់ឯង តាមពិតវាក៏ស្អាតដែរ តែអៀនដៃពេកដែលទៅលូកយកនេះយកនោះមកធ្វើជារបស់ខ្លួន ទោះជាគេប្រាប់ថាទិញឲ្យក៏ដោយ ។

ហៀក! ដូចជាមានមនុស្សសម្លឹង!

"កើតអីអត់ហ្នឹង"

បុគ្គលិកស្រីដែលដើរមកមើលរបៀបរៀបរយឃើញឫកពាប្លែកៗ

របស់ខ្ញុំក៏សួរដោយការចម្លែកចិត្ត ទើបខ្ញុំបានតែញញឹមស្ងួតដាក់ហើយឈឺឈុតបន្ត តែថា...

ហឿក! ច្បាស់ជាមាន ខ្ញុំមានអារម្មណ៍ថាអីចឹងមែន!

"អ្នកនាង..." បុគ្គលិក ។

"អី ជួយប្រាប់ សាំយ៉ុង ផងថាខ្ញុំលែងរើសហើយ អរគុណ"

"ចាំៗ"

បុគ្គលិកហាងនេះក៏បម្រើបានល្អ ឫកពាព្រួយបារម្ភ ហើយមានសភាពចម្លែកចិត្តតាមខ្ញុំដូចជាយល់ថាអីចឹងដែរ (ចង់មានចំណែកក្រុមហ្វីងវ៉ែ្អង) ពេលនាងដើរទៅតាម សាំយ៉ុង ខ្ញុំក៏បានតែឈរម្នាក់ឯងហើយគិតនេះគិតនោះរហូតដល់មានដៃធំមួយពីខាងក្រោយមកបិទមាត់ជិត ។

"អ្ហឺៗ"

"ទៅជាមួយខ្ញុំ"

"O_O"

"ភ្លាម!"

មិនបាច់ខាតពេលទាយថាជាអ្នកណា ពេលឮសម្លេង ក៏ដឹងភ្លាមថាជា ចុងកូអឺន គេអូសខ្ញុំចេញទៅក្រៅហាងយ៉ាងលឿនដោយខ្លាចថា សាំយ៉ុង ចេញមកទាន់ ។

"អ៊ូយ នាងខាំដៃខ្ញុំ!" គេរលាស់ដៃ ហើយផ្ដុំហាក់ដូចជាសូត្រមន្តគាថា "ម៉េចចាំបាច់ប្រើកម្លាំង"

"លោកយកដៃប្រៃៗនេះម៉ោបិទមាត់ខ្ញុំធ្វើអី ថែមទាំងម៉ោធ្វើលឹបៗលបៗទៀត"

"ចេញពីត្រង់នេះសិនទៅ ខ្ញុំចង់និយាយជាមួយ"

"ម៉េចក៏និយាយត្រង់នេះមិនបាន"

"ខ្ញុំមិនចង់ឲ្យ សាំយ៉ុង ឃើញ"

"បើឃើញហើយវាយ៉ាងម៉េច"

"មិនដឹង តែមិនចូលចិត្ត!"

"=O="

សម្លេងគំហករបស់គេ ធ្វើឱ្យខ្ញុំត្រូវដើរតាមដូចកូនចៀមតាមមេ កូអ៊ីន នាំខ្ញុំដើរចេញឆ្ងាយពីហាងនោះដោយការចុះជណ្តើរយន្តដើង ទៅជាន់ក្រោមបំផុត ថែមទាំងនាំមកនិយាយគ្នានៅមុខបន្ទប់ទឹកប្រុស ដែលជាកន្លែងងងឹត បើមិនតាំងចិត្តគឺច្បាស់ជារកខ្ញុំមិនឃើញទេ ។

"មានអីក៏ចាប់និយាយម៉ោ ថ្មើរនេះបើ សាំយ៉ុង រកខ្ញុំមិនឃើញគឺ ចារម្តស្លាប់ហើយ"

"អីយ៉ា ចារម្តពីគ្នាដល់ហើយណាំ ឆ្ងាយគ្នាតិចតួចវាមិនដាច់ខ្យល់ ងាប់ទេ"

"ខ្ញុំដឹងថាគេមិនដាច់ខ្យល់ងាប់ តែនេះជាដេតតំបូងរបស់យើង ហើយលោកកំពុងតែបំផ្លាញវាដែរ!"

"ហឹស ដេត ស្លាប់ហើយចង់ក្អួត នាងគិតថានេះគឺជាដេតមែនអ្ហ៎ នាងដឹងទេថា សាំយ៉ុង ពូកែរឿងនេះប៉ុណ្ណា ពេលថ្ងៃនាំនាងម៉ោទិញ ខោអាវ ពេលយប់នាំឡើងសណ្ឋាគារ ហើយដឹងទេថាវានឹងធ្វើអីបន្ត"

"រឿងផស់ខ្ញុំ"

"ខ្ញុំនិយាយដល់ថ្នាក់នេះហើយនាងនៅមិនភ្ញាក់អីទៀតឬ បំជា មុខក្រាស់មែន!"

"មនុស្សសេពគប់គ្នា ចង់ធ្វើអីលើសលុះបន្តិចវាមិនមែនជារឿង ចម្លែកស្អីទេ លោកម៉ោនិយាយដើម្បីអី គូដណ្តឹងក៏មាន គួរតែយល់ ច្បាស់ថាសេពគប់គ្នាត្រូវធ្វើស្អីខ្លះហើយ"

"ខ្ញុំមិនធ្លាប់ធ្វើស្អីបែបនោះជាមួយគូដណ្តឹងខ្ញុំឱ្យបានម្តងទេ"

"ចុះម៉េចក៏មិនសាកទៅ នឹងបានឈប់ភីភល់នឹងជីវិតអ្នកផ្សេង"

"គឺខ្ញុំចារម្តពីនាង!"

កូអ៊ីន ក្លួចខ្លួននិយាយចេញមកខ្លាំងៗ ធ្វើឱ្យខ្ញុំភ្ញាក់ព្រើត តែនៅ ក្នុងភាពភ្ញាក់ផ្អើល បបូរមាត់ខ្ញុំក៏ញោចដូចជាចង់ញញឹមដោយការ សប្បាយចិត្ត តែត្រូវទប់វាព្រោះខ្លាចគេឃើញ ។

"ក្នុងឋាន:អី បងប្រុសដ៏សែនល្អបែបនោះឬ"

"អ៎!"

"អីចឹងមិនបាច់ចារម្តទេ ខ្ញុំមើលថែខ្លួនឯងបានបងប្រុស"

អ្ហ៎ា ខ្ញុំខឹងហើយ គេយកពាក្យថាបងប្រុសចេញពីវេចនានុក្រមឯកជនទៅក្នុងខួរក្បាលបន្តិចមិនបានឬយ៉ាងម៉េច! ដោយសារខឹងពេកទើបខ្ញុំដើរទន្ទ្រាំជើងចេញពីច្រកអាប់នោះដោយមាន កូអឹន ដើរតាម ។

"ម៉េចចាំបាច់ខឹងដល់ម្លឹង ខ្ញុំប្រាប់ថាបារម្ភ មិនចូលចិត្តឬ"

"មិនចូលចិត្ត"

"ចុះចង់ឲ្យខ្ញុំធ្វើម៉េ..."

ខ្ញុំ និង កូអឹន ច្ចក់ព្រមគ្នាពេលជួបម៉ាក់ដែលឈរកៀកដៃប្រុសចំណាស់ថ្ងៃមុន ហើយម៉ាក់ដែលកំពុងសើចរីករាយក៏ស្លេកមុខភ្លាមពេលឃើញយើង ។

"ម៉ាក់..."

"ម៉ាក់ចុងរបស់ខ្ញុំតើ" កូអឹន ញញឹមទំនងដាក់ "ម៉ោជាមួយណាគេទៅណ៎ា មើលទៅស្និទ្ធស្នាលផ្អែមល្ហែមអីយ៉ាងនេះ"

ម៉ាក់រហ័សដកដៃចេញពីដៃអ៊ំប្រុសនោះ ហើយលើកមកឱបដូចជាការពារខ្លួន÷

"និយាយស្អី នេះជាមិត្តខ្ញុំ"

"អ្ហ៎ មែនឬ មើលទៅជិតដិតគ្នាណាស់ ចុះចាំខ្ញុំស្គាល់មិត្តជិតដិតរបស់នាងទេនេ៎ះ ម៉ាក់ចុង"

ខ្ញុំទាញជាយអាវរបស់ កូអឹន ជាការសុំឲ្យគេឈប់ អាម្សៀនេះមើលមុខខ្ញុំដោយខ្សែភ្នែកយល់ពីអ្វីម្យ៉ាង ហើយក៏ញាក់ស្មា ។

"ថ្ងៃនេះមិនទំនេរ ចាំនិយាយគ្នានៅផ្ទះទៅចុះ ម៉ាក់ចុង"

និយាយចប់ កូអឹន ក៏ដើរចេញទៅដោយមិនងាកមកមើលម៉ាក់សូម្បីតែបន្តិច ចំណែកខ្ញុំដែលទោះយ៉ាងណាក៏ទ្រាំមិនបាន ត្រូវងាកទៅមើលក៏ឃើញម៉ាក់មើលមកខ្ញុំ និង កូអឹន ដោយខ្សែភ្នែកពេញទៅដោយភាពឃោរឃៅ ។

ច្បាស់ជាមានរឿងហើយ...

១៦

នៅតាមផ្លូវដើរមកវិញ កូអឺន មិនបាននិយាយដល់រឿងដែលទើបនឹងកើតឡើងទេ ភាពស្ងៀមស្ងាត់របស់គេកាន់តែធ្វើឲ្យខ្ញុំតានតឹងជាងអ្វីទាំងអស់ ជឿជាក់បានថាពេលទៅដល់ផ្ទះវិញ ថ្ងៃនេះច្បាស់ជាមានរឿងគគ្រីកគគ្រេងកើតឡើងទៀតហើយ ។

"ចុងអ៊ុល!"

សាំយ៉ុង ស្រែកហៅខ្ញុំពីកន្លែងដែលនៅមិនឆ្ងាយប៉ុន្មានដោយមានថង់ខោអាវយឺងរយោងពេញដៃ ពេលរត់មកដល់ក៏ត្រូវច្ងក់ដោយសារឃើញ កូអឺន នៅជាមួយ បួកពារបស់គេមើលទៅផ្លាស់ប្តូរមួយរំពេចតែក៏ប្រឹងញញឹម ធ្វើដូចគ្មានអ្វីកើតឡើង ។

"ឯងម៉េចទីនេះបានយ៉ាងម៉េចនេះ មិញនេះឯងនៅផ្ទះតើ"

"ខ្ញុំមានឡាន ខ្ញុំក៏បើកម៉ោ ចៃដន្យជួបនាងប្រមក់នេះទើបឈរនិយាយគ្នារាងយូរបន្តិចទៅ ឯងបែបអើត-ករកមើលឡើងចុកហើយមើលទៅ"

"គឺធម្មតាទេ សង្ស័យបាត់ទៅទាំងមូល!"

បើមិនបានគិតដោយខ្លួនឯងទេ ខ្ញុំមានអារម្មណ៍ថាពីរនាក់នេះកំពុងតែប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លាតាមរាចានិងខ្សែភ្នែក ទើបនឹងមានរឿងតានតឹងថ្មីៗ នៅមកធ្វើឲ្យរឿងនៅចំពោះមុខនេះតានតឹងលើសដើមធ្វើស្អីទៀតតត!

"ទៅវិញបានហើយ កូអឺន ខ្ញុំជួប សាំយ៉ុង ហើយ ចាំនិយាយគ្នានៅផ្ទះចុះ"

"អូខេ!" កូអឺន តំឡើងសម្លេងលាយបញ្ឈឺ "បើយើងមានរឿងត្រូវ

និយាយគ្នា តែខ្ញុំថាខ្ញុំគ្មានរឿងអីនិយាយជាមួយនាងទេ តែបើជាមួយម៉ាក់នាង...គឺមិនប្រាដកដែរ ហ៊ី។"

"កូអីន!"

"ទៅហើយ"

គេដើរចេញទៅ ព្រមទាំងគ្រវីដៃលាបែបមិនងាកមកមើល ភាពអន្ទះអន្ទែងវាយសម្រុកចូលមកក្នុងទ្រូងខ្ញុំសឹងតែចង់ស្រែកចេញមកឱ្យដឹងណាណាភ្លាម តែក៏ធ្វើមិនបាន ។

"មានរឿងអីអត់"

"អ្ហ៎...គ្នា...គ្មានអីទេ ចៃដន្យគេម៉ាទីនេះ ហើយខ្ញុំក៏ទៅនិយាយជាមួយគេ សុំទោសដែលធ្វើឱ្យចាំ"

"អ្ហឹម"

ហើយការដេតថ្ងៃនេះក៏បញ្ចប់ទៅ ព្រោះចិត្តខ្ញុំងងឹតអស់ដោយសារគិតតែរឿងរបស់ម៉ាក់រហូតដល់ធ្វើអីមិនកើត កុនក៏មិនល្អមើល បាយក៏មិនឆ្ងាញ់ សាំយ៉ុង ប្រហែលជាមើលដឹង ទើបនាំខ្ញុំមកផ្ទះវិញ អារម្មណ៍ខុសឆ្គងរបស់ខ្ញុំវាមានច្រើនឡើងសឹងតែស្រែកយំទៅហើយ ។

"សុំទោសផងដែលថ្ងៃនេះខ្ញុំធ្វើខ្លួនមិនគួរឱ្យស្រលាញ់"

"នាងកែខ្លួនបាននៅថ្ងៃក្រោយ"

សាំយ៉ុង និយាយហើយក៏ចុះពីឡានមកបើកទ្វារឱ្យខ្ញុំ ខ្ញុំរាងខ្មាសៗតិចតួច ធ្លាប់តែឃើញបែបនេះនៅក្នុងកុន តាមពិតគេក៏ជាសុភាពបុរសអាចប្រើការបានដែរ ។

"កុំភ្លេចយកថង់ខោអាវទៅផង នាងនឹងបានស្លៀកទៅដើរលេងជាមួយខ្ញុំនៅពេលក្រោយ"

"តែលើកក្រោយមិនចាច់ទិញអីច្រើនបែបនេះទៀតទេ"

"នោះអាស្រ័យត្រង់ថានាងពាក់វាទៀតអត់បន្ទាប់ពីទៅដើរលេងជាមួយខ្ញុំ"

"មិនគួរឱ្យស្រលាញ់សោះ ដាក់លក្ខខណ្ឌតិចតួចផងក៏មិនបាន"

"នាងជាស្រីតំបូងដែលមិនទទួលយកលក្ខខណ្ឌរបស់ខ្ញុំដូចគ្នា"

"អីចឹងទៅហើយណ៎ា"

"ឈប់"

សាំយ៉ុង ទាញខ្ញុំទៅរក ហើយថើបចុងច្រមុះតិចៗ ខ្ញុំរន្ធត់ចិត្តអស់បីវិនាទី ហើយលោតចេញមកយ៉ាងលឿន ។

"ស្អីនេះ!" ខ្ញុំចាប់ច្រមុះខ្លួនឯង "មិញលោកធ្វើអី"

"នាងគួរឱ្យស្រលាញ់មែន គ្រាន់តែថើបច្រមុះសោះ មិនអីទេ តិចទៀតស៊ាំហើយ លើកនេះច្រមុះ លើកក្រោយកន្លែងផ្សេងក៏បាន ហើយវាក៏មានកន្លែងផ្សេងៗទៀតជារឿយៗ"

"ឆ្កួត!"

សាំយ៉ុង សើច ហើយដើរឡើងឡាន មុននឹងបើកចេញទៅ ។ ទោះជាមានអារម្មណ៍ថារន្ធត់ចិត្ត តែក៏ខ្មាសអៀនដោយប្រាប់មិនត្រូវ ដើរចូលក្នុងផ្ទះ យកដៃអង្អែលច្រមុះហើយអង្អែលទៀត ឆ្កួតៗ អ្នំា។ មិនដឹងជាបរិយាយជាតួអក្សរយ៉ាងណាទេនេះ ។

"ផ្អែមល្ហែមណាស់ណា៎!"

កូអឹន ឈរឱបដៃជាបងធំរបស់គ្រួសារដូចដើម ដូចជារង់ចាំការត្រលប់មកវិញរបស់ខ្ញុំ នេះបើខ្ញុំមកវិញយប់ គេក៏ប្រហែលជាឈរចាំត្រង់នេះមិនទៅណាទេឬយ៉ាងម៉េច ។

"កូអឹន...លោកម៉ោឈរធ្វើអីនៅត្រង់នេះ មានអារម្មណ៍ថាថ្ងៃនេះខ្ញុំឃើញមុខលោកញឹកដល់ហើយ"

"ខ្ញុំស្មានថានាងមានរឿងចង់និយាយជាមួយខ្ញុំទៀត បើគ្មានទេ...អីចឹងខ្ញុំទៅហើយ"

"ឈប់!"

ខ្ញុំរត់ទៅស្ទាក់មុខមិនឱ្យគេទៅណា ហើយកាងដៃកាងជើង កូអឹនផ្អៀង-កមើលមុខខ្ញុំ ហើយក៏លើកចិញ្ចើមម្ខាង ។

"នឹកឃើញហើយឬគួរសថាចង់និយាយជាមួយខ្ញុំពីរឿងស្អី"

"លោកនឹងនិយាយពីរឿងថ្ងៃនេះអត់"

"និយាយ"

"តែយើងមិនទាន់ច្បាស់ទេថាអ្វីដែលឃើញគឺអ្វីដែលគិតឬអត់"

"នាងគិតស្អី"

"គឺគិតដូចដែលលោកគិតហ្នឹងហើយ"

"ប្រែថាចិត្តយើងដូចគ្នាហើយអីចឹង នាងលួចចូលចិត្តខ្ញុំមែនទេ"

"នេះយើងនិយាយរឿងតែមួយឬអត់នេ៎ះ ខ្ញុំនិយាយរឿងម៉ាក់របស់ខ្ញុំ វាទាក់ទងនឹងរឿងចូលចិត្ត មិនចូលចិត្តលោកត្រង់ណា មិនបាច់ម៉ោដូររឿងទេ"

កូអឹន ដែលធ្វើមុខលលេងរហូតមកក៏ដូរមកប្រាកដប្រជា÷

"អីចឹងប្រែថានាងគិតដូចខ្ញុំត្រង់ថាម៉ាក់នាងមានសហាយ!"

"ឈប់ភ្លាម លោកគ្មានភស្តុតាង!"

"មិនឃើញចាំបាច់អីមានភស្តុតាងផង រឿងកំប៉ិកកំប៉ុកបែបនេះគ្រាន់តែប្រាប់ប៉ា ប៉ាក៏ស៊ើបដឹងទៅហើយ"

"លោកគួរតែពិសោធសិន វាមិនយុត្តិធម៌ចំពោះម៉ាក់ខ្ញុំទេ បើជាមិត្តភក្តិនឹងគ្នាពិតមែននោះ"

"ប៉ាខ្ញុំស៊ើបដឹងទៅហើយថាមិត្តឬមិនមែន ខ្ញុំជាកូន មានតួនាទីនិយាយ និយាយ និងនិយាយៗ" កូអឹន ស្រែកដាក់មុខខ្ញុំ ហើយចង់ដើរចេញ តែមើលទៅដូចជានឹកឃើញអី ទើបថយមកវិញ "តែខ្ញុំអាចនឹងមិននិយាយ"

"ហឺ? មែនអ្ហ៎ស"

"មែន ព្រោះមើលទៅនាងមិនចង់ឱ្យខ្ញុំនិយាយប៉ុន្មានទេ គឺដូចថាអីចឹង ទើបនឹងបានឱកាសមានជាលើកតំបូង សុខៗម៉ាក់មានសហាយខ្លួនឯងក៏ធ្លាក់ខ្លួនទៅក្រវិញ អ្នកណាចង់ឱ្យនិយាយទៅ"

"វាមិនមែនបែបនោះទេ ខ្ញុំមិនធ្លាប់ចង់បានជីវិតបែបនេះទេ!"

"អ៊ំហ៊ឺ"

"មិនបាច់ម៉ោធ្វើសម្លេងបែបនោះទេ"

"ខ្ញុំមានសំណើ" កូអឹន ក្អក់ ហើយធ្វើឫកវំខានប្រសាទ "បើនាងធ្វើតាម ខ្ញុំនឹងមិននិយាយប្រាប់ប៉ាទេ"

"ចង់ឱ្យខ្ញុំធ្វើអី លោកថាម៉ោ"

ទឹកមុខរបស់ កូអឹន មើលទៅអស់សង្ឃឹមដោយប្រាប់មិនត្រូវដល់ថ្នាក់ខ្ញុំជម្រុញឱ្យគេនិយាយទៅជាមានអារម្មណ៍ខុសឆ្គង គឺមិនមែនថា

មិនយល់ទេថាគេមានអារម្មណ៍យ៉ាងម៉េច ការពិតខ្ញុំក៏យល់ថាជារឿងសមគួរដែលគេគួរតែប្រាប់ចាំគេ តែខ្ញុំក៏ស្រលាញ់ម៉ាក់ខ្ញុំ បើមានអ្វីអាចជួយបន្ធូរបន្ថយបាន ខ្ញុំក៏គួរតែជួយ។

"ទៅសុំបែកពី សាំយ៉ុង ទៅ នេះគឺជាលក្ខខណ្ឌ"

"ឱ្យខ្ញុំទៅសុំបែកពីគេ លោកឡប់សតិទេអ្ហ៎ស!"

"មិនធ្វើក៏មិនថាអីដែរ"

"ធ្វើ!"

កូអ៊ីន ងាកមកសម្លឹងមុខខ្ញុំ÷

"ច្បាស់ហើយ"

"ខ្ញុំនឹងធ្វើ ដើម្បីកុំឱ្យលោកនិយាយ ខ្ញុំនឹងធ្វើគ្រប់យ៉ាង"

កូអ៊ីន ញញើមពេបមាត់ ហើយចាប់ចង្កាខ្ញុំបង្វែរទៅមក÷

"នាងពីតំបូងដែលខ្ញុំជួបនិងពេលនេះមិនដូចគ្នាទេ...ពេលនោះនាងមិនចាប់អារម្មណ៍លុយរបស់ខ្ញុំទៀតផង តែពេលនេះនាងបែរជាបោះបង់អ្វីដែលខ្លួនឯងកំពុងមានចោលមិនបាន" គេលាស់ដៃចេញ "ព្រមធ្វើគ្រប់យ៉ាងទោះជាធ្វើចាបចិត្តអ្នកដទៃដើម្បីបានអ្វីដែលខ្លួនឯងត្រូវការ"

"វាជាសំណើរបស់លោកមិនអីចឹង អាការធ្វើចាបចិត្តអ្នកដទៃដើម្បីបានអ្វីដែលខ្លួនឯងត្រូវការ"

"មិនបាច់មកវាយបកទេ ណ្ហើយ បើនាងសន្យាហើយ ខ្ញុំនឹងមិននិយាយដល់រឿងនេះទៀតទេ តែនាងត្រូវធ្វើឱ្យឃើញថានាងនឹងបែកពីវាពិតមែន"

លើកនេះ កូអ៊ីន ដើរចេញទៅមែនទែន ដោយមិនងាកមកមើលខ្ញុំទៀត វាចំជាលក្ខខណ្ឌដែលវាយប្រហារអារម្មណ៍បានល្អណាស់ តែខ្ញុំមិនច្បាស់ទេថាវាជាការធ្វើបាបអារម្មណ៍អ្នកណាឱ្យប្រាដកទៅ...

វាង កូអ៊ីន ដែលអស់សង្ឃឹមចំពោះខ្ញុំ ឬ សាំយ៉ុង ដែលនឹងត្រូវខ្ញុំសុំបែកផ្លូវ?

ពេលដល់វេលាត្រូវមកអង្គុយជុំគ្នានៅតុបាយពេលល្ងាច កូអ៊ីន ក៏

មើលទៅម៉ាក់ដោយខ្សែភ្នែកពេញចិត្ត ទឹកមុខពព្រឹមពព្រឹមដូចក្អាប់អាថ៌កំបាំងរបស់ផែនដីនេះទុកតែម្នាក់ឯង ចំណែកម៉ាក់ដែលឃើញខ្សែភ្នែកបែបនោះក៏គិតតែអង្គុយរសាប់រសល់ ឯខ្ញុំបានតែអង្គុយស្ងៀម អាហារដ៏ឆ្ងាញ់នៅចំពោះមុខមិនបានធ្វើឱ្យអណ្តាតខ្ញុំមានអារម្មណ៍អីផ្សេងទេក្រៅអីតានតឹង រហូតដល់ពេលញ៉ាំបាយកន្លងផុតទៅ អ៊ំប្រុសក៏មើលទៅ កូអឹន ដែលថ្ងៃនេះស្ងប់ស្ងាត់ខុសប្រក្រតីដោយការប្រុងប្រយ័ត្ន ។

"ម៉េចក៏ថ្ងៃនេះមិនញ៉េះញ៉ោះ ច្បាស់ជាមានរឿងអីមិនខាន អូនថាអីចឹងទេ"

"គ្មានអីគឺល្អហើយ" ម៉ាក់តបដោយសម្លេងញ័រៗដូចត្រូវជំទាស់ផ្ទុះចូលសណ្ឋិត ។

"មានអីអត់ហ្នឹង ម៉េចក៏អូនញ័រសាច់ម្ល៉េះ"

"ប្រហែលមិនស្រួលខ្លួន"

"កើតអីធ្ងន់ធ្ងរទេ"

"មិនអីទេ សម្រាកបន្តិចទៅប្រហែលជា តែនឹងល្អជាងបើបានទៅដើរលេងនៅបរទេសចាប់ៗ"

"បាទៗ ចាំបងឈ្លៀវការងាររួច យើងនឹងទៅ អូនចង់បានអី បងឱ្យបានទាំងអស់ អីចឹងបងឡើងទៅងូតទឹកសិនហើយ ស្អិតខ្លួនណាស់"

អ៊ំប្រុសដើរឡើងទៅខាងលើ នេះហើយទើបជាឱកាសដែលម៉ាក់អូសខ្ញុំទៅកន្លែងស្ងាត់ គឺសួនក្រោយផ្ទះដែលមានតែមូសជាសាក្សីនិងដឹងថាយើងកំពុងនិយាយអ្វី ។

"ម៉ាក់មិនទុកចិត្តវាទេ"

"អ្នកណា...កូអឹន ឬ"

"មានអាណាទៀត វាគួរឱ្យចម្លែកទេ ពេញមួយថ្ងៃដែលជួបមុខគ្នា វាបែរជាមិនព្រមនិយាយរឿងដែលកើតឡើង វាច្បាស់ជាមានផែនការស្អីហើយ"

"បែបគ្មានអីទេ ម៉ាក់សប្បាយចិត្តទៅ"

"ឱ្យម៉ាក់សប្បាយម៉េចកើត"

"ហើយម៉េចក៏ម៉ាក់សប្បាយចិត្តមិនកើតលើអ្វីដែលម៉ាក់ធ្វើ ម៉ាក់ថាត្រឹមត្រូវហើយនោះ គឺម៉ាក់និយាយដោយខ្លួនឯងមិនមែនឬ ថាប្រុសម្នាក់នោះជាមិត្តភក្តិ ឬថាមិនមែនទេ"

ទាំងដែលវាមិនមែនជាចម្លើយដែលយ៉ាប់ តែម៉ាក់បែរជាអាក់អួល ឆ្លើយមិនបាន នោះហើយដែលធ្វើឱ្យខ្ញុំប្រាកដចិត្តថាប្រុសម្នាក់នោះលើកពីមិត្ត ភាពអស់សង្ឃឹមចូលមកជ្រៀតជ្រែកពេញបេះដូងខ្ញុំ នេះខ្ញុំកំពុងតែជួយម៉ាក់បិទបាំងកំហុសដែលមិនអាចលើកលែងឱ្យបានពីក្រុមគ្រួសារ កូអឹន ម៉េចចាំបាច់ធ្វើបែបនេះ!

"គេជាស្អីគឺជារឿងផស់ម៉ាក់ ឯងមិនចាប់រវល់"

"មិនមែនម៉ោពីខ្ញុំទេផ្អើសទើបម៉ាក់រួចខ្លួន"

"ឯងចង់មានន័យថាម៉េច"

"សរុបទៅម៉ាក់ប្រើជីវិតតាមបែបរបស់ម៉ាក់ទៅបានហើយ ខ្ញុំមិនជួយអីម៉ាក់ទៀតទេ នេះជាលើកទីមួយនិងចុងក្រោយ!"

ហៅបានថាជាលើកតំបូងរបស់ខ្ញុំក៏បាន ដែលធ្វើចរិតមាំមួនដាក់ម៉ាក់យ៉ាងនេះ ពេលនិយាយចប់ ខ្ញុំក៏ដើរចេញ តែមកប្រឈមមុខនឹង កូអឹន ដែលដូចជាលួចមើលមុនទៅហើយ ។

"ម៉ោឈរត្រង់នេះយូរហើយនៅ"

"គឺគិតថាយូរអាចនឹងបានឮអ្វីទាំងអស់ អឺហឺ...កតញ្ញូផស់គេ ធ្វើឱ្យខ្ញុំ អ្នកដែលមិនព្រមនិយាយការពិតអីប្រាប់ចាំ ស្តាប់ទៅដូចក្លាយជាមនុស្សអាក្រក់ហើយ"

ខ្ញុំខាំមាត់សឹងតែបែកឈាមទៅហើយព្រោះតែអាម៉ាស់មុខនិងមានអារម្មណ៍ខុសច្ចង ។

"បើម៉ោដើម្បីឡូកឡឺយ ក៏ថយទៅ"

"ខ្ញុំមិនបានម៉ោដើម្បីឡូកឡឺយ តែម៉ោដើម្បីបញ្ជាក់"

"បញ្ជាក់ស្អី"

"សន្យាដែលនាងយកមកបិទមាត់ខ្ញុំមិនឱ្យនិយាយ នាងត្រូវតែធ្វើតាមសម្តីខ្លួនឯងដូចគ្នា!"

១៧

ខ្ញុំកាន់ថង់ខោអាវមកឱ្យ សាំយ៉ុង វិញនៅពេលឃើញគេមកដល់សាលាហើយ គេធ្វើមុខមីងមាំង នោះហើយដែលកាន់តែធ្វើឱ្យខ្ញុំមានអារម្មណ៍ពិបាកចិត្ត ។

"ខ្ញុំយកមោឱ្យវិញ"

"ឱ្យវិញធ្វើអី"

"ខ្ញុំថាខ្ញុំមិនសមគួរទឹងបានរបស់អស់នេះទេ យកវិញទៅ"

ខ្ញុំសឹងតែយកថង់ញាត់ក្នុងដៃគេ តែ សាំយ៉ុង បែរជាវាសចេញដោយការមិនពេញចិត្ត ។

"ខ្ញុំទិញឱ្យហើយគឺមិនយកវិញទេ ហើយខ្ញុំក៏ពាក់ខោអាវអស់នេះមិនកើតដែរ យើងមោចូលសាច់រឿងល្អជាង មានអីកើតឡើងឱ្យប្រាកដទៅ ម៉េចក៏សុខៗយកខោអាវមោឱ្យវិញ"

"លោកកំពុងតែធ្វើឱ្យខ្ញុំពិបាកចិត្តហើយ"

"ពិបាកចិត្តរឿងអីក៏និយាយមោ" សាំយ៉ុង លូកដៃមកលេងសក់ខ្ញុំ តែខ្ញុំឈានថយយ៉ាងសុភាព "ហឺ? ស្អីគេ"

"ខ្ញុំគិតច្បាស់លាស់ហើយ យើងមិនគួរសេពគប់គ្នាទេ"

អារម្មណ៍ខុសច្គងចាក់ទម្លុះពីក្បាលដល់ចុងជើង ហើយហូរមកកកនៅក្នុងក្បាលវិញ ខ្ញុំចាប់ផ្តើមមានអារម្មណ៍ថាវិលវល់ ការប្រាប់ថាសុំបែកពីអ្នកណាម្នាក់គឺវាបែបនេះអ្ហែង ព្រោះយើងមិនអាចស្មានដឹងទេថាគេនឹងមានអេហ្យហេកតីបែបណា ។ ខ្ញុំបិទភ្នែកជិតមិនហ៊ានសូម្បីតែប្រសព្វភ្នែក សាំយ៉ុង តែថា...បែរជាមានសម្លេងសើចតិចៗចេញពីអ្នកនៅចំពោះមុខដែលវាខុសពីការគិតរបស់ខ្ញុំឆ្ងាយណាស់ ។

"ស្អីដែលធ្វើឱ្យនាងគិតថាយើងមិនគួរសេពគប់គ្នាទេ"

"គឺ...គឺគ្រាន់តែមិនទំនង ខ្ញុំមិនចូលចិត្ត សរុបទៅថាយើងមកធ្វើជាមិត្តនឹងគ្នាដូចដើមទៅ យើងសន្យាគ្នាតាំងពីដំបូងហើយថាបើមិនមែន គឺអាចបដិសេធអ្នកម្ខាងទៀតបាន ហើយនេះទើបនឹងដើរលេងជាមួយគ្នាជាលើកដំបូង ខ្ញុំក៏មានអារម្មណ៍ថាមិនមែនទៅហើយ ដកខ្លួនពេលនេះនៅទាន់ លោកថាអីចឹងទេ"

"អីចឹងតាមចិត្តនាង"

"មែនឬ៎ស"

"តែខ្ញុំយកខោអាវនេះវិញមិនបានទេ គិតថាខ្ញុំឱ្យនាងជាកាដូនៅថ្ងៃដេតលើកដំបូងនិងចុងក្រោយទៅចុះ"

"សាំយ៉ុង..."

"ម៉េចចាំបាច់ធ្វើសម្លេងបែបនោះ ខ្ញុំមិនបានកើតស្អីទេ"

គេធ្វើសម្លេងពព្រាយហាក់ដូចជាគ្មានអ្វីកើតឡើង ការប្រាប់ថាសុំបែកគ្នារបស់ខ្ញុំគឺត្រឹមតែជាខ្យល់បក់មកហើយក៏បក់ហួសទៅ ។

"ច្បាស់ហើយថាមិនអី"

"បើកើតអីមែន ខ្ញុំនឹងយំដាក់មុខនាងហើយ បំបែកគ្នាទៅរៀនល្អជាង តែនាងកុំដើរទៅប្រាប់គេឯងថាសុំបែកពីខ្ញុំ វាខូចក្រឌីត យល់?"

វានិយាយយ៉ាងនេះឬនេ៎ះ ហើយដែលខ្ញុំដេកខ្វល់ចិត្តអស់ពេញមួយយប់ថ្ងៃសៅរ៍ដល់ថ្ងៃអាទិត្យ ហើយព្រឹកថ្ងៃចន្ទមករៀននេះវាគ្មានន័យអីទេមែនទេ តែក៏ល្អចខូចចិត្តតិចតួចដែលគេគ្មានអារម្មណ៍ថាសោកស្ដាយ ខូចចិត្ត ឬ សម្ដែងអ្វីពេលខ្ញុំសុំបែក តែប្រុសព្រានមានសង្សារច្រើនគឺបែបនេះ ប្រហែលជាស៊ាំនឹងអ្វីបែបនេះទេដឹង ។

ពេល សាំយ៉ុង ដើរចេញទៅហើយ ខ្ញុំក៏ជួប កូអឺន ដែលឈរចាំនៅមុខថ្នាក់រៀន ហើយខ្ញុំក៏ដឹងភ្លាមថាគេមកទីនេះដើម្បីអ្វី ។

"មិនចាំបាច់តាមដានលទ្ធផលដល់ថ្នាក់នេះក៏បាន ខ្ញុំសុំបែកពីគេហើយ"

"ចុះម៉េចក៏កាន់ថង់របស់របរស្អីអស់នោះមោទៀត"

"គេមិនយកទេ សាំយ៉ុង ប្រាប់ថាបើយកក៏ពាក់មិនកើតដែរ ឱ្យជា

កាដូថ្ងៃដេតលើកតំបូង"

"ចោះចោលទៅ"

"ឡប់សតិទេអ្នកស ហេតុអីខ្ញុំត្រូវចោះចោល!"

"ខ្ញុំទិញថ្មីឲ្យ មិនបាច់ពាក់របស់វាទេ"

"វាច្រើនជ្រុលហើយ ឲ្យសុំបែកពីគេក៏ខ្ញុំធ្វើហើយ កុំបង្ខាប់គំរាមគ្នាពេកមើល៍!"

ខ្ញុំគំហកដាក់មុខគេ មុននឹងដើរចូលទៅក្នុងថ្នាក់ មិត្តភក្តិនាំគ្នាអើត-កមើលដោយការចង់ដឹង តែពេលឃើញខ្សែភ្នែកមិនទទួលភ្ញៀវរបស់ខ្ញុំក៏ងាកទៅនិយាយរឿងថបកឹងបន្ត កើតមកជាខ្ញុំចំដាលំបាកអីក៏យ៉ាងនេះ ចង់មានសង្សារម្នាក់ក៏មានឧបសគ្គ ចង់ឆ្កួតហើយ!

ចេញពីរៀន...

"ទៅផ្ទះមុនចុះអ៊ំ ថ្ងៃនេះខ្ញុំមានធុរៈត្រូវធ្វើ"

ខ្ញុំប្រាប់អ៊ំតែកុងមិនឲ្យចាំ ព្រោះថ្ងៃនេះខ្ញុំតាំងចិត្តថាទៅចាំចាំនៅផ្ទះគាត់ តែពេលចោះជំហានចេញទៅផ្លូវម្ខាងទៀតក៏ត្រូវចាប់គ្រវែងមករកឡានវិញដោយដៃដ៏រឹងមាំរបស់ កូអ៊ីន ដែលផុសមកពីក្រោយខ្នង ។

"នាងចង់ទៅធ្វើធុរៈនៅឯណា ចាំខ្ញុំកំដរ"

"មិនបាច់ ខ្ញុំមានរឿងចង់ចាត់ការដោយខ្លួនឯង"

"មិនបាន ក្នុងឋានៈខ្ញុំជាអ្នករួមគំបូលជាមួយ ខ្ញុំគួរតែដឹងថា១ថ្ងៃៗនាងធ្វើអីខ្លះ អីយ៉ា...ថ្នាក់ម៉ាក់នាងនៅខ្ញុំដឹង ម៉េចក៏ខ្ញុំដឹងរឿងនាងមិនបាន"

"ចុងកូអ៊ីន!"

"វាយប្រហារចំៗទៀតហើយ" កូអ៊ីន ធ្វើឫកពារទ្ធត់បែបរំខានចិត្ត "ណ្ហើយៗ ខ្ញុំមិននិយាយរឿងនោះទៀតក៏បាន ហើយនាងចង់ទៅធ្វើធុរៈនៅឯណា ចាំខ្ញុំកំដរ"

"មិនបាច់ ខ្ញុំមិនទៅ"

"តែខ្ញុំមានកន្លែងដែលត្រូវទៅ"

"ជារឿងផស់លោក"

"ហើយនាងក៏ត្រូវទៅដែរ"

"ទាក់ទងស្អីនឹងខ្ញុំ វ៉ាយ! មិនឃើញចាំបាច់អឺរុញក្បាលខ្ញុំទេ ខ្ញុំឡើងខ្លួនឯងបាន!"

ពេលត្រូវបង្គាប់ឱ្យទៅជាមួយ ខ្ញុំក៏អង្គុយធ្វើមុខក្រមូវដូចបង្គាប់ឱ្យទៅបឹតឈាមថ្កៃពេញមួយផ្លូវ ហើយដែលគួរឱ្យចម្លែកចិត្តជាងអ្វីៗទាំងអស់គឺ គូអឹន នាំខ្ញុំមកផ្សារទំនើប ហើយអូសទៅហាងខោអាវដ៏សែនថ្លៃនិងកាលីប ។

"រើសទៅ"

"ហឺ? នាំខ្ញុំម៉ោទីនេះធ្វើអី ក្រែងប្រាប់ថាទៅធ្វើធុរៈផ្ទាល់"

"នេះហើយធុរៈរបស់ខ្ញុំ ខ្ញុំតាំងចិត្តនាំនាងម៉ោទិញខោអាវ"

"មានកម្មវិធីអីឬ"

"គ្មានកម្មវិធីទិញមិនបានឬយ៉ាងម៉េច គឺខ្ញុំមាន!"

ខ្ញុំមើលមុខគេដោយអារម្មណ៍ចម្លែកៗ ហើយផ្កាយស្នាមញញឹមចេញមកទោះជាប្រឹងទប់ឱ្យមុខមើលទៅមាំក៏ដោយ គូអឹន បែបមើលដឹង ទើបមុខក្រហម ហើយឡូឡា ។ 143

"មិនចាំបាច់ម៉ោធ្វើមុខបែបនោះទេ គឺប្រាប់ថាម៉ោទិញឱ្យ ម៉េចនាងចាំបាច់ទៅទទួលរបស់អ្នកដទៃ ផ្ទះយើងក៏មានមហាមាន ខ្ញុំមិនត្រូវការឱ្យអ្នកផ្សេងមើលមកថាអ្នកនៅក្នុងផ្ទះរបស់ខ្ញុំជាអ្នកសុំទាន!"

"មិនឃើញចាំបាច់អីនិយាយផ្លូវផ្លូវដល់ម្លឹងទេ និយាយត្រឹមតែថាខ្ញុំចង់ទិញឱ្យនាង ធម្មតាៗក៏ខ្ញុំយល់ទៅហើយ"

"មិនបានចង់ទិញឱ្យអីបន្តិចទេ គឺគ្រាន់តែ...គ្រាន់តែ...គ្រាន់តែទៅរើស វាងាប់ទេនេះ!"

"ហឹស អីចឹងខ្ញុំក៏មិនក្រែងចិត្តដែរ លោកបើកឱកាសឱ្យទេ"

"ចាំមើលទៅថាខ្ញុំ និង សាំយ៉ុង មួយណាមើលថែនាងបានល្អជាង យកទៅ ចង់បានស្អីក៏រើសទៅ!"

ខ្ញុំមើលឫកពាក្មេងក្អាងរបស់ គូអឹន ដោយការជិនឆ្អន់ ហើយស្ទុះចូលទៅយកខោអាវដោយមិនមើលពីរូបរាង ពណ៌ ឬទំហំ ក្រៅពីស្លាក

តម្លៃ ចូលទៅល ហើយចេញមកបង្ហិលខ្លួនឱ្យ កូអឹន មើលប្រហែលជា ១០ឈុត ចូលចិត្តឬអត់ ខ្ញុំចេះតែយកសិនទៅ ព្រោះវាថ្លៃសមចិត្ត តែដែលគួរឱ្យឈឺចិត្តគឺគេមិនញាប់ញ័រអីទាំងអស់ ក្រៅពីញញឹមពេលខ្ញុំដើរចេញមកដោយឈុតថ្មី ។

"នាងពិតជាស្រីស្អាតមែន"

"=O="

"តែនឹងស្អាតជាងនេះបើនាងស្រាត"

"អាយ!"

"លេងសើចទេ យកស្អីទៀតទេ ទៅរើសឱ្យអស់ម៉ោ គ្រាន់តែមានកាតមួយសន្លឹក ចូតខ្វាកៗ នាងនឹងបានខោអាវអស់នេះទៅផ្ទះហើយ"

"ជ្រេញ! មិនបានរកដោយខ្លួនឯងសោះ នៅម៉ោក្អេងក្អាង"

"បើមានអ្នកផ្សេងរកឱ្យចាយហើយ ហេតុអីខ្ញុំត្រូវទៅហត់នឿយរកម៉ោធ្វើអី ម្យ៉ាងទៀតម៉ាក់នាងក៏ដូចខ្ញុំដែរ ព្រោះប៉ាខ្ញុំរកលុយបានទើបព្រមរៀបការជាមួយ"

ពេលគេនិយាយចប់ ខ្ញុំក៏គ្រវែងខោអាវអស់នោះចោលដោយការខឹងសម្បា កូអឹន មើលអ្វីដែលខ្ញុំធ្វើដោយការអៀសចិត្ត តែក៏មិនព្រមបន្ទាបខ្លួន ។

"នាងធ្វើឆ្កួតស្អី ដឹងទេថាឈុតអស់នេះថ្លៃណាស់"

"ខ្ញុំមិនយកមិនអីទេ ថ្ងៃនេះប៉ុណ្ណឹងបានហើយ!"

"នាងត្រូវតែយក ខ្ញុំតាំងចិត្តទិញឱ្យហើយ"

កូអឹន រើសឈុតទាំងនោះញាត់ក្នុងដៃខ្ញុំដល់ថ្នាក់ក្រសោបពេញដៃតែម្តង ព្រោះវាច្រើនពេក ហើយអូសទៅកន្លែងគិតលុយដោយការប្រើកាតចូតខ្វាកៗរបស់គេ តែហើយវាដូចជាដែនដីនេះរលាយពេលអ្នកគិតលុយមើលមុខគេដោយទឹកមុខពិបាកចិត្ត ។

"លោក កាតនេះត្រូវបានបិទហើយ"

"ស្អីគេ ម៉េចនឹងអាចទៅរួចទៅ នេះជាកាតមាសណា៎"

"គឺប្រើបានពេលទៅព្យាបាលនៅពេទ្យ ៥ពាន់រ៉ុន" ខ្ញុំ ។

"បិទមាត់!"

"ហឹស"

"ម៉ាស៊ីនទាងខូចអត់ហ្នឹង ចូតម្ដងទៀតទៅ!"

តែគ្រប់យ៉ាងគឺនៅតែដូចដើម កាតប្រើការមិនបាន កូអីន ទាំងមួម៉ៅ ក្ដៅក្រហាយ ខូចអារម្មណ៍ ដោយទាំងខ្ញុំឲ្យខូចចិត្តដែរ យើងដើរចេញពីហាងទាំងអាម៉ាស់ រើសខោអាវឡើងដប់ម្ភៃឈុត តែកាតចូតមិនបាន ។

"ខ្ញុំត្រូវទៅនិយាយជាមួយចា៎ ម៉េចនៅសុខៗម៉ោបិទកាតខ្ញុំអីចឹង វាច្បាស់ជាមានមូលហេតុ"

"ចិត្តត្រជាក់សិនទៅ គាត់ប្រហែលជាឃើញលោកចាយលុយច្រើនពេក"

"នេះច្បាស់ជាប្ដីដៃម៉ាក់នាងហើយ"

"កុំម៉ោចោទម៉ាក់ខ្ញុំ"

"បើមិនមែនម៉ាក់នាង ចុះជាអ្នកណា ខ្ញុំត្រូវដឹងរឿងនេះឲ្យបាន!"

កូអីន ដើរីបៗទៅដល់ចំណត ហើយបញ្ជាឲ្យតៃកុង ដឹកទៅផ្ទះជាបន្ទាន់ ពេលមកដល់ក៏ត្រូវជួបនឹងភាពអស់សង្ឃឹមដែលធ្វើឲ្យគេខឹងកាន់តែខ្លាំងពេលអ៊ំប្រុសមិនទាន់មកវិញ គេទៅក៏មិនទទួល ថែមទាំងអ្នកបម្រើដែលរត់ឲ្យប្រវាត់ពេញផ្ទះមិនចាប់អារម្មណ៍នឹងយកទឹកយកភក់ឲ្យគេដឹកទៀត ។

"កើតស្អីអស់ហើយហ្នឹង រត់រកស្អី ហេ៎! ខ្ញុំសួរថារត់ធ្វើស្អី!"

គេចាប់ទាញដៃក្មេងស្រីម្នាក់ដែលមានតួនាទីជាអ្នកបោសជូតឲ្យងាកមកនិយាយ ទឹកមុខក្មេងម្នាក់នេះមើលទៅមិនល្អទេ ថែមទាំងធ្វើមុខដូចជាចង់យំទៀតផងពេលដែលត្រូវគំហក ។

"យើងកំពុងតាមរកអ្នកនាងតូច"

"រកអ្នកនាងតូច រកធ្វើអី"

"បាត់ខ្លួន"

"បាត់ខ្លួន ឡប់សតិអ្ហែស!" កូអីន ស្រែកលាន់ដោយកំហឹង "ប្អូនខ្ញុំមិនដែលរត់លេងកន្លែងណាឆ្ងាយក្រៅពីបន្ទប់ទេ ម៉េចនៅសុខៗទៅជាបាត់ខ្លួនបាន បុះអ្នកមើលថែ"

"កំពុងតែតាមរកដែរ"

ពេលនេះមើលទៅ កូអ៊ីន ដូចជាភ្លេចរឿងកាតគ្មានលុយហើយ គេស្ទុះរត់តាមរកប្អូនពេញផ្ទះ ។ ស្ថានការណ៍ចាប់ផ្ដើមតានតឹងពេលនាឡិកាដើរបានកន្លះម៉ោងទៀត នៅខណៈដែលយើងកំពុងខ្វល់ ម៉ាក់ក៏ដើរចុះមកពីខាងលើដោយឬកពាក្យឲ្យស្អប់ខ្ពើម ។

"ធ្វើស្អី"

"អ្នកនាងតូចបាត់ខ្លួនហើយម៉ាក់"

"ក្មេងម្នាក់នោះបាត់ខ្លួនវាទាក់ទងអីទីងឯងដែរ ទុកឲ្យអ្នកផ្ទះនេះតាមរកទៅ"

ម៉ាក់ដែលមើលទៅដូចមិនក្ដៅក្រហាយអីទើបធ្វើឲ្យខ្ញុំខឹង ហើយសម្លឹងមុខគាត់បែបមិនពេញចិត្តនឹងទង្វើអត់ចិត្តនោះ ។

"ក្មេងបាត់ទាំងមូល ទោះជាម៉ាក់មិនស្រលាញ់ ក៏គួរតែព្រួយបារម្ភខ្លះផង"

"គឺមិនមែនជាកូនម៉ាក់ហ្នឹងណាំ ម្យ៉ាងទៀត...ក្មេងខុសប្រក្រតីបែបនោះបាត់ពីផ្ទះកាន់តែល្អ ម៉ាក់ថាវាជាភាពអាម៉ាស់របស់អាប្រុសឯងដែលមានកូនកើតរោគចម្លែក ចង់ថាធម្មតាក៏មិនមែន អន់បញ្ញាក៏មិនទំនង"

"បិទមាត់ភ្លាម!"

កូអ៊ីន ដែលដើរកាត់មកបានឮល្មមក៏ស្រែកលាន់ហាក់ដូចមេឃមានរន្ទះ ម៉ាក់ក៏ភ្ញាក់ព្រើតព្រោះមិនទាន់បានតាំងខ្លួន ។

"ម៉េចចាំបាច់ស្រែក លោះព្រលឹងអស់ហើង!"

"ស៊ីដេកដោយសារគេហើយនៅម៉ោឈរនិន្ទាកូនគេទៀត ភាពខ្មាសអៀនគ្មានខ្ញុំមិនថាទេ តែគ្មានទឹកចិត្តបែបនេះវាជ្រុលពេកហើយ សួរតាមត្រង់ នេះជាម៉ែនាងមែន ឬគេរើសនាងម៉ោចិញ្ចឹមទេ!" កូអ៊ីនងាកមកសួរខ្ញុំ ធ្វើឲ្យម៉ាក់កញ្ជ្រោលភ្លាម ។

"អាក្មេងច្កួត កុំម៉ោរាលដាលដាក់ខ្ញុំបែបនេះ តិចទះបែកមាត់"

"ចូលម៉ោ!"

កូអ៊ីន ក្ដាប់ដៃណែនត្រៀមប្រដាល់រួចរាល់ តែខ្ញុំគោងដៃជាប់

ម៉ាក់ឃើញបែបនោះក៏ស្ទុះមកទាញខ្ញុំឱ្យទៅឈរក្បែរ ។

"ទៅគោរពវាធ្វើអ្វី ឱ្យប្រឡាក់ដៃ ហឺស ស៊ូមិនបានក៏ប្រើកម្លាំងមនុស្សគ្មានខួរ គិតបានតែប៉ុណ្ណឹង"

"ចុះអ្នកណាទៅដែលប្រាប់ថាចង់ទះមាត់ខ្ញុំ ទោះខ្ញុំគ្មានខួរ តែក៏មានចិត្ត មិនដូចអ្នកខ្លះ ភាពអៀនខ្មាសក៏គ្មាន ចិត្តក៏គ្មាន ហិចហើរហ៊ីហារជាមួយប្រុសផ្សេង"

"ឈប់ភ្លាមអាក្មេងឆ្កួត"

"មិនឈប់"

"អីចឹងតើបានជាប៉ាឯងមិនស្រលាញ់ ព្រោះឯងជាក្មេងបែបនេះ"

"វាជារឿងផ្ទាល់ខ្លួនខ្ញុំ ក្រុមគ្រួសារខ្ញុំ នាងមិនបាច់ចេះដឹង"

"មិនចេះមិនបាន ព្រោះមរតកពាក់កណ្ដាលរបស់ឯងជិតក្លាយជារបស់ខ្ញុំហើយ ភ្លេ ប្អូនស្រីឯងបាត់ខ្លួន ខ្ញុំនឹងបានថែមទៀត ថ្មើរនេះម៉េចម៉ាហើយណា ច្បាស់ជាយំហើមមុខព្រោះខ្លាចងងឹតហើយ"

ខ្ញុំមើលមុខម៉ាក់ដែលរបូតសម្ដីមកគួរឱ្យសង្ស័យ÷

"នេះម៉ាក់ដឹងមែនទេថាអ្នកនាងតូចនៅឯណា"

"មិនដឹង!"

"ម៉ាក់មិនបាច់កុហកទេ មិញម៉ាក់របូតមាត់ចេញមកហើយ ម៉ាក់ដឹងមែនទេថាអ្នកនាងតូចនៅឯណា"

"រកអ្នកនាងតូចឃើញហើយ រកឃើញហើយ"

អ្នកបម្រើរត់មករាយការណ៍ប្រាប់ ពេលឮដូច្នោះ កូអឺន ក៏ឈប់ឈ្លោះជាមួយម៉ាក់ ហើយចេញទៅភ្លាម ។ ម៉ាក់បានតែឈរសើចសមចិត្តហាក់ដូចជាមេមត់ចិត្តយក្សរហូតដល់ខ្ញុំត្រូវឈានថយក្រោយ ។

"ឯងវាស្អីណាស់ណា ម៉េចក៏ចាំបាច់ធ្វើឬកស្អប់ខ្ពើមម៉ាក់ដែរ"

"ម៉េចក៏ម៉ាក់ធ្វើអីចឹង កូសង មិនដឹងរឿងអីទេ"

"គឺម៉ាក់ជ្រេញ អាកូអឺន ហ្នឹងណា៎ ម៉ាក់ត្រូវការឱ្យវាដឹងថាកុំម៉ោចង់ល្បែងជាមួយម៉ាក់ ថ្ងៃនេះយកមីក្មេងនោះទៅលាក់ ថ្ងៃក្រោយអាចនឹងសម្លាប់ចោលក៏ថាបាន"

"ម៉េចក៏ម៉ាក់ក្លាយជាមនុស្សបែបនេះ"

"យើងបែបនេះតាំងពីយូរហើយ ឯងមិនដឹងទេរឺញទេ"

"ចុះនេះម៉ាក់យក កូសង់ ទៅលាក់នៅឯណា"

"បន្ទប់ដាក់របស់នៅចុងសួន ចោះរបស់លេងឲ្យតែពីរបីទៅ វាក៏នៅក្នុងនោះបានពេញម៉ាថ្ងៃទៅហើយ"

"ម៉ាក់!!!"

"ឯងក៏ម្នាក់ដែរ ម៉េចក៏ចូលចិត្តដំឡើងសំលេងដាក់ម៉ាក់ម្លេះ ម៉ាក់ជាម៉ាក់ឯង"

"ស្រីបិសាច!" កូអ៊ីន ដឹកដៃ កូសង់ ចូលមក ហើយស្រែកលាន់ព្រមទាំងចង្អុលមុខម៉ាក់ "បើថ្ងៃនេះខ្ញុំមិនសម្លាប់នាង ខ្ញុំមិនមែនជាមនុស្សទេ!"

"កូអ៊ីន ចិត្តត្រជាក់"

"ឯងមានខួរក្បាលអីខ្ញុំបាន វ៉ាយ!"

១៨

កូអឹន លែងដៃប្អូនស្រី ស្ទុះចូលមកប្រចាប់-កម៉ាក់ ហើយគ្រវែងទៅស្លាបលើឥដ្ឋ កម្លាំងកំហឹងរបស់គេហាក់ដូចជាព្យុះកំបុតត្បូង មិនថាអ្នកណាចូលទៅហាមក៏ត្រូវគ្រវាសចេញដោយមិនចាប់អារម្មណ៍មុខព្រះណាទាំងអស់ ។

"ស្រីបិសាច ស្រីឃោរឃៅ ឯងធ្វើដាក់អ្នកដែលគ្មានផ្លូវស៊ូបែបនេះបានយ៉ាងម៉េច ឯងចង់ធ្វើអី ម៉ោធ្វើដាក់ខ្ញុំម៉ោ"

"ខ្ញុំច្បាស់ជាធ្វើដាក់ឯង មិនបាច់ពន្យុះទេ"

"អី អីចឹងហត់ម៉ោ"

ម៉ាក់ចាប់ផ្ដើមមុខក្រហម សរសៃឈាមនៅក្នុងភ្នែកឡើងចោ់ង ខ្ញុំមិនដឹងថាហាមអាការៈស្រេកឈាមរបស់ កូអឹន យ៉ាងម៉េច ទើបសម្រេចចិត្តយកគោមភ្លើងនៅលើតុម្ដុំនោះវាយក្បាលគេ កូអឹន លែងដៃម៉ាក់ ហើយចាប់ក្បាលខ្លួនឯងត្រង់ម្ដុំដែលត្រូវវាយ ក៏ឃើញថាមានឈាមជ្រាបចេញមក មុននឹងមើលមុខខ្ញុំ ។

"នាងចង់ងាប់ម្អ៉ស"

"ឈឺ...ឈឺអត់"

"អីចឹងខ្ញុំដាក់នាងម្ដងមើលី អ៊ូយ!"

ម៉ាក់យកបំណែកកញ្ចក់ដែលរាយចាយពេញនោះមកចាក់ដៃគេទាល់តែចេញឈាម ហើយរុញឱ្យខ្ទាតទៅឆ្ងាយ ។

"ឯងគិតថាច្ចតបានតែម្នាក់ឯងទេអ្ហ៎ ខ្ញុំនឹងធ្វើឱ្យមើលថាមនុស្សពិតប្រាកដវាយ៉ាងម៉េច" ម៉ាក់យកអំបែងកែវនោះអារបាតដៃខ្លួនឯងទាល់តែចេញឈាម ខ្ញុំមើលទង្វើនោះដោយភាពស្រឡាំងកាំង ។

"ម៉ាក់ច្កួតហើយឆ្កួស ម៉េចក៏ធ្វើអីចឹង"

"ឯងមិនចាំបាច់ម៉ោវល់ទេ!"

និយាយចប់ ម៉ាក់ក៏អារត្រង់នេះត្រង់នោះ ធ្វើឱ្យ កូអ៊ីន ដែលឆ្កួតពីតំបូងទៅជាច្ងល់ ហើយងាកមករកខ្ញុំបែបសុំជំនួយ មិនមែនទេ សុំយោបល់និងជួយអធិប្បាយថាម៉ាក់ចង់ធ្វើអី មួយសន្ទុះក្រោយម៉ាក់ក៏ចោះបំណែកកញ្ចក់ចោល ហើយកណ្ឌាមចាក់តាមដងខ្លួន ។

"មានតែមនុស្សឆ្កួតប៉ុណ្ណោះដែលធ្វើបែបនេះបាន"

"ហើយខ្ញុំជាមនុស្សឆ្កួតដែលកម្ចាត់ឯងចេញឱ្យបាននៅថ្ងៃនេះ"

"កើតអី!"

អាំអច្ឆរិយៈ ដែលមិនដឹងមកពីអង្កាល់ ព្រោះយើងមិនបានសង្កេតថាមានសម្លេងឡានចូលផ្ទះ មើលហេតុការណ៍ដោយការចម្លែកចិត្ត ហើយក៏ស្លើពេលឃើញឈាមប្រឡាក់ពេញខ្លួនម៉ាក់ ខ្ញុំដៅថាម៉ាក់គួរតែបានឮសម្លេងឡាន ទើបប្រើពេលវេលាដែលឡានចូលចំណត ធ្វើបាបខ្លួនឯងដើម្បីហេតុការណ៍នេះ ។

អស្ចារ្យ...!

"កូនប្រុសបងឆ្កួតហើយ ចូលមកច្របាច់-កអូន ហើយគំរាមថានឹងសម្លាប់អូនទៀត"

"ស្អីគេ!" អាំប្រុស ។

"ទេ៎ ស្រីឆ្កួត នាងនិយាយស្អីឱ្យវាទំនងបន្តិចទៅ ទោះខ្ញុំចង់សម្លាប់នាងមែន តែខ្ញុំក៏មិនមែនជាមនុស្សចិត្តយក្សគិតចង់ធ្វើឱ្យមនុស្សហូរឈាមបែបនេះទេ មិនជឿសួរអ្នកបម្រើក៏បាន គ្រប់គ្នាសុទ្ធតែឃើញ"

តែមើលទៅអ្នកបម្រើដូចជាខ្លាចលោកស្រីថ្មីដូចជាម៉ាក់ខ្ញុំដាងទើបបានតែឈ្ងោកមុខមិនហ៊ាននិយាយអ្វីទាំងអស់ នោះហើយដែលធ្វើឱ្យ កូអ៊ីន ឡូឡា ។

"ស្អីគេ ឈ្ងោកមុខធ្វើអី ឃើញស្អីក៏និយាយមោ!"

ផាច់!

អាំប្រុសដើរទៅឈប់ពីមុខកូនប្រុស ហើយទះគេអស់ទំហឹង កូអ៊ីនជ្រមិលថយក្រោយ ហើយត្រឡប់ក្បាលទៅមកដោយការងឿងឆ្ងល់ មុន

ទឹងសម្លឹងមុខឪពុក ព្រមទាំងស្រែកលាន់÷

"ម៉ោទះខ្ញុំធ្វើអី ខ្ញុំមិនបានធ្វើស្អីបន្តិចទេ"

"ឯងជាមនុស្សប្រុសអត់ ឯងធ្វើគឺត្រូវតែព្រមទទួលថាធ្វើ ឬឯងចង់ប្រាប់ថាប្រពន្ធខ្ញុំធ្វើបាបខ្លួនឯង"

"គឺវាធ្វើបាបខ្លួនឯងមែន"

ផាច់!

អ៊ំប្រុសទះម្តងទៀត ធ្វើឲ្យ កូអ៊ន ដួលខ្លោក កូសង ដែលមិននឹកស្មានថានៅត្រង់នេះក៏រត់មកឱបបងប្រុសដែលដេកដួល ហើយសម្លឹងមុខឪពុកដោយការរករឿង ។

"កុំម៉ោវល់!"

"យកអ្នកនាងតូចចេញពីត្រង់នេះ" អ៊ំប្រុស ។

"អ្ហ៎ាៗ"

កូសង ស្រែកលាន់គ្របដណ្តប់គ្រប់សកម្មភាព បន្ទាប់ពីនោះក៏សម្លឹងមុខម៉ាក់ដោយការចងអាឃាត អ្នកដែលគ្មានសកម្មភាពអ្វីក្រៅពីអង្គុយលេងនៅក្នុងពិភពរបស់ខ្លួន ពេលនេះកំពុងតែធ្វើនូវអ្វីដែលគួរឲ្យព្រឺរោមនៅក្នុងខ្សែភ្នែកគ្រប់គ្នាដែលមើលហើយ ។

"មិនអីទេប្អូនស្រី បងមិនអីទេ" កូអ៊ន ងើបឈរ ហើយសម្លឹងមុខឪពុក "ប៉ាមិនជឿក៏មិនអីដែរ ព្រោះប៉ាមិនធ្លាប់ជឿខ្ញុំបានសូម្បីតែម្តង"

"ខ្ញុំធ្វើតាមអ្វីដែលខ្ញុំឃើញ" សម្លេងរបស់អ៊ំស្តាប់ទៅរាងស្រាលដូចជាចាប់ផ្តើមដឹងថាខ្លួនឯងចេវចាវពេកហើយ "ឯងឈឺអត់"

"គ្រាន់តែទះមុខវាមិនសូវជាឈឺទេ តែខ្ញុំឈឺចិត្ត!" កូអ៊ន យកដៃប៉ះក្បាលខ្លួនឯង ហើយហុចឲ្យឪពុកមើល "ប៉ាចាប់អារម្មណ៍តែប្រពន្ធខ្លួនឯង តែមិនធ្លាប់ចាប់អារម្មណ៍ទេថាខ្ញុំឈឺត្រង់ណា ខ្ញុំក៏មានឈាមដែរ ប៉ាធ្លាប់សង្កេតវាខ្លះអត់ ឈាមពាក់កណ្តាលគឺជារបស់ប៉ា!"

"ឯងបែកក្បាល! ម៉េចមិនលាងចេញ"

"មិនបាច់ម៉ោធ្វើជាចាប់អារម្មណ៍ទេ វាយឺតទៅហើយ!" គេវាសដៃឪពុកចេញយ៉ាងសោះកក្រោះ "បើប៉ាមានយុត្តិធម៌ខ្លះ រឿងក៏មិនទៅជាអីចឹងដែរ ប៉ាគួរតែសួរសិនថាវាកើតឡើងបានយ៉ាងម៉េច ហើយស្អី

ដែលធ្វើឱ្យខ្ញុំត្រូវចាប់ច្របាច់-កស្រីបិសាចប្រពន្ធរបស់ចាំ"

"គឺមិនឃើញមានអ្នកណានិយាយឱ្យខ្ញុំស្ដាប់បានម្នាក់"

"ចុះបើស្ដាប់ ចាំនឹងជ្រើសរើសស្ដាប់អ្នកណា!"

"..."

"បើខ្ញុំប្រាប់ថាប្រពន្ធចាំនាំប្អូនស្រីទៅឃាំងនៅក្នុងបន្ទប់ដាក់របស់នៅចុងសួន ចាំជឿអត់"

"ម៉េចនឹងអាចទៅ"

"និយាយប៉ុណ្ណឹងក៏ចាំមិនជឿទៅហើយ បើមានរឿងផ្សេងចាំក៏គង់បិទភ្នែកបិទត្រចៀកមិនជឿដូចគ្នា"

"ចុះនេះមានអ្នកណាធ្វើជាសាក្សីថាអ្វីដែលឯងនិយាយគឺជាការពិត ពេលខ្ញុំងាកទៅមើលក៏មិនឃើញមានអ្នកណាហ៊ាននិយាយស្អី"

កូអ៊ីន ងាកមកមើលខ្ញុំ តែគេក៏ដូចជាឈប់មានសង្ឃឹម ព្រោះយ៉ាងណាក៏ខ្ញុំចូលខាងម៉ាក់ដែរ ហើយអ្នកក្នុងផ្ទះនៅតែគ្មានអ្នកណាម្នាក់ហ៊ាននិយាយការពិត ព្រោះខ្លាចម៉ាក់ខ្ញុំ ពេលនេះ កូអ៊ីន ធ្លាក់នៅក្នុងសភាពការណ៍មិនល្អហើយ ។

"អ៊ីចឹងខ្ញុំនឹងនិយាយគ្រប់យ៉ាងឱ្យចាំស្ដាប់ បន្ទាប់ពីនោះខ្ញុំនឹងចាកចេញពីទីនេះ ចង់ចាំជឿ ឬមិនជឿគឺជារឿងរបស់ចាំ"

"អឺ និយាយម៉ោ ហើយខ្ញុំនឹងសម្រេចដោយខ្លួនឯងថាអ្វីដែលឯងនិយាយគឺជាការពិតរឺអត់"

"ខ្ញុំម៉ោផ្ទះវិញព្រោះតាំងចិត្តនឹងសួរចាំថាម៉េចក៏បិទកុងរបស់ខ្ញុំ តែពេលមកដល់អ្នកបម្រើក៏រក់ឱ្យខ្វែងដៃខ្វែងជើង..."

គេនិយាយគ្រប់ហេតុការណ៍ គ្រប់ចន្លោះប្រហោងឱ្យឪពុកស្ដាប់ មិនលើកលែងសូម្បីតែអ្វីដែលម៉ាក់បាននិយាយជាមួយខ្ញុំ អ៊ំប្រុសធ្វើមុខមិនជឿដូចរាល់ដង តែក៏មិនកាត់សម្ដីកូន កូអ៊ីន ដែលមើលឃើញឫកពាឪពុក ក៏អស់សង្ឃឹមដូចមនុស្សអស់កម្លាំងប្រយុទ្ធ ។

"រឿងគឺវាអ៊ីចឹង ចង់យ៉ាងម៉េចគឺស្រេចតែចាំ"

"ចាំក៏ចង់ជឿឯងដែរ តែវាហួសពីជឿពេក...អ្នកណាយកអំបែងកញ្ចក់មកអារសាច់ខ្លួនឯងដើម្បីហៅការចាប់អារម្មណ៍ដល់ថ្នាក់នេះ"

"ខ្ញុំមានរឿងតែប៉ុណ្ណឹង"

អ៊ំប្រុសមើលទៅអ្នកបម្រើគ្រប់គ្នា តែក៏ឃើញថាគ្មានអ្នកណាហ៊ានប្រសព្វភ្នែកបានម្នាក់ ក្ដីសង្ឃឹមចុងក្រោយរបស់គាត់គឺការមើលមកខ្ញុំ ហើយដកដង្ហើមធំ ។

"ចុះក្មួយ ថុងអ៊ុល មានអីចង់និយាយទេ"

"អឺ..."

"ហឺស!"

កូអឺន មើលមុខខ្ញុំ ហើយក៏បម្រុងនឹងដើរចេញ ម៉ាក់ញញឹមសមចិត្តពេលគិតថាហ្គេមនេះខ្លួនជាអ្នកឈ្នះ ខ្ញុំឃើញស្នាមញញឹមបែបនោះរបស់គាត់ ទើបធ្វើឲ្យអារម្មណ៍ខុសឆ្គងហូរមកលុបភាពកតញ្ញូតាអស់រលីង ។

"អ្វីដែល កូអឺន និយាយ...ជាការពិត"

ស្ថានការណ៍ដូចជាក្រឡាប់ចាក់ កូអឺន ដែលកំពុងដើរចេញក៏បែរខ្លួនមកមើលខ្ញុំដោយភាពស្រឡាំងកាំង ម៉ាក់ដែលញញឹមសមចិត្តក៏ស្មៀក អ្នកបម្រើគ្រប់គ្នាដែលឈ្ងោកមុខក៏ងើបឡើងដោយក្ដីសង្ឃឹម អ៊ំប្រុសដែលបានឮដូច្នោះក៏ចំហមាត់ផ្លុង ។

"ថុងអ៊ុល ក្មួយច្បាស់ហើយអ្ហ៎ស"

ខ្ញុំគេចភ្នែកពីម៉ាក់ ហើយងក់ក្បាលផ្ញក់ៗ÷

"ចាំ ម៉ាក់ជាអ្នកយកអ្នកនាងតូចទៅយាំង ពេល កូអឺន ចូលមកធ្វើបាបម៉ាក់ ម៉ាក់ក៏តបត ខ្ញុំជាអ្នកយកគោមភ្លើងវ៉ៃក្បាលគេ" ខ្ញុំមើលដៃខ្លួនឯង ហើយមើលទៅគេ "ទើបម៉ាក់យកអំបែងកែវចូតសាច់ខ្លួនឯងដើម្បីឲ្យអ៊ំម៉ោឃើញ អ៊ុយ ម៉ាក់ ខ្ញុំឈឺ!"

ម៉ាក់ស្ទុះចូលមកចាប់ទាញសក់ខ្ញុំឡើងផ្ងារក្រោយ ដើម្បីឲ្យខ្ញុំឈប់និយាយ តែ កូអឺន ស្ទុះចូលមករុញម៉ាក់ចេញ ហើយឱបខ្ញុំជាប់ ។

"ថ្កូតស្អី នេះគិតធ្វើបាបកូនខ្លួនឯងអ្ហ៎ស"

"វាមិនមែនកូនខ្ញុំ បើវាជាកូនខ្ញុំ វាមិននិយាយបែបនេះទេ!"

"ទទួលមិនបានដែលគ្មានអ្នកកាន់ជើងឬយ៉ាងម៉េច គួរពិចារណាពីខ្លួនឯងបានហើយថាហេតុអីក៏សូម្បីតែកូនស្រីខ្លួនឯងក៏ត្រូវនិយាយ

ការពិតក្នុងពេលដែលអ្នកផ្សេងទៀតមិនហ៊ាន នាងវាយ៉ាប់!"

"ឯងលែងកូនខ្ញុំភ្លាម លែង!" ម៉ាក់ព្យាយាមទាញខ្ញុំចេញពីគេ តែ កូអីន ឱបខ្ញុំណែន មិនថាត្រូវទះតប់ ឬ ក្តិចខ្លាំងយ៉ាងណាក៏គេមិនលែងខ្ញុំដែរ ថែមទាំងយកខ្លួនបាំងទៀត ព្រោះខ្លាចខ្ញុំឈឺ ។

"ហេតុអីខ្ញុំត្រូវបណ្តោយឲ្យម៉ែបិត្តយកក្បួចជានាងធ្វើបាបគេទៀតទៅ ចាំមើលឲ្យច្បាស់ទៅ ថាប្រពន្ធចាំជាមនុស្សយ៉ាងម៉េច បើសូម្បីតែកូនគេក៏ចាំមិនជឿ ខ្ញុំក៏គ្មានអីនិយាយទៀតដែរ" កូអីន ឱបខ្ញុំ ហើយនាំដើរទៅខាងក្រៅដោយមិនភ្លេចដឹកដៃប្អូនស្រីទៅជាមួយផង ។

"ឯងចង់ទៅណា"

"ខ្ញុំមិនដឹងជានៅទីនេះធ្វើអី"

"ចុះ ជុងអ៊ុល"

"បើនៅ នឹងត្រូវម៉ែបិត្តយកក្បធ្វើបាបអីខ្លះក៏មិនដឹង ខ្ញុំមិនទុកចិត្តដូចគ្នា ដូច្នោះហើយ...ខ្ញុំនិងនាងនឹងទៅរាប់ជាមួយគ្នា!"

តែមើលទៅម៉ាក់ដូចជាមិនព្រម ព្រោះគាត់រត់តាមមក ហើយព្យាយាមទាញ កូអីន ចេញពីខ្ញុំ គ្រប់យ៉ាងមើលទៅចលាចលអស់ដល់ថ្នាក់ កូអីន ត្រូវប្រើយុទ្ធសាស្រ្តចុងក្រោយ ។

"ស្រលាញ់កូនណាស់មែនទេ មិនឲ្យកូនត្រូវពង្រាត់មែនទេ"

"មែន ទោះយ៉ាងណាក៏នាងជាកូនយើង"

"បើអីចឹងខ្ញុំនឹងឲ្យនៅជាមួយកូនស្រីតាមសប្បាយ តែខ្ញុំនឹងប្រាប់ចាំពីរឿងដែលនាងចេញទៅដើរលេងជាមួយសហាយ!"

ម៉ាក់ទៅជាធ្ងក់ ហើយព្រលែង កូអីន ហាក់ដូចជាត្រូវភ្លើងរោលពេញខ្លួន កូអីន ញញឹមសមចិត្ត ខុសពីខ្ញុំដែលមានអារម្មណ៍ថាអស់សង្ឃឹមចំពោះម៉ាក់ គ្រាន់តែខ្លាចត្រូវប្តីដឹងក៏ព្រមឈប់ដណ្តើមយកខ្ញុំ អ៊ំប្រុសដែលឈរនៅឆ្ងាយក៏មើលមកយើង ទើប កូអីន លើកម្រាមដៃពីរដាក់លើក្បាលដូចស្នែងក្របីដាក់ឪពុក ហើយនាំខ្ញុំចេញភ្លាម ។

"សង្ឃឹមថាចាំនឹងយល់"

"យល់ស្អី"

"ថាចាំត្រូវគេពាក់ស្នែងឲ្យ"

១៩

"ហឺៗ"

"ឈប់យំទៅ ខ្ញុំចង់យំតាមនាងហើយ"

ហេតុអីក៏ជោគជតាលេងកំប្លែងបែបនេះ ហើយហេតុអីបានជាខ្ញុំអកតញ្ញូចំពោះម៉ាក់ដោយសារតែប្រុសម្នាក់នេះ តាមពិតទៅក៏មានហេតុផលច្រើនដែរដែលធ្វើឱ្យខ្ញុំធ្វើបែបនោះ តែពេលនេះអារម្មណ៍ខុសច្បងដែលមានចំពោះម៉ាក់ក៏ហូរហៀរមកព្រមៗគ្នា ខ្ញុំមើល កូអឺនដែលដើរទៅមកនៅពីមុខខ្ញុំដែលគិតតែអង្គុយចាំនៅចំណតឡានក្រុងគេប្រហែលជាចង់លួង តែខ្ញុំបែកសតិលើលពីការដែលគេនឹងធ្វើបានកាន់តែលួង កាន់តែយំ ។

ប៉ាច់!

ដៃតូចៗរបស់ កូសង់ ដាក់នៅលើស្មាខ្ញុំ តែខ្សែភ្នែកនៅតែមើលទៅរបស់លេងនៅក្នុងដៃម្ខាងទៀតដដែល នេះខ្ញុំកំពុងធ្វើឱ្យនាងបារម្ភឬនេះ!

"សុំទោស ខ្ញុំតាំងសតិបានហើយ"

"រាងគ្រាន់បន្តិច"

កូអឺន ដកដង្ហើមធំ ហើយអង្គុយបោងហោងនៅចំពីមុខ ហើយញញឹមបង្ហាញធ្មេញជំពើសអួតធ្មេញសមានមន្តស្នេហ៍របស់គេ ។

"ពេលនាងយំគឺមិនគួរឱ្យស្រលាញ់ទេ ពេលធម្មតាមុខមាត់គួរឱ្យស្អប់ស្រាប់ទៅហើយ"

"ចង់ផាប់អ្ហែស"

"ខឹងហើយស្អាតជាងឡើងម៉ាគំនរ"

"នៅម៉ោញញឹមបាននៅក្នុងស្ថានភាពណ៍បែបនេះទៀតឬ"

"ស្ថានការណ៍បែបណាក៏ខ្ញុំអាចយករួចខ្លួនបានដែរ" គេងើបឈរ ហើយញាក់ស្មា ព្រមទាំងជំរែងដែលបន្តិចដោយមិនរអា "ព្រោះខ្ញុំជឿថា មនុស្សដូចជាខ្ញុំឋានសួគ៌មិនដាក់ទោស ខ្ញុំមិនត្រឹមតែមានមុខមាត់ស្អាតទេ ថែមទាំងសំណាងទៀត"

"មនុស្សសំណាងបែបណាទើបបានដារត់ចេញពីផ្ទះដោយគ្មានលុយសូម្បីមួយរ៉ុន"

"គឺមនុស្សសំណាងដែលមិនបានត្រៀមខ្លួននោះអ្វី"

"យើងគួរតែទៅដេកផ្ទះមិត្តភក្តិមួយយប់ទៅ ម៉េចក៏លោកមិនតេទៅ សាំយ៉ុង"

ពេលខ្ញុំនិយាយដល់ សាំយ៉ុង ស្នាមញញឹមដ៏សែនរីករាយរបស់គេក៏រលាយបាត់ភ្លាមហាក់ដូចជាដប់បាន ។

"ហេតុអីក៏ខ្ញុំត្រូវទាក់ទងទៅវ៉ា នាងចង់ទៅរកវ៉ាផ្អើស"

"គឺគេជាមិត្តជិតដិតតែម្នាក់ជសល់លោក ឬមានមិត្តផ្សេងទៀត"

"គ្មានទេ"

"ចុះម៉េចចាំបាច់សោះអង្កើយ ពេលនេះលោកម៉ោដល់ផ្លូវទាល់ហើយ គ្រាន់តែតេទៅរកមិត្ត វ៉ាមិនងាប់ទេ"

"ខ្ញុំ ឬ នាងឲ្យប្រាកដទៅដែលចង់តេទៅវ៉ា"

"ម៉េចចាំបាច់ធ្វើសម្លេងរករឿងដែរ"

"ខ្ញុំមិនតេទៅវ៉ាទេ...តេទៅ ណាយ៉េ ល្អជាង"

"ចុះម៉េចចាំបាច់តេទៅ ណាយ៉េ!"

ហើយខ្ញុំក៏យល់ពីអារម្មណ៍របស់គេភ្លាមថាហេតុអីក៏គេមិនត្រូវការឲ្យខ្ញុំតេទៅ សាំយ៉ុង មនុស្សក្នុងលោកនេះមានឲ្យម៉ាគំនរចាំបាច់តេទៅរកគូដណ្តឹងដ៏ស្រស់ស្អាតរបស់ខ្លួនឯងដែរឬយ៉ាងម៉េច ហើយ!

"គឺ ណាយ៉េ ជាទីពឹងពាក់ចុងក្រោយដែលខ្ញុំមាន ម្យ៉ាងទៀតគេក៏ជាគូដណ្តឹងរបស់ខ្ញុំដែរ ខ្ញុំថា ណាយ៉េ បែបមិនចិត្តអាក្រក់មិនជួយយើងទេ...តែថាម៉េចក៏មុខក្រមូវអីចឹង"

"ខ្ញុំធ្វើមុខក្រមូវត្រង់ណា ចង់តេក៏តេទៅ អីចឹងខ្ញុំតេទៅ សាំយ៉ុង"

ពេលមានការតវ៉ាកើតឡើង ខ្ញុំ និង កូអ៊ីន ក៏រង់ចាំម្នាក់ៗគេទៅរកអ្នកដែលខ្លួនឯងចង់គេទៅសិន រហូតដល់កន្លងផុតទៅ១០នាទី កូសង់ដែលអង្គុយក៏ស្ទាបជាសញ្ញាតឿនឲ្យយើងដឹងថាគួរឈប់ខ្ចតហើយ ។

"គឺបើយើងមិនតេទៅរកអ្នកដែលអាចជួយបាន អ៊ីចឹងយើងគួរធ្វើម៉េចទៅ" កូអ៊ីន ជាអ្នកនិយាយមុន "បើមានកន្លែងដេកឲ្យបានម៉ាយប់សិនក៏គ្រាន់ដែរ"

"កន្លែងដេកឬ ផ្អូ៎ មើលទៅខ្ញុំដូចជាមាន"

"កន្លែងណា"

កន្លែងដែលខ្ញុំតែងតែមករាល់ពេលចេញពីរៀនគឺផ្ទះរបស់ចាហ្វឹងផ្អែង ខ្ញុំ និង កូអ៊ីន ជួយគ្នាបី កូសឹង ឡើងឡានក្រុងទាំងលំបាកលំបិន ។ ដោយសារគេមិនធ្លាប់ជួបប្រទះការលំបាកបែបនេះនៅក្នុងជីវិតដូចជាការជិះឡានក្រុងជាមួយមនុស្សម្នា ទើបសាងបញ្ហាទៅដណ្ដើមកន្លែងអង្គុយរបស់ស្ត្រីពោះធំនិងចាស់ជរាដោយមិនចេះខ្មាស នៅមានការស្អប់ខ្ពើមដោយការប្រាប់នេះប្រាប់នោះដែលស្មោកគ្រោក ទម្រាំដល់គោលដៅគឺសឹងតែដាច់ខ្យល់ទៅហើយ ។

"គឺកៅអីវាស្មោកគ្រោកពិតមែន នាងមិនធ្លាប់មើលព័ត៌មានទេផ្អ៊ូស ដែលរថភ្លើងមានធូលីពេញកៅអី"

"នោះជារថភ្លើង នេះជាឡានក្រុង"

"គេគួរតែសម្អាតឲ្យវាល្អជាងនេះ ខ្ញុំចាំបានថាឡានក្រុងមានអ៊ែរមិនមែនឬ ម៉េចក៏នាងនាំឡើងឡានបែបនេះ"

"លុយដែលខ្ញុំមានត្រូវទុកទិញបាយញ៉ាំទាំងបីនាក់ ឯអ្នកកម្លោះដាក់តែកាតដែលគ្មានលុយតាមខ្លួន"

"ម៉េចចាំបាច់ផ្ចាញ់ខ្ញាំងម្ល៉េះ តែថានេះជាផ្ទះអ្នកណា ម៉េចក៏តូចហើយទ្រុឌទ្រោមអីបែបនេះ"

"ផ្ទះចាខ្ញុំ"

"ចានាងមិនទាន់ងាប់ទៀតផ្អ៊ូស"

"នេះមាត់ឬ!"

"អូខេ ខ្ញុំមិននិយាយអីបែបមាត់ត្រង់ចិត្តទៀតទេ តែថាផ្ទះនេះដូចជាគ្មានមនុស្សនៅ"

"គឺគ្មានទេ បើមានលោកបែបចូលទៅមិនបានឡើយ ប៉ានឹងគិតយ៉ាងម៉េចដែលកូនស្រីនាំមនុស្សប្រុសចូលផ្ទះ"

"ប៉ានឹងគិតថាកូនស្រីរបស់គាត់ចំដាភ្នែកមុតមែនដែលនាំប្រុសមុខស្អាត មានវង្សត្រកូលដូចជាខ្ញុំចូលផ្ទះ"

"មានវង្សត្រកូល តែគ្មានលុយមួយរ៉ុន"

"ឈប់ផ្ទាញ់រឿងនេះទៅ ចាប់នាំខ្ញុំនិងប្អូនស្រីចូលទៅក្នុងផ្ទះ ប្អូនខ្ញុំដេកទាំងឈរយូរហើយ"

"គឺចង់នាំចូលទៅបែបងាយៗដែរ"

"ប្រែថាវាយ៉ាប់ឬ ស្អីទៀតហើយ"

"យើងត្រូវគាស់ចូលទៅ"

"គាស់? វ៉ាយ ចោរស្រីបាតផ្សារ"

"អីចឹងលោកនិងប្អូនដេកនៅខាងក្រៅហើយ"

"គាស់ក៏បាន!"

ព្រោះខ្លាចគ្មានកន្លែងដេក ទើប កូអឺន ផ្ញើប្អូននឹងខ្ញុំ ហើយគាស់ចូលទៅដោយការចូលតាមក្រោយ តែអាគ្រាន់តែធ្វើដូចនៅក្នុងកុនវាមើលទៅយ៉ាប់ជាងប្រើដែកតូចមួយគាស់ទៅទៀត ទើបចុងក្រោយទ្រាំលែងបានក៏ទម្លុះកញ្ចក់បង្អួចយ៉ាងឃោរឃៅ ហើយវារចូលទៅ ។

"ចេញពីអ្នកមានបំផុតដូចជាខ្ញុំពេលនេះត្រូវគាស់ផ្ទះអ្នកក្រចូលដេកហើយ"

"អ្នកក្រដែលថានោះជាប៉ាខ្ញុំពីយ!"

"សុំទោស តែថាផ្ទះនេះមានអ៊ីអែត់...អ្ហ៎ា ភ្លើងក៏គ្មាន នេះនាងនាំពួកខ្ញុំមកផ្ទះដែលគ្មានសូម្បីតែភ្លើងឬ!"

"សង្ស័យប៉ាមិនបានបង់ថ្លៃភ្លើង"

"នាងបានត្រៀមស្អីខ្លះនេះ"

"ស្អីក៏មិនបានត្រៀមដែរ លោកខ្លាចលំបាកណាស់ម៉េចក៏មិនទៅផ្ទះវិញពីយ"

"ពីយជង និយាយដូចនាងទៅបានអីចឹង ទាំងដឹងហើយថាមានអីកើតឡើង ពេញ្ញីយ នៅទីនេះក៏គ្រាន់ជាងដេកតាមថ្នល់ដែរ តែថាផ្ទះនាងមានសៀវភៅទេ"

"ភ្លើងគ្មានផង ចង់មើលសៀវភៅធ្វើអី"

"ខ្ញុំយកមកបក់ឱ្យប្អូនខ្ញុំទៅវិញទេ"

"អ្ហ៎"

ថាទៅ កូអឹន ក៏គួរឱ្យអាណិតដែរ តាំងពីម៉ែកូនយើងទៅនៅផ្ទះគេ គេមិនដែលមានក្ដីសុខឡើយ ណាបារម្ភពីឪពុក ណាត្រូវប្រយ័ត្នម៉ាក់ខ្ញុំ ហើយអ្វីដែលគួរឱ្យខ្លាចបែរក្លាយជាការពិត ហើយពេលនេះគេក៏ត្រូវរត់ចេញពីផ្ទះ លុយក៏គ្មាន មកនៅផ្ទះតូចចង្អៀតរបស់ចាក៏គ្មានភ្លើងថែមទាំងយកសៀវភៅបក់ឱ្យប្អូនទៀត តែគួរឱ្យចម្លែក...ទោះមកនៅទីនេះ តែគេបែរជាមានក្ដីសុខជាងនៅផ្ទះខ្លួនឯងទៅទៀត ។

"នៅក្នុងទូទឹកកកគ្មានអីទេក្រៅពីទឹក លោកញ៉ាំទ្រាប់ពោះសិនទៅ តិចទៀតភីហ្សាម៉ោដល់ហើយ"

"ក្រែងប្រាប់ថាគ្មានលុយ ចុះម៉េចក៏ភីហ្សាម៉ោបាន"

"ត្រូវមានសំនួរហ្ហូតឬយ៉ាងម៉េច គឺខ្ញុំខ្លាចលោកនិងប្អូនស្រីឃ្លានទើបកុម្ម៉ង់ម៉ោឱ្យ!"

"មិនឃើញចាំបាច់អីតំហាក" គេរអ៊ូរទាំ "តែក៏អរគុណ"

"មិនបាច់អរគុណទេ ខ្ញុំធ្វើដើម្បីលុបលាងទោសប៉ុណ្ណោះ ថ្ងៃនេះម៉ាក់ខ្ញុំលេងខ្លាំងពេកហើយ"

"ម៉េចក៏នាងជួយខ្ញុំ តាមពិតបើជួយម៉ាក់នាង ក៏មិនបាច់លំបាកបែបនេះដែរ"

"មែនហើយ ម៉េចក៏ខ្ញុំត្រូវជួយលោក ខ្ញុំក៏នៅសង្ស័យខ្លួនឯងដែរ"

"ចុះបានចម្លើយហើយនៅ"

តាមពិតចម្លើយគឺខ្ញុំដឹងច្បាស់ពេញទ្រូងទៅហើយ ថាខ្ញុំមិនអាចទ្រាំបានទេបើគេមើលមកខ្ញុំជាមនុស្សមិនល្អ តាមរយៈខ្សែភ្នែកដែលគេមើលមកខ្ញុំដោយអស់សង្ឃឹមកាលនោះ ស៊ូឱ្យខ្ញុំត្រូវមនុស្សមួយផែនដីនេះស្អប់វិញល្អជាង ការចូលចិត្តរបស់ខ្ញុំដែលមានចំពោះគេវាខ្លាំងក្លា

ដល់ថ្នាក់នេះបានយ៉ាងម៉េចទៅ ទាំងដែលត្រូវគេធ្វើបាបសព្វសារពើ សឹងតែរាប់មិនបាន ។

"ទៅ"

"បើម៉ាក់នាងមិនបាននៅក្នុងផ្ទះ វាបែបប្រសើរច្រើនរឿង"

"ហើយស្ដ្រីដែលប្រសើរនោះ សាកឱ្យឧទាហរណ៍ម៉ោមើល៍"

"គឺ...អ្ហឹម គឺម៉េចណ៎"

"លោកបែបចូលចិត្តខ្ញុំ ចែចង់ខ្ញុំ អ្វីបែបនោះ"

"និយាយច្ឆតស្ដ្រី"

ខ្ញុំមានអារម្មណ៍ថាអស់សង្ឃឹមនឹងបូកពាបដិសេធរបស់គេ ។

"តែក៏ប្រហែលជាអ្វីបែបនោះ"

"ហឺ?"

"ម៉េចចាំបាច់ធ្វើមុខភ្ញាក់ផ្អើលបែបនោះ គិតថាខ្ញុំនិយាយចោល មិនចាប់យកម៉ោគិតទេ" គេទះមាត់ខ្លួនឯង ហើយអ្វី តែស្ដាប់ន័យបាន ថាមិនគួរបូតចេញមកបែបនោះ នោះហើយដែលធ្វើឱ្យខ្ញុំញញឹម ។

"ចោលមិនបានទេ"

"នាងធ្វើជាភ្លេចបន្តិចមិនបានឬយ៉ាងម៉េច"

"គ្រាន់តែប្រាប់ថាចូលចិត្តខ្ញុំ វាងាប់ឬយ៉ាងម៉េច ខ្លាចស្ដ្រីទៅ"

"ឱ្យខ្ញុំនិយាយបានយ៉ាងម៉េច!"

"..."

"បើនាងមិនចូលចិត្តវិញ ខ្ញុំនឹងយ៉ាប់ហើយ ខ្ញុំទទួលយកភាពអស់សង្ឃឹមបែបនោះមិនបានទេ នាងក៏ឃើញតើថាពេលខ្ញុំអស់សង្ឃឹម ចំពោះអ្វីមួយ ខ្ញុំក៏កម្ចាយអារម្មណ៍បែបកូនក្មេង ព្រោះនាង ធ្វើបាបចិត្តនាង គ្រប់តែម្ដង!"

"ចង់ប្រាប់ថាកន្លងមកព្រោះលោកចូលចិត្តខ្ញុំអីចឹងឬ"

"ឈប់និយាយ!"

"កុំស្រែកមើល៍"

"អីចឹងនាងឈប់និយាយទៅ"

"ឈប់ក៏បាន តែបញ្ចប់ប្រយោគនេះសិន"

"ស្អី"

"ខ្ញុំក៏ចូលចិត្តលោកដែរ"

សៀវភៅ កូអ៊ីន ដែលកំពុងបក់ឱ្យប្អូនត្រូវបួតពីដៃ នេះបើមានភ្លើងគេនឹងមើលឃើញហើយថាមុខខ្ញុំក្រហាមដូចត្រូវដះឈាមដាក់ក្រៅពីពន្លឺព្រាលៗចេញពីភ្លើងនៅតាមផ្លូវដើរហើយគឺគ្មានភ្លើងអីទៀតទេ ឃើញបានគឺមានតែស្រមោលដែលព្រាលៗប៉ុណ្ណោះ ។

"ម៉េចក៏មិនប្រាប់តាំងពីដំបូង"

"ខ្ញុំជាស្រីឱ្យប្រាប់មុនបានយ៉ាងម៉េច"

"ម៉ោប្រាប់ពេលខ្ញុំគ្មានលុយម៉ារ៉ុននេះ"

"ចុះម៉េចចាំបាច់ប្រាប់ពេលមានលុយ"

"បើនាងប្រាប់ពេលខ្ញុំមានលុយ ខ្ញុំប្រហែល...ធ្វើអីបានល្អជាងនេះ ដូចជានាំនាងទៅញ៉ាំអីឆ្ងាញ់ៗ ទិញខោអាវស្អាតៗ ធ្វើភេទះយើងមានកូនជាមួយគ្នាទៅហើយ"

"គំរក់មែន!"

"អ្ហ៎ា ខ្ញុំនិយាយឆ្ងាយពេកឬ" កូអ៊ីន រំកិលមកអង្គុយជិតខ្ញុំ "តែថាខ្ញុំគ្មានលុយ វាមានបញ្ហាចំពោះនាងទេ"

"តិចតួច"

"ម៉េចដែរ"

"លោកប៉ុនអ៊ូពេក"

"ចុះបើមិនអ៊ូ"

"គឺអូខេ"

"គួរឱ្យស្រលាញ់បំផុត!"

ទោះជាងងឹត តែក៏មើលឃើញថាគេជាបុរសដើមទ្រូង៥ហត្ថដែរ កូអ៊ីន ទាញខ្ញុំទៅថើបបានចំប្លង់ល្អ ខ្ញុំហ៊ាសរុញគេចេញទាំងខឹង តែក៏ចាញ់ធម្មជាតិដែលចូលចិត្តគេពេក ទើបបណ្តោយឱ្យគេធ្វើតាមចិត្ត ។

"ដឹងអីចឹងឈ្លោះជាមួយម៉ាក់នាងតាំងពីយូរ"

"បានហើយ តិច កូសង់ ភ្ញាក់ម៉ោឃើញ បានហើយ ទៅអង្គុយឱ្យឆ្ងាយៗទៅ ទៅៗ ឈឺៗ អ្ហ៎ លោកដាក់ដៃម៉ោធ្វើអីក្នុងអាវខ្ញុំ!"

"អ៊ិៗ"

"គីហ្សាមោដល់ហើយ-"

សម្លេងរបស់ សីជីន និងភ្លើងពិលដែលពេញទៅដោយថាមពលពន្លឺជះមកចំយើងទាំងពីរបានចំពេលល្អណាស់ សីជីន ចំហាមាត់ឆ្ងល់ពេលឃើញដៃរបស់ គូអ៊ីន នៅក្នុងអាវខ្ញុំ មុននឹងគ្រវីក្បាល ។

"ធ្លាក់ខ្លួនដល់ម្លឹងហើយនៅមានអារម្មណ៍ធ្វើអីបែបនេះទៀត"

"ម៉េចក៏អ្នកដឹកគីហ្សានិយាយច្រើនម្ល៉េះ" គូអ៊ីន ។

"សីជីន មិត្តខ្ញុំទេ"

"អ្ហំ ខ្ញុំមិនបានមោម្នាក់ឯងទេ" សីជីន ញាក់ស្មា ហើយចង្អុលទៅខាងក្រោយ "សាំយ៉ុង ក៏មោដែរ"

"ថាម៉េច!" គូអ៊ីន ។

សាំយ៉ុង បង្ហាញខ្លួនយឺតៗចេញពីក្រោយខ្នង សីជីន ហាក់ដូចជាការសម្តែងដ៏អស្ចារ្យ គូអ៊ីន រហ័សដាក់ដៃឱបខ្ញុំណែនដូចពស់វែកកាងស៊ុត តែខ្ញុំបែរជាខ្មាសមិនហ៊ានប្រឈមមុខនឹង សាំយ៉ុង ។

"ខ្ញុំមោចំពេលល្អអីយ៉ាងនេះ"

២០

"ចាំងតេម៉ោរកខ្ញុំឡើងខ្សៅចង់ជេះហើយ ព្រោះទាក់ទងឯងមិនបាន" សាំយ៉ុង ។

"ទូរសព្ទដៃឯងមានខ្សែដែរឬ" កូអ៊ីន ។

"អាឡប់!"

"ហឺស!"

មើលទៅ កូអ៊ីន មិនសប្បាយចិត្តឡើយនឹងវត្តមានរបស់ សាំយ៉ុង ខ្ញុំហាក់សបេះដៃគេដែលធ្វើឫកជាម្ចាស់កម្មសិទ្ធពេញទី ព្រោះនៅសុខៗក៏មានអារម្មណ៍ថាក្រែងចិត្ត សាំយ៉ុង នោះហើយដែលធ្វើឲ្យ កូអ៊ីន កាន់តែមួម៉ៅ ។ @ amazingshelf.blogspot.com

"ចុះម៉េចក៏លោកម៉ោជាមួយ ស៊ីជីន បាន"

ស៊ីជីន ញាក់ស្មា ហើយតបជំនួស៖

"ព្រោះគេដឹងច្បាស់ថាខ្ញុំជាទីពឹងពាក់ចុងក្រោយជស់ឯង ក្រៅពីចាំ គឺមានតែខ្ញុំហ្នឹងអ្ហី គេតេម៉ោក្រោយឯងតែមិនប៉ុន្មាននាទី ដឹងដូចខ្មោចប្រាប់អីចឹង"

ស៊ីជីន មើលអតីតមិត្តប្រុសដោយខ្សែភ្នែកជិនជ្រេញ តែមើលទៅដូចជាមិនយករឿងចាស់មកពាក់ព័ន្ធទេ សម្ព័ន្ធភាពរបស់មនុស្សយើងនេះវាងាយផ្សារភ្ជាប់ដល់ថ្នាក់នេះឬនេះ!

"ពេលនេះចាំងឯងបារម្ភពីឯង និង កូសង់ ខ្លាំងណាស់ ទាក់ទងឯងក៏មិនបាន ទើបទៅរកខ្ញុំឲ្យជួយរក"

"ចឹស ធ្វើជាតាមរក កាលដេញម៉េចមិនគិតមុខក្រោយផង"

"ចាំលោកមិនបានដេញទេ" ខ្ញុំ ។

"ឆ្កួ៎ ម៉េចក៏នាងចាំបាច់ដំទាស់នឹងខ្ញុំ ការដែលគាត់ពីខ្ញុំគឺប្រែថាដេញហើយ ខ្ញុំត្រូវតែឱ្យគាត់បេះមានអារម្មណ៍អីខ្លះ"

"តែ កូសង មិនគួរម៉ាលំបាកទេ ឯងនាំក្មេងដែលត្រូវបានទទួលការមើលថែយ៉ាងល្អម៉ោលំបាកជាមួយបានយ៉ាងម៉េច ភ្លើងក៏គ្មាន ទឹកមានឬអត់ក៏មិនដឹង លើឈើនោមឈើដុះ ប្អូនឯងនឹងធ្វើយ៉ាងម៉េច ឯងជាប្រុស ឯងលាងគូថឱ្យនាងបានទេ"

"មិនឃើញចាំបាច់និយាយហេតុផលច្រើនដល់ថ្នាក់នេះក៏បាន" កូអ៊ីន ចាប់ផ្ដើមមានអារម្មណ៍ចុះចាញ់ តែក៏មិនព្រម "ចុះឱ្យធ្វើម៉េចបើមិននាំម៉ោ នឹងត្រូវស្រីបិសាចនោះសម្លាប់ហើយ"

គ្រប់គ្នានៅស្ងៀមហាក់ដូចជាសម្ដីរបស់ កូអ៊ីន គឺជាពាក្យដែលត្រូវហាម ថាត្រូវតែអ៊ីចឹង អ្នកដែលគេនិយាយដល់គឺជាម៉ាក់ខ្ញុំ ។ ខ្ញុំបានតែនៅស្ងៀម ហើយមើលទៅ កូអ៊ីន ដូចជាចាប់ផ្ដើមដឹងខ្លួន ទើបងាកមកមើលខ្ញុំបែបអៀសចិត្ត តែមាត់រឹងមិនសុំទោស ។

"ម៉េចចាំបាច់ធ្វើមុខបែបនោះដែរ ខ្ញុំភ្លេចទៅថាគេជាម៉ាក់នាង... ហើយហេតុអីនាងចាំបាច់ជាកូនរបស់ស្រីនោះដែរ"

"ហើយខ្ញុំជ្រើសរើសកន្លែងកើតបានទេពីយ!"

"នាងតំឡើងសម្លេងពីយដាក់ខ្ញុំផង"

"អាខ្មោច ខ្ញុំមិននិយាយជាមួយលោកទៀតទេ"

"នាងជេរខ្ញុំថាជាអាខ្មោច!"

ខ្ញុំដើរចេញពីក្នុងផ្ទះដែលយើងនិយាយមិនសុីខ្សែគ្នានៅក្រោមពន្លឺទៀនពីតំបូង ខ្ញុំគិតថា កូអ៊ីន តាមមកលួងខ្ញុំដូចដែលគួរធ្វើ តែក៏ត្រូវអស់សង្ឃឹមពេលអ្នកតាមមកជា សេសីជីន ។

"មិនបាច់ធ្វើមុខដូចបៀមឈាមនៅក្នុងមាត់បែបនេះក៏បាន អស់សង្ឃឹមខ្លាំងដល់ថ្នាក់នោះផង?"

"អស់សង្ឃឹមស្អី"

"អស់សង្ឃឹមដែលជាខ្ញុំ មិនមែន កូអ៊ីន ឯងនេះអាចចិត្តងាយជាងស្អីនៅក្នុងលោកនេះទៅទៀត ដឹងខ្លួនផងទៅ"

"ឈប់និយាយរឿងនោះទៅ"

"ឯងទៅខឹងគេក៏មិនត្រូវដែរ ថ្ងៃនេះ កូអឹន ជួបរឿងធ្ងន់ធ្ងរណាស់ទៅហើយ សូម្បីតែឯងក៏មិនកាន់ជើងម៉ាក់ បើគេខឹងខ្លះរបូតមាត់ចេញស្តីម៉ោខ្លះ ក៏បណ្តោយឲ្យវាកន្លងផុតទៅ"

"ខ្ញុំព្យាយាមធ្វើបែបនោះហើយ តែគេបេះបួយ!"

"គេក៏ចង់សុំទោស ឯងមិនឃើញមុខគេទេអ្ហ៎ អៀនថ្នាហើយ"

"សព្វស្តីផស់ឯងនេ៎ះ"

"អៀនឡក់នៅមានបាន អៀនថ្នាមានខ្លះមិនបានឬយ៉ាងម៉េច" សឺជីន ក្អក់អណ្តាត ហើយដូររឿងនិយាយ "តែថាបើខ្ញុំម៉ោយូរជាងនេះ ពួកឯងចង់ធ្វើស្អីគ្នាទៅ"

"ស្អីនេ៎ះ អត់ទេ យើងមិនបានធ្វើអីទេ"

"ខ្ញុំឃើញរូបភាពនោះ កុំម៉ោកូត ខ្ញុំជាមិត្តជិតដិតបំផុតរបស់ឯងនៅក្នុងលោកទាំងបី ឯងកុំភ្លេច ធ្លាក់នរកក៏ឯងត្រូវតែជួបខ្ញុំ ឡើងឋានសួគ៌ក៏ឯងនៅតែចាំឈ្មោះខ្ញុំបាន ដូច្នេះហើយពេលយើងនៅលើលោកនេះ ឯងគួរតែចាំទុកទៅថាខ្ញុំជាមិត្តជិតដិតផស់ឯង និយាយម៉ោ!"

ហេតុអីរឿងរបស់ខ្ញុំទៅទាក់ទងនឹងនរកឋានសួគ៌ដែរ ខ្ញុំឈរអៀនតិចតួច តែក៏ព្រមនិយាយ ។

"យើងទើបនិយាយរឿងក្នុងចិត្ត"

"វ៉ាយ ហើយគេក៏យកដៃទៅដាក់ក្នុងអាវឯងនេ៎ះ"

"ច្កួត! អាម្សៀនោះវាលាមក ខ្ញុំមិនទាំងបានតាំងខ្លួនតាំងជំហរផង ដូររឿងនិយាយភ្លាម"

"ម៉ោប្រាប់ថាស្រលាញ់គ្នានៅក្នុងពេលធ្លាក់ខ្លួនក្របែបនេះនេ៎ះមិនល្អទេ តែវាល្អសម្រាប់ខ្ញុំដែលបានឃើញអ្វីបែបនោះ និងបែបនេះ"

"បែបនោះគឺស្អី បែបនេះគឺស្អី"

"បែបនោះគឺបានឃើញឯងមានមូមែនតឹពេញទៅដោយស្នេហាគ្រាតំបូងរបស់ស្រីក្រមុំ ចំណែកបែបនេះគឺ...មុខដ៏សែនឈឺចាប់របស់ សាំយ៉ុង ហ៊ឺៗ"

មើលទៅ សឺជីន ដូចជាពេញចិត្តមែនពេលដែលនិយាយ តែនេះជាអ្វីដែលខ្ញុំចម្លែកចិត្តច្រើនជាង ។

"ឈឺចាប់ឬ ឯងគិតច្រើនពេកអត់"

"មិនច្រើនទេ គឺខ្ញុំឃើញមែន ពេល កូអឹន ទាញឯងទៅឱបពេលឃើញ សាំយ៉ុង ផុសក្បាល ខ្ញុំបានឮសម្លេងខាំធ្មេញរបស់គេទៀតណា ឯងនេះចំជាមិត្តសម្លាញ់មែន សង់សឹងឲ្យខ្ញុំបាននៅក្នុងពេលដ៏សែនខ្លី"

"ឯងគិតច្រើនពេកហើយ បែបគ្មានអីបែបនោះទេ សាំយ៉ុង និងខ្ញុំមិនធ្លាប់មានពេលវេលារ៉ូមែនទិកដល់ថ្នាក់ដែលគេត្រូវមកឈឺចាប់ទេ ខ្ញុំធ្លាប់ទៅដើរលេងជាមួយគេបានម្ដងហ្នឹង ហើយជាអ្នកប្រាប់គេទៀតផង ថាយើងមិនអាចទៅរួច គេហ្នឹងហើយដែលញញឹមដាក់ខ្ញុំ"

"មនុស្សឈឺចាប់ត្រូវសម្ដែងការឈឺចាប់ឲ្យឃើញដែរឬ ឯងត្រូវប្រយ័ត្នខ្លួនទៅ មនុស្សស្រីធ្វើឲ្យមិត្តភក្តិឈ្លោះវ៉ៃគ្នាម៉ោច្រើនហើយ យកបុិនពេលនេះគឺបានហើយ កូអឹន បេះបួយ សាំយ៉ុង ដូចក្មេង ៨ឆ្នាំ គ្រាន់តែទូរស័ព្ទដៃចេះខ្សែនៅយកមកពោះបាន"

"ស្រីៗមិនចូលទៅញុំាកីហ្បាទេឬ ឈរនិយាយគ្នាអីណាស់ណាមូសមិនខាំទេឬយ៉ាងម៉េច" សាំយ៉ុង ដើរចេញមកដោយបី កូសង់ មកផង ខ្ញុំមើលគេដោយការចម្លែកចិត្ត ។

"ចង់ទៅណា"

"នាំ កូសង់ ទៅផ្ទះសំណាក់ កូអឹន មិនព្រមទៅទេ"

"ហេតុអី"

"វាប្រាប់ថាចង់នៅជាមួយនាង"

"អ៊ុយ ខ្ញុំមិនព្រមទេ" នេះមិនមែនសម្លេងខ្ញុំទេ "មាន កូសង់ ផងនៅអសុវត្ថិភាព បើអាម្សៀនោះនៅតែពីរនាក់មិត្តខ្ញុំ លើកនេះច្បាស់ជាមិនរស់ទេ"

"ហើយខ្ញុំធ្វើអីបាន" សាំយ៉ុង ។

"ខ្ញុំចេញច្បាំងដោយខ្លួនឯង"

សឺជីន ដើរត្រុកៗចូលទៅក្នុង ទុកឲ្យខ្ញុំឈរជាមួយ សាំយ៉ុង ដោយភាពស្ងៀមស្ងាត់ ព្រោះសម្តីរបស់ សឺជីន ហ្នឹងហើយធ្វើឲ្យខ្ញុំមិនដឹងជានិយាយអីជាមួយ សាំយ៉ុង គេឈឺចាប់ពិតមែនឬ ហើយបើគេឈឺ ចុះម៉េចក៏ញញឹមបានសមម្លេះ ថែមទាំងមកជួយមិត្តភក្តិទៀត ។

"នាងគិតថាខ្ញុំជាមនុស្សមិនគួរឱ្យទុកចិត្តដល់ថ្នាក់នោះឬ!"

កូអ៊ីន ស្រែកតាមពីក្រោយ ស៊ីជីន ជាប់រហូតដល់មិត្តជើងល្អរុញខ្ញុំឱ្យឈរក្រោយខ្នងនាង ។

"អ៊ី ខ្ញុំដឹងថាលោកមិនព្រមទៅជាមួយ សាំយ៉ុង មិនមែនម៉ោពីខ្លាចថាខ្លួនសុខស្រួលតែម្នាក់ឯងដូចដែលអះអាងទេ តែចង់នៅជាមួយ ចុងអ៊ុល តែពីរនាក់ ហើយធ្វើអីមិនល្អមែនទេ"

"លាមកបំផុត! ខ្ញុំមិនមែនជាមនុស្សបែបនោះទេ"

"លោកជាមនុស្សបែបនោះ" ខ្ញុំ ។

"នេះនាងកាន់ជើងអ្នកផ្សេងជាងសង្សារខ្លួនឯងឬ!"

"រ៉ូ!!"

ស៊ីជីន ស្រែកចេញមកដោយការភ្ញាក់ផ្អើល ហើយក៏ចូលចិត្ត ឯខ្ញុំបានតែឈរចំហមាត់ ទាំងខ្មាស ទាំងអៀន ទាំងភាំង និងព្យាយាមបង្ហាប់ខ្លួនឯងមិនឱ្យញញឹម ទើបគំហក÷

"អ្នកណាជាសង្សារលោក"

"ខ្លួនឯងទើបនឹងប្រាប់ថាចូលចិត្តគេសោះ ម៉ោក្រឡាស់សម្ដី"

"មិនទាក់ទងគ្នាអីបន្តិចទេ ទោះយ៉ាងណាក៏ខ្ញុំមិននៅជាមួយដែរយប់នេះ"

"ចុះនាងចង់ទៅណា"

"ទៅផ្ទះខ្ញុំ!" ស៊ីជីន ។

"ចុះខ្ញុំ!"

"គឺទៅនៅផ្ទះមិត្តទៅ ឬចង់ដេកលេងទៀននៅផ្ទះនេះក៏បាន គ្មានអ្នកណាហាមទេ" ស៊ីជីន និយាយផងសើចផងដូចមនុស្សបានទទួលជ័យជំនះ "ទប់អារម្មណ៍ខ្លួនឯងបន្តិចទៅអ្នកកម្លោះឈាមហូរប្រាសប្រាល ប្រាប់ថាស្រលាញ់ភ្លាមក៏លាមកភ្លែត គឺមិនបានទេ"

"ស្រីជើងល្អ!" កូអ៊ីន ស្រែកដាក់ ស៊ីជីន ហើលោតមកទាត់បានគេប្រហែលជាធ្វើទៅហើយ ។

"អ៊ីចឹងឯងទៅដេកនៅផ្ទះខ្ញុំ បណ្ដោយឱ្យមិត្តពីរនាក់ហ្នឹងនិយាយគ្នាគេទៅ"

"ឈប់!" កូអ៊ីន ដើរមករកខ្ញុំ ហើយខ្សឹបក្បែរត្រចៀកដែលធ្វើឱ្យបានឮតែពីរនាក់"

"ថ្ងៃផ្សេងនៅមាន កុំគិតថាគេចផុត"

"លោកជាខ្មោចចៅឬយ៉ាងម៉េច ទៅហើយនៅម៉ោគំរាមទៀត"

"ជាស្អីក៏បានឱ្យតែនាងចង់ឱ្យធ្វើ"

"O_O"

"សិចស៊ីណាំ ខឹកៗ"

កូអ៊ីន សើចខឹកខាក់ ទើបធ្វើឱ្យខ្ញុំសើចតាម មុននឹងទាត់គេ១ជើងហើយធ្វើសម្លេងមាំ÷

"ទៅបានហើយ"

"ស៊ី យូ"

កូអ៊ីន ដើរតាម សាំយ៉ុង ទៅរកឡានដោយមានយើងទាំងពីរតាមមើលទាល់តែគេឡើងឡាន តាមពិតពីដំបូងគេក៏តាំងចិត្តថាជូនយើងទៅដែរ តែ ស៊ីជីន ប្រាប់ថាមិនចាំបាច់ អាចនឹងខ្ពើម ឬជាអ្វីក៏ខ្ញុំមិនដឹងដែរ ចំណែក សាំយ៉ុង ពេលចូលទៅអង្គុយក្នុងឡានហើយក៏មើលមកខ្ញុំម្តងទៀត ខ្សែភ្នែកមានភាពទទេស្អាត គ្មានព្រលឹងព្រលះ តែមាត់បែរជាញញឹម វាមើលទៅមិនស៊ីនឹងឥរិយាបថសោះ ។

"ឯងឃើញស្នាមញញឹមនោះទេ"

"ម៉េច" ទោះជាឃើញ តែខ្ញុំគេចវេសមិនតបល្អជាង ព្រោះចង់ដឹងថាមិត្តនឹងនិយាយថាម៉េច ។

"វាជាស្នាមញញឹមរបស់...អ្នកដែលជិតអស់ការអត់ធ្មត់"

ខ្ញុំមកស្នាក់នៅជាមួយ ស៊ីជីន មួយរយៈ រាងគ្រាន់បើបន្តិចដែលប៉ាម៉ាក់របស់នាងស្វាគមន៍យ៉ាងកក់ក្តៅ តែមិនថាកក់ក្តៅប៉ុណ្ណាក៏ពួកគាត់នៅតែជាឪពុកម្តាយរបស់មិត្ត តែម៉ាក់របស់ខ្ញុំវិញ...មិនឃើញគេមកបានម្តង ទោះជាខ្ញុំខំបើកទូរសព្ទពេញ២៤ម៉ោងដោយមានសង្ឃឹមថាម៉ាក់នឹងតេមក ។

"ចាក់អី!"

"ហេ៎"

"ដុប!"

កូអ៊ីន ដែលលេចចេញពីខាងក្រោយពញ្ញាក់ឱ្យខ្ញុំភ្ញាក់ ពេលងាកមុខទៅ មាត់ក៏ដល់នឹងថ្ពាល់ ហាក់ដូចជារៀបផែនការយ៉ាងច្បាស់ថាត្រូវធ្វើមកឱ្យចេញជាបែបនេះ ខ្ញុំជូតថ្ពាល់ ហើយលួចញញឹម តែក៏ជ្រួញចិញ្ចើម ។

"ធ្វើបែបនេះទៀតហើយ"

"តែនាងក៏ចូលចិត្ត នឹកដល់ហើយ!"

គេទាញខ្ញុំទៅឱបពេញដោយក្តីស្រលាញ់ ធ្វើឱ្យមុខខ្ញុំជ្រប់នឹងទ្រូងហាប់ណែនរបស់គេ ក្លិនទឹកអប់ប្រេនទនេមធ្វើឱ្យខ្ញុំជ្រួលជ្រើម១សន្ទុះគេស័ក្តិសមនឹងក្លិនទឹកអប់នេះណាស់ ។

"បានហើយៗ ខានជួបគ្នាតែពីរថ្ងៃផ្តេសផ្តាសដល់ម្លឹងឬ ហើយម៉ោធ្វើអីនៅម្តុំនេះ"

"គឺម៉ោរកនាងហ្នឹងហើយ"

"ហើយម៉ោចំបួងបានយ៉ាងម៉េច"

"ខ្ញុំឱ្យ សាំយ៉ុង នាំម៉ោ" កូអ៊ីន ប្រាប់ទាំងម្ងូម៉ៅ "ការពិតគឺចង់ម៉ោរកតាំងពីម្សិល តែពេលវាចង់នាំម៉ោរក ខ្ញុំក៏មិនព្រម"

"តែចុងក្រោយក៏មិនខ្មេះទើបពឹងគេដដែល"

"គឺមានតែម្តងនេះប៉ុណ្ណោះ ហើយម៉េចដែរ នាងសុខសប្បាយទេនាងស្គមឬអត់នេ៎ះ បែបនឹកខ្ញុំណាស់ហើយ គឺដូចថា នាងមានសង្សារដែលមិនត្រឹមតែសង្ហាទេ នៅជាមហាសេដ្ឋីទៀត"

"មហាសេដ្ឋីបែបណាគ្មានលុយមួយរ៉ុន"

"មានហើយ ហេ៎!" កូអ៊ីន ហែសគ្រីកាតពណ៌មាស ហើយមិចភ្នែកដាក់ "ចាំធ្វើឱ្យថ្មី ហើយផ្ញើតាម សាំយ៉ុង ម៉ោ ហឹស បែបចង់លួងហើយ តែខ្ញុំមិនល្អជាមួយទេ"

"មិនល្អជាមួយ ចុះយកលុយគាត់ម៉ោធ្វើអី"

"យកម៉ោដើម្បីនាំនាងទៅដើរលេងនៅកន្លែងល្អៗហ្នឹង!"

"យកលុយទុកទៅ វាមិនមែនជាពេលវេលាទៅដើរលេងទេ"

"កើតអី ម៉េចមើលទៅសោកសៅម្ល៉េះ" គេក្រសោបមុខខ្ញុំដោយការព្រួយបារម្ភ ពេលយើងត្រូវរ៉ូវគ្នា ហេតុអីក៏គេមើលទៅជាមនុស្សចិត្តល្អគួរឲ្យស្រលាញ់អីយ៉ាងនេះ ។

"គ្មានអីទេ"

"នឹកម៉ាក់ហើយហ្នឹង"

"O_O"

"ទោះជាខ្ញុំមិនចូលចិត្តម៉ាក់នាង តែខ្ញុំក៏មិនចិត្តអាក្រក់ដល់ថ្នាក់ហាមនាងនឹកម៉ាក់ដែរ ព្រោះសូម្បីតែខ្ញុំក៏អត់នឹងនឹកបាមិនបាន បានតេទៅរកហើយនៅ"

"មិនហ៊ានតេទៅទេ"

"ម៉េចក៏មិនហ៊ាន នោះជាម៉ាក់នាង តេទៅ"

"អ្ហ៎ លោកម៉ោបង្គាប់ធ្វើអី គឺខ្ញុំមិនទាន់ចង់តេទេ"

"បើមិនតេ ម៉ោអង្គុយសំកុកដូចខ្មោចងកាសោកសៅធ្វើអី ចាប់តេទៅ" កូអីន យកទូរសព្ទដៃរបស់ខ្លួនមកញាត់ក្នុងដៃខ្ញុំ "ចាំលេខម៉ាក់នាងបានទេ ឬមិនអីចឹងតេចូលលេខផ្ទះក៏បាន"

ខ្ញុំបម្រុងនឹងចុចតាមកម្លាំងបង្គាប់ តែថាទូរសព្ទដៃក្នុងហោប៉ៅខោខ្លួនឯងរោទិ៍មុន ដែលជាចង្វាក់ធ្វើឲ្យភ្ញាក់ផ្អើល ។

"ទូរសព្ទ!"

"ដូនកាលយើងមិនបាច់តេទៅក៏បាន ម៉ាក់នាងក៏នឹកនាងដូចគ្នា ចាប់ទទួលទៅ ម៉ាក់នាងហ្នឹងហើយ"

ខ្ញុំយកទូរសព្ទចេញមកចុចដោយមិនមើលលេខហៅចូល ហើយនិយាយចូលទៅ តែភ័យៗខ្លាចៗ តែអ្នកតេមកបែរមិនមែនម៉ាក់ ភាពអស់សង្ឃឹមវាផុសឡើងមក ហើយកាន់តែពេលដឹងថាអ្នកណាតេមក ភាពអស់សង្ឃឹមគឺដូចជាត្រូវព្យុះស៊ូណាមិជាត់យកទៅ ។

"ម៉េចម៉ាហើយនាងប្រមក់"

"ប៉ា!"

ទោះមិនមែនម៉ាក់ តែពេលដឹងថាអ្នកណាតេមក នោះក៏ធ្វើឲ្យខ្ញុំឈរមិនជាប់នឹងដី សប្បាយចិត្តស្រែកដាក់ទូរសព្ទធ្វើឲ្យប៉ាឈឺត្រចៀក

ស្រែកចាច ចេញពីអាការៈរីករាយទៅជាខឹង ។

(ហេ៎ ចិត្តត្រជាក់ៗ មានអីកើតឡើង ម៉េចចាំបាច់សម្លេងញ៉េរដល់ថ្នាក់នោះដែរ សរុបទៅសប្បាយចិត្ត ឬខូចចិត្តដែលប៉ាតេទៅ)

"ហើយប៉ាបាត់ទៅណា ដឹងទេថាជីវិតខ្ញុំពេលនេះវិលវល់ប៉ុណ្ណា"

(ប៉ាទៅបរទេស អ៊ំក្បែរផ្ទះប្រាប់កូនហើយតើ)

"ចុះម៉េចបានជាបាត់ទៅយូរដល់ថ្នាក់នោះ"

(គឺម៉ាវិញហើយតើ ព្រោះអ្នកជិតខាងប្រាប់ថាកូនម៉ាររករាល់ថ្ងៃ ទើបប៉ាគិតថាច្បាស់ជាមានរឿងអីសំខាន់ហើយ ម្យ៉ាងទៀតផ្ទះប៉ាត្រូវគាស់ មិនដឹងអាចោរចាតផ្សារណាធ្វើទេ ទោះជាកញ្ចក់ចាស់ បង្អួចចាស់ តែបើជួសជុលគឺត្រូវចំណាយលុយ)

ចោរដែលថាគឺកូនស្រីប៉ាហ្នឹងហើយ!

"រឿងនោះតាមតែវាសិនទៅ ពេលនេះខ្ញុំចង់ជួបប៉ាខ្លាំងណាស់ មានរឿងច្រើនណាស់ដែលខ្ញុំចង់ប្រាប់ប៉ា ហើយក៏មានរឿងចង់សុំដែរ"

(ល្អដូចគ្នា ប៉ាក៏មានរឿងចង់ប្រាប់កូនច្រើនដែរ អីចឹងប៉ានៅចាំ)

ខ្ញុំហាសដាក់ទូរសព្ទចុះ ហើយយកមកផ្អឹបនឹងទ្រូង ធ្វើឱ្យ គូអ៊ីនមើលមកដោយឫកពាម្ងួម៉ៅ ។

"កើតអី ម៉េចក៏ធ្វើមុខបែបនោះ"

"ម៉េចចាំបាច់សប្បាយចិត្តដល់ថ្នាក់នោះ"

"គឺប៉ាខ្ញុំតេម៉ោ"

"នាងមិនឃើញសប្បាយចិត្តពេលជួបខ្ញុំទេ"

"តែនេះជាប៉ាខ្ញុំ"

"ប៉ានាងជាមនុស្សប្រុស"

"អាប្រុសឆ្កួត!!!"

"លេងសើចខ្លះមិនបានទេរឺ តែថានាងចង់ទៅរកប៉ាឬ"

"វាច្បាស់ជាអីចឹងហើយ ប៉ាគឺជាក្ដីសង្ឃឹមតែមួយគត់ដែលខ្ញុំមានហើយខ្ញុំចង់ជួបគាត់ខ្លាំងណាស់" នៅសុខៗទឹកភ្នែកខ្ញុំក៏ហូរ ញែកមិនចេញទេថាវាជាទឹកភ្នែកអ្វីឱ្យប្រាកដ ព្រោះពេលនេះរសាប់រសល់អស់ហើយ "សុំទោស គួរឱ្យខ្មាសណាស់"

"ខ្មាសស្អី ឃើញនាងសប្បាយចិត្ត ខ្ញុំក៏សប្បាយចិត្តដែរ អីចឹងទៅ រកចាំទាំងអស់គ្នាទៅ"

"អ៊ឹម" ខ្ញុំនាំ កូអីន ចូលទៅក្នុងផ្ទះក៏ជួប សាំយ៉ុង កំពុងតែនិយាយជាមួយ ស៊ីជីន ដោយឫកពាចម្លែកៗ មើលទៅអួអាប់ ខ្ញុំប៉ះដឹងតាមរយៈបរិយាកាស ។

"និយាយគ្នាយូរដល់ហើយ ចាក់ទឹកហើយនៅ ម៉ោដល់ក៏ស្រែកឡេឡូ ខ្ញុំទឹកថាំងអាចម៍ ខ្ញុំចង់ជួបថាំងអាចម៍ គួរឲ្យធុញមែន" ស៊ីជីន ងាកទៅរក កូអីន ហើយសើចខឹកខាក់ តែមុខខ្ញុំនេះដូរដូចទឹកដោះគោហួសដីឡើងទៅហើយ ម៉េចក៏ចូលចិត្តហៅខ្ញុំថាថាំងអាចម៍ម្លេះ ឈ្មោះខ្ញុំគួរឲ្យស្រលាញ់សឹងអ្វី ។

"រិះនឹងចាត់ហើយ តែត្រូវកាត់ចង្វាក់ដោយអ្នកដែលនាងប្រមក់នេះនឹករលឹកដាច់ខ្ញុំ"

"អ្នកណា" ស៊ីជីន ។

"ចាំខ្ញុំ ចាំម៉ោវិញហើយ"

ស្ងួប្បតែ ស៊ីជីន ក៏ធ្វើមុខសប្បាយចិត្តដែរ ចំជារឿងល្អដែលចូលមកចំពេលដែលខ្ញុំកំពុងយ៉ាប់បំផុតអីយ៉ាងនេះ ។

"អីចឹងឯងចាប់ទៅរកទៅ"

"គឺទៅឥឡូវហើយ ទើបចូលម៉ោប្រាប់ឯង"

"ឲ្យខ្ញុំទៅដែរទេ"

"បើឯងទៅ អ្នកណាចាំផ្ទះ"

"ចាំខ្ញុំជូនទៅ" សាំយ៉ុង យកអាសារក្លាម កូអីន រកប្រកែក តែស៊ីជីន គ្រហែម ហើយជ្រែកសម្តីដោយដឹងទាន់ ។

"ឲ្យអ្នកមានឡានជូនវាល្អសឹងអ្វី ម៉េចក៏ចាំបាច់លំបាកជិះតាក់ស៊ីម្យ៉ាងទៀតលោកបែបមិនបណ្តោយឲ្យ ចុងអ៊ុល ជិះតាក់ស៊ីម្នាក់ឯងទេ ហើយលោកក៏មិនមែនជាអ្នកដែលចូលចិត្តប្រើឡានសាធារណៈរួមជាមួយអ្នកផ្សេងដែរ"

"កុំម៉ោធ្វើជាដឹងច្បាស់" កូអីន ។

"ឬមិនពិត"

"ហឺស!"

"ដូច្នោះហើយអង្គុយឱ្យសប្បាយៗ ហើយលោកក៏មិនបាច់សម្តែងអារម្មណ៍ប្រចណ្ឌស្អីណាស់ណា មាន សាំយ៉ុង ជាអ្នកជូនវាល្អសឹងអ្វីមិនបាច់ខាតថ្លៃតាក់ស៊ីទៀត កញ្ជះដាច់ថ្លៃ" សឺជីន បញ្ឆឺចំៗតែម្តង តែ សាំយ៉ុង បែរជាញញឹមទទួល ហើយងើបឈរ ។

"អីបឹងតស់ទៅយើង"

ពេលអស់អីតបត បុងក្រោយ កូអ៊ីន ក៏ព្រមឱ្យខ្ញុំជិះឡាន សាំយ៉ុង ដោយមានគេនិងប្អូនស្រីមកជាមួយ ចំណែក សាំយ៉ុង ក៏ធ្វើតួនាទីជាអ្នកបើកបរឱ្យដូចដែល សឺជីន បញ្ឆឺ ។ នៅតាមផ្លូវខ្ញុំគិតដល់ចាវហ្វូតហើយគិតថាគួរតែនិយាយស្អីឱ្យគាត់ស្តាប់មុន វហ្វូតដល់មិនដឹងថាពេលនេះឡានមកចតនៅក្នុងហ្គារ៉ាស់សាំងទៅហើយ ។

"ចូលចាក់សាំងសិន"

"ម៉េចក៏ឯងមិនចាក់ឱ្យហើយតាំងពីពេលម៉ោ ខាតពេល ហឺយ! ម្យ៉ាងទៀតឯងក៏គួរតែដឹងថាខ្ញុំមិនចូលចិត្តក្លិនសាំង វាស្អុយ"

"បើមិនចូលចិត្តក៏ទៅទិញអីនៅមីនីម៉ាតសិនទៅ ចាក់ម៉ាក្លែតក៏រួចទៅហើយ ចាំខ្ញុំបើកឡានទៅយក"

កូអ៊ីន ធ្វើឡឺងឡង់គិតបន្តិច មុននឹងងាកមកសួរខ្ញុំ÷

"នាងចុះទៅទេ"

"ទេ ខ្ញុំចង់អង្គុយលើឡាន ខ្ជិលចុះ"

"នាងត្រូវតែចុះ!"

"អ្ហ៎ ខ្ញុំមិនចុះទេ"

"ចុះនាងអង្គុយលើឡានបានយ៉ាងម៉េចដោយគ្មានខ្ញុំ"

"ពេលខ្ញុំរៀនដើរ លោកជាអ្នកបង្រៀនខ្ញុំអត់ ខ្ញុំមិនមែនក្មេងបីឆ្នាំទេដែលត្រូវឃុំក្នុងឡាន ហើយបើកមិនបាន"

កូអ៊ីន ដកដង្ហើមវាងញាប់បន្តិច តែក៏ព្រមទុកឱ្យខ្ញុំនៅលើឡានដោយមិនភ្លេចងាកមកធ្វើកោងកាចដាក់÷

"ហាមនិយាយជាមួយ សាំយ៉ុង"

"អាដែលឱ្យខ្ញុំចុះទៅជាមួយព្រោះហេតុផលនេះអ្ហ៎ស"

"ចឺស" កូអ៊ីន ចុះពីឡានដោយមិនភ្លេចដឹកដៃ កូសង់ ទៅជាមួយផង ហើយងាកទៅមើលមិត្តដែលឈរត្រង់ទូសាំងមើលលេខដែលរត់តាមចំនួនលុយ មុននឹងដើរទៅមីនីម៉ាត ។ ពេល កូអ៊ីន ចូលក្នុងហាងក្លាម សាំងក៏ពេញល្មម សាំយ៉ុង ហុចលុយឱ្យអ្នកលក់ ហើយចូលមកក្នុងឡានវិញ បញ្ឆេះ បើកយ៉ាងលឿនចេញពីហ្គារ៉ាស់សាំងក្លាម ។

"ឈប់ៗ លោកភ្លេច កូអ៊ីន និង កូសង់ ហើយ"

"មិនបានភ្លេច"

"ហឺ?"

"ខ្ញុំនឹងពង្រត់នាង"

"ហ៉ា!!!"

២១

សាំយ៉ុង ដាន់ហ្វ៊ែរី បែបមិនគិតពីជីវិតចេញពីហ្គារ៉ាស់សាំង ហួតសឹងតែបុកនឹងឡានដឹកទំនិញដែលបើកបញ្ច្រាសទិសមកយ៉ាងលឿន មុននឹងកាច់ចង្កូតគេច ហើយបើកតម្រង់ទៅមុខរកទិសដៅដែលគេគូរទុកក្នុងចិត្តដោយមិនសួរអីខ្ញុំមួយម៉ាត់ ពេលនេះចិត្តខ្ញុំកំពុងតែខ្វល់ខ្វាយពី កូអ៊ីន យ៉ាងខ្លាំង ព្រោះមិនដឹងថាគេដឹងឬនៅថាត្រូវ សាំយ៉ុង ទុកចោល ។

"ម៉េចក៏ធ្វើបែបនេះ ទៅរក កូអ៊ីន ភ្លាម"

"ហេតុអីខ្ញុំត្រូវធ្វើបែបនោះ មិនសម្លាប់វាគឺល្អពេកហើយ"

"និយាយស្អីរបស់លោកហ្នឹង សាំយ៉ុង តាំងសតិ ហើយបើកទៅហ្គារ៉ាស់សាំងវិញ មិនអីចឹងខ្ញុំនឹងលោតចុះហើយ"

សម្ដីរបស់ខ្ញុំគឺគ្រាន់តែជាខ្យល់ដែលបក់ទៅបក់មកសម្រាប់គេ សាំយ៉ុង បានតែញញឹមចម្អក ហើយបើកទៅមុខដោយមិនខ្វល់ពីអ្វីទាំងអស់ ព្រោះស្នាមញញឹមរបស់គេ ធ្វើឱ្យខ្ញុំគិតអ្វីច្រូកៗដូចជាការលោតចុះពីឡាន តែពេលលូកដៃទៅរកទ្វារក៏បើកវាមិនចេញ ។

"នាងគិតថាឡាននេះថ្លៃប៉ុន្មាន អាគ្រាន់តែនាងគំរាមថាលោតចុះ គិតថាខ្ញុំចាក់សោមិនបានអ្ហេស"

"ធ្វើបែបនេះធ្វើអី សាំយ៉ុង លោកមិនមែនមនុស្សបែបនេះទេ"

"នាងមិនដឹងទេថាខ្ញុំជាមនុស្សយ៉ាងណា!"

"..."

"នាងហ៊ានណាស់ដែលធ្វើដូចជាស្គាល់ខ្ញុំច្បាស់ ហើយខ្ញុំនឹងធ្វើឱ្យនាងដឹងថាធាតុពិតរបស់ខ្ញុំវាយ៉ាងណា ចាំមើលទៅ!"

ខ្ញុំមានអារម្មណ៍ថារង៉ារត្រជាក់ពេលបានឮសម្លេងប្រកាសបែបនោះ ទើបបានតែអង្គុយរឹងខ្លួនកម្រើកទៅណាមិនបាន ហើយអ្វីដែលខ្ញុំខ្វល់ខ្វាយក៏កើតឡើង ពេលទូរសព្ទដៃរបស់ខ្ញុំរោទិ៍និងជាខ្សែហៅចូលរបស់ កូអ៊ីន តែពេលខ្ញុំចុចទទួល សាំយ៉ុង ក៏ចក់យកទៅនិយាយ ។

"មែន...ខ្ញុំទុកឯងចោល និងនាំសង្សារឯងរត់ម៉ោជាមួយខ្ញុំ...ជួយមិនបានទេ គឺឯងដឹងថាខ្ញុំមិនមែនជាមនុស្សដែលទុកចិត្តបាន ឯងភ្លាត់ស្នៀតដោយខ្លួនឯងទេ!"

និយាយចប់ គេក៏បើកកញ្ចក់បង្អួច ហើយបោះទូរសព្ទខ្ញុំចេញទៅដោយមិនខ្វល់ថាវាមានតម្លៃប៉ុណ្ណា ។

"នោះគឺទូរសព្ទខ្ញុំ"

"នាងមិនចាំបាច់ប្រើវា...ទៀតទេ"

"កូអ៊ីន ថាម៉េចខ្លះ ហើយម៉េចក៏លោកនិយាយបែបនោះ ខ្ញុំមិនបានរត់តាមលោកអីបន្តិចទេ!"

"នៅជាមួយខ្ញុំមួយរយៈ នាងនឹងមានអារម្មណ៍ថាចង់រត់តាមខ្ញុំ"

ប្រឺននន~

នោះគឺជាប្រយោគចុងក្រោយរបស់គេ មុននឹងយើងមិននិយាយគ្នាទៀតនៅលើផ្លូវធ្វើដំណើរដោយមិនដឹងគោលដៅ...

សមុទ្រដែលស្រស់ស្អាតនៅក្នុងអារម្មណ៍របស់ខ្ញុំរាល់ពេលដែលបានឃើញ ពេលនេះវាបែរក្លាយត្រឹមតែជាផ្ទៃទឹកប្រែធ្វើឲ្យផ្សារភ្នែកនិងទោរម្នេញចិត្តលើសពីការនៅជាមួយវាបានយូរ សម្លេងរលករបស់វាដូចជាសម្លេងគំរាមដ៏គួរឲ្យធុញទ្រាន់ ព្រោះខ្ញុំចង់ចេញពីទីនេះឲ្យផុត ។

សាំយ៉ុង នាំខ្ញុំមកផ្ទះលំហែនៅម្តុំពូសាន ដែលនេះវាមើលទៅមានលក្ខណៈឯកជនរហូតដល់ខ្ញុំមួម៉ៅ ព្រោះនោះមានន័យថាគ្មានមនុស្សនៅទេ ហើយខ្ញុំនឹងសុំជំនួយពីអ្នកណាបាន ទូរសព្ទដៃក៏ត្រូវគេវែងចោលតាមផ្លូវ ។

"ចូលក្នុងផ្ទះសិនទៅ ធំណាស់"

"ធ្វើបែបនេះដើម្បីស្អី"

"ចាំនិយាយរឿងនេះនៅពេលក្រោយ"

"ខ្ញុំចង់និយាយឥឡូវ!"

សាំយ៉ុង ងាកមកសម្លឹងខ្ញុំហាក់ដូចជាសត្វព្រៃដែលអស់ការអត់ធ្មត់ចំពោះភាពស្រេកឃ្លាន គេតម្រង់ចូលមកចាប់ក្របួច-កអាវខ្ញុំឲ្យចូលទៅជិត ។

"ខ្ញុំនាំម៉ោព្រោះចង់នាំម៉ោ ពេលនេះខ្ញុំគិតមិនចេញទេថាខ្ញុំចង់ធ្វើស្អី!"

ពន្លឺភ្នែករបស់គេពេញទៅដោយភាពរសាប់រសល់និងឈឺចាប់ ហួតដល់មួយភ្លែតនោះខ្ញុំកើតចិត្តអាណិត តែព្រោះថាមិនយល់ពីទង្វើរបស់គេ ទើបវាធ្វើឲ្យខ្ញុំចង់ឈ្លោះជាមួយគេឲ្យវាណាណី វាមិនសមហេតុផល គេមិនគួរធ្វើដាក់ខ្ញុំបែបនេះទេ ។

"លោកនាំខ្ញុំចេញពីសេអ៊ូលដើម្បីមកទីនេះដោយមិនដឹងថាចង់ធ្វើអីអីចឹងឬ ថែមទាំងនាំចេញពី កូអីន ទៀត"

"កូអីន ទៀតហើយ ស្អីៗក៏ កូអីន បុះខ្ញុំ!"

"លោកម៉េច គឺយើងនិយាយគ្នាដឹងរឿងហើយតើ"

"នាងដឹងតែម្នាក់ឯង តែខ្ញុំមិនបានដឹងស្អីជាមួយទេ!"

"នេះប្រែថាលោកមិនបានមានអារម្មណ៍ធម្មតាៗបែបដែលលោកសម្ដែងចេញមកទេអ៊ុំស"

"..."

សម្ដីរបស់ សឺជីន ចូលមកក្នុងខួរក្បាលខ្ញុំភ្លាម នាងធ្លាប់តឿនថា សាំយ៉ុង ឈឺចាប់ តែខ្ញុំមិនធ្លាប់គិតនឹងយកចិត្តទុកដាក់ គឺគេបិទជិតដល់ថ្នាក់នោះ...

"យើងមិនដែលមានពេលវេលាមានក្ដីសុខដូចគូស្នេហ៍ផ្សេងទេ ខ្ញុំចាកចេញព្រោះវាមិនមែន លោកគួរតែយល់"

"ខ្ញុំមិនធ្លាប់ត្រូវអ្នកណាចាកចេញមុនទេ ហើយក៏មិនធ្លាប់ស៊ាំនឹងអារម្មណ៍នេះដែរ អារម្មណ៍ដូចមនុស្សខូចចិត្តរឿងស្នេហា!"

"O_O"

"ហើយខ្ញុំក៏មិនព្រមឈឺចាប់ដោយសារវាដែរ នៅក្នុងពេលដែល

ខ្ញុំមិនបាន អ្នកផ្សេងសូម្បីតែមិត្តជិតដិត...ក៏មិនបាន!"

"វ៉ាយ!"

សាំយ៉ុង លើកខ្ញុំដាក់លើស្មា ហើយនាំចូលក្នុងផ្ទះ មុននឹងបោះទៅលើព្រូកពណ៌ក្រហមលាន់ក្លុក ការភ្ញាក់ផ្អើលធ្វើឱ្យខ្ញុំភ្លេចការឈឺចាប់អស់ពេលដឹងថាអ្វីនឹងកើតឡើងបន្ត សាំយ៉ុង ស្ទុះមករក ហើយព្យាយាមហែកខោអាវខ្ញុំចេញ តែខ្ញុំតស៊ូរើបម្រះហាក់ដូចជាឆ្កែទាល់ច្រក ទាំងក្តិច ទាំងខ្វៅ ទាំងជាក់ ។

"លែងខ្ញុំ!!"

"នាងដឹងទេថានេះជាលើកតំបូងហើយដែលខ្ញុំគិតចង់ធ្វើបែបនេះ ព្រោះមិនធ្លាប់មានស្រីណាបដិសេធខ្ញុំទេ"

"កុំធ្វើបែបនេះ កុំធ្វើឱ្យខ្ញុំស្អប់លោកច្រើនជាងនេះ!"

"អី ស្អប់ខ្ញុំទៅ ស្អប់ឱ្យច្រើនទៅ ទោះជានាងមិនស្អប់ ក៏ខ្ញុំយកស្នេហាពីនាងមិនបានដែរ ហើយវាមានប្រយោជន៍អ្វី ខ្ញុំមិនត្រូវការធ្វើជាមិត្តនាងទេ យល់ទេ!"

"លោកគ្រាន់តែចង់យកឈ្នះ ព្រោះលោកមិនធ្លាប់ចាញ់នៅក្នុងរឿងស្រីៗ ពេលត្រូវខ្ញុំធ្វើបែបនេះដាក់ ក៏ទ្រាំមិនបាន វាមិនមែនជាស្នេហាទេ យល់ទេ វាមិនមែនទេ!"

"នាងចង់និយាយអ្វីជារឿងរបស់នាង តែសម្រាប់ខ្ញុំវាជាស្នេហា"

"កុំ ហឺៗ ចាំជួយកូនផង"

ពេលខ្ញុំស្រែកបែបនោះ សាំយ៉ុង ដែលកំពុងចុះប្រេងក៏ច្ងក់ ពន្លឺភ្នែករបស់គេរសាប់រសល់ ហើយមើលខ្លួនឯងដោយមានសំនួរ ។

"នេះខ្ញុំកំពុងធ្វើអី"

"ហ៊ឺៗ ចេញទៅ ចេញទៅ!"

ខ្ញុំប្រើកម្លាំងចុងក្រោយច្រាន សាំយ៉ុង ឱ្យដួល ពេលនេះខ្ញុំមិនខុសអីពីក្មេងតូចដែលខ្លាចរបស់នៅជុំវិញខ្លួន កន្លែងដែលខ្ញុំគិតថាមានសុវត្ថិភាពបំផុតគឺគៀនបន្ទប់ដែលធ្វើឱ្យខ្លួនឯងអាចប្រជ្រៀតខ្លួន ហើយយកដៃការពាររាងកាយបាន សាំយ៉ុង ពេលឃើញឫកពាក្យខ្លាចរបស់ខ្ញុំបែបនោះក៏និយាយដោយដឹងកំហុស តែវាយឺតពេលទៅ

ហើយដែលគេធ្វើបែបនោះ ។

"កុំខ្លាចខ្ញុំ...ចុងអ៊ីល"

"ចេញទៅ ខ្ញុំចង់ទៅផ្ទះ"

"ខ្ញុំមិនឲ្យទៅ!"

"ហ៊ឺៗ"

"ខ្ញុំមិនធ្វើអីនាងទេ ឈប់យំទៅ តែទោះយ៉ាងណាក៏ខ្ញុំមិននាំនាងទៅវិញដែរ នាងត្រូវនៅទីនេះជាមួយខ្ញុំ ខ្ញុំត្រូវការឲ្យ កូអ៊ិន គិតវែងឆ្ងាយថានាងនិងខ្ញុំមានស្អីៗគ្នាហើយ"

"មនុស្សអាក្រក់!"

"ខ្ញុំក៏មិនគិតថាខ្លួនឯងធ្វើបានដល់ថ្នាក់នេះដែរ តែខ្ញុំទ្រាំឃើញនាងនៅជាមួយអ្នកផ្សេងមិនបាន!"

"ដកក្បាលចេញទៅ កុំមកឲ្យខ្ញុំឃើញមុខទៀត ទៅ!"

សាំយ៉ុង មើលមុខខ្ញុំដោយការឈឺចាប់ តែក៏ព្រមដើរចេញទៅ ហើយទុកឲ្យខ្ញុំនៅម្នាក់ឯង ហេតុអីត្រូវកើតរឿងឆ្កួតៗបែបនេះដែរ អ្នកណាក៏បាន នាំខ្ញុំចេញពីទីនេះផង ។

ខ្ញុំមិនដឹងថានៅសេអ៊ូលមានអ្វីកើតឡើងខ្លះទេ តែខ្ញុំនៅពេលនេះគឺកំពុងធ្វើបាតុកម្មអត់អាហារអត់ទឹក មិនព្រមញុំាអ្វីទាំងអស់ នេះវាកន្លងផុតច្រើនថ្ងៃទៅហើយ តែខ្ញុំនៅតែនៅកន្លែងដដែល ត្រង់នេះ និងមិនធ្លាប់ចេញទៅណាបាន ។

ខ្ញុំមិនខុសអ្វីពីអ្នកទោស បើ សាំយ៉ុង ចេញទៅទិញអាហារ គេនឹងចាក់សោផ្ទះសោបន្ទប់ ព្រោះខ្លាចខ្ញុំរត់ មានម្តងនោះខ្ញុំលួចរត់ចេញបានពេលអាធ្រាត្រ តែក៏ត្រូវតាមចាប់មកវិញ សាំយ៉ុង សម្រាប់ខ្ញុំនៅពេលនេះជាបិសាចដែលអាចស៊ីខ្ញុំបានគ្រប់ពេល ចុងក្រោយគេទាញខ្ញុំទៅថើប ហើយគំរាមថា...

'បើមានលើកក្រោយទៀត ខ្ញុំនឹងធ្វើឲ្យនាងដឹងថាហេតុអីក៏ព្រះឲ្យមនុស្សប្រុសមានកម្លាំងច្រើនជាងមនុស្សស្រី'

សាំយ៉ុង ដឹសែនទទន់ភ្លន់ មានស្នាមញញឹមជាប់ជានិច្ច ពេលនេះ

គេម្នាក់នោះបានស្លាប់បាត់ទៅហើយ ស្លាប់ដំណាលនឹងខ្ញុំដែលគ្មានកម្លាំងកំហែងព្រោះមិនញ៉ាំអាហារ មានច្រើនដងណាស់ដែលខ្ញុំសឹងតែស្ទុះទៅរកអាហារសមុទ្រដែលគេទិញមកឱ្យ តែថាការស្អប់ខ្ពើមដែលមានចំពោះគេ វាច្រើនជាងការចង់ញ៉ាំ ទើបត្រូវឱ្យសត្វសមុទ្រងាប់នៅក្នុងធុងសម្រាមដោយគ្មានតម្លៃ។

"បើនាងមិនញ៉ាំខ្លះ ឧបមាខ្ញុំត្រេកកាមចង់រំលោភនាង នាងនឹងគ្មានកម្លាំងរើបម្រះទេ"

គេនិយាយដោយញញឹមជង តែនោះធ្វើឱ្យខ្ញុំសម្លឹងគេថ្មែរ។

"ពេលណាខ្ញុំត្រូវធ្វើបាប ខ្ញុំនឹងងាប់ឱ្យមើល!"

"គួរឱ្យខ្លាចមែន ខ្ញុំដាក់អាហារនៅត្រង់នេះ ឃ្លានក៏ញ៉ាំទៅ"

"ចង់ឃុំខ្ញុំយូរទៀតប៉ុណ្ណា ខ្ញុំនឹកផ្ទះ!"

សាំយ៉ុង ចូក់ ហើយសួរដោយស្នាមញញឹម÷

"ផ្ទះណាដែលនាងនឹក ផ្ទះដែលមានម៉ាក់ ឬផ្ទះដែលមានប៉ា"

"ខ្ញុំចង់ទៅសេអ៊ូល ធុញនឹងនៅទីនេះហើយ"

"តែខ្ញុំមិនធុញ"

"លោកស្រលាញ់ខ្ញុំពេកដល់ថ្នាក់ធ្វើអីបែបនេះបានឬ លោកកំពុងតែធ្វើឱ្យខ្ញុំងាប់ទាំងរស់ហើយ"

"ខុសពីខ្ញុំដែលស្លាប់ទៅហើយគ្រាន់តែឃើញនាងនៅជាមួយវា"

ផ្លូង!!!

ដោយគេមិនបានតាំងខ្លួន ខ្ញុំក៏ដើរទៅប្រកៀក ហើយយកថូផ្កាកញ្ចាស់ដែលគ្មានសូម្បីតែម៉ូតរចនាវាយក្បាលគេ ធ្វើឱ្យថូផ្កាបែកខ្ចាយ សាំយ៉ុង ដេកស្លាបដោយមានឈាមស្រោចក្បាល ទោះជារន្ធត់បិត្ត តែនេះគឺឱកាសចុងក្រោយនិងតែមួយដែលខ្ញុំចេញពីទីនេះបាន។

"អីចឹងគួរតែងាប់បែបដែលមិនចាប់ធ្វើបាបអ្នកផ្សេងល្អជាង"

ប៊ឹប!

សាំយ៉ុង ចាប់កដើងខ្ញុំខណៈដែលរត់គេច ខ្ញុំប្រើកម្លាំងដែលមិនស្មានជាមានរបស់ខ្លួនគ្រវាត់ ហើយប្រើជើងម្ខាងទៀតជាន់ដៃគេដល់ថ្នាក់ស្រែកបាចមិនចេញជាភាសាមនុស្សលោក។

"ខ្ញុំស្អប់លោក!"

និយាយចប់ ខ្ញុំក៏រត់ចេញមកយ៉ាងលឿន នៅខាងក្រៅផ្ទៃមេឃក្លាយជាពណ៌ខ្មៅទៅហើយ សម្លេងរលកសមុទ្រកាន់តែធ្វើឱ្យខ្ញុំខ្លាចហួសកម្រិត តែការចង់ចាកចេញធ្វើឱ្យខ្ញុំលែងខ្លាចអ្វីទៀតហើយ ។

ផ្ទះលំហែរបស់ សាំយ៉ុង នៅច្រកដែលមិនសូវមានមនុស្សស្នាក់នៅ សងខាងផ្លូវពេញទៅដោយដើមឈើ ឱកាសដែលខ្ញុំគេចចេញពីសាំយ៉ុង បានហៅថាសឹងតែសូន្យ តែបើមិនគេច ខ្ញុំក៏ត្រូវនៅក្នុងបន្ទប់នោះដល់ស្អិតជាប់ ខ្ញុំគួរតែយកពិលមកបានមួយ យ៉ាងហោចណាស់ក៏អាចដឹងថាខាងមុខមានអ្វី វាងងឹតពេកហើយ ។

"ឈប់!"

សម្លេងស្រែករបស់ សាំយ៉ុង ធ្វើឱ្យខ្ញុំភ្ញាក់ព្រើត ភាពងងឹតមានតម្លៃស្មើសូន្យបើធៀបនឹងមាត្រដ្ឋានវាស់ភាពភ័យខ្លាច ខ្ញុំវាយគេឱ្យសន្លប់ហើយតើ ។

ពេលឮបែបនេះ ខ្ញុំក៏ដាក់មេជាយបែបមិនគិតជីវិត ខ្ញុំខុសខ្លួនឯងដែលមិនព្រមញ៉ាំបាយ កម្លាំងពេលនេះជិតអស់ហើយ អ្នកណាក៏បាន ជួយខ្ញុំផង ខ្ញុំមិនត្រូវឱ្យគេចាប់បានទៀតទេ មិនអីចឹងម្តងនេះអាចនឹងត្រូវអ្វីខ្លះក៏មិនដឹង ។

ពីននន!!

សម្លេងស៊ីផ្លេឡានឮលាន់ ធ្វើឱ្យខ្ញុំភ្ញាក់ដួលស្លាបលើដី ពន្លឺភ្លើងឡានដូចជាក្តីសង្ឃឹមដែលផុសចេញពីភាពងងឹត ទ្វារត្រូវបើកព្រមគ្នានឹងសម្លេងជើងដែលដើរមករក បុរសរាងខ្ពស់ដែលគួរតែចាស់ជាងខ្ញុំមិនប៉ុន្មានខ្ញុំដើរមកដោយការម្ហូម៉ៅ ។

"កើតអី ម៉េចម៉ោឈរមុខឡាន ខ្ញុំបិះនឹងបុកជាប់ហើយ ដឹងទេ"

"ជួយខ្ញុំផង"

"ស្អីនេះ"

"នាំខ្ញុំចេញពីទីនេះទៅ សូមមេត្តា"

២២

គឺមិនដឹងថាសតិល្អ ឬឆ្កួតឲ្យប្រាកដទេ ទើបបានជាព្រមឡើងឡាន
របស់មនុស្សចម្លែកមុខនៅកណ្ដាលភាពងងឹត តែពេលនេះនៅក្នុង
អារម្មណ៍របស់ខ្ញុំ ជីវិតគឺដូចជា រ៉ាត់សៀន រ៉ូលេត បើមិនគេចបែបនេះ
នឹងត្រូវឃុំនៅកន្លែងដើមនិងមិនដឹងថាមានអ្វីកើតឡើងខ្លះទេ ។ បុរស
ដែលអង្គុយគិតតែមើលទៅមុខរហូតខណៈដែលបើកឡាន ភាពស្ងៀម
ស្ងាត់ធ្វើឲ្យគេទ្រាំលែងបាន ក៏ធ្វើជាអ្នកនិយាយមុន ។

"នាងប្រហែលជាមិនដូររាងកាយ នៅសុខៗមុខក៏មានឈាម...
ស្អីបែបនោះទេមែនទេ"

"ម៉េចក៏មុខខ្ញុំចាំបាច់មានឈាម"

"គឺបែប..នាងអាចជាខ្មោច"

"ខ្មោចឯណាគ្មានកម្លាំងកំហែងបែបនេះអ្ហ៎ស"

គ្រូកកក~

សម្លេងក្រពះរបស់ខ្ញុំសាងភាពអាម៉ាស់ដល់ម្ចាស់ខ្លួន រហូត
ដល់អ្នកមានទឹកចិត្តមើលមុខខ្ញុំដោយការសង្ស័យ ។

"ខ្ញុំជឿហើយថានាងជាមនុស្ស ពោះក្រូវដូចរន្ទះ"

"TTOTT"

"ចុះម៉េចក៏ទៅត្រង់នោះពេលយប់ងងឹត ដឹងទេថាម៉ោងប៉ុន្មាន
ហើយ ថែមទាំងមកសុំឲ្យខ្ញុំជួយដូចត្រូវតាមប្រមាញ់ទៀត"

"ខ្ញុំត្រូវតាមប្រមាញ់ពិតមែន"

"O_O ពីអ្នកណា"

"ប្រុសម្នាក់"

"..."

"ខ្ញុំមិនបាននិយាយលេងទេ ខ្ញុំត្រូវគាមប្រមាញ់មែន"

"អឺ ជឿក៏ជឿ តែថានាងឈ្មោះអីទើងបានហៅត្រូវ ហើយចង់ឲ្យខ្ញុំជូននាងទៅណា"

"ខ្ញុំឈ្មោះ ម៉ាឋុងអ៊ុល ចុះលោក"

"ហៅខ្ញុំថា ជេស ក៏បាន កុំម៉ោលោកម៉ោលួយស្អី ព្រឺរោម"

"ខ្ញុំមិនដឹងថាជំនួសសព្ទនាមថាម៉េចទេ មើលមិនដឹងថាអ្នកណាចាស់ជាង"

"ខ្ញុំរៀនឆ្នាំទីពីរ"

"អឺចឹងខ្ញុំហៅថាបងប្រុសចុះ"

"អូខេ"

"ចុះបងកំពុងទៅណា"

"បេះតែបើកទៅ បើធុញអាចទៅសេអ៊ូលវិញ"

ពេលបានឮថា សេអ៊ូល រាងកាយរបស់ខ្ញុំក៏កន្ត្រាក់ដោយការរំភើប មិនបាច់និយាយក៏ ជេស អាចមើលដឹងច្បាស់ដែរ។

"នាងចង់ទៅសេអ៊ូលឬ ក៏បាន ចាំជូនទៅ តែត្រូវចាក់សាំងសិនជិតអស់ហើយម្យ៉ាងទៀត...នាងនឹងបានញុំាបាយផង"

"មិនបាច់ក៏បាន ខ្ញុំគ្មានលុយផង"

"ខ្ញុំចាំវ!"

"គំប្រាប់ថាមិនបាច់ក៏បាន"

"អឺ ចាំវក៏បាន សំណាងល្អដែលខ្ញុំជាអ្នកមាននិងមានចិត្តមេត្តាមុទិតា ឧបេក្ខា តាឡូឡា"

"ភ្ញើងដល់ហើយ តែក៏អរគុណ"

ប្រុសម្នាក់នេះមើលទៅមិនគួរជាមនុស្សអាក្រក់ទេ ព្រោះគេគ្មានឫកពាថាជាមនុស្សអាក្រក់ ហើយថែមទាំងចាំវបាយខ្ញុំទៀត តែ...ទោះយ៉ាងណាក៏ដោយក៏គេជាមនុស្សប្រុស នៅសុខៗមកជួយដោយគ្មានបំណងគឺវាមិនពិតទេដឹង យើងគួរប្រយ័ត្នខ្លួនប្រសើរជាង ។ ខ្ញុំមើលទៅជុំវិញខ្លួនដោយមិនដឹងថាធ្វើយ៉ាងណាល្អ ហ្វូតដល់ប្រទះនឹងទូរសព្ទ

ដៃទៅក្នុងប្រអប់ដាក់របស់។

"មានអីដែរទេបើខ្ញុំសុំខ្ចីទូរសព្ទបន្តិច"

"មាន"

"=O="

"មានគឺអូខេ នាងកើតរោគប៉ិនសុំឬ សុំទៅផង សុំឱ្យចាំវចាយ សុំប្រើទូរសព្ទ"

"ប៉ិនអ៊ីមែន"

"អីគេ"

"អត់ទេ អីចឹងសុំខ្ចី"

ខ្ញុំប្រើពេលាប្រហែលជាពីរនាទីក្នុងការរកទឹកលេខ ពេលនេះខ្ញុំមានអារម្មណ៍ថាខឹងនឹងទិចណូឡូជីដែលទាន់សម័យភ្លាម ពេលមានអ្នកឱ្យលេខមកក៏គិតតែសេវទុកក្នុងទូរសព្ទរហូតដល់មិនចាំថាលេខប៉ុន្មានជារបស់អ្នកណា តែពេលទឹកបានខ្លះ ទើបគ្មានបញ្ហាអីប៉ុន្មាន ហើយលេខដែលទឹកឃើញជារបស់អ្នកផ្ទះ ស៊ីជីន កាលពីសម័យអនុវិទ្យាល័យ ខ្ញុំតែងតែគេទៅជាញឹកញាប់។

"ស៊ីជីន នេះគឺខ្ញុំ"

(ហេ៎ ជុងអ៊ីល)

សម្លេងរបស់ ស៊ីជីន រំភើបភ្លាមពេលដឹងថាអ្នកណាគេទៅរក ខ្ញុំស្ទើរតែយំទៅហើយពេលបានសម្លេងមិត្ត។

(ឯងម៉េចម៉ាហើយ ដឹងទេថាខាងនេះខ្វាត់ខ្វែងប៉ុណ្ណាពេលដឹងថាឯងបាត់ខ្លួន)

"ខ្ញុំកំពុងទៅវិញហើយ តែប្រហែលទៅគេងផ្ទះប៉ា ឯងជួយទាក់ទងទៅប៉ាឱ្យបន្តិចផង"

(មានអីកើតឡើង)

"ចាំនិយាយឱ្យស្តាប់ពេលក្រោយ ឯងប្រាប់ប៉ាឱ្យបន្តិច ខ្ញុំត្រូវដាក់ទូរសព្ទចុះហើយ សុំខ្ចីគេប្រើទេ"

ខ្ញុំដាក់ទូរសព្ទចុះដោយការក្រែងចិត្ត ព្រមទាំងហុចទៅឱ្យ ជេស ម្ចាស់ខ្លួនញាក់ស្មាមិនញញើត។

"ចង់និយាយយូរក៏បាន ទូរសព្ទខ្ញុំមានប្រមូសិន"

"ប៉ុណ្ណឹងក៏អរគុណច្រើនហើយ"

ជេស ចូលចាក់សាំងឲ្យពេញ មុននឹងនាំខ្ញុំទៅញ៉ាំបាយនៅហាងម្ដុំនោះ ពេលអង្គុយញ៉ាំ គេក៏គិតតែសម្លឹងមុខខ្ញុំ ។

"ជាការពិតឬដែលនាងត្រូវចាប់ខ្លួន"

ខ្ញុំច្រូកដៃដែលកំពុងកាន់ស្លាបព្រាដួលបាយចូលមាត់ ហើយងក់ក្បាលទាំងតូចចិត្ត÷

"ចាំ"

"អ្នកដែលចាប់នាងទៅ គេត្រូវការអីពីនាង"

ខ្ញុំធ្វើមុខពិបាកចិត្ត ព្យាយាមបង្ហាញឲ្យដឹងថាខ្ញុំមិនចង់និយាយ តែមើលទៅដូចជាមានកម្លាំងអំណាចអ្វីម៉្យាងបង្គាប់អារម្មណ៍ខ្ញុំតាមខ្សែភ្នែកគេ ធ្វើឲ្យខ្លួនឯងត្រូវនិយាយចេញមក ទោះជាចិត្តមិនចង់ គេជាអ្នកណា តែសម្លឹងមកហើយ ខ្ញុំក៏ខ្លាចចង់ភគនោម ។

"គេជាអ្នកដែលប្រាប់ថាស្រលាញ់ ហើយខ្ញុំក៏ព្រមសេពគប់ តែមានអារម្មណ៍ថាមិនមែនទើបសុំបែក គេឈឺចាប់ដែលខ្ញុំសុំបែក តែទៅសេពគប់មិត្តគេ..."

"អាក្រក់!"

"គេឬ?"

"នាងហ្នឹងហើយ!"

មើលទៅ ជេស ដូចជាខឹងពិតមែនតាមរយៈសម្លេងដែលធ្វើឲ្យខ្ញុំភ្ញាក់ព្រើត គេចង់ចូលតួទៅធ្វើអី!

"ម៉េចក៏មនុស្សស្រីក្លាយជាបែបនេះ ចាកចេញពីប្រុសម្នាក់ទៅរកប្រុសម្នាក់ទៀត ហើយប្រុសម្នាក់នេះជាមិត្តទៀត" ជេស ក្ដាប់ដៃណែន "នាងសមគួរហើយដែលត្រូវចាប់ទៅធ្វើបាប"

"មិនមែនបែបនោះទេ!"

"ចុះបែបណា"

"យើងមានខសន្យាថាបើសាកល្បងដេតជាមួយគ្នាម្ដងហើយមិន

មែន នឹងប្រាប់គេតាមត្រង់ យើងនឹងធ្វើជាមិត្តនឹងគ្នាវិញ ហើយខ្ញុំក៏មានអារម្មណ៍ថាយើងមិនមែន យើងត្រូវតែមានយុត្តិធម៌ចំពោះរឿងបែបនេះ ព្រោះវាមិនទាន់ហួសពេលនឹងត្រលប់ទៅធ្វើជាមិត្ត ពេលនោះគេក៏ធ្វើឫកថាយល់ តែនៅស្រុកៗក៏មកចាប់ពង្រត់ខ្ញុំយកទៅឃុំទុកបែបនោះ វាមិនយុត្តិធម៌ទេ!"

ជេស សម្លឹងមុខខ្ញុំ នៅក្នុងពន្លឺភ្នែករបស់គេមើលទៅស្ងប់ ហើយដកដង្ហើមធំ ÷

"និយាយទៅនិយាយម៉ោ ខាងប្រុសគឺជាអ្នកមានអារម្មណ៍ទទួលយកមិនបានដែលត្រូវនាងទាត់ចោល ទើបធ្វើបែបនោះ ចុះនាង...អីមានត្រូវគេធ្វើអី...ដែលវាបែប...អ៊្ហឹម...អ៊្ហា"

"អត់ទេ មិនបានត្រូវធ្វើអីទាំងអស់"

"មនុស្ស ឬ ក្របី"

"ហឺ?"

"តែខ្ញុំក៏យល់ ដូចជាមានបទពិសោធបែបនោះតិចតួច" ជេស គ្រវីដៃគ្រវីជើង "តាមតែវាទៅ"

និយាយមិនទាន់ចប់ផងក៏មានភេសជ្ជៈមកបម្រើពីអ្នកលក់ស្រី... មិនមែនទេ អ្នកលក់ប្រុសដល់ទៅបីនាក់ឈរក្បែរតុ មកបម្រើហើយក៏មិនព្រមដើរចេញទៅ គិតតែឈរអឹមអៀន ហើយមើលទៅ ជេស ដោយការចូលចិត្ត ។

"មានការអី" ជេស មើលដោយការប្រុងប្រយ័ត្ន "ធ្វើការហើយក៏ទៅវិញទៅ!"

"គឺថា...ម៉ោដើរលេងឬ"

សម្លេងដ៏ធំ តែត្រូវតៀតឡើងតូច ស្តាប់ទៅម៉ៃ្ររបស់អ្នកលក់ប្រុសសួរដោយការខ្មាសអៀន ជេស ញញោចមាត់ រោមដៃបះព្រោង ។

"ខ្ញុំម៉ោដើរលេងហើយទាក់ទងស្អីដែរ កុំម៉ោឈរមើល ខ្ញុំនិយាយការងារបន្ត"

"សុំនិយាយដែរម៉ោ"

"ស្នេហ៍ខ្លាំងមែន" ខ្ញុំសើចទឹកខាក់ តែត្រូវខ្សែភ្នែករករឿងរបស់

ជេស ចាក់ទម្លុះចំមុខឱ្យក្លាយជារណ្ដៅផ្លូវ (ជ្រុលពេក) ។

"ខ្ញុំមិនចូលចិត្តខ្មៅ...អ៊ី..."

"មិនចាច់ខ្មាសទេហើចង់ហៅពួកយើងទាំងបីថាខ្មៅខ្មើយ ពួកយើងដឹងនិងយល់តាំងពីកំណើតថាយើងជាអ្វី យើងនៅធ្លាប់និយាយលេងថាយើងនឹងបង្កើតក្រុមរបស់យើងថា ចតុរង្គសន្និបាត"

"ជាស្អី?" ជេស ។

"យើងជាខ្មៅយបែបមិនបានណាត់ទុកជាមុន ហើយមកជួបគ្នាដោយការព្រមព្រៀងតែម្ដង ហ៊ូៗ"

"គិតបានយ៉ាងម៉េចនេះ លែងតឹងតែងហើយ សើចសិន" ខ្ញុំ ។

"ទៅឱ្យឆ្ងាយទៅ មិនដែលត្រូវប្រុសដាល់មែនទេ"

"ម៉េចចាំបាច់ចិត្តអាក្រក់"

"ខ្ញុំស្អប់ខ្មៅយ ទៅៗ ឃើញអត់ថាខ្ញុំម៉ោជាមួយសង្សារ ពួកឯងឃើញអត់នេះ"

"គ្រាន់តែសង្សារ មិនមែនប្ដីប្រពន្ធផង"

"ទៅ!!!"

ពេលត្រូវគំហកបែបនោះ ទើបខ្មៅយក្របីអស់នោះនាំគ្នាគេចទៅដោយឫកពាប្រផេងប្រផាង ចំណែកខ្ញុំបានតែអង្គុយអៀន ព្រោះត្រូវម៉ៅថាសង្សារ ។

"មិនចាច់ធ្វើឫកសប្បាយចិត្ត ខ្ញុំនិយាយការពារខ្លួនឯងទេ!"

"អ្នកណាប្រាប់ថាសប្បាយចិត្ត វ៉ាយ!"

កៅអីដែកវាយចំខ្នងរបស់ ជេស ដែលមិនបានតាំងជំហរ ធ្វើឱ្យគេដួលទៅលើឥដ្ឋ សាំយ៉ុង ដែលផុសមកពីខាងក្រោយដោយឈាមស្លូតត្រៀមក៏ជង្គក់ខ្យល់ដែរ ។

"នាងគេចពីខ្ញុំមិនផុតទេ ខ្ញុំមិនឱ្យនាងទៅ!"

ជេស ប្រឹងងើប ហើយគ្រវីក្បាលទៅមក ដោយខ្លាចថា ជេស មកជណ្ដើមខ្ញុំទៀត សាំយ៉ុង ក៏ស្ទុះមកចាប់ដៃខ្ញុំ ហើយអូសទៅរកឡាន តែក៏ជ្រមិលដួលផ្កាប់មុខ ហើយ ជេស ក៏មកពាំងមុខជាប់ ។

"ឯងហ៊ានណាស់ដែលម៉ោវ៉ៃយើងពីក្រោយខ្នង ឯងជាអ្នកណា

ជាពួកណា"

"ជេស" ខ្ញុំរត់ទៅពួនក្រោយខ្នង ហើយឱបដៃគេជាប់ដូចកូនខ្លាឃ្មុំ ខូអាឡា "ជួយខ្ញុំផង"

"ផ្អើ ឬថាម៉ោព្រោះនាង មិនមែនខ្ញុំ"

"ជួយខ្ញុំផង គេហ្នឹងហើយដែលចាប់ខ្ញុំ"

"ហើយវារឿងស្អីដែលត្រូវម៉ោពីខ្ញុំនេះ"

"គឺឯងចេះដឹងរឿងគេ" សាំយ៉ុង ងើបឈរ ចង្អុលមុខ "វាមិនមែនជារឿងរបស់ឯងទេ"

"មែន វាមិនមែនរឿងផស់យើង"

"ជេស!" ខ្ញុំ ។

"តែបន្ទាប់ពីឯងយកកៅអីពីយើងមិញនេះ វាក៏ក្លាយជារឿងផស់យើងភ្លាម សំណាងមិនល្អដែលឯងម៉ោជួបយើង ងាប់!"

ជេស ស្ទុះទៅរក សាំយ៉ុង យ៉ាងលឿន ហើយព្រលែងកណ្ដាប់ដៃទៅមួយពេញស្រលាញ់ មនុស្សជាច្រើននៅហ្កាវ៉ាស់សាំងមើលដោយការចាប់អារម្មណ៍ ខ្លះក៏ជេរ ខ្លះក៏ស្រែកព្រោះសម្លេងផ្គើងទង្គិចនឹងឥដ្ឋរបស់គូប្រកួត ជេស មើលទៅសមទំនងណាស់នឹងការមានរឿងបែបនេះ វាដូចជាមិនមែនរឿងចម្លែកសម្រាប់គេ ខុសពី សាំយ៉ុង ដែលទៅដេកដួលបណ្ដោយឱ្យ ជេស ជាល់ដូចបាវខ្សាច់ ។

"បានហើយ ជេស គិចគេងាប់ទៅ"

"គឺយកឱ្យងាប់ហ្នឹង!"

ពេលនេះ ជេស ដូចមនុស្សឆ្កួតហើយ ភ្នែករបស់គេក្រហមដូចវិញ្ញាណត្រូវដកចេញពីរាងកាយ បន្ទាប់ពីជាន់ សាំយ៉ុង បានហើយគេក៏ដើរទៅរកឡាន យកកាំបិតមុខសមុតប្រវែងមួយហត្ថដើរតម្រង់មកស្រមោលរបស់វាចាំងនឹងពន្លឺភ្លើង ធ្វើឱ្យបះរោមជ្រោងប្រាង ។

"ងាប់!"

"អ្ហា!"

២៣

ចង្វាក់ដែល ជេស លើកយារ ខ្ញុំក៏ស្ទុះទៅពាំងមុខកាំបិតដោយមិនខ្លាចឆាប់ ជេស ធ្វើសម្លេងស៊ីតដោយការធុញទ្រាន់ ហើយយកជើងផ្តុះខ្លួនខ្ញុំដូចផ្តុះអាចម៍ឆ្កែ ។

"ម៉ោឈរពាំងធ្វើអី នាងមិនមែនឬដែលប្រាប់ថាវាតាមចាប់"

"មែន ខ្ញុំប្រាប់បែបនោះ តែមិនឃើញចាំបាច់អីត្រូវប្រើកាំបិតទេ"

"វាហ៊ានណាស់ដែលយកកៅអីម៉ោពីមនុស្សដូច ជេស ដឹង ដល់ណាខ្មាសគេដល់នោះ!"

">_<"

"ខ្ញុំចង់ស្រែកហើយ នាងធ្វើឲ្យខ្ញុំចង់ឆ្កួត!"

ជេស ទទ្រាំជើងដោយការម្ហូម៉ៅនឹងអាចយកកាំបិតនោះកាប់អ្នកណាក៏បានគ្រប់ពេល រហូតដល់ខ្ញុំត្រូវដើរទៅរកគេដោយនិយាយស្តីពិរោះៗ ឆាប់ហើយ នេះខ្ញុំគេចពីខ្លាមកជួបក្រពើដូចដែលខ្លួនឯងគិតតាំងពីដំបូងឬ ជួបមនុស្សចាប់ឃុំហើយ មកជួបអ្នកស្លាយកាំបិតតាមខ្លួនទៀត ។

"បងប្រុស បងមិនចាំបាច់ធ្ងន់ដៃ..."

"វាយកកៅអីពីខ្ញុំ កៅអី!"

"តែបងពីគេឡើងដង្ហើមចង្រិតហើយ យើងមិនចាំបាច់ដល់ថ្នាក់យកកាំបិតមកកាប់គេក៏បាន យើងគ្រាន់តែ...ទុកចោលនៅត្រង់នេះល្អជាង ម៉ាសន្ទុះទៀតប៉ូលិសច្បាស់ជាម៉ោ កើតរឿងធំយ៉ាងនេះគួរតែមានអ្នកទៅប្តឹងហើយ"

ជេស ធ្វើមុខស្អាក់ស្ទើរ មុននឹងដើរទៅជាន់ សាំយ៉ុង ម្តងទៀត÷

"លើកក្រោយកុំម៉ោធ្វើឡូយ ក្នុងលោកជសង់ឯង ឯងធំម៉ោពីណា យើងមិនដឹងទេ តែក្នុងពិភពពិត យើងធំ!" ជេស យកកាំបិតចង្អុលមុខ "សំណាងល្អប៉ុណ្ណាហើយដែលមួយរយៈនេះយើងកាន់ស៊ីល ទើបដាក់តែកាំបិត ធម្មតាយើងដាក់កាំភ្លើង ឯងនេះរាសីខ្ពស់ត្រដែត ហ៊ើយ... ភ្លាំ ឬថាខ្ញុំស៊ីយ"

"=O="

ចំជាបុរសដែលនិយាយម្នាក់ឯងអីអើម្នាក់ឯងដោយមិនប្រឹក្សាអ្នកណាមែន ជេស អូសខ្ញុំទៅឡានដោយច្នៀតឈរមើលឡានស្ប៉តកាលីប១គ្រឿងដែលមុននេះធ្លាប់ជារបស់ កូអ៊ិន ដោយការជិនធ្អន់។

"នេះជាឡានអាឆ្កួតនោះមែនទេ ព្រោះពេលចូលម៉ោខ្ញុំមិនបានឃើញឡានដែលលេចធ្លោយ៉ាងនេះ"

"អឺ...អឺ"

"ល្អ"

វ៉ែកកក~

"=O="

"វ៉ាយ សមចិត្ត ជេស មែនទែន"

ជេស យកកាំបិតធូតជុំវិញឡានដោយការសមចិត្ត ហើយមើលទៅរឿងនេះដូចជាធ្វើឲ្យគេមានអារម្មណ៍ល្អ។

"សមមុខ ហ៊ានណាស់ដែលម៉ោបើកឡានថ្លៃជាងខ្ញុំ មិនបានទេ ទៅវិញត្រូវប្រើឡានពណ៌ក្រហមខ្លះ"

"ឡានបងស្អាតស្រាប់ហើយ ពណ៌ស"

"ពណ៌សជានិមិត្តសញ្ញារបស់ខ្ញុំ តែបន្ទាប់ពីបានធូតឡាន១នេះហើយ ខ្ញុំសាកមើលពណ៌ក្រហមខ្លះ"

ជេស បើកឡានចេញពីហ្គារ៉ាស់សាំងយ៉ាងលឿន ខ្ញុំមើលតាមកញ្ចក់ចំហៀង សាំយ៉ុង នៅតែដេកស្លាបដោយអ្នកភូមិដងចាប់ផ្ដើមចូលទៅចោមមើលអាការៈ ខ្ញុំមិនដឹងទេថាគេមានអារម្មណ៍បែបណាតែដែលច្បាស់គឺពេលនេះខ្ញុំខ្លាចគេខ្លាំងណាស់ ហើយ...មែន តែកុងឡានដែលខ្ញុំជិះជាមួយក៏គួរឲ្យខ្លាចមិនតិចដែរ។

"បងជាអ្នកណាឱ្យប្រាកដទៅ"

"ហឺ? ប្រាប់ទៅក៏នាងមិនដឹងដែរ ខ្ញុំល្បីតែនៅក្នុងសង្គមរបស់ខ្ញុំប៉ុណ្ណោះ"

"បងនៅក្នុងសង្គម? សង្គមសិល្បៈឬ"

"អត់ទេ"

"សង្គមនយោបាយ"

"អត់"

"សង្គមផ្ទះ"

"មានអីអន្ទាល់អាហ្នឹង ចាប់ដេកទៅ ខ្ញុំបើកឡាន គ្មានសមាធិដល់សេអ៊ូល ចាំដាស់"

"ចាំ"

ខ្ញុំមិនដឹងទេថាពេលវេលាកន្លងផុតទៅយូរប៉ុណ្ណា ភ្ញាក់ឡើងក៏ដល់សេអ៊ូលទៅហើយ ជេស ដាស់ ហើយសួរថាឱ្យជូនទៅណា ។ ដោយភាពលឿនរហ័សរបស់ឡាន ធ្វើឱ្យខ្ញុំមកដល់ផ្ទះចាំយ៉ាងលឿន និងវាក្លាយជាពេលវេលាដែលហៅបានថាល្អបំផុតនៅក្នុងជីវិតក៏បាន ពេលឃើញថាភ្លើងនៅក្នុងផ្ទះបើកនៅឡើយ ។

"អរគុណបងប្រុស ខ្ញុំនាំរឿងហើយ នៅជូនម៉ោទៀត"

"ខ្ញុំកំពុងនៅអំឡុងពេលកាន់សីល ញ៉ាំបួសនិងធ្វើអំពើល្អ នាងគឺដូចសត្វទាល់ច្រកដែលខ្ញុំចង់មើលថែ ឃើញនាងហើយក៏នឹកដល់ឆ្មានៅផ្ទះ"

"=O="

"ចាប់ចូលទៅ តាមរយៈពន្លឺភ្នែកវាប្តឹងថានាងសប្បាយចិត្តចង់ហោះទៅហើយ"

"បងបុិនមើលដល់ហើយ"

"ទៅៗ ដឹងថាឡានខ្ញុំអ៊ីវត្រជាក់ តែខ្ញុំក៏ត្រូវទៅផ្ទះដែរ"

គេចំជាមនុស្សប្រុសចិត្តល្អនិងសោះកក្រោះនៅក្នុងពេលតែមួយ ហួតដល់ខ្ញុំវង្វេងអស់ហើយ តែសរុបទៅខ្ញុំមានអារម្មណ៍ថាប្រុស

ម្នាក់នេះជាមនុស្សល្អ មុននឹងខ្ញុំប្រើភាពក្លាហានចុងក្រោយនៅក្នុងការសួរ÷

"បងប្រុស"

"ស្អីទៀត"

"សរុបទៅបងនៅក្នុងសង្គមណា បងមិនទាន់ប្រាប់ខ្ញុំទេ"

មានស្នាមញញឹមមួយបែបផុសចេញមក តែខ្ញុំមិនដឹងថាវាជាស្នាមញញឹមបែបណាទេ ឬកពាមានមោទនភាពរបស់គេធ្វើឲ្យខ្ញុំចាប់អារម្មណ៍ភ្លាម ។

"ខ្ញុំនៅក្នុងសង្គមម៉ាហៀ"

"O_O"

"អ្នកណាៗក៏ហៅខ្ញុំថា ជេស ល្បងធំក្រុមខ្លាខ្មៅ"

"ចេះម៉េនិយាយលេង បងអាយុប៉ុន្មានសោះហ្នឹង" ហើយខ្ញុំក៏ចូកពេលនឹកដល់អ្វីដែលបានកើតឡើងនៅថ្ងៃនេះ បន្ទាប់ពីនោះក៏មានអារម្មណ៍ថាបេះដូងដូចធ្លាក់ដល់ចុងជើង ហើយត្រលប់មកនៅកន្លែងដើមវិញ "ពិតមែនឬ!"

"ឃើញទេ ប្រាប់ហើយថាអ្នកនៅក្រៅសង្គមមិនសូវជាស្គាល់ខ្ញុំទេទៅៗ"

ពេលខ្ញុំបិទទ្វារ ជេស ក៏បើកឡានចេញទៅភ្លាមដោយមិនភ្លេចបើកកញ្ចក់ គ្រវីដៃលា វាមិនមែនជាការមានមោទនអ្វីបែបនោះទេ តែក៏ប្រហែលជាមានមនុស្សតិចណាស់ជួបអ្វីបែបនេះ អ្នកដែលជួយលោកអ្នកតាំងពីដើមដល់ចប់គឺជាអ្នកដែលគួរឲ្យខ្លាចបំផុត ។

ល្បងធំម៉ាហៀ!

"ចុងអ៊ីល!"

សម្លេងហៅរបស់ចា៎ធ្វើឲ្យខ្ញុំឈប់មើលកន្ទុយឡានដែលទើបជូនមក ហើយងាកទៅមើល ពេលបានឃើញរាងរបស់ចា៎ ទឹកភ្នែកក៏ហូរជាបន្តាល់បែបមិនបានតាំងខ្លួន ។

"ចា៎!"

យើងឱបគ្នាណែន ទាំងទឹកភ្នែក ទាំងបារម្ភ ។

"ជុងអ៊ុល"

"ស៊ីជីន"

"ចូលផ្ទះសិនទៅ សឹមនិយាយគ្នា"

ចាំនាំយើងចូលផ្ទះ នៅពេលនេះមានទាំងទឹកទាំងភ្លើង ហើយផ្ទះមើលទៅមានរបៀបរៀបរយ តែអ្វីដែលគួរឱ្យចម្លែកចិត្តគឺកញ្ចប់ពណ៌ផ្កាតជាច្រើនដាក់គរពេញនោះ ពេលរកសួរ ចាំក៏សុំឱ្យនិយាយរឿងរ៉ាវខ្ញុំមុន ពេលខ្ញុំនិយាយហើយ គ្រប់គ្នាក៏ធ្វើមុខតានតឹង ពិសេស ស៊ីជីន ដែលខឹង សាំយ៉ុង ស្រាប់ទៅហើយ ពេលនេះកាន់តែចេះដុំ ។

"ខ្ញុំគិតដឹងទៅហើយថាគេអាក្រក់ តែមិនគិតទេថាគេច្កួតដល់ថ្នាក់យកឯងទៅឃុំបែបនោះ គេធ្វើបាបឯងអត់"

"អត់ទេ"

ស៊ីជីន ធ្វើដូចជាមិនប្រាកដចិត្ត តែក៏មិនហ៊ានសួរ ព្រោះមានចាំនៅជាមួយ ពេលដែលឃើញខ្សែភ្នែករបស់មិត្តបែបនេះ ខ្ញុំក៏អះអាងម្តងទៀត ។

"ពិតជាគ្មានមែន ខ្ញុំយករូបខ្លួនបាន ខ្ញុំថានៅក្នុងសំណាងអាក្រក់របស់យើងក៏មានសំណាងល្អខ្លះដែរ វាជាលើកតំបូងដែលគេធ្វើអីប៊ីង"

"តែគេមិនគួរនាំឯងទៅបែបនោះទេ រឿងនេះពួកយើងយល់ថាឯងនិយាយការពិត ចុះអ្នកផ្សេង"

"ខ្ញុំមិនចាប់អារម្មណ៍អ្នកផ្សេងទេ"

"អ្នកផ្សេងដែលថាខ្ញុំមានន័យដល់..." ស៊ីជីន ដកដង្ហើមធំ ហើយគ្រវីដៃ "តាមតែវាទៅ ឯងមិនអីគឺល្អហើយ ចុះនេះអ្នកណាជូនម៉ោ"

"មនុស្សចិត្តល្អ"

"ហ៊ឺ?"

"ចុះពេលនេះម៉ាក់ម៉េចដែរ ម៉ាក់ដឹងរឿងដែលខ្ញុំបាត់ខ្លួនអត់"

ទើបពេលនេះបទសន្ទនាក្លាយជារឿងរបស់យើងទាំងពីរ ចាំបានតែអង្គុយស្តាប់ដោយមិនជ្រៀតជ្រែក ស៊ីជីន ធ្វើមុខពិបាកចិត្តពេលនិយាយ ប្រែថាច្បាស់ជាមានរឿងហើយ ។

"តាំងពីឯងទៅ រឿងក៏រញ៉េរញ៉ៃអស់ ពេលនេះម៉ាក់ឯងមិនទៅផ្ទះនោះទៀតទេ"

"គាត់ទៅណា"

"គ្មានអ្នកណាដឹង"

"ម៉េចក៏មិនទៅ"

"ប៉ាចុងឯងចាប់បានថាម៉ាក់ឯងមាន...អឺ មានសហាយ" សីជីននិយាយដោយក្រែងអារម្មណ៍របស់ខ្ញុំ "ពេលនេះគ្មានអ្នកណាដឹងពីដំណឹងម៉ាក់ឯងទេ អាគ្រាន់តែទៅសួរ កូអឺន គេក៏មិនបានជិតដិតអីនឹងខ្ញុំណាស់ណា"

"អ្ហឹម...ខ្ញុំយល់ហើយ តែថា...កូអឺន គេម៉េចម៉ាដែរ"

"ឈប់និយាយពីអាច្ឆតនោះទៅ ឯងគួរចាប់ផ្ដើមជីវិតជាថ្មីបានហើយ មិនបាច់ទៅចាប់អារម្មណ៍នឹងក្រុមគ្រួសារនោះទេ អ្នកនៅជុំវិញខ្លួនតែងតែធ្វើឲ្យឯងមានបញ្ហា ផ្លូវអ្នកណា អ្នកនោះដើរ"

"មានអីកើតឡើង"

"គ្មានទេ"

"ច្បាស់ជាមាន តែឯងមិននិយាយ"

"ចង់ដឹងក៏ទៅសួរវាទៅ តែខ្ញុំណែនាំថាកុំទៅសួរល្អជាង អំប្រុសនិយាយជាមួយ ចុងអ៊ីល សិនទៅ ខ្ញុំទៅបន្ទប់ទឹកម៉ាភ្លែត"

សីជីន ដើរចេញពីការសន្ទនា ទុកខ្ញុំឲ្យនៅជាមួយប៉ា ក៏ល្អដែរ ព្រោះតាំងពីមកដល់ ខ្ញុំនិយាយជាមួយប៉ាបានប៉ុន្មានម៉ាត់ទេ។

"ខានជួបគ្នាយូរហើយប៉ា កូនម៉ោរកច្រើនដង គេប្រាប់ថាប៉ាទៅបរទេស ឥឡូវនេះប៉ាអភិវឌ្ឍដល់ថ្នាក់ទៅបរទេសបរអីផងអ្ហ៎"

"គឺតិចតួច តាមពិតប៉ាថាម៉ោមិនយូរទេ នឹងទៅវិញហើយ តែពេលឃើញថាកូនមានរឿង ទើបប៉ានៅ"

"ប៉ានឹងទៅបរទេសទៀតឬ ហេតុអី"

ប៉ាខិតចូលមកជិតដោយតាំងចិត្តនិយាយ ដែលឫកពាបែបនោះធ្វើឲ្យខ្ញុំក៏តាំងចិត្តស្ដាប់ដែរ។

"ប៉ារៀបការថ្មី"

"O_O"

"ប៉ាទឹងទៅនៅទីនេះ"

នេះឬអត់ដែលគេហៅថាគ្រូដាក់អារក្សដាន់ ពេលបានជួប ប៉ាក៏ត្រូវទៅវិញ ចំណែកម៉ាក់ក៏មិនដឹងជានៅឯណា ពេលនេះខ្ញុំមិនសល់អ្នកណានៅក្បែរឲ្យពឹងពាក់ទេឬយ៉ាងម៉េច?

"ប៉ាដឹងថាកូនកំពុងគិតអី...ទៅនៅជាមួយប៉ាទេ"

"ចាំ?"

"ទៅនៅជាមួយប៉ាទៅ ទៅមានជីវិតថ្មី សង្គមថ្មី មិនបាច់ម៉ៅទីនេះទៀតទេ"

២៤

ខ្ញុំគិតរឿងដែលចាំនិយាយពេញមួយយប់សឹងតែមិនបានដេកក៏ថាបាន មួយរឿងៗដែលចូលមកក្នុងជីវិតពេលនេះចំជាលឿនបែបមិនបានតាំងខ្លួន ណាទៅរឿងម៉ាក់ចាត់ដំណឹង ណាទៅរឿងចាំរៀបការថ្មីហើយទៅនៅបរទេស ណាទៅរឿងរបស់ សាំយ៉ុង ដែលទើបនឹងកើតឡើង ហើយណាទៅរឿងរបស់ កូអ៊ីន...

ពេលគិតដល់ឈ្មោះនេះហើយ ខ្ញុំក៏សម្រេចចិត្តទៅជួបគេនៅថ្ងៃបន្ទាប់ យើងខានជួបគ្នាលើសមួយអាទិត្យហើយតាំងពីខ្ញុំត្រូវពង្រត់ហើយបើសួររឿងនេះពី សឺជីន នាងក៏គេចមិនព្រមឆ្លើយដូចជាមានអ្វីនៅក្នុងចិត្ត ដូនកាលបើខ្ញុំទៅនិយាយជាមួយគេ អាចនឹងដឹងរឿងទាក់ទងនឹងម៉ាក់បានខ្លះ ។

ខ្ញុំមកឈរនៅមុខផ្ទះយ៉ាងលឿនដូចចិត្តគិត នៅសុខៗក៏មានអារម្មណ៍ភ័រភិប ផ្ទះមួយនេះ មិនមែនទេ ភូមិគ្រឹះមួយនេះនៅតែធំដូចដើម គ្រាន់តែវាធ្វើឱ្យមានអារម្មណ៍ផ្សេង...វាមិនមែនជាផ្ទះរបស់ខ្ញុំទៀតទេ ។

"អ្ហា៎ អ្នកនាង ជុងអ៊ីល"

អ្នកបំរើដែលកំពុងចេញមកក្រៅក៏មកឃើញខ្ញុំឈរគិតអ្វីម្នាក់ឯងល្ហម ។

"ចា៎"

"ម៉ោធ្វើអី"

សួរគួរឱ្យខ្លាចដល់ហើយ!

"ម៉ោរក...អី ម៉ោសួរសុខទុក្ខអំប្រុស និង កូអ៊ីន ខ្ញុំចូលបានទេ"

"អឺ...ខ្ញុំសុំទៅប្រាប់គាត់សិន តិចទៀតម៉ោវិញ"

ស្រីបំរើម្នាក់នោះបែរខ្នងដើរចូលទៅក្នុងផ្ទះ ឫកពាចម្លែកៗរបស់នាងធ្វើឱ្យខ្ញុំចាប់ផ្ដើមប្រយ័ត្នខ្លួន ខ្ញុំប្រហែលជាធ្វើខ្លួនសប្បាយៗដូចពេលកន្លងមកមិនបានទេ អាប្រុសប្រហែលជាខឹងម៉ាក់ហើយរាលដល់ខ្ញុំដែរ ទើបអ្នកបំរើមិនបានអញ្ជើញខ្ញុំឱ្យចូលទៅ តែមិនដល់បីនាទីផងក៏មានអ្នកលេចមុខមកជំនួស នេះហើយដែលធ្វើឱ្យបេះដូងរបស់ខ្ញុំរីកមាឌពេញទ្រូង ។

"កូអឺន"

កូអឺន មិនសម្ដែងទឹកមុខរីករាយដែលឃើញខ្ញុំ គេដើរមកបើកទ្វារតែពេលខ្ញុំឈានចូលទៅ គេក៏យកដៃរុញស្មា ។

"ហាមចូល"

"ហឺ?"

"ផ្ទះនេះមិនស្វាគមន៍នាងទេ"

នេះត្រចៀកខ្ញុំមានបញ្ហា ឬថាខ្ញុំកំពុងយល់សប្ដិ សម្ដីដ៏សែនសោះកក្រោះរបស់គេផ្ទុយពីចិត្តដែលខ្ញុំមានចំពោះគេខ្លាំងណាស់ តែខួរក្បាលរបស់ខ្ញុំក៏ព្យាយាមយល់ហេតុផលថាហេតុអ្វីក៏ក្លាយជាបែបនោះ ជួនកាល...អាចមកពីម៉ាក់ ។

"អ្ហឹម ខ្ញុំយល់ហើយ ម៉ាក់បែបធ្វើឱ្យអាប្រុសខឹងខ្លាំងណាស់"

"មែន"

"..."

"..."

ចម្លើយខ្លីៗរបស់គេធ្វើឱ្យខ្ញុំបន្តការសន្ទនាមិនត្រូវ ហេតុអីបានជាបរិយាកាសទៅជារអាក់រអួលបែបនេះនេ៎ះ អីចឹងមិនទេ ខ្ញុំត្រូវដូររឿងទោះយ៉ាងណាក៏ថ្ងៃនេះតាំងចិត្តមកនិយាយជាមួយគេស្រាប់ហើយ ។

"លោកម៉េចម៉ាដែរ"

"សុខសប្បាយ មានលុយចាយ មានឡានបើក គ្រប់យ៉ាងដែលគួរជារបស់ខ្ញុំត្រលប់មកវិញហើយ"

"អបអរផង"

"អ៊ឹម"

"ខ្ញុំទៅវិញល្អជាង មើលទៅលោកមានអារម្មណ៍មិនល្អទេ"

ការខូចចិត្តមិនដឹងជាមកពីណាបានស្ទុះចូលមកក្នុងទ្រូង នេះខ្ញុំកំពុងតែតូចចិត្តនឹងគេ ទើបបានជាបញ្ចប់ការសន្ទនាលៀនយ៉ាងនេះ តែមិនត្រឹមតែ កូអ៊ីន មិនឃាត់ខ្ញុំទេ គេបែរជាដើរចូលទៅក្នុងផ្ទះដោយមិនងាកមកមើលខ្ញុំទៀត រហូតដល់ខ្ញុំទ្រាំមិនបាន បើកទ្វារតូច ហើយដើរចូលទៅចាប់ក្របួច-កអាវគេពីក្រោយ ។

"នេះគឺជាអ្វីដែលមនុស្សស្រលាញ់គ្នា គេធ្វើដាក់គ្នាអីចឹងហ្អ៎ស បន្ទាប់ពីកើតរឿងចំពោះខ្ញុំ លោកមិនគិតនឹងសួរខ្ញុំមួយម៉ាត់ទេថាម៉េចម៉ាខ្លះហើយ"

កូអ៊ីន វាសខ្ញុំដួលទៅលើដី មួយភ្លែតនោះខ្ញុំឃើញទឹកមុខគេមានការភ្ញាក់ផ្អើល តែក៏រហ័សធ្វើជាសោះកក្រោះដូចដើម ។

"ហេតុអីខ្ញុំត្រូវសួរនាង គឺឃើញនឹងភ្នែកស្រាប់ហើយថានាងសុខសប្បាយ ថែមទាំងសប្បាយខ្លាំងទៀតផង"

"ខ្ញុំឬសុខសប្បាយ នេះគឺមុខមាត់មនុស្សសុខសប្បាយឬក៏ម៉េច"

"នាងត្រូវការអីក៏និយាយជាច់ៗម៉ោល្អជាង ចង់មកសើរើអាឋិ-កំបាំងជាមួយខ្ញុំឬយ៉ាងម៉េច ចង់មកសើរើបន្ទាប់ពីនាងរត់ទៅជាមួយសាំយ៉ុង ហើយទុកខ្ញុំចោលនៅហ្កាវ៉ាស់សាំងតែពីរនាក់ កូសង!" កូអ៊ីនក្ដាប់ដៃណែន ហើយដើរមកខ្ញុំដែលអង្គុយថ្កុប "អីចឹងខ្ញុំសួរក៏បាន ម៉េចម៉ាដែរ រត់តាមវាសប្បាយទេ វាធ្វើអីនាងខ្លះ!"

នេះជាការស្មានមិនដល់ ទឹកភ្នែករបស់ កូអ៊ីន ហូរជាបថ្ពាល់ដោយការឈឺចាប់ខណៈដែលសួរ ខ្ញុំលូកដៃទៅរកគេដោយភ្លេចខ្លួនតែក៏ត្រូវវាសចេញ ។

"ខ្ញុំមិនបានរត់តាមគេទេ ពេលលោកចូលមីនីម៉ាត គេក៏បើកឡានចេញទៅ"

"នាងចង់ឲ្យខ្ញុំជឿថានាងមិនបានមានចំណែកដឹងស្អីចំពោះរឿងនេះដែរឬយ៉ាងម៉េច"

"គឺមែន ខ្ញុំមិនដឹងមិនឃើញស្អីទេ!"

"ហឺ"

"កុំម៉ោធ្វើសម្លេងបែបនេះ លោកត្រូវស្ដាប់រឿងរ៉ាវទាំងអស់"

"អីចឹងក៏និយាយឱ្យអស់ម៉ោ និយាយរួចហើយក៏ដកក្បាលចេញទៅ ពេលនេះខ្ញុំធុញមុខនាងពេញបន្ទុកហើយ!"

ខ្ញុំព្យាយាមងើបឈរ ទោះជាខូចចិត្ត តែខ្ញុំក៏ចង់និយាយរឿងរ៉ាវដែលកើតឡើងឱ្យគេស្ដាប់ ព្រោះថាយ៉ាងហោចណាស់វាអាចធ្វើឱ្យគេយល់អ្វីបានខ្លះនៅក្នុងពេលដែលអារម្មណ៍មិនល្អដល់ថ្នាក់នេះ តែពេលហាមាត់និយាយ សិស្សច្បង ណាយ៉េ ដែលមិនដឹងផុសមកពីណាក៏ជ្រែកសម្ដីមិនត្រូវចង្វាក់ ។

"ឡូឡាស្អី កំពុងលេងស្អីហ្នឹង ហេ៎ ជុងអ៊ីល ម៉ោដែរឬ"

"សិស្សច្បង!"

"ម៉េចក៏មុខស៊ីរៀសម្ល៉េះ ខ្ញុំម៉ោខុសចង្វាក់ឬអត់"

"នាងម៉ោមិនខុសទេ មើលទៅជាលើកតំបូងហើយដែលនាងផុសម៉ោបានត្រូវពេលត្រូវវេលា អី! ចំណែកនាងចង់និយាយអីក៏ថាម៉ោ ខ្ញុំឈរស្ដាប់ ហើយមិនចាប់បារម្ភទេ ខ្ញុំដឹងរឿងស្អី ណាយ៉េ ក៏អាចដឹងបានដែរ ពេលនេះគេជាស្រីលំដាប់លេខមួយរបស់ខ្ញុំ"

កូអឹន បង្ហាញខ្នងដៃខាងឆ្វេងដែលត្រូវការបញ្ជាក់ថានៅលើម្រាមដៃនាងគេពាក់ចិញ្ចៀន ទើបអ្វីដែលគិតចង់និយាយក៏រលាយទៅក្នុងអាកាសធាតុ ។

"អឺ ខ្ញុំមិននៅស្ដាប់ល្អជាង វ៉ា..."

"មិនអីទេ សិស្សច្បងធ្វើខ្លួនតាមសប្បាយចុះ ខ្ញុំថាបញ្ចប់រឿងដែលចង់និយាយល្អជាង"

"ហេ៎ ចុះនាងទៅវិញហើយអ្ហ៎ស"

សម្លេងទូរសព្ទរបស់ កូអឹន រោទិ៍ ធ្វើឱ្យគេចុចទទួលទាំងមួម៉ៅ តែហើយក៏ធ្វើមុខរន្ធត់ចិត្ត ព្រមគ្នានឹងសម្ដីដែលចាប់ន័យបានទំនងជារកសាំយ៉ុង ឃើញហើយ ។

"នៅពេទ្យណា ចុះវ៉ាទៅត្រូវស្អី...មិនដឹងទេ អាចនឹងទៅ ឬ មិនទៅ សុំគិតមើលសិន...អរគុណដែលតេមកប្រាប់ លោកពូ"

គេដាក់ទូរសព្ទចុះ សិស្សច្បង់ក៏សួរដោយការចាប់អារម្មណ៍÷

"មានអីអត់ ម៉េចក៏ទឹកមុខក្ដាក់ផ្អើលម្ល៉េះ"

"សាំយ៉ុង ដេកពេទ្យនៅពូសាន បានឮថាត្រូវគេវ៉ៃ!" គូអ៊ីន មើលមកខ្ញុំបែបមិនយល់ "មិនដឹងថាជាថ្ងៃដៃអ្នកណា"

ខ្ញុំប្រសព្វភ្នែក គូអ៊ីន បន្តិច ហើយញញឹមដាក់ដោយការហត់នឿយ÷

"ខ្ញុំទៅល្អដាង"

"ស្អែគេ ទៅថ្កុយៗអីចឹងម្ដ" សិស្សច្បង់ ។

"ចាំ គិតថាពេលនេះបែបជារស់ មិនរំខានល្អដាង"

"គួរតែទៅពីយូរហើយ ផ្អាំ ឬថាប្រញាប់ទៅសួរសុខទុក្ខប្រុសជស់នាងដែលដេកពេទ្យ!" គូអ៊ីន ។

"លាសិនហើយ"

ការនិយាយពាក្យ លា ដែលមើលទៅមិនធម្មតារបស់ខ្ញុំ ធ្វើឱ្យសិស្សច្បង់ត្រូវរត់ចូលមកពាំងមុខ មុននឹងធ្វើមុខស្រឡាំងកាំងពេលឃើញថាមុខខ្ញុំជាបដោយទឹកភ្នែក ។

"សុំអង្វរ កុំប្រាប់គេថាបងឃើញស្អីនៅលើមុខខ្ញុំ"

ខ្ញុំនិយាយពាក់កណ្ដាលខ្សឹប ហើយដើរចេញទៅដោយមិនងាកមកមើលទៀត រនាំងចុងក្រោយដែលគិតថានឹងរាំងខ្ញុំមិនឱ្យទៅជាមួយចាំបាន ដាច់បាត់ទៅហើយ ។

ពេលខ្ញុំឡើងតាក់ស៊ី ហើយប្រាប់ពីគោលដៅរបស់ខ្លួនរៀបរយហើយ ឡានក៏បើកចេញពីច្រកផ្ទះរបស់ គូអ៊ីន ទៅតែហើយបែរជាត្រូវជាន់ហ្វ្រាំងទាន់ហន់ធ្វើឱ្យខ្លួនខ្ញុំសឹងតែធ្លាយចេញពីឡាន ពេលងាកទៅមើលក៏ឃើញឡានធំមួយគ្រឿងរបស់អ្នកណាម្នាក់បើកមកពាំងមុខជាប់ ។

"ហេ៎ បើកឡានប្រភេទស្អី!"

សិស្សច្បង់ ណាយ៉េ ចុះពីឡាន ហើយឱនគោរពដោយដឹងពីកំហុសរបស់ខ្លួន ព្រមទាំងញាក់លុយចូលហោប៉ៅពូតាក់ស៊ីឡើងទល់

មុនទឹងលើកទ្វារខាងខ្ញុំ ហើយអូសចុះ ។

"សិស្សប្បង"

"យើងត្រូវនិយាយគ្នា ខ្ញុំបណ្ដោយឱ្យរឿងនេះកន្លងផុតទៅមិនបានទេ"

"តែ..."

អាចមកពីភាពគួរឱ្យស្រលាញ់និងភាពបន្ទឹបន្ទារបស់នាងទើបធ្វើឱ្យខ្ញុំព្រមដើរទៅឡើងឡាន ពេលចូលអង្គុយហើយ សិស្សប្បងក៏បើកចេញទៅដោយអាងអំណាចមហាសាល ។

"បើកឱ្យយឺតបំផុតតាមដែលអាចធ្វើបាន តែត្រូវបើកជារឿយៗ ទាល់តែខ្ញុំនិយាយចប់ យល់ទេ"

"បាទ"

សិស្សប្បង ងាកមករកខ្ញុំភ្លាមពេលនិយាយជាមួយតែកុងរបស់នាងចប់ ។

"ពាក្យថាលារបស់នាងមានន័យដល់អី"

"គ្មានអីទេ" ខ្ញុំគេចភ្នែក តែក៏ត្រូវដៃទាំងពីររបស់សិស្សប្បងចាប់ឱ្យងាកទៅរក ។

"ខ្ញុំដឹងថាមាន ហើយខ្ញុំក៏មិនត្រូវការឱ្យមានរឿងនៅទាក់ទើរចិត្តដែរ នាងគួរតែដឹងថានាងនិយាយគ្រប់យ៉ាងឱ្យខ្ញុំស្ដាប់បាន ខ្ញុំមិនត្រូវការធ្វើជាមេបញ្ហាដែលខ្លួនឯងក៏មិនដឹងថាវាគឺជាអ្វី នេះខ្ញុំនិយាយអីម៉េចក៏ខ្ញុំមិនយល់ពីខ្លួនឯង!"

"ចុះសិស្សប្បងចង់ឱ្យខ្ញុំនិយាយរឿងអី"

"ចាប់ផ្ដើមពីអ្វីដែលនិយាយជាមួយ កូអឺន មុនខ្ញុំម៉ោដល់ ហើយចាំអធិប្បាយបន្តពីន័យរបស់ពាក្យថា លា"

ទោះជាព្យាយាមគេចមិននិយាយ តែពេលត្រូវដេញដោលយ៉ាងនេះ ខ្ញុំក៏ត្រូវតែព្រមចុះចាញ់ ហើយនិយាយឱ្យសិស្សប្បងស្ដាប់ តាមពិតគួរឱ្យតែប្រាប់ កូអឺន រហូតដល់មិនចង់សូម្បីតែជ្រលក់មាត់ជាមួយស្រីម្នាក់នេះ តែភាពគួរឱ្យស្រលាញ់រួសរាយរបស់នាង ធ្វើឱ្យខ្ញុំចុះចាញ់ ព្រមនិយាយគ្រប់យ៉ាងឱ្យសិស្សប្បងស្ដាប់ដល់ថ្នាក់រំជួលចិត្ត

ខ្លួនឯង ត្រូវជូតទឹកភ្នែកដោយជីស៊ូអស់ជាច្រើន ពេលស្ដាប់សិស្សច្បងគិតតែអង្គុយស្ងៀម អ្វីដែលជានិមិត្តសញ្ញាថាគេស្ដាប់គឺការជ្រួញចិញ្ចើមនិងខាំបបូរមាត់ ។

"សាំងយ៉ុង ឆ្កួតហើយ វាធ្វើបែបនោះដាក់នាងបានយ៉ាងម៉េច! នាងប្រាកដចិត្តហើយថាគ្មានរបួសត្រង់ណា ហើយ...វាមិនបានបង្ខំនាងស្អីបែប...នោះ"

"កំហឹងគ្រប់គ្រងគេដល់ថ្នាក់ដូចមនុស្សឆ្កួតក៏ពិតមែន តែផ្នែក១នៅក្នុងខ្លួនរបស់គេក៏តតាំងបានដូចគ្នា ព្រោះនិស្ស័យពិតរបស់គេ គឺមិនមែនជាមនុស្សអាក្រក់ស្អីទេ"

"ស្ដាប់មើលទៅក៏ដឹងថាវាធ្វើព្រោះមានអារម្មណ៍ថាខូចឈ្មោះសមមុខ ត្រូវពីក្នុងហ្គារ៉ាស់សាំងបែបនោះ យកល្អឱ្យផ្លាយពោះវៀន នាងមិនគួរទៅពាំងកាំបិត គួរតែឱ្យប្រុសម្នាក់នោះ ឈ្មោះស្អី... ជេស"

"ជេស"

"អី ជេស យកកាំបិតកាប់ៗ ឱ្យវាបាត់ឆ្កួត"

ខ្ញុំញញឹមដាក់សិស្សច្បងដោយមានអារម្មណ៍ថាអរគុណដែលចូលតួតាម នាងញញឹមដាក់ខ្ញុំវិញ ។

"បានកម្ចាយចេញហើយមានអារម្មណ៍ថាស្រួលចិត្តទេ"

"ចា៎"

"តែតាមពិតទៅរឿងនេះនាងគួរតែប្រាប់ កូអីន"

"ដំបូងថាប្រាប់ដែរ តែបែបគ្មានប្រយោជន៍ទេ គេជឿថាខ្ញុំរត់តាម សាំយ៉ុង បែបស្ម័គ្រចិត្ត"

"ម៉ែចង់ស្រែកហើយ មនុស្សឆ្កួតស្អីគ្មានបានការអីចឹង"

"ម្យ៉ាងទៀត...គេក៏មានសិស្សច្បងដែរ"

"វ៉ែកកក"

"=O="

"កុំទៅជឿស្អីដែលវានិយាយ ជាគូដណ្ដឹងមែន តែខ្ញុំមានគូដែលខ្ញុំដៅទុករួចហើយ ម្យ៉ាងទៀតចិញ្ចៀនដែលវាបង្ហាញ១វង់ ៩៩០០ វ៉ុន នាងគិតថាបាន:ខ្ញុំពាក់ចិញ្ចៀនដែលមានតម្លៃ Standless ឬម៉េច"

ការពិតដែលនាងនិយាយកាន់តែធ្វើឱ្យខ្ញុំឈឺ!

"គេប្រហែលជាចង់កៀរខ្ញុំទៅឱ្យឆ្ងាយទើបកុហកអ្វីបែបនោះទេដឹង តែក៏ធ្វើបានសម្រេច ខ្ញុំសម្រេចចិត្តបានហើយថានឹងទៅឱ្យឆ្ងាយ"

"ទៅណា"

"ខ្ញុំទៅនៅជាមួយប៉ានៅបរទេស"

"ហ៎"

"នេះហើយជាន័យរបស់ពាក្យ លា"

ខ្ញុំត្រលប់មកដល់ផ្ទះដោយការបើកក្នុងល្បឿនយ៉ាងលឿន ព្រោះពេលនិយាយចប់ សិស្សច្បងក៏បញ្ជាឱ្យតែកុងជាន់ហ្វ្រាំមួយអស់ជើង ហើយមកដល់ផ្ទះខ្ញុំនៅក្នុងពេល១០នាទី ស៊ីជីន ដែលចាំនៅក្នុងផ្ទះមើលខ្ញុំដោយដឹងរឿងមុន ហើយបក់ដៃហៅ ។

"ចូលម៉ោឱបខ្ញុំម៉ោ"

"ឯងដឹងឬ..."

"ពេលឯងបាត់ខ្លួន ខ្ញុំដឹងច្បាស់ជាងអ្នកណាទាំងអស់ ព្រោះខ្ញុំជាអ្នកសុំឱ្យគេតាមរក តែគេមិនព្រម ប្រាប់ថាឯងជ្រើសរើសទៅជាមួយអ្នកផ្សេង ទើបខ្ញុំមិននិយាយរឿងគេឱ្យឯងស្តាប់ហ្នឹងអ្ហ៎"

ខ្ញុំស្ទុះទៅឱប ស៊ីជីន ហើយយំហ្ស៊ូ ។

"ខ្ញុំសម្រេចចិត្តហើយ"

"សម្រេចចិត្តថា?"

"ខ្ញុំនឹងទៅនៅជាមួយប៉ា"

ស៊ីជីន ថ្ងូក់ ហើយរុញខ្ញុំចេញដើម្បីមើលមុខ÷

"ឯងប្រាកដហើយអ្ហ៎ អាគ្រាន់តែប្រុសម្នាក់ ឯងក៏បោះបង់គ្រប់យ៉ាងនេ៎ះ"

"គ្រប់យ៉ាងទៅវិញទេដែលជាអ្នកបោះបង់ខ្ញុំមុន!"

២៥

គ្រប់គ្នាព្រមទទួលយកការសម្រេចចិត្តរបស់ខ្ញុំដោយមិនជំទាស់អ្វី ខ្ញុំលួចគិតថាប៉ានឹងគិតថាខ្ញុំជាបន្ទុកឬអត់ ទោះយ៉ាងណាក៏គាត់មានក្រុមគ្រួសារ នៅស្ពាយខ្ញុំទៅតាមទៀត...

"គិតច្រើនមែន ប៉ាចង់ឱ្យកូននៅជាមួយតាំងពីយូរហើយ ហើយនេះជាឱកាសល្អដែលយើងបាននៅជាមួយគ្នា គិតមើលចុះ យើងទៅប្រើជីវិតថ្មី មានសង្គមថ្មី ហើយកូននឹងចេះភាសាអង់គ្លេសទៀត"

"ចុះប្រពន្ធថ្មីរបស់ប៉ាទទួលកូនទេ"

"បើមិនទទួល ប៉ានឹងលែង"

ខ្ញុំមានអារម្មណ៍ថាជ្រៀលជ្រៅរហូតដល់ទឹកភ្នែកធ្លាយម្តងទៀត ទើបប៉ាបានតែសើចដែលខ្ញុំទន់ជ្រាយពេក ។

"តែមានរឿងច្រើនណាស់ដែលត្រូវចាត់ការ ណាវីសា ណារឿងសុំផ្ទេរការសិក្សា"

"មិនអីទេ កូនយ៉ាងម៉េចក៏បាន អីចឹងយើងចាប់ផ្តើមធ្វើអីមុនល្អ... ប្រមូលឥវ៉ាន់ដាក់វ៉ាលីល្អទេ"

"ជាការចាប់ផ្តើមដែលមិនអាក្រក់"

ទីងតង់ៗ

សម្លេងកណ្តឹងនៅមុខផ្ទះឮញាប់ឱ្យរន្ធើន មើលទៅការចាប់ផ្តើមជីវិតថ្មីរបស់ខ្ញុំត្រូវកាត់ចង្វាក់ទៀតហើយ គ្រាន់តែប្រមូលឥវ៉ាន់ដាក់វ៉ាលីក៏មានឧបសគ្គឬនេះ?

"ចាំប៉ាទៅបើក"

"មិនអីទេ កូនទៅបើកវិញ"

ខ្ញុំញញឹមដាក់ចាំ ហើយប្រញាប់ទៅបើកទ្វារ ស្នាមញញឹមដែលទើបនឹងមានត្រូវរលុបអស់ ព្រោះគ្រាន់តែ កូអ៊ីន មកឈរធ្វើមុខក្រាក់ផ្អើលនៅមុខផ្ទះ ខ្សែភ្នែករបស់គេនៅពេលនេះមិនដូចពីព្រឹកទេ យើងឈរសម្លឹងមុខគ្នាមួយសន្ទុះ ខ្ញុំក៏ទាញទ្វារបិទដោយមិននិយាយអ្វី តែ...

"វ៉ាក!"

កូអ៊ីន យកដៃមកពាំងទ្វារក៏ត្រូវកៀប សម្លេងស្រែករបស់គេធ្វើឱ្យខ្ញុំភ្ញាក់ក្រញាង ។

"កើតអីខ្លាំងអត់"

"ស៊ីងដាច់ខ្យល់ទៅហើយ"

"ឈ្ល!"

"ឈប់!"

លើកនេះ កូអ៊ីន យកខ្លួនមករាំង ព្រមទាំងចង់ជ្រៀតចូលមកក្នុងផ្ទះទាំងមុខក្រាស់ ។

"ចេញទៅ"

"និយាយគ្នាឱ្យដឹងរឿងសិន មិនអីចឹងខ្ញុំមិនទៅ!"

"ខ្ញុំមិននិយាយ"

"អ្ហូ មើលទៅសប្បាយដល់ហើយក្មេង។ តែថាភ្ញៀវដែលម៉ោនេះជាអ្នកណា"

ចាំចេញមកទទួលដោយសម្លេងពេញដោយមិត្តភាព កូអ៊ីន ឱនគោរពយ៉ាងមានមាយាទនិងណែនាំខ្លួនដោយសម្លេងគ្រលរស្រទន់មិនចាញ់គ្នា ។

"ខ្ញុំឈ្មោះ ចុងកូអ៊ីន លោកពូជាចាំរបស់ ជុងអ៊ុល ហើយ"

"ត្រឹមត្រូវវ៉ា"

"ជេកជតស៊ីងតែបែកហើយនេ៎ះ ចង់សប្បាយនឹងការណែនាំខ្លួនទៅដល់ណា ហើយចាំ គេមិនមែនមិត្តទេ!"

"បើមិនមែនមិត្ត ចុះជាអ្នកណា"

"ខ្ញុំជាសង្សារ"

"អ្ហាៗ។ យើងត្រូវចេញទៅនិយាយគ្នាខាងក្រៅភ្លាម!"

ខ្ញុំស្រែកលប់សម្លេងថា សង្សារ ដែលរបូតចេញពីមាត់ កូអ៊ីន ដោយអាការៈភិតភ័យ ព្រោះមិនប្រាកដចិត្តទេថាចាំបានឮពាក្យនោះឬអត់ កូអ៊ីន សើចខឹកខាក់ខណៈដែលត្រូវអូសចេញមក ។

"សប្បាយណាស់មែនទេ"

"ទេ ការដែលខ្ញុំសើច មិនមែនមានន័យថាខ្ញុំសប្បាយទេ តែខ្ញុំគ្រាន់តែមានអារម្មណ៍ល្អដែលបានណែនាំខ្លួនបែបនោះ គឺនាងប្រាប់ថាយើងមិនមែនជាមិត្តហ្នឹងណាំ នាងចង់ឲ្យអ្នកផ្សេងដឹងរឿងរបស់យើងមែនទេ"

"ពីមុននេះអាចមែន"

សម្លេងប្រាកដប្រជារបស់ខ្ញុំ ធ្វើឲ្យគេបិទស្នាមញញឹមភ្លាម បានពេលាដែលយើងត្រូវប្រាកដប្រជាហើយ ។

"ហ៊ើយ...ខ្ញុំដឹងថាខ្ញុំខុស"

"មែន លោកខុសខ្លាំងទៀតផង!"

"បើមានអីដែលខ្ញុំអាចធ្វើដើម្បីនាងបាន..."

"អ្វីដែលលោកធ្វើដើម្បីខ្ញុំគឺការចាំស្តាប់តាំងពីថ្ងៃ មិនមែនមករលឹកនៅពេលនេះទេ នេះប្រហែលជាដឹងរឿងពីសិស្សច្បងហើយ ទើបរត់មករកខ្ញុំបាន"

"កាលនោះខ្ញុំចេវចាវបន្តិច ពេល ណាយេ ប្រាប់ទើបមានសតិឡើងវិញ ហើយក៏តាំងចិត្តម៉ោរកដើម្បីប្រាប់ថាខ្ញុំមិនសង្ស័យអីទេ"

"ត្រូវឲ្យសិស្សច្បងជាអ្នកនិយាយ ទើបលោកជឿផ្អើស"

"..."

"នេះទៅវិញទេគឺចំណុចដែលយើងចូលគ្នាមិនបាន ព្រោះលោកមិនធ្លាប់ទុកចិត្តខ្ញុំ ខ្ញុំនិយាយអីក៏លោកមិនស្តាប់ មាត់ក៏ប្រាប់ថាចូលចិត្តខ្ញុំ ស្រលាញ់ខ្ញុំ តែលោកជឿអ្នកផ្សេងមុនខ្ញុំជានិច្ច"

"តែចង់បន្ទោសខ្ញុំក៏មិនត្រូវដែរ ស្ថានការណ៍បបួលឲ្យគិតអីចឹងថែមទាំង អាសាំយ៉ុង ក៏និយាយបែបនោះដាក់ទូរសព្ទ..."

"នោះហើយគឺជាអ្វីដែលខ្ញុំហៅថាការមិនទុកចិត្ត លោកជឿគេច្រើនជាងខ្ញុំ នោះហើយគឺជាអ្វីដែលខ្ញុំទទួលមិនបាន"

"ខ្ញុំដឹង...ខ្ញុំដឹង"

"នៅក្នុងពេលដែលដឹងហើយក៏ត្រលប់ទៅវិញទៅ មិនចាំបាច់ម៉ោឲ្យឃើញមុខទៀតទេ ពេលនេះខ្ញុំមានអ្វីផ្សេងត្រូវធ្វើច្រើនណាស់"

"ពិតទេដែលថានាងនឹងទៅបរទេស"

"ពិត"

ចម្លើយរបស់ខ្ញុំ ធ្វើឲ្យ កូអ៊ីន ស្លេកមុខ បន្ទាប់ពីតាំងចិត្តនិយាយដោយការធ្វើពុតជារីករាយបន្ទប់ក៏ក្លាយជាសម្លេងដែលពេញដោយភាពសោកសៅឯកា រហូតដល់ខ្ញុំអាណិត តែក៏ត្រូវគ្រវីក្បាលបណ្ដេញគំនិតនោះចេញពេលនឹកដល់អ្វីដែលគេធ្វើដាក់កាលពីថ្ងៃមិញ ។

"ការដែលនាងទៅព្រោះខ្ញុំមែនទេ"

"កុំលង់ខ្លួនឯងពេក ខ្ញុំទៅព្រោះចង់ទៅ!"

"បងស្រលាញ់អូន!"

គួរឲ្យឈឺចិត្តខ្លាំងណាស់ដែលគ្រាន់តែគេស្រែក ខ្ញុំក៏ចិត្តទន់ខ្លួបដូចក្រមួនត្រូវភ្លើង វាចាំជាពាក្យសម្ដីដែលគួរឲ្យចង់ស្ដាប់មែនទែន តែវាមិនស័ក្តិសមនឹងស្ថានការណ៍បែបនេះទេ ខ្ញុំក្ដាប់ដៃណែន ហើយព្យាយាមធ្វើចិត្តឲ្យរឹងបំផុតតាមដែលអាចធ្វើបាន ។

"ឈប់និយាយ ស្រលាញ់ខ្ញុំអីចឹងឬ បើស្រលាញ់ម៉េចក៏ធ្វើដាក់ខ្ញុំបែបនេះ!"

"..."

"មនុស្សស្រលាញ់គ្នាត្រូវស្ដាប់គ្នា ជឿចិត្តគ្នា តែអ្វីដែលលោកធ្វើវាផ្ទុយស្រឡះ លោកមិនស្ដាប់ខ្ញុំ មិនជឿខ្ញុំ ជាមនុស្សបន្តិចល្អបន្តិចអាក្រក់ នៅជាមួយលោកដូចនៅជាមួយខ្លា ខ្ញុំមិនអាចទ្រាំនឹងស្នេហាបែបនេះបានទេ ខ្ញុំព្រមទទួលថាខ្ញុំខ្លាច ខ្លាចខ្លាំងណាស់!"

កូអ៊ីន ឈានជើងចូល តែខ្ញុំឈានថយ ទង្វើរបស់ខ្ញុំធ្វើឲ្យគេដូចមនុស្សត្រូវដាល់ ទាំងចុក ទាំងភាំង និងពេញទៅដោយការខូចចិត្ត ។

"បងដឹងថាបងធ្វើបាបចិត្តអូន អូនមិនអភ័យឲ្យបងទេអ្ហ៎ស"

"ខ្ញុំភាំងចាល"

"ចុងអ៊ីល"

"ទៅវិញទៅ ពេលនេះខ្ញុំចង់បានពេលាធ្វើចិត្តបន្តិច មិនមែនថាខ្ញុំមិនអស់អាល័យអីទេ តែខ្ញុំត្រូវការធ្វើឱ្យខ្លួនឯងជឿឱ្យបានថាខ្ញុំមិនត្រូវការលោកទៀតទេ ហើយចាប់ពីពេលនេះទៅយើងទាំងពីរដើរផ្លូវរៀងខ្លួន វាប្រហែលជាកាន់តែល្អបើមិនជួបគ្នា"

"បងមិនចុះចាញ់ មនុស្សដូចបងមិនធ្លាប់ចាញ់!"

ខ្ញុំដើរចូលក្នុងផ្ទះ ហើយបណ្ដោយឱ្យគេឈរតែម្នាក់ឯង ទោះជាខ្ញុំធ្វើឫកសោះកក្រោះ តែចិត្តខ្ញុំកំពុងយំ ខ្ញុំធ្វើបែបនេះគឺត្រឹមត្រូវហើយ បើបង្ខំសេពគប់គ្នាទៀតគឺឈឺចាំងសងខាង ស្នេហាដែលខ្ញុំមានឱ្យគេពីតំបូងគឺដូចជាយល់សប្តិស្រាប់ទៅហើយ ពេលនេះខ្ញុំគ្រាន់តែត្រូវភ្ញាក់មករកពិភពពិតប៉ុណ្ណោះ ។

រូបភាពចុងក្រោយដែលខ្ញុំឃើញនៅយប់នោះ គឺគេឈរយំតែម្នាក់ឯង ភ្លើងនៅតាមផ្លូវបានបញ្ចាំងឱ្យឃើញច្បាស់ ។

"ច្បាស់ហើយថាឯងត្រូវការបែបនេះ មាត់ធ្វើជានិយាយថាមិនអីតែភ្នែកសោកសៅដូចខ្មែសំណាញ់ចិត្តត្រូវបំពុលងាប់អីចឹង" សីជីនដែលនាំខ្ញុំមកបើកភ្នែកបើកត្រចៀកនៅក្រៅផ្ទះក៏សួរដោយការព្រួយបារម្ភបណ្ដើរបឺតទឹកក្រូចៗបណ្ដើរ មើលទៅព្រួយបារម្ភបានប្រាកដប្រជាខ្លាំងណាស់ ។

"ច្បាស់ហើយ គឺនៅក្នុងពេលដែលគេមិនធ្លាប់គិតនឹងជឿស្អីខ្ញុំបានម្យ៉ាង មនុស្សស្រលាញ់គ្នា តែមិនជឿជាក់គ្នា នៅជាមួយគ្នាមិនកើតនោះទេ"

"ពួកឯងរៀបការហើយឬក៏ម៉េច និយាយដូចលែងគ្នា"

"ឯងកុំធ្វើឱ្យខូចរឿង"

"មនុស្សប្រុសជាពពួកដែលយកខ្លួនឯងជាមូលដ្ឋាន ទើបខ្ញុំមិនសូវចូលចិត្តពួកនោះប៉ុន្មាន ពិសេសអ្នកមាន ខ្ញុំចាត់ទុកមនុស្សប្រុសជាសត្វចម្លែកម្យ៉ាងដែលមានគ្រប់យ៉ាងដូចមនុស្ស តែគ្មានខួរក្បាលនិងបេះដូង"

"ពេកហើយ! អីចឹងគេទើបឯងរួចពីប្រុសៗបាន"

"ហើយចោកយកលុយវាបានទៀត...អី មិនដឹងថាឯងដឹងដំណឹងហើយនៅ សាំយ៉ុង ម៉ោដេកពេទ្យនៅសេអ៊ូលហើយ"

"មែនអ៊្ហើស" ខ្ញុំធ្វើសោះកក្រោះដាក់ឈ្មោះនេះ ហើយងាកទៅចាប់អារម្មណ៍នឹងហាងខោអាវដែលនៅជិតក្អែក "ហើយម៉េច"

"ពេលមកដល់ កូអ៊ីន ក៏ទៅបំផ្លាញឧបករណ៍ព្យាបាលបែកខ្ចាត់ខ្ចាយ ចេញពីបាក់ឆ្អឹងជំនីរ ពេលនេះក្លាយជាជនពិការ ព្រោះត្រូវ កូអ៊ីន យកខ្សែអុកស៊ីសែនរឹត-ក ហើយអូសចុះពីគ្រែដើម្បីវ៉ៃ"

"ហ៉ា?" @ amazingshelf.blogspot.com

"លែងអ៊្ហើសអ៊្ហាហើយឬ គួរឲ្យចាប់អារម្មណ៍ទេ ខឹកៗ"

"ម៉េចក៏ កូអ៊ីន ធ្វើបែបនោះ"

"សួរមោយៗណ៎ ឯងថាគេធ្វើបែបនោះព្រោះអ្នកណា! ចេញពីត្រូវដេកបន្តបួនប្រាំថ្ងៃ ពេលនេះក្លាយជាគ្មានកំណត់"

"ឯងទៅសួរសុខទុក្ខគេញឹកអ៊្ហើស"

"ខ្ញុំតាំងចិត្តទៅវ៉ៃវាដូចគ្នា តែត្រូវបញ្ញាហាមចូល ទើបដឹងរឿងនេះ...ឯងចង់ទៅមើលសភាពរបស់វាបន្តិចទេ ក្រែងលោធ្វើឲ្យឯងមានកម្លាំងចិត្តនៅក្នុងដំណើរជីវិតខ្លាំងឡើង"

"ខ្លាំងយ៉ាងម៉េច"

"គឺពេលឯងបានឃើញ ឯងនឹងបានជឿថាកម្មមានពិតមែន អ្នកដែលធ្វើបាបឯង វាទទួលផលកម្មហើយ ហ៊ឺៗៗ"

"ក៏ល្អ តស់ទៅ"

បើនិយាយតាមអារម្មណ៍ពិតគឺបារម្ភពីអាការៈរបស់ សាំយ៉ុង ខ្លាំងដាស់ទើបមកសួរសុខទុក្ខ តែគឺដូចស្លាកដែលព្យួរមុខបន្ទប់ថា បើមិនមែនសាច់ញាតិ គឺចូលមិនបាន ដៅថាគួរតែជាបញ្ញាពីក្រុមគ្រួសាររបស់អាម្សៀនោះ ព្រោះខ្លាចថា កូអ៊ីន អាចនឹងមកធ្វើបាបទៀត ។

"ខាតជើងទទេ" ខ្ញុំ ។

"មិនទេ យើងនឹងចូលទៅ"

"ហឺ? ហេ៎ ឯងចង់ចូលទៅឬ បើមានអ្នកឃើញ..."

និយាយមិនទាន់ចប់ផង ខ្ញុំក៏ត្រូវអូសចូលទៅក្នុងបន្ទប់ រាងខក ចិត្តបន្តិចដែលបន្ទប់អ្នកជម្ងឺគ្មានសៀមបន្ទោងរយេងរយោងច្រើនដូច ដែលគិត គេគ្រាន់តែដេកនៅគ្រែ ហើយដកដង្ហើមម្ហបៗប៉ុណ្ណោះ ។

"ក្រែងឯងប្រាប់ថាអាការៈធ្ងន់នោះអ្វី"

"គឺបានឮថាអីចឹង តែបួកពាសុខសប្បាយ មើលីសាកបន្តិចសិន"

សីជីន ជ្រេញ ដើរទៅរក ហើយលើកកណ្ដាប់ដៃដាល់ដើមទ្រូង លាន់ប៉ុក សាំយ៉ុង បើកភ្នែក ចំហាមាត់ថ្គង ស្រែកចេញមកបែបគ្មាន សម្លេង ទឹកមុខឈឺចាប់ធ្វើឲ្យ សីជីន លោតគេចមួយជំហាន ។

"បែបឈឺមែនហើយ"

"គឺឈឺ...មែន" សាំយ៉ុង និយាយដូចមនុស្សជិតដាច់ខ្យល់ មុន នឹងមើលមកខ្ញុំ "ប៉ុងអ៊ីល"

ខ្សែភ្នែកដែល សាំយ៉ុង បញ្ជូនមកគឺមានន័យច្រើនយ៉ាង ទាំង សុំទោស ដឹងខុស និងស្រលាញ់...ខ្ញុំគេចភ្នែកចេញ ដោយឲ្យ សីជីន មកឈរពាំងមុខ ។

"ម៉េចក៏លោកមិនទាន់ងាប់ទៀត"

"ខ្ញុំមិនព្រមងាប់ងាយៗទេ"

"ខ្ញុំចង់ឃើញមុខអ្នកពីលោកដល់ថ្នាក់ដេកស្លាបលើគ្រែមែនទែន អ្នំ មិនរាប់ កូអ៊ីន ទេ អានោះឃើញញ៉ឹក" សីជីន និយាយជង់សើចផង ដោយការសមចិត្ត "អាចនឹងឲ្យផ្កាអ្នកដែលធ្វើឲ្យលោកជិតងាប់បាន ម៉ាចាប់ជាការអរគុណ ហើយអាចនឹងខោកក្បាលម៉ាក្រញូវពីរដែល ហេតុអីមិនធ្វើឲ្យលោកងាប់!"

"សីជីន" ខ្ញុំ ។

"គឺវាគួរឲ្យឡកឡឺយហ្នឹង មនុស្សឆ្កួតស្អី ធ្វើរឿងអាក្រក់បែបនោះ បាន ហើយប្រាប់ឲ្យដឹងមុនដែលម៉ោនេះមិនមែនម៉ោលេងទេ ព្រោះ ប៉ុងអ៊ីល ស្អប់លោកដូចអាចម៍!"

សាំយ៉ុង ញញឹមតិចៗ ហើយងក់ក្បាលបែបអស់កម្លាំង៖

"ខ្ញុំយល់"

"ឈប់ធ្វើជាមនុស្សចិត្តល្អគិតតែញញឹមបានទេ ចង់ក្អួត វ្វកៗ"

"ឯងឈប់ទៅ ម៉េះទៅវិញ"

"ស្អីគេ ប៉ុណ្ណឹង!"

"អឺ"

"នេះឯងម៉ោសួរសុខទុក្ខព្រោះសមចិត្ត ឬ បារម្ភ"

"ខ្ញុំទៅវិញហើយ" ខ្ញុំដើរទៅរកទ្វារ តែ...

"ប៉ុងអ៊ុល"

"..."

"អរគុណដែលម៉ោ"

"គិតថាខ្ញុំមកលាទៅចុះ"

"O_O"

ខ្ញុំនិយាយតែប៉ុណ្ណឹង ហើយបម្រុងដើរទៅរកទ្វារ តែថា...ទ្វារនៅចំពោះមុខបែរជាត្រូវប្រានមកមុនដោយដៃរបស់ប្រុសពីរនាក់ តំបូងគិតថានឹងដើរចេញព្រោះយល់ថាជាគិលានុដ្ឋាក តែថាសម្លេងមាំៗរបស់ពីរនាក់នោះ ធ្វើឱ្យខ្ញុំ និង សីជីន ត្រូវច្នក់ជើង ហើយឈរលួចស្តាប់នៅត្រង់ទ្វារ ។

"បានឮថាស្រមោចនិងកន្លាតជាច្រើនកំពុងតាមរកស្លាកលេខឡាន XX 999 មែនទេ"

"ពួកឯងជាអ្នកណា ហ៊ឺ!!!"

ដៃរបស់អ្នកណាម្នាក់ចូលទៅប្រចាប់-ករបស់ សាំយ៉ុង ណែនហើយនិយាយដោយសម្លេងខ្លាំងៗដូចគម្រាម÷

"ចៅហ្វាយយើងបញ្ជាម៉ោប្រាប់ឯងថា...បើនៅតែមិនចប់ ចេញពីកាំបិតដងវែងក្លាយជាកាំភ្លើង ទោះឯងតាមស៊ើបដើម្បីស្អីក៏ដោយតែវាមិនបានផលទេ"

"ពួកឯងជាអ្នកណា "

"យើងជាកូនចៅរបស់ចៅហ្វាយធំ ជេស អ្នកដែលឯងយកកៅអីពីក្រោយ"

"ចៅហ្វាយធំ?"

"បងធំក្រុមខ្លាខ្មៅនោះអ្វី"

"បងធំ? បេះនិយាយលេង អ៊ូយ!!!"

មិនដឹងថាពីរនាក់នោះធ្វើអីខ្លះ តែ សាំយ៉ុង ឈប់លេងសើចហើយ ។

"នេះជាពាក្យតឿន ឯងមិនដឹងទេថាកំពុងតាមរកស្អី កុំម៉ោឲ្យតឿនជាលើកទីពីរ ព្រោះដល់ពេលនោះពួកយើងនឹងធ្វើឲ្យឯងបានដឹងថានរករាយ៉ាងម៉េច!"

ពេលពីរនាក់នោះដើរចេញមក ខ្ញុំ និង ស៊ីជីន ក៏ពួនទាល់តែពីរនាក់នោះដើរចូលជណ្តើរយន្តបាត់ ។ ស៊ីជីន យកដៃជូតញើស ចាប់កដៃខ្ញុំណែន ហើយតាំងសតិ ។

"នេះប្រែថាអ្នកដែលម៉ោមិញនេះជាសត្រូវរបស់ សាំយ៉ុង"

"អឺហឺ"

"សត្រូវរបស់ សាំយ៉ុង គឺអ្នកដែលជួយឯង...ឬថាជាការពិត"

"ការពិតស្អី"

ការពិតរបស់ ជេស នៅក្នុងពេលនេះគឺទទេស្អាតសម្រាប់ខ្ញុំខ្លាំងណាស់ ព្រោះនៅមានអារម្មណ៍ញាប់ញ័រនឹងហេតុការណ៍ដែលដូចនៅក្នុងកុនអម្បាញ់មិញនៅឡើយ ។

"គឺដែលថាគេជាល្បងធំម៉ាហ្វៀ!"

គ្មានការពិសោធណាដែលច្បាស់ថែសជាងការពិសោធនេះទេ!

២៦

ទីបំផុតខ្ញុំក៏ទៅដាក់ពាក្យសុំផ្អាកការសិក្សា មួយរយៈនេះជាពេលវេលាដែលខ្ញុំរវល់បំផុត ណាត្រៀមឯកសា ណាត្រូវមានហត្ថលេខារបស់ម៉ាក់ ដែលបញ្ហានៅពេលនេះមានត្រឹមតែម្យ៉ាងគឺហត្ថលេខារបស់ម៉ាក់ ដែលពេលនេះមិនដឹងម៉ាក់នៅឯណា ហើយពេលមកដល់ផ្ទះក៏ត្រូវធ្វើមុខស្មឿកពេលជួបនឹង កូអឹន កំពុងនិយាយជាមួយប៉ាបានយ៉ាងស៊ីសង្វាក់ និងជួយជួលជុលឡាន ឬអ្វីម្យ៉ាងដែលខ្ញុំមិនដឹងរឿង ។

"ម៉ោធ្វើអី"

សំនួរដែលសុទ្ធតែគ្មានមាយាទរបស់ខ្ញុំ ធ្វើឱ្យការសន្ទនានោះត្រូវបញ្ចប់ ប៉ាធ្វើមុខឡេឡាទិងរហ័សចេញពីត្រង់នេះដោយដឹងរឿង ។

"អីចឹងប៉ាឡើងទៅចាត់ការរបស់ដែលសល់នៅខាងលើសិន"

ទើបពេលនេះសល់តែខ្ញុំ និង កូអឹន គេធ្វើឫកអែនអនដូចមិនដឹងធ្វើយ៉ាងណាបន្ត ក្រៅពីញញឹមខ្មាស់ ហើយញាក់ស្មា ។

"បងម៉ោចាំអូនយូរហើយ"

"ម៉េចក៏មិនទៅរៀន ម៉ោសំកុកស្អីនៅទីនេះ"

"គឺតាំងចិត្តម៉ោរកអូនហ្នឹងស្រីស្អាត"

"..."

"មិនញញឹម" គេធ្វើមុខអន់ចង់ "តែថាអូនទើបម៉ោពីណា"

"ទៅសាលា"

"អ្ហា! ដឹងអីចឹងបងទៅហើយ តែថាម៉េចក៏អូនទៅសាលាដោយឈុតធម្មតាបែបនោះ"

"ខ្ញុំមិនបានទៅរៀនទេ ទៅសុំឈប់"

ហើយមើលទៅដូចជាបានផលចំពោះគេខ្លាំងណាស់ ព្រោះពេលនិយាយចប់ កូអឺន ក៏មានទឹកមុខភ្ញាក់ផ្អើល ឈានមករកខ្ញុំយ៉ាងលឿនហាក់ដូចជាថាបើមិនចាប់មករក ខ្ញុំអាចនឹងបាត់ខ្លួនពីត្រង់នេះ ។

"សុំឈប់! នេះអូនទៅសុំឈប់ពិតមែនអ្ហ៎ស"

"ខ្ញុំគ្មានហេតុផលអីដែលត្រូវករទេ ចាំមិនបានប្រាប់អីលោកទេឬថាខ្ញុំទៅនៅជាមួយ"

"ប្រាប់...តែបងមិនជឿ អូ...អូនទៅព្រោះតែបងឬអត់"

"កុំគិតថាខ្លួនឯងសំខាន់ពេក អ្វីដែលរុញច្រានឱ្យខ្ញុំចាកចេញគឺមានច្រើនយ៉ាង ខ្ញុំថាយើងគ្មានអីត្រូវនិយាយគ្នាទេ"

"យើងត្រូវតែនិយាយគ្នា បងមិនចង់ឱ្យអូនទៅទេ!"

ទោះជាសប្បាយចិត្តដែលបានគេនិយាយចេញមកបែបនោះ តែខ្ញុំក៏តូចចិត្តលើសនឹងទន់ចិត្តបាន ។

"កុំនិយាយទៀត លោកទៅវិញបានហើយ ខ្ញុំត្រូវរៀបឥវ៉ាន់"

"ឱ្យធ្វើយ៉ាងណាទើបអូនមិនទៅ ឱ្យបងធ្វើយ៉ាងណា"

"មិនបាច់ធ្វើអីទាំងអស់"

"បងនឹងធ្វើ បងនឹងធ្វើគ្រប់យ៉ាង!"

ខ្ញុំដើរគេចពីគេឡើងទៅលើផ្ទះ ហើយក៏បានតែលួចមើលនៅត្រង់បង្អួច កូអឺន គិតតែឈ្ងោកមុខមើលដី បើខ្ញុំមើលមិនខុស...គេកំពុងយំទៀតហើយ ។

"ឈ្លោះគ្នាធ្វើអីកូន គេម៉ោជានាតើ"

ចាំលេចមកពីខាងក្រោយ ធ្វើឱ្យខ្ញុំភ្ញាក់សងាកទៅមើល ហើយខំបន្លប់ទឹកមុខទន់ជ្រាយរបស់ខ្លួនឯង ។

"ពេលគេដឹងខុសក៏មកបែបនេះរហូត អភ័យឱ្យញឹកញាប់គឺមិនបាននោះទេ"

"មនុស្សយើងត្រូវចិញ្ចឹមមកមិនដូចគ្នាទេកូន"

"តាមតែគេទៅ"

"ចិត្តរឹងមែន តែថាថ្ងៃនេះទៅសុំឈប់បានសម្រេចទេ"

"មិនទេ ត្រូវមានហត្ថលេខារបស់ម៉ាក់ គឺមិនដឹងថាហេតុអីត្រូវ

រឿងច្រើនដល់ថ្នាក់នេះដែរ ហើយម៉ាក់ចាត់ទៅណាក៏មិនដឹង"

"សម្រេចថាទៅជាមួយប៉ាមែនអ្នកស"

"ម៉ោដល់ដំណាក់កាលនេះហើយ"

"មែន ព្រោះម៉ោដល់ដំណាក់កាលនេះហើយប៉ានឹងបានត្រៀមដំណើរការអីផ្សេងទៀត ច្បាស់ហើយថាទៅមែន ប៉ាឲ្យពេលគិត"

"ចាំ កូនទៅជាមួយប៉ា"

"ចុះទុកគេចោលអីចឹងឬ"

ប៉ាអើតមើលទៅខាងក្រៅ ហើយក៏ឃើញថា កូអ៊ីន មើលមកដូចដឹងថាខ្ញុំឈរត្រង់នេះ ទើបខ្ញុំរហ័សគេចចេញ ហើយឱបដៃ ។

"ចាំ ទុកចោលអីចឹងហើយ ចង់ធ្វើអីក៏ធ្វើទៅ"

"តាមចិត្ត"

ទោះមាត់ប្រាប់ថាមិនចាប់អារម្មណ៍ តែពេញមួយថ្ងៃនេះខ្ញុំគិតតែបារម្ភថា កូអ៊ីន ត្រលប់ទៅវិញហើយឬនៅ នេះក៏ចូលដល់ម៉ោង៥ល្ងាចហើយដែលគេអង្គុយបញ្ឈរជង្គង់នៅមុខផ្ទះរហូតដល់មេឃដូរពីពណ៌ផ្ទៃមេឃទៅខ្មៅ នេះគេតាមបែបប្រែខ្ញុំទៅដល់ណា ខ្ញុំនៅទុក្ខចិត្តដោយសារគេមិនគ្រប់គ្រាន់ទៀតឬយ៉ាងម៉េច!

ខ្វាក!

ខ្ញុំបើកទ្វារយ៉ាងខ្លាំង ហើយគំហកលាន់៖

"ចាប់ទៅផ្ទះវិញបានហើយ ធុញ!"

ហើយទីបំផុតខ្ញុំក៏ទ្រាំលែងបានទៀត ព្រោះការអង្គុយសំកុករបស់គេរាប់ម៉ោងនៅមុខផ្ទះវាដាក់សម្ពាធផ្លូវចិត្តខ្ញុំយ៉ាងខ្លាំង ។ កូអ៊ីន ងាកមកមើល ហើយញញឹមតិចៗដាក់ដោយការសប្បាយចិត្ត ទាំងដែលទើបនឹងត្រូវខ្ញុំជេរ ។

"សប្បាយចិត្តដល់ហើយដែលអូនចេញម៉ោ"

"នៅម៉ោសប្បាយចិត្តឆ្កួតអីទៀត! ចេះម៉ោអង្គុយនៅមុខផ្ទះអ្នកដទៃទៅកើត គ្មានអីឲ្យធ្វើឬយ៉ាងម៉េច"

"គឺនេះហើយអ្វីដែលបងត្រូវធ្វើ...បងកំពុងចាំអូន"

"យើងគ្មានអីទាក់ទងគ្នាទៀតទេ កូអ៊ីន ត្រូវឲ្យខ្ញុំនិយាយប៉ុន្មានដង

ទៀតថាវាចប់ហើយ វាគ្មានអីត្រូវនិយាយទៀយ!"

"បងនឹងរង់ចាំរហូតដល់អូនចិត្តទន់ ដល់ពេលនោះយើងនឹងមានរឿងនិយាយគ្នា"

"វាគ្មានថ្ងៃនោះទេ!"

"យ៉ាងហោចណាស់ពេលនេះយើងក៏តមាត់ត-កគ្នា"

ខ្ញុំញញ្ញឹមដោយកំហឹងហួសហេតុ ខណៈដែល កូអ៊ីន នៅតែយកស្នាមញញឹមមកតស៊ូ ហើយខ្ញុំក៏មានអារម្មណ៍ថាចុះចាញ់ចំពោះការព្យាយាមរបស់គេទាល់តែហត់នឹងដេរ ឬដេញទៀត ។

"ញាំបាយនៅ"

"មិនឃ្លានប៉ុន្មានទេ បងញាំទឹកច្រើនសមគួរ" គេងាកដៃទៅរកសំបកកំប៉ុងទឹកក្រូចជាច្រើន "ទឹកវាណែនពេញពោះ"

"អាឆ្កួត! បើញាំទឹកហើយឆ្អែត គេចាំបាច់មានបាយម៉ោធ្វើអី ញាំបាយក្លាម"

"គឺបងមិនចង់ចេញពីត្រង់នេះហ្នឹងណា៎"

"ត្រូវធ្វើឲ្យខ្ញុំបែកទ្រូងស្លាប់ឬយ៉ាងម៉េច!"

ខ្ញុំដើរចូលក្នុងផ្ទះ ហើយដួសបាយនិងម្ហូបដាក់ចាន យកមកឲ្យគេ កូអ៊ីន គេទទួលយកទាំងមីងមាំង ។

"ញាំទៅ"

"អូនបារម្ភពីបងអ្ហ៎"

"បិទមាត់ ខ្ញុំមិនចូលចិត្តធ្វើបាបអ្នកណា លោកចង់ធ្វើអីវាមិនទាក់ទងនឹងខ្ញុំស្រាប់ទៅហើយ តែអាដែលម៉ោឈរនៅមុខផ្ទះ ឬ ម៉ោងាប់នៅមុខផ្ទះខ្ញុំនេះ មិនបានទេ"

គេយកអណ្តាតទល់ថ្ពាល់ ហើយញញឹមចូលចិត្ត ពេលឃើញខ្ញុំសម្លក់ក៏រហ័សធ្វើមុខស្ងួញ ហើយយកស្លាបព្រាច្រឹះបាយ ។

"នេះដាស្អី បងមិនចេះញាំទេ"

"សម្លពោះត្រី"

"យកពោះត្រីម៉ោញាំឬ វាញាំបានឬ បងមិនចេះញាំទេ!"

"អាអ្នកមាន!"

"ត្រឹមត្រូវ បងមាន"

"មានឱ្យត្រូវកន្លែងជងទៅ គឺឃើញស្រាប់ហើយថាផ្ទះខ្ញុំក្រ មានឱ្យញ៉ាំនៅល្អជាងអត់ស្លាប់! ញ៉ាំទៅ បើមិនក៏ទៅរកអីញ៉ាំនៅផ្ទះទៅ"

ពេលត្រូវដេញបែបនេះ គេក៏ហ៊ុសដួលចាយដាក់មាត់ ហើយក៏សឹងតែព្រួសចេញមកដោយសារហឹរ ខ្ញុំមើលមុខក្រហមឆាំងរបស់គេ ហើយរបូតសំណើចចេញមក នោះទើបធ្វើឱ្យគេខឹងខ្លះ ។

"អូនធ្វើបាបបង!"

"ខ្ញុំចង់ឱ្យលោកញ៉ាំចាយ តែអារឿងហឹរដល់ថ្នាក់ចេះនេះវាអាចប្រើការបាន"

"បងមិនញ៉ាំទេ វាហឹរពេកហើយ"

"អីចឹងក៏ទៅញ៉ាំនៅផ្ទះទៅ! រឿងច្រើនណាស់" ខ្ញុំដណ្ដើមចានចាយពីដៃគេ "ទៅវិញបានហើយ នេះវាយប់ហើយ ចាំលោកបារម្ភ"

"តែ..."

"ដរាបណាលោកមិនទាន់ឆាប់ ចង់ម៉ោពេលណាក៏ម៉ោម៉ោ!"

កូអឹន ញញឹមពព្រាយពេលបានឮខ្ញុំបើកផ្លូវឱ្យ÷

"បងម៉ោបានពិតមែនអ្ហ៎ស"

"តែជួបខ្ញុំឬអត់ ខ្ញុំមិនធានាទេ"

"បើអង្គុយចាំអូនដោយមិនញ៉ាំចាយបែបនេះ ច្បាស់ជាជួប បើអីចឹង...បងទៅវិញហើយ"

"ហឺ...អ៊ុយ!"

កូអឹន ថើបថ្ពាល់ខ្ញុំយ៉ាងលឿន ហើយហ៊ុសរត់ចេញទៅដោយឫកពារីករាយគួរឱ្យចង់ជាក់ ខ្ញុំរត់តាមគេដោយគិតថាតាមទៅដេរ តែក៏ឃើញថាគេនៅតែរីករាយ ។

"បងគ្មានផ្លូវបណ្ដោយឱ្យអូនទៅណាទាំងអស់ ម៉ាថុងអ៊ីល អូនជារបស់ប..."

ផាំង!!!

ចម្រៀកវិទាទីដែលគេនិយាយមិនទាន់ចប់ប្រយោគផង រាងរបស់កូអឹន ក៏ខ្ទាតឡើងទៅលើកាប៉ូឡាន ហើយរមៀលចុះមកលើដី វាស្មើរ

តែគ្មានពេលស្រែករន្ធត់ ឬអ្វីផ្សេងទៀតពេលឃើញថាគេដេកស្ដូកស្ដឹងបែបនោះ ឡានទំនើបដែលបើកមកបុកគេក៏ចតស្ងៀម ។

"កូ...អ៊ីន"

ហើយពេលបានសតិ ខ្ញុំក៏ហក់សរត់ទៅរកគេភ្លាម នៅត្រង់ក្បាលរបស់ កូអ៊ីន ពេញទៅដោយឈាម គេដេកគ្មានសតិដូចមនុស្សស្លាប់ មិនថាអង្រួន ឬ ហៅយ៉ាងណាក៏មិនតបស្នងខ្ញុំសូម្បីតែបន្តិច ។

"សមមុខ"

សម្លេងបើកទ្វារឡានឮព្រមគ្នានឹងសម្លេងដែលស្គាល់ច្បាស់ ធ្វើឲ្យខ្ញុំងាកទៅមើលដោយអារម្មណ៍តក់ស្លុត ស្ត្រីដែលខ្ញុំស្គាល់ច្បាស់តាំងពីកំណើតកំពុងឈរស្លេកមុខ តែក៏ព្យាយាមធ្វើដូចជាថាអ្វីដែលខ្លួនធ្វើនោះវាត្រឹមត្រូវ ។

"ម៉ាក់!"

"វាសមគួរនឹងងាប់ ងាប់បានក៏ល្អដែរ!

២៧

ខ្ញុំមិនចាំរហ័សបញ្ជូន កូអ៊ីន ទៅមន្ទីរពេទ្យ ព្រោះខ្លាចថាបើហៅឡានពេទ្យគឺមិនទាន់សភាពការណ៍ ហើយពេលមកដល់ពេទ្យគេក៏ត្រូវបញ្ជូនទៅកាន់បន្ទប់អាយស៊ីយូភ្លាមនៅកណ្ដាលភាពព្រួយបារម្ភរបស់ពុកកូនយើង ។ ខ្ញុំគិតតែយំ ហើយបន្ទោសខ្លួនឯងដោយភ្លេចពីមូលហេតុពិតទៅថាហេតុអីបានគេជាត្រូវឡានបុក ។

"គេត្រូវតែមិនអី" ចាំ ។

"បើកូនមិនដេញគេឱ្យទៅផ្ទះ គេក៏មិនត្រូវបុក!"

"យើងក៏ដឹងថាហេតុអីក៏ កូអ៊ីន ត្រូវឡានបុក"

"ម៉ាក់..."

"មែន!"

ពេលខ្ញុំតាំងសតិបានក៏ប្រញាប់តេទៅរកម៉ាក់ តែលេខនៅចុងខ្សែមិនអាចទាក់ទងបាន ម៉ាក់អាចនឹងកំពុងតែខ្លាច ហើយរត់គេចទៅណាហើយក៏មិនដឹង ខណៈដែលសតិខ្លួនឯងកំពុងតែខ្វាត់ខ្វាយ ហើយត្រលប់មកបន្ទោសខ្លួនឯងម្ដងទៀត សម្លេងរបស់អ៊ំ កូម៉ា ដែលស្រែកហៅ ធ្វើឱ្យខ្ញុំងាកទៅមើល ហើយយំដោយដឹងកំហុស ។

"កូអ៊ីន ម៉េចហើយ"

"ហឹក...ជាកំហុសរបស់ខ្ញុំ"

"មានអីកើតឡើង!"

"ខ្ញុំមិនដឹងថាពេលនេះគេយ៉ាងម៉េចទេ ពេទ្យនាំចូលបន្ទប់អាយ-ស៊ីយូ មិនទាន់មានអ្នកណាចេញមកប្រាប់ទេ"

"ហើយ កូអ៊ីន ត្រូវឡានបុកបានយ៉ាងម៉េច"

"..."

"អ៊ំសួរថាវាត្រូវបុកបានយ៉ាងម៉េច!"

ចាំដែលឃើញថាខ្ញុំចាប់ផ្ដើមភ័យ ទើបយកខ្លួនមកចាំង ហើយញញឹមដាក់អ៊ំ កូម៉ា ជាការតឿនឱ្យគាត់ចិត្តត្រជាក់ ។

"ទៅសម្រាកសិនទៅកូន ត្រង់នេះចាំប៉ាចាត់ការ"

"ចាំ"

ខ្ញុំរហ័សចេញពីត្រង់នេះភ្លាម ព្រោះសភាពរបស់អ៊ំប្រុសដាក់សម្ពាធខ្ញុំសឹងតែដកដង្ហើមមិនចេញ ខ្ញុំយល់ច្បាស់ដល់បេះដូងរបស់អ្នកដែលជាឪពុក និងកំពុងតែបារម្ភ តែខ្ញុំក៏មានបេះដូងរបស់អ្នកដែលជាកូនដូចគ្នា ចង់ឱ្យខ្ញុំនិយាយបានយ៉ាងម៉េចថាអ្នកដែលបើកឡានបុកកូអឺន គឺជាម៉ាក់របស់ខ្លួនឯង ។ ទោះជានៅក្រោមន្ទីរពេទ្យវាមិនបានជួយអ្វីឱ្យប្រសើរឡើង តែយ៉ាងហោចណាស់ក៏ខ្ញុំមិនបាច់ហិតក្លិនថ្នាំនៅខាងក្នុង មិនបាច់មានអារម្មណ៍ថានៅក្នុងនោះមានអ្នកដែលខ្ញុំរង់ចាំឱ្យដឹងខ្លួនដូចពេលឈរត្រង់នេះ តែហើយភាពសប្បាយចិត្តរបស់ខ្ញុំក៏ត្រូវកញ្ឆក់យកពេលម៉ាក់ប្រាកដនៅចំពោះមុខ ។

"វាងាប់ហើយនៅ"

"ម៉ាក់!"

"កុំនិយាយឮៗ ក្រែងមានអ្នកម៉ោឃើញ!"

សំនួររបស់ម៉ាក់ដូចជាត្រជាក់ តែខ្ញុំក៏ចាប់បានពីអារម្មណ៍ដឹងកំហុសនិងភ័យខ្លាចនៅក្នុងសម្លេង តាមពិតនិស្ស័យរបស់ម៉ាក់មិនមែនជាមនុស្សឃោរឃៅអ្វីទេ ទោះជាអាត្មានិយមខ្លះក៏ដោយ តែអារឿងធ្វើបាបអ្នកដទៃ មិនមែនជានិស្ស័យរបស់ម៉ាក់សូម្បីតែបន្តិច រឿងនេះប្រហែលជាធ្វើឱ្យម៉ាក់ស្លុតមិនតិចទេ ។

"ហេតុអីក៏ម៉ាក់ធ្វើបែបនេះ បើគេស្លាប់មែន ម៉ាក់ដឹងទេថានឹងក្ដៅក្រហាយប៉ុណ្ណា"

"ពេលនោះម៉ាក់មិនបានគិតដល់លទ្ធផលទេ គ្រាន់តែឃើញវាម៉ាក់ក៏ហាមចិត្តមិនបាន ត្រូវបុកវាឱ្យបាន!" ម៉ាក់អង្អែលក្បាលខ្លួនឯងទៅមកដោយការទ្រាំទ្រតូចចិត្ត "ដឹងខ្លួនម្ដងទៀត វាក៏មកដល់កាប៉ូឡាន

និងធ្លាក់ទៅលើដីទៅហើយ"

"ម៉េចក៏ម៉ាក់គុំគួនគេយ៉ាងនេះ នេះវាដល់ថ្នាក់ស្លាប់បានណ៎ា"

"វាបំផ្លាញម៉ាក់!"

"គេធ្វើអី"

"ព្រោះទៅនិយាយឱ្យលោក ចុង ផ្ទោចអារម្មណ៍ដល់ថ្នាក់ជួលអ្នកស៊ើបមកតាមម៉ាក់រហូតដល់ចាប់បានថាម៉ាក់មានប្រុស ហើយដេញម៉ាក់ចេញពីផ្ទះ ព្រោះវា...វាធ្វើឱ្យឯងគេចពីម៉ាក់"

"ខ្ញុំមិនបានគេចពីម៉ាក់ទេ"

"បើមិនគេច ចុះឯងបាត់ទៅណា"

"នោះជាអ្វីដែលខ្ញុំចង់ប្រាប់ តែមិនបានជួបម៉ាក់ ម៉ាក់មិនគួរពេចចារធ្វើអីបែបនេះទេ"

"មិនដឹង!" ម៉ាក់ហូរទឹកភ្នែក តែធ្វើដូចជាគ្មានអីកើតឡើង "វាងាប់គង់ល្អបំផុត យ៉ាងហោចណាស់ក៏ម៉ាក់បានសមចិត្ត"

"ម៉េចក៏ម៉ាក់ធ្វើបែបនេះ"

"គឺម៉ាក់ស្អប់វា"

"តែខ្ញុំស្រលាញ់គេ!"

ខ្ញុំស្រែក ហើយយំ ម៉ាក់សម្លឹង ហើយចង្អុលមុខមិនព្រម÷

"ឯងទៅស្រលាញ់វាបានយ៉ាងម៉េច វាជាសត្រូវម៉ាក់ ឯងនិងវាគ្មានផ្លូវទៅរួចទេ"

"ព្រោះម៉ាក់ហ្នឹងហើយដែលធ្វើឱ្យវាទៅមិនរួច ម៉ាក់ធ្វើឱ្យខ្ញុំនិងគេទៅមិនរួច ហឺៗ"

"រត់ទៅជាមួយម៉ាក់"

"អីគេ"

"ឯងគួរតែរត់ទៅជាមួយម៉ាក់ ទៅនៅជាមួយគ្នាតែពីរនាក់ ទៅ!"

ម៉ាក់ទាញដៃអូសខ្ញុំឱ្យទៅជាមួយ តែដូចជាមានកម្លាំងមហាសាលពីដៃម្ខាងទៀតរបស់ខ្ញុំ ធ្វើឱ្យម៉ាក់ឆ្ងក់ ។

"នៅវែងទៀត គឺប្រាប់ឱ្យទៅ...លោក!"

អ៊ំកូម៉ា មានកម្លាំងច្រើនជាង ទាញខ្ញុំទៅរកបានសម្រេចរហូត

ដល់ម៉ាក់ត្រូវព្រលែង អាចមកពីស៊ូមិនបាន ឬព្រោះវន្ទត់ចិត្តក៏មិនដឹង តែពេលនេះម៉ាក់មុខស្លេក ខ្លួនញ័រអស់ដូចគោដំបៅខ្នងដែលខ្លាចត្រូវចាប់បានថាធ្វើខុស ។

"ខ្ញុំមិនគិតថា...នាងធ្វើបានដល់ថ្នាក់នេះទេ"

"ខ្ញុំ...ខ្ញុំ...ព្រះអើយ!"

ម៉ាក់បម្រុងនឹងរត់គេច តែក៏ត្រូវប៉ាស្ទាក់ផ្លូវជាប់ ពេលដឹងថាខ្លួនឯងគេចមិនរួច ទើបម៉ាក់ឡូឡា ។

"លែងខ្ញុំអាច្កត លែង!"

"នាងត្រូវទទួលខុសត្រូវចំពោះអ្វីដែលខ្លួនបានធ្វើ នាងបុកគេ អ្នកត្រូវតែទទួលខុសត្រូវ"

"ប៉ា" ខ្ញុំរត់ទៅរកម៉ាក់ តែប៉ាគ្រវីដៃហាម ។

"ទុកឲ្យរឿងនេះជារបស់មនុស្សចាស់ទៅ កូនកុំរវល់"

"តែ..."

"ជុងអ៊ីល!"

ពេលត្រូវប៉ាសំលុត ទើបខ្ញុំបានតែឈរស្ងៀម ម៉ាក់ដែលនៅតែរើបម្រះមិនឈប់ក៏ព្រមចាញ់ រហូតដល់ដឹងថាខ្លួនឯងស៊ូកម្លាំងមិនបានក៏យំហ៊ួសុំអង្វរឲ្យប៉ាលែង ។

"លែងខ្ញុំ ខ្ញុំមិនចង់ជាប់គុក លែងខ្ញុំ ហឺៗ ជុងអ៊ីល ជួយម៉ាក់ផង"

ខ្ញុំបានតែមើលប៉ានាំម៉ាក់ទៅឡើងឡាន ហើយអង្គុយតែពីរនាក់ដោយមិនដឹងថាមនុស្សចាស់កំពុងធ្វើអី បន្ទាប់ពីនោះគាត់ក៏យំ... ហេតុអីក៏មានតែរឿងយ៉ាប់ៗកើតឡើងចំពោះខ្ញុំ ម្នាក់នៅក្នុងបន្ទប់អាយស៊ីយូ មិនទាន់ដឹងលទ្ធផល ចំណែកម្នាក់ទៀតក៏មើលទៅដូចជាគេចមិនផុតពីពន្ធនាគារ រឿងទាំងអស់ដែលកើតឡើងគឺសុទ្ធតែទាក់ទងនឹងខ្ញុំ...

ខ្ញុំម្នាក់ឯង!

"ជុងអ៊ីល"

"អ៊ំប្រុស"

ខ្ញុំដែលគិតតែឈរម្នាក់ឯងយូរហើយក៏ភ្ញាក់ព្រើតពេល អ៊ំកូម៉ា

ដាក់ដៃលើស្មា ហើយនិយាយដោយសម្លេងលួងលោម ទាំងដែលខ្ញុំមិនគួរនឹងបានទទួលវាដោយសារទង្វើរបស់ម៉ាក់ ។

"យ៉ាងហោចណាស់នៅក្នុងរឿងយ៉ាប់ៗក៏មានរឿងល្អបង្កប់ដែរ"

"អីគេ"

"ពេទ្យប្រាប់ថា កូអឹន គ្រាន់តែបាក់ជើងបែកក្បាលប៉ុណ្ណោះ"

"មែនអ្ហ៎ស"

"អាកូនពិបាកងាប់ ចង់ទៅមើលទេ"

អ៊ំប្រុសបិទស្នាមញញឹមទាំងដែលព្យាយាមពេញទីក្លាមពេលខ្ញុំឈានថយក្រោយជាការបដិសេធ ។

"មិនល្អដាង"

"ហេតុអី"

"កើតហេតុការណ៍បែបនេះ ខ្ញុំគ្មានមុខទៅជួបគេទេ រឿងមិនល្អទាំងអស់ដែលកើតឡើងព្រោះតែខ្ញុំ គេត្រូវមកឈឺខ្លួនក៏ព្រោះតែខ្ញុំ បើគេមិនមកលួងខ្ញុំ ក៏គ្មានរឿងបែបនេះដែរ"

"ក្មួយគិតច្រើនពេកហើយ...ម្យ៉ាងទៀត អ៊ំដឹងថាក្មួយចង់ទៅមើលគេ អ៊ំបានឮអ្វីដែលក្មួយនិយាយជាមួយម៉ាក់អស់ហើយ"

ខ្ញុំមុខក្រហម តែពេលនេះគួរតែរអៀសចិត្តច្រើនជាងអៀននៅក្នុងរឿងស្នេហា ទើបធ្វើឱ្យខ្ញុំញញឹមមិនចេញ ។

"មិនជួបគេល្អជាង ទោះយ៉ាងណាក៏វាទៅមិនរួចដែរ កើតរឿងដល់ថ្នាក់នេះទៅហើយ"

"ក្មួយនិងម៉ាក់គឺខុសគ្នា"

"តែម៉ាក់គឺម៉ាក់របស់ខ្ញុំ ទោះជាខុសគ្នា តែម៉ាក់នៅតែម៉ាក់របស់ខ្ញុំ មិនអីទេ គ្រាន់តែបានឮថាគេមិនអី ខ្ញុំក៏សប្បាយចិត្តទៅហើយ សុំផ្តាំតាមអ៊ំសួរសុខទុក្ខគេផង"

"ម៉េចក៏មិនទៅមើលខ្លួនឯង បើក្មួយទៅ គេអាចនឹងសប្បាយចិត្តក៏ថាបាន គឺឯងទាំងពីរស្រលាញ់គ្នាមិនមែនឬ"

ខ្ញុំងើយមើលមុខគាត់ ហើយទឹកភ្នែកកាន់តែហូរ÷

"អរគុណដែលអ៊ំមិនស្អប់ខ្ញើម...តែទោះយ៉ាងណា ខ្ញុំទៅរកគេឬ

អត់ក៏នៅតែបុំណ្ណឹង ព្រោះខ្ញុំត្រូវទៅហើយ"

"ទៅណា"

"កូអ៊ីន ដឹងច្បាស់ថាខ្ញុំទៅណា"

គឺមិនដឹងទេថាខ្លួនឯងលេងឬកទៅធ្វើស្អី តែខ្ញុំថាវាសមហេតុសមផលល្អមែនទេដែលមិនបានទៅសួរសុខទុក្ខគេអស់ជាច្រើនថ្ងៃដែលកន្លងមក ទោះជាចាំនិងអ្នកនៅជុំវិញព្យាយាមនិយាយលួងលោមយ៉ាងណា ក៏ខ្ញុំនៅតែចិត្តរឹងនិងអះអាងពាក្យដើម រហូតដល់សីជីន ទ្រាំមិន បានដល់ថ្នាក់ស្រែកឡូឡា ។

"អ្ហាៗៗ!"

"ឯងច្កួតហើយអ្ហ៊ុស"

"អឺ ខ្ញុំធុញឯង ធុញខ្លាំងណាស់!"

"ខ្ញុំទៅធ្វើអីឲ្យឯងមានអារម្មណ៍បែបនោះ"

"ឯងធ្លុះកញ្ចក់មើលមុខខ្លួនឯងខ្លះអត់ថាពេលនេះភ្នែកខាងក្រោមខ្មៅទៅដល់ណា ហើយណារនៅរាងកាយដែលស្គាំងស្គមដូចខ្មោចច្កួតនេះទៀត ចិត្តក៏ចង់ទៅមើលគេ តែមាត់បេះតែនិយាយថាខ្ញុំមិនចាំបាច់អីត្រូវទៅ ខ្ញុំមិនទៅ ឯងគិតថាខ្លួនឯងលេងអ៊ីមីឈុតផាប់ឬយ៉ាងម៉េច"

ខ្ញុំងាកទៅមើលកញ្ចក់ដែលនៅឆ្ងាយ ហើយសង្កេតខ្លួនឯងតាមសម្ដីមិត្ត តែមិនទាន់បានមើលផង ក៏ត្រូវបង្ខាប់ឲ្យងាកទៅមើលដោយដៃទាំងពីររបស់មិត្ត ។

"បើចង់ទៅ ឯងត្រូវតែទៅ"

"គេចេញពីពេទ្យហើយមិនមែនឬ"

"នេះឯងមិនបានស្ដាប់ខ្ញុំនិយាយទេអ្ហ៊ុសនេះ៎ តំបូងខ្ញុំប្រាប់ថាអាអ្នកដែលចេញពីពេទ្យគឺ សាំយ៉ុង"

"អ្ហ៎...គេសុខសប្បាយហើយមែនទេ"

"ឯងទៅសួរវាធ្វើអី ឯងត្រូវសួរដល់ កូអ៊ីន អ្ហា!"

ចំជាមនុស្សដែលមានអ៊ីនណឺច្រើនមែន!

"សម្រាប់ កូអឺន សម្រេចថាចាំទំនេរខ្ញុំនឹងទៅមើលគេចុះ ប៉ុណ្ណឹងមែនទេដែលឯងត្រូវការ"

"ខ្ញុំហត់នឹងឯងណាស់ ម៉ាថុងអ៊ុល ហត់ណាស់! ឯងលេងប្ដូកធ្វើស្អី ចង់ទៅមើលក៏ទៅទៅ មិនបាច់ម៉ោអាងរឿងម៉ាក់អីចេះអីចុះទេ ព្រោះខ្ញុំប្រាប់ហេតុផលដល់ឯងអស់ហើយ ថាចាំរបស់ កូអឺន មិនបានទឹងស្អីឯងទេ ម៉ាក់គឺម៉ាក់ ឯងគឺឯង ចំណែក កូអឺន ក៏សួរកឯងរាល់ថ្ងៃម៉េចក៏ឯងនៅចិត្តរឹងបាននេះ"

"ខ្ញុំរអៀសចិត្ត"

"ឯងប្រាប់ខ្ញុំហើយ តែបើឯងមិនទៅនឹងរអៀសចិត្តដាងទេ"

"កុំដាក់សម្ពាធខ្ញុំ!"

ខ្ញុំតំឡើងសម្លេងខ្លះ សឺជីន ចូក់ពេលឃើញប្ដូកពាបែបនោះ ។

"ខ្ញុំ...មិនហ៊ានទៅជួបគេ"

"អ្ហា រឿងរបស់ឯងទេ ចង់ធ្វើអីក៏ធ្វើទៅ ខ្ញុំចង់ទៅស្រែក!"

ប្ដូកពារបស់ខ្ញុំបែបគួរឱ្យធុញមែនហើយ ទើប សឺជីន រត់ចេញទៅក្រៅផ្ទះ ព្រមទាំងស្រែកដូចដែលប្រាប់មែន ចាំមើលខ្ញុំ ហើយគ្រវីក្បាលតិចៗដូចមនុស្សហត់ចិត្ត ក៏សង្ស័យខ្លួនឯងដូចគ្នាហ្នឹងថាហេតុអីក៏ខ្ញុំរឹងទទឹងដល់ថ្នាក់នេះ តែ...ខ្ញុំមិនហ៊ានទៅជួបគេពិតមែន ។

ខ្ញុំខ្លាច...

"អ្ហា!"

"នេះឯងនៅស្រែកមិនទាន់រួចទៀតឬ ស្មានថាទៅផ្ទះហើយ"

"សាំយ៉ុង មោរកឯង"

"ហឺ?"

"គេប្រាប់ថាមោសុំទោស"

២៨

សាំយ៉ុង ដែលឈរចាំនៅមុខផ្ទះដោយឫកពាសប្បាយៗ បញ្ជូនស្នាមញញឹមមកឱ្យភ្លាមពេលឃើញខ្ញុំប្រាកដខ្លួន ទោះជាខ្ញុំបានទទួលស្នាមញញឹមរីករាយដែលអ្នកណាៗឃើញហើយក៏ត្រូវសន្លប់ តែបែរជាក្លាយជាខ្ញុំឃើញហើយក៏មានអារម្មណ៍ភ័យខ្លាចរហូតដល់ត្រូវច្រក់ជើងនៅកន្លែងដើម រហូតដល់ សាំយ៉ុង ត្រូវបិទស្នាមញញឹម ។

"នៅខ្លាចខ្ញុំទៀតអ្ហេស"

"លោកមានការអី"

ខ្ញុំកាត់បទភ្លាម សាំយ៉ុង ដែលមកដោយឫកពាសប្បាយៗពេលជួបខ្ញុំម៉ាជាក់ ទើបធ្វើឱ្យវាមើលទៅជាផ្លូវការឡើង ។

"ខ្ញុំមកសុំទោស"

"អ្ហឹម ខ្ញុំនឹងទទួល...អ្ហេ? មុខលោកនៅមិនទាន់ជាទៀតឬនេះ"

ខ្ញុំអាចដឹងមកខ្លះថា សាំយ៉ុង ត្រូវពើសើងតែងាប់ដោយសារ ជេសល្បងជម៉ាហៀ តែនេះវាក៏ច្រើនថ្ងៃហើយ ម៉េចក៏របួសបបូរមាត់វានៅថ្មីៗស្រស់ៗ...

"តាមពិតជាយូរហើយ តែនេះជារបួសថ្មី"

"យកមុខខ្លួនឯងទៅរំខានប្រសាទអ្នកណាទៀតហើយ

"កូអឺន"

"នេះប្ដីដៃ កូអឺន ឬ កើតអី"

សង្ស័យតែខ្ញុំមានឫកពាភ្ញាក់ផ្អើលពេកហើយ ទើប សាំយ៉ុង អស់សំណើច នោះហើយទើបខ្ញុំហាក់សម្រួលអារម្មណ៍ឱ្យស្ងប់ស្ងាត់ម្ដងទៀត តែប្រហែលជាលែងទាន់ហើយ ។

"ខ្ញុំទៅនិយាយការពិតប្រាប់វាពីរឿងរបស់យើង"

"រឿងរបស់យើងស្អី ធ្លាប់មានរឿងរបស់យើងពីអង្កាល់"

"មានរឿងរបស់យើងតាំងពីមានការយល់ច្រឡំនោះ តាមពិតគឺខ្ញុំតាំងចិត្តឱ្យវាយល់ច្រឡំ...ព្រោះខ្ញុំដិតដិតនឹងវាណាស់ ទើបស្គាល់ពីធម្មជាតិពិតរបស់វាច្បាស់...វាជាប្រភេទពួកដែលជឿអ្នកផ្សេងច្រើនជាងអ្នកនៅជិតខ្លួន ទើបខ្ញុំអាស្រ័យចន្លោះប្រហោងនោះដោយការធ្វើឱ្យវាយល់ច្រឡំនិងឈ្លោះជាមួយនាងកាន់តែខ្លាំង ខ្ញុំពូកែណា៎"

"..."

"ម៉េចក៏នាងមិនខឹង នាងគួរតែខឹង ស្ទុះមកទះតប់ខ្ញុំ"

"គ្រាន់តែកំពុងគិតរឿងផ្សេងៗដែលកើតឡើង បើមិនមែនព្រះ ក៏ជាព្រហ្មលិខិតដែរដែលលិខិតទុកហើយ"

"និយាយជ្រៅដល់ហើយ ខ្ញុំមិនយល់ទេ"

"តាមតែវាទៅ សរុបទៅគឺខ្ញុំ និង កូអឺន មិនអាចដើរផ្លូវជាមួយគ្នាបានទេ អ្វីដែលលោកបានធ្វើវាជាផ្នែកមួយដែលជាស់តឿនថាខ្ញុំ និង កូអឺន ស្រលាញ់គ្នាមិនបាន"

"ខ្ញុំក៏អាចដឹងមកខ្លះថាអ្នកទាំងពីរជួបរឿងរ៉ាវច្រើន តែនាងមិនឃើញចាំចាច់អីព្រមចុះចាញ់ទេ..."

"ពេលនេះអ្វីដែលខ្ញុំព្រមចុះចាញ់គឺជោគជតារបស់ខ្លួនឯងទៅវិញទេ"

"តែ កូអឺន ស្រលាញ់នាង"

"ខ្ញុំក៏ស្រលាញ់គេ"

"ចុះម៉េច..."

"បើលោកធ្លាប់ជាកូនចុងរបស់ប៉ាគេ ហើយមានម៉ាក់ទៅបើកឡានបុកគេជិតស្លាប់ដូចខ្ញុំ លោកនឹងបានដឹងថាហេតុអីក៏ខ្ញុំនិងគេស្រលាញ់គ្នាមិនបាន សម្ពន្ធភាពរបស់យើងវានៅជិតគ្នាពេក បើខ្ញុំជាអ្នកផ្សេង ហើយមិនពាក់ព័ន្ធអីនឹងគេ វានឹងធ្វើឱ្យខ្ញុំស្រួលចិត្តជាងនេះ"

"នាងគិតច្រើនពេកហើយ"

"ខ្ញុំជិតទៅនៅបរទេសជាមួយប៉ាហើយ"

"O_O"

"ជួនកាលការចាកចេញប្រហែលជាធ្វើឱ្យអ្វីៗប្រសើរឡើង ពេលវេលាកន្លងផុតទៅ គ្រប់យ៉ាងនឹងកាត់បន្ថយបានខ្លះ ស្នេហារបស់យើងគឺដូចភាពគួរឱ្យត្រេកត្រអាលនៅគ្រាយុវវ័យ ពេលវេលាកន្លងផុតទៅ យើងធំធាត់ក្លាយជាមនុស្សធំ ខ្ញុំ និង កូអឺន ក៏នឹងក្លាយត្រឹមតែជាអ្នកស្គាល់គ្នា លោកយល់ទេ"

"ហើយនាងនឹងបណ្ដោយឱ្យគ្រប់យ៉ាងកន្លងផុតទៅងាយៗបែបនេះនេះ៎ ចុះនាងទៅអង្គាល់"

"បីថ្ងៃទៀត គ្រប់យ៉ាងត្រៀមរួចរាល់ហើយ ហើយដែលខ្ញុំមិនទៅរក កូអឺន..."

"ហេតុអី"

"ខ្ញុំ..."

"ធ្វើចិត្តនិយាយលាគេមិនបានមែនទេ"

ខ្ញុំសម្លឹងមុខ សាំយ៉ុង ហើយសើចទាំងបង្ខំ ស្អប់មែនអាមនុស្សដែលមកដឹងពីគំនិតរបស់ខ្ញុំ ហើយធ្វើមុខងាប់មិនសម្ដែងពីអារម្មណ៍អ្វីបែបនេះ ។

"សម្រេចថាអ្វីដែលកន្លង ខ្ញុំអភ័យឱ្យទៅចុះ យើងចាកចេញពីគ្នាតាមសម្រួលទៅគឺបានហើយ"

ខ្ញុំលូកដៃទៅឱ្យ សាំយ៉ុង ចាប់ តែគេបែរជាទាញខ្ញុំទៅឱប ហើយខ្សឹបដោយសម្លេងញ័រៗដូចមនុស្សយំ÷

"ខ្ញុំសុំទោស...ពិតមែន"

"..."

"ព្រោះខ្ញុំស្រលាញ់នាង"

ហើយនោះគឺជាការលាចុងក្រោយរបស់យើង ទោះជាមិនស្រួលចិត្តប៉ុន្មានចំពោះសម្ដីរបស់គេ តែក៏លួចមានអារម្មណ៍ល្អដែលបានដឹងថានៅក្នុងជីវិតយុវវ័យ មានម្ដងដែលមានមនុស្សប្រុសមកប្រាប់ថាស្រលាញ់ខ្ញុំ...

ល្អដល់ហើយ!

ហើយនៅទីបំផុតថ្ងៃធ្វើដំណើរក៏មកដល់

ជាច្រើនថ្ងៃកន្លងមកខ្ញុំត្រូវរត់ខ្វេងដៃខ្វេងជើងនឹងរឿងឯកសារជាច្រើន ណាត្រូវទៅលាសាច់ញាតិថាខ្លួនឯងមិនបានរស់នៅក្នុងប្រទេសកូរ៉េទៀតទេ មាមីងបងប្អូននាំគ្នាសោកសៅខូចចិត្ត (ខ្ញុំថាពួកគេធ្វើពុតច្រើនដាង) តែយ៉ាងហោចណាស់ក៏ធ្វើឲ្យមានអារម្មណ៍ល្អថានៅទីនេះមានអ្នកស្រលាញ់និងបារម្ភពីយើងដែរ។

ចំណែកម៉ាក់...ចុងក្រោយដែលខ្ញុំទៅសួរសុខទុក្ខគឺនៅផ្ទះជួលរាងចាស់ បន្ទាប់ពីត្រូវជានាឲ្យចេញក្រៅឃុំដោយ អ៊ំកូម៉ា ក៏គិតតែយំនិងសម្ងំក្នុងបន្ទប់តែម្នាក់ឯង ។

"ឯងទៅចោលម៉ាក់"

ម៉ាក់គិតតែនិយាយពាក្យនេះរហូតធ្វើឲ្យខ្ញុំមានអារម្មណ៍ល្ហល្ហេវអស់ហើយ ពេលនេះម៉ាក់ត្រូវធ្លាក់នៅក្នុងពិភពរបស់ខ្លួនឯងរហូតដល់គ្មានអ្នកណាចូលទៅជ្រែកបាន ។ អ៊ំកូម៉ា ប្រាប់ឲ្យខ្ញុំសប្បាយចិត្តរឿងម៉ាក់បាន តែខ្ញុំមិនដឹងថាខាងគាត់នឹងធ្វើយ៉ាងម៉េចបន្តទេ ទើបខ្ញុំបានតែចាំសុំអង្វរឲ្យគាត់ជួយម៉ាក់ឲ្យដល់ទីបំផុត ទោះជាការសុំនោះវាគ្មានប្រយោជន៍ក៏ដោយ អ្នកណាប្រើឲ្យម៉ាក់ទៅជិះឡានបុកកូនគេ ។

"ខ្ញុំស្អប់ឯង"

សឺជីន យំ ទឹកភ្នែកហូរហាមពេលមកជូនដំណើរខ្ញុំនៅព្រលានយន្តហោះ ធ្លាប់ឃើញតែក្នុងកុន ពេលបានមកឈរនៅកណ្តាលផ្ទៃដីដ៏ធំល្វឹងល្វើយនិងពេញដោយកន្លែងទិញសំបុត្រនិងអីវ៉ាន់ហូតេសស្អាត ។ វាធ្វើឲ្យខ្លួនឯងតូចតឿទាបតុញ ។

"ខ្ញុំមិនទាន់ស្លាប់ទេ ម៉េចក៏យំដល់ថ្នាក់នេះ"

"ឯងមកវិញពេលណា"

"ពេលខ្ញុំសន្សំលុយទិញសំបុត្រយន្តហោះបាន"

"ជាតិក្រោយឬ ង៉ែៗ"

វាមិនគិតថាខ្ញុំសន្សំលុយបានពិតឬនេះ!

"ឯងជាស្រីគ្មានខួរ គ្មានគំនិត ធ្វើជាឯងទៅនៅបរទេស ប្រាប់

គ្រង់ៗម៉ោណ្ណដាង់ថាឯង់មិនហ៊ានទៅកូរ៉េ ព្រោះត្រូវការគេចពីមនុស្សប្រុស អាមនុស្សទន់ជ្រាយ!"

"ខ្ញុំមិនបានគេចពីមនុស្សប្រុសទេ ហើយក៏មិនបានទន់ជ្រាយ... តែខ្ញុំមិនដឹងថាទៅធ្វើអី ហើយខ្ញុំនឹងទៅជាមួយអ្នកណា ចាក់មិនទៅម៉ាក់ម៉េចម៉ាក៏មិនដឹង"

"ឯង់ទៅជាមួយខ្ញុំហ្នឹងអ្ហ៎"

"ខ្ញុំទៅទៅជាមួយក្រុមគ្រួសារឯង់បានយ៉ាង់ម៉េច រំខានទទេៗ ខ្ញុំមិនមែនជាកូនចៅផ្ទះឯង់ទេពីយ"

"គឺទៅទៅជាមួយ កូអឹន គេមានវាល់កោដ្ឋ ហើយក៏ស្រលាញ់ឯង់ណាស់ៗ។ គេមានបញ្ហាចិញ្ចឹមឯង់ ឱ្យរបស់ដែលឯង់ចង់បាន មានកូនជាមួយឯង់បានដោយគ្មានបញ្ហា"

"ឯង់ឡប់អ្ហ៎ស"

"មិនឡប់ទេ"

សម្លេងរបស់ កូអឹន ឮនៅមិនឆ្ងាយ មកដោយឈើច្រត់ ជើងម្ខាង់របស់គេនៅប្រើការមិនបាន តែក៏ព្យាយាមយ៉ាង់ខ្លាំង់ដែលនឹង់ដើរមករកខ្ញុំដោយមាន សាំយ៉ុង ជួយគ្រាហ៍ ។ ខ្ញុំមើល កូអឹន ដោយមានអារម្មណ៍ខុសប្លែក ។

"អូនអាចទៅជាមួយបង់បាន យើង់នឹង់ទៅជាមួយគ្នា មានកូនជាមួយគ្នា អូនចង់បានអីក៏បង់ឱ្យបាន!"

សម្ដីដ៏សែនបើកចំហរបស់គេធ្វើឱ្យខ្ញុំមុខក្រហមទោះជាស្ថានការណ៍តានតឹង ខ្ញុំឈានថយក្រោយមួយជំហាន ហើយដកដង្ហើមចូលស្ងួត ។

"ខ្ញុំមិនអាចទៅជាមួយលោកបានទេ"

"ឯង់លេង់ឫកទៀតហើយ"

"ស្ងាត់ទៅ ស៊ីជីន"

"ចាំ"

"បើអូនចង់ប្រាប់ថាហេតុផលរបស់អូនគឺព្រោះតែម៉ាក់អូនធ្វើអីនោះ បង់មិនចាប់អារម្មណ៍ទេ បង់ប្រាប់ហើយតើថាបង់មិនប្រកាន់

ចាប់បងមិនថាអីទេ គ្រប់យ៉ាងគឺអូនខេ ចុះម៉េចក៏អូនទៅតែទៅ ឬព្រោះអូនគ្មានលុយ មិនអីទេ បង..."

"នឹងចេញឱ្យ?"

"គឺ..អូនមិនសល់អ្នកណាក្រៅពីបងនោះអ្វី"

ខ្ញុំមើលមុខ កូអឺន ដោយការចេះចូល អ្វីដែលគេនិយាយ ទោះជាបំណងល្អ តែស្តាប់យ៉ាងណាក៏ធ្វើឱ្យខ្ញុំតូចទាបដែរ ។

"បើខ្ញុំចាប់អារម្មណ៍លុយរបស់លោកគឺប្រហែលជាសេពគប់លោកតាំងពីដំបូងហើយ"

"បងមិនបានមានន័យថាអីចឹងទេ"

"លោកគឺបែបនេះ ស្អីៗក៏ប្រើលុយកាត់ក្តី ជីវិតលោកមិនធ្លាប់មានបញ្ហាអីទេ" ខ្ញុំក្តាប់ដៃណែន "លោកចង់បានស្អីក៏បានមកងាយៗតែរហូត"

"មានតែអូនហ្នឹងហើយដែលធ្វើមិនឱ្យវាងាយ"

"រឿងដែលកើតឡើងចំពោះយើង វាពិសោធហើយថាយើងមិនមែនជាគូនឹងគ្នា!"

"អូនយកមជ្ឈដ្ឋាននៅជុំវិញខ្លួនមកប្រាប់ថាយើងមិនមែនជាគូនឹងគ្នាមិនបានទេ ស្នេហារបស់យើងគឺជាស្នេហារបស់យើង គ្រប់យ៉ាងដែលកើតឡើងគឺជាថ្វីដៃរបស់អ្នកផ្សេង"

"តែអ្នកផ្សេងដែលថាជាម៉ាក់របស់ខ្ញុំ"

"..."

"បើខ្ញុំសម្រេចចិត្តហើយ...ហើយថ្ងៃមួយយើងឈ្លោះគ្នា ឧបមាថាត្រូវបែកគ្នា ធ្លាប់គិតខ្លះអត់ថានឹងមានអ្វីកើតឡើង"

"វាគ្មានថ្ងៃនោះទេ"

"វាគ្មានបានយ៉ាងម៉េច កូអឺន មិត្តតែមួយដែលលោកមាននៅត្រូវឈ្លោះគ្នាព្រោះតែខ្ញុំ គ្រួសារដែលមានក្តីសុខរបស់លោកត្រូវបំផ្លាញព្រោះតែម៉ាក់ខ្ញុំ រាងកាយដែលធ្លាប់សំបូរបែបរបស់លោកពេលនេះត្រូវមកឈឺព្រោះតែខ្ញុំ ហើយបើថ្ងៃមួយយើងត្រូវបែកគ្នាប្រាកដចិត្តហើយអ្នកសថាមិនលើកយកមកនិយាយ"

"អូនឈប់យករឿងនេះយកនោះមកនិយាយបានទេ បងប្រាប់បានថា វាគ្មានអីកើតឡើងទេ បងស្រលាញ់អូនខ្លាំងណាស់ដល់ថ្នាក់មិនដឹង យកស្អីមកនិយាយបានទៀត អូនយល់អត់!"

"យើងនៅក្មេងពេកហើយ គូអ៊ីន"

"ចាប់ពីថ្ងៃនេះទៅដល់ដប់ម្ភៃឆ្នាំទៀតក៏បងនៅតែប្រាប់បាន ពេញមាត់ថា អូនជាស្នេហ៍តំបូងរបស់បង ហើយបងស្រលាញ់អូន ខ្លាំងណាស់ៗ!"

"ពិសោធទៅ"

"ចង់ឱ្យពិសោធយ៉ាងម៉េច"

"បើខ្ញុំត្រលប់មកវិញយើងនៅតែមានចិត្តចំពោះគ្នា ដល់ពេល នោះចាំយើងមកគិតរឿងរបស់យើង ល្អទេ"

"អូនចង់មានន័យថា..."

"បើខ្ញុំមកវិញលោកនៅតែស្រលាញ់ខ្ញុំ ដល់ពេលនោះ..."

"បងមិនឱ្យអូនទៅ!"

សម្លេងប្រកាសហៅអ្នកដំណើរដែលត្រូវទៅអាមេរិកឱ្យត្រៀម ឡើងយន្តហោះ ចាំដែលឱ្យពេលាខ្ញុំយ៉ាងយូរក៏ដើរមកអង្រួនតិចៗ ខ្ញុំខាំ មាត់ ទឹកភ្នែកហូរ មានអារម្មណ៍ថាស្ទះដង្ហើមដែលវាដល់ពេលត្រូវ ចាកចេញមែនទែនហើយ ។

"ខ្ញុំនឹងមកវិញ!"

"ប៉ុន្មានថ្ងៃ ប៉ុន្មានខែ ប៉ុន្មានឆ្នាំ!"

ខ្ញុំបែរខ្នងដាក់គេ ហើយដើរទៅរកចាំ សម្លេងរបស់ គូអ៊ីន ស្រែក ដេញពីក្រោយដូចចង្កូតរហូតដល់មនុស្សម្នានៅម្តុំនោះងាកទៅមើល គេ លើកលែងតែខ្ញុំដែលគិតតែឈ្ងោកមុខដើរ ហើយយំ ។

"បងនឹងរកស្រីដែលល្អជាងអូន ស្អាតជាងអូន ហើយបងនឹង ស្រលាញ់គេឱ្យច្រើនជាងអូន ចាំមើលទៅ!"

"..."

"កុំទៅ ហ៊ឺៗ កុំទៅ!"

ភាគបញ្ចប់

បីឆ្នាំកន្លងផុតទៅ....

គ្រប់យ៉ាងមើលទៅដូចជាយល់សប្តិយ៉ាងអីចឹង ខ្ញុំមកអង្គុយសម្លក់សម្លឹងកុំព្យូទ័រ ហើយអានមែលដែល សឺជីន ឧស្សាហ៍ផ្ញើមកអាប់ដេតព័ត៌មាននៅសេអ៊ូល ព្រមទាំងដកដង្ហើមធំ ដែលមើលនោះគឺចង់ដឹងថាមានអ្វីសប្បាយៗខ្លះដែលធ្វើឲ្យខ្ញុំចង់ត្រលប់ទៅវិញ ។

កាលពីច្រើនថ្ងៃមុន ម៉ាក់បានតេមកប្រាប់ថាគាត់ជិតរៀបការហើយ ប្តីថ្មីជាពោះម៉ាយមានជីវភាពល្អ ជាមន្ត្រីរដ្ឋការជាន់ខ្ពស់ ម៉ាក់រៀបរាប់ពីស្នេហាដែលគាត់មានចំពោះគេឡើងខ្ញុំអៀនជំនួស សឹងតែរមៀលខ្លួនទៅមកនៅលើឥដ្ឋ ព្រមទាំងបបួលឲ្យខ្ញុំទៅនៅជាមួយ ។

'មកនៅជាមួយម៉ាក់វិញម៉ោ ម៉ាក់ចង់តបស្នងអ្វីដែលមិនល្អ'

រហូតមកដល់ពេលនេះខ្ញុំនៅតែនឹកដល់រឿងនេះ ហើយនៅតែមិនបានសម្រេចចិត្តអ្វីទាំងអស់ ព្រោះមិនថាការត្រលប់ទៅវិញវានឹងធ្វើឲ្យខ្ញុំមានអារម្មណ៍យ៉ាងណា តាមពិតការរស់នៅទីនេះជាមួយប៉ាក៏អូខេ ប៉ាធ្វើការនៅហាងអាហារកូរ៉េ បូកជុំនឹងការលក់រូបគំនូររបស់គាត់ ថែមទាំងពេលនេះខ្ញុំមានប្អូនប្រុសអាយុបាន២ខួបផង មុខមាត់គួរឲ្យស្រលាញ់ទៀត តែនៅទីនេះខ្ញុំក៏មិនសូវជាមានមិត្តប៉ុន្មាន ទើបវាអផ្សុក ពេលមកអង្គុយគិតដល់អ្នកណាម្នាក់នៅក្រុងសូល ពេលនេះគេប្រហែលជាសប្បាយនឹងជីវិតយុវវ័យរបស់គេហើយ ។

ចុងកូអ៊ីន...

"ចង់ទៅកូរ៉េក៏ទៅៗ"

"ប៉ា"

ចាំដែលបីប្អូនប្រុសចូលមកឃើញខ្ញុំអង្គុយមើនៅមុខកុំព្យូទ័រប្រហែលជាដៅចេញ ខ្ញុំភ្ញាក់ព្រើត ងើបអង្គុយត្រង់ខ្លួន ហើយញញឹមដាក់គាត់ ។

"និយាយរឿងអី កូនចង់ទៅកូរ៉េពីអង្កាល់"

"មាត់ក៏ប្រាប់ថាមិន តែចិត្តហោះទៅដល់ទីនោះទៅហើយ ចង់ទៅក៏ទៅទៅ!"

"ចាំដេញកូនឬ"

"មិនមែនបែបនោះទេ គឺឃើញកូនទឹកមិត្តភក្តិ អ្នកណាក៏ដោយឲ្យតែចាកចេញពីប្រទេសកំណើតគឺតែងតែនឹកអីចឹងហើយ យកអានេះទៅ" ចាំបោះសំបុត្រយន្តហោះមកលើតុ ធ្វើឲ្យខ្ញុំបើកភ្នែកធំៗដោយការភ្ញាក់ផ្អើល "មុខមាត់សម្តែងចេញដល់ថ្នាក់នោះហើយនៅថាមិនទៀត"

ខ្ញុំរុញសំបុត្រនោះចេញឆ្ងាយ ហើយធ្វើមាត់អេចអូច÷

"កូនចង់ទៅពីអង្កាល់"

"ចាំទុកត្រង់ហ្នឹង សម្រេចចិត្តដោយខ្លួនឯងទៅថាទៅឬមិនទៅ"

"ចាំយកលុយពីណាទៅវិញ"

"គឺលក់គំនូរបាន"

"មិនគួរខាតលុយទេ"

"គិតថាជាកាដូថ្ងៃកំណើតទៅចុះ"

"មិនទេ ទោះយ៉ាងណាក៏កូនមិនទៅ"

"មែនឬអ៊ំស"

"មែន!!!"

មកដឹងខ្លួនម្តងទៀតខ្ញុំក៏ឆ្លងទឹកឆ្លងសមុទ្រដោយមានវ៉ាលីមកជាមួយនៅព្រលានយន្តហោះទៅហើយ (លឿនជាងការគិត) ប្រទេសកូរ៉េនៅតែដូចដើម គ្រប់គ្នាដើរខ្វាត់ខ្វែងនិងមានស្នាមញញឹមឲ្យគ្នាមិនប្រែប្រួល ខុសតែម្នាក់ៗត្រលប់មកវិញមានគ្រួសារ ចំណែកខ្ញុំនៅតែឈរសំកាំងនៅកន្លែងដើម ព្រោះមិនដឹងថាធ្វើយ៉ាងម៉េចបន្ត ។

"ប៉ុងអ៊ុល!"

សម្លេងរបស់ម៉ាក់ធ្វើឱ្យខ្ញុំភ្ញាក់ព្រើត ងាកទៅមើលដោយការចម្លែកចិត្ត ខ្ញុំមិនបានប្រាប់អ្នកណាផងថាមក?

"ម៉ាក់"

ខ្ញុំឱបម៉ាក់ ហើយយំដោយការនឹករលឹក ម៉ាក់មើលទៅចាស់ជាងមុន តែបែរជាមានស្នាមញញឹមស្រស់ថ្លាដែលខ្ញុំមិនធ្លាប់ជួប យើងឱបគ្នាយោលខ្លួនទៅមកដូចអង្រឹង ។

"ធំពេញក្រមុំហើយ"

"ម៉ាក់មើលទៅមានក្តីសុខដល់ហើយ!"

"ប្រាកដហើយ គឺម៉ាក់មានស្នេហា" ម៉ាក់ធ្វើដៃជារូបបេះដូងព្រមទាំងលាដៃទៅបុរសដែលមានឫកពាចិត្តល្អ មានស្នាមញញឹមឱ្យខ្ញុំ "បុរសម្នាក់នេះហើយជាស្នេហារបស់ម៉ាក់"

"អ៊ឺ"

"យើងនិយាយគ្នាក្នុងឡានទៅ"

នៅតាមផ្លូវធ្វើដំណើរ ម៉ាក់គិតតែនិយាយពីរឿងស្នេហារបស់ខ្លួនរហូតដល់ខ្ញុំញញឹមតាមដែរ ម៉ាក់មិនធ្លាប់មើលទៅមានក្តីសុខបែបនេះទេ មិនថាអាយុប៉ុន្មាន មនុស្សយើងមានស្នេហាបានជានិច្ច ។

"ម៉ាក់សំណាងល្អដល់ហើយ"

"មនុស្សស្រីយើងបានទទួលសិទ្ធិបែបនេះគ្រប់គ្នាហ្នឹង ហើយកូនស្នេហាម៉េចម៉ាដែរ"

"ខ្ញុំមានពីអង្កាល់ស្នេហានោះ នៅជាមួយប៉ាគឺបានតែជួយគាត់លើកអាហារ មិនអីបើងគឺលាងចាននៅផ្ទះ ក្រៅពីនោះគឺរៀន ខ្ញុំមិនចូលចិត្តអាមេរិកទេ"

"ប្រែថានៅចូលចិត្តកូរៀន"

"ប្រាកដហើយ"

"ចុះជាកូរៀនមុនអត់"

"កូរៀនមុនអីគេ ខ្ញុំគ្មានទេ"

"បើស្រលាញ់គ្នាជាមួយគេ ម៉ាក់ក៏គ្មានបញ្ហាដែរ"

ខ្ញុំមើលមុខម៉ាក់ ហើយសើច÷

"ម៉ាក់និយាយស្អីហ្នឹង វាផុតអស់ហើយ"

"ដែលគេចទៅព្រោះម៉ាក់ជាឧបសគ្គមិនមែនឬ"

"ម៉ាក់..."

"បើពេលនោះគ្មានម៉ាក់ កូនអាចនឹងមិនសម្រេចចិត្តថាទៅ កូន និង កូអឹន ក៏ប្រហែលជាបានស្រលាញ់គ្នាដូចគូស្នេហ៍ទូទៅ ជាសង្សារនឹងគ្នាបាត់ទៅហើយ"

"នោះជារឿងសម័យក្មេងណាម៉ាក់ ម្យ៉ាងទៀតទោះជារឿងនេះម៉ាក់មិនពាក់ព័ន្ធ ក៏ខ្ញុំនៅកូរ៉េមិនបានដែរ ម៉ាក់មិនទៅ ប៉ាមិនទៅ ខ្ញុំទៅនៅជាមួយអ្នកណា ស្រលាញ់ មិនស្រលាញ់ ចុងក្រោយក៏ខ្ញុំត្រូវទៅដដែល"

ម៉ាក់ដកដង្ហើមធំដាក់ហេតុផលនេះ ហើយអង្អែលក្បាលខ្ញុំ÷

"ស្នេហាពេលនោះជារឿងរបស់ក្មេង ចុះពេលនេះធំហើយនៅស្រលាញ់គេអត់"

"វាកន្លងផុតទៅយូរហើយ...មិនដឹងទេ ត្រូវជួបគ្នាមួយរយៈទៀតទើបខ្ញុំអាចតបបាន"

"ជាំ"

"មនុស្សយើងគឺត្រូវតែធំហើយ"

"មិននិយាយរឿងតានតឹងល្អជាង ថ្ងៃនេះទៅគេងនៅផ្ទះម៉ាក់ កូនក៏ទាក់ទងទៅមិត្តភក្តិឱ្យរៀបរយទៅ ស្អែកម៉ាក់នឹងនាំទៅញ៉ាំបាយនៅហាងទំនើបៗ"

"អ៊ុំ អរគុណ"

បន្ទប់ដេករបស់ខ្ញុំត្រូវបានតុបតែងយ៉ាងល្អហាក់ដូចខ្ញុំមកនៅជាមួយម៉ាក់១០ឆ្នាំហើយ ឬអាចមកពីម៉ាក់ព្យាយាមបញ្ចុះបញ្ចូលខ្ញុំឱ្យមកនៅក៏ថាបាន ទើបដាក់សម្ពាធខ្ញុំដោយការតុបតែងបន្ទប់ស្អាតៗដើម្បីឱ្យខ្ញុំដឹងខ្លួនខុស ។ អ្វីដំបូងដែលខ្ញុំត្រូវធ្វើបន្ទាប់ពីងូតទឹកហើយគឺទាក់ទងទៅ ស៊ឺជីន ហើយពេលបានឮសម្លេងរបស់ខ្ញុំ នាងប្រមក់នោះក៏ស្រែកលាន់ ។

(អ្ហាៗៗ ខ្ញុំទឹកតាំងពីក្បាលដល់ចុងជើង)

"អី ស្តាប់ឯងហើយខ្ញុំអាចដឹងបានថាឯងទឹកខ្ញុំប៉ុណ្ណា"

(យើងត្រូវចេញមកជួបគ្នា ស្អែកនេះ យើងត្រូវជួបគ្នា)

"ខ្ញុំមានណាត់ជាមួយម៉ាក់ស្អែកនេះ ចាំខ្ញុំគេទៅណាត់ឯងចុះ ខ្ញុំមិនចាប់ទៅវិញទេ ឯងភ័យទៅដល់ណានេះ"

(បានយ៉ាងម៉េច ខ្ញុំទឹកឯង តែឯងមើលឃើញថាជារឿងកំប្លែងនេះ ឯងដឹងទេថាយើងខានជួបគ្នាយូរប៉ុណ្ណា បីឆ្នាំហើយពីយ ខ្ញុំចង់អាប់ដេតរឿងនោះរឿងនេះ មានរឿងច្រើនដែលត្រូវនិយាយឲ្យឯងស្តាប់)

"ឯងប្រាប់តាមមែលហើយតើ"

(វានៅមិនទាន់ដល់ពេលដែលខ្ញុំចង់និយាយ ឯងដឹងទេថាទីនេះមានរឿងអីកើតឡើងខ្លះ កូអឹន ជស់ឯងក្លាយជាខាណូវ៉ា សម្លាប់មិនងាប់ហើយ"

ខ្ញុំក្តាប់ទូរសព្ទណែន ឈ្មោះរបស់គេនៅតែមានឥទ្ធិពលចំពោះខ្ញុំជានិច្ច ខាណូវ៉ា អ្ហឹម...ក៏មិនគួរឲ្យចម្លែក ។

"បើគេមិនព្រានទើបចម្លែក មុខមាត់ក៏ល្អ ឋានៈក៏ល្អ អ្នកណាក៏ចង់ធ្វើជាសង្សារគេដែរ"

(ឯងបណ្តោយឲ្យមនុស្សបែបនោះរបូតពីដៃបានយ៉ាងម៉េច ខ្ញុំថាចំណុចមួយដែលគេប្រើជីវិតបែបនេះគឺមកពីឯងក្បត់ចិត្តគេ)

"ខ្ញុំយកបញ្ហាឯណាទៅក្បត់ចិត្តគេ"

(បញ្ហាដែលគេស្រលាញ់ឯងនោះអ្ហី គ្មានអារម្មណ៍ថាស្តាយខ្លះទេអ្ហី ឯងបំផ្លាញបេះដូងគេតាំងពីថ្ងៃនោះ)

"គេប្រហែលជាតាមរកស្រីដែលគេចង់ប្រគល់ស្នេហាឲ្យហើយ"

"មើលទៅដូចជារកមិនឃើញទេ នៅទីនេះខ្ញុំឮព័ត៌មានរបស់គេមិនលើកលែងសូម្បីមួយថ្ងៃ គេក្លាយជាពួកកូនហៃសូដែលសេពគប់តារាដើម្បីឲ្យបានព័ត៌មានទៅមួយថ្ងៃៗ"

"បើគេជួបអ្នកដែលល្អ ខ្ញុំក៏សប្បាយចិត្តដែរ"

(អ៊ុ មនុស្សល្អ!)

មាត់ប្រាប់ថាសប្បាយចិត្ត តែដៃបែរជាញ័រពេលដាក់ទូរសព្ទចុះ នេះប្រែថាគេនៅតែតាមរកស្នេហាដែលធ្លាប់ប្រាប់ថានឹងស្រលាញ់ឱ្យបានច្រើនជាងខ្ញុំមែនឬ?

បើគេជួបស្នេហាបែបនោះមែន ខ្ញុំ...នឹងធ្វើយ៉ាងណា?

ថ្ងៃបន្ទាប់

ម៉ាក់នាំខ្ញុំមកហាងអាហារទំនើបកណ្តាលក្រុងដែលអាហារមួយចានៗតម្លៃជិត៥ម៉ឺនវ៉ុន ខ្ញុំមើលមីនុយហើយក៏អង្គុយរឹងខ្លួន ទោះជាប្រាប់ថាចាំវ តែថ្ងៃបែបនេះក៏បបួលឱ្យញ៉ាំមិនចូល មើលទៅតុក្បែរដែលកុម្ម៉ង់ចុះ អាហារមួយចានស្មើនឹងថ្នាំហិត ញ៉ាំយ៉ាងណាក៏មិនឆ្អែត តែថ្លៃដល់ជិត៥ម៉ឺន ។

"កុម្ម៉ង់ទៅ មួយពេលនេះអីតាំងចិត្តចាំវ"

"តែថាវ៉ា..."

"បានទៅនៅបរទេសកុំប្រាប់ថាមិនចេះញ៉ាំរបស់អស់នេះ មិនអីទេ ម៉ាក់កុម្ម៉ង់ឱ្យ!"

ម៉ាក់ចាត់ចែងកុម្ម៉ង់អាហារឱ្យខ្ញុំរៀបរយដោយដឹងច្បាស់ថាខ្ញុំចូលចិត្តប្រភេទណា ហាងនេះជាហាងបែបស្ងប់ស្ងាត់ក៏ពិតមែន តែមនុស្សមកច្រើនគួរសម ។

"ទម្រាំតែមកហាងនេះបាន ត្រូវកក់ទុកមុនណ៎ា"

"លក់ដាច់ថ្នាក់នេះឬ ប្រែថាឆ្ងាញ់"

"ទើបនឹងផ្សាយតាមធីវី ទើបមនុស្សដង្ហែរគ្នាម៉ោ ម៉ាក់ចង់ឱ្យកូនជាប់ចិត្តទើបជ្រើសរើសហាងនេះ"

"អីចឹងមុនញ៉ាំ កូនសុំចូលបន្ទប់ទឹកលាងដៃឱ្យរៀបរយសិន"

"ឱ្យម៉ាក់ទៅជាមួយទេ"

"ទៅបន្ទប់តើម៉ាក់ កូនធំហើយ"

"បារម្ភក៏ខុស"

ខ្ញុំញញឹមដាក់ម៉ាក់ មុននឹងដើរទៅបន្ទប់ទឹក តែហើយខ្សែភ្នែកដូចជាទៅឃើញរូបភាពអ្វីម្យ៉ាងរហូតដល់រាងកាយទាំងមូលទៅ

ដារីងព្រោះខួរក្បាលមិនបញ្ញា ដាចផ្ទាក់តែមួយដែលគេក៏ធ្វក់ ហើយផាកមកប្រសព្វភ្នែកព្រមគ្នាដោយមិនបានណាត់ ។

"ជុងអ៊ុល"

"កូអ៊ីន"

យើងសម្លឹងគ្នាយ៉ាងយូរ ហាក់ដូចពិភពលោកទាំងមូលនៅពេលនេះមានតែយើងពីរនាក់ តែហើយពិភពរបស់យើងក៏នៅតែដំណើរការបន្តពេលសម្លេងរបស់ស្រីតូចដែលមកជាមួយហៅគេ ។

"មានអីឬអត់បង"

ខ្ញុំមើលដៃដែលចាប់ កូអ៊ីន ដោយការឈឺចាប់ បែបមិនអាចបរិយាយបាន ទោះពេលវេលាកន្លងផុតទៅ តែបេះដូងខ្ញុំនៅតែលោតញាប់ពេលបានជួបគេ ។

"ជុងអ៊ុល!"

ខ្ញុំរត់គេច មិនដឹងខ្លួនដូចគ្នាថាកំពុងរត់គេចអ្វី តែក៏រត់រហូតដល់ភ្លេចទៅថាម៉ាក់កំពុងចាំនៅក្នុងហាងបាយ កូអ៊ីន រត់តាមដូចមនុស្សឆ្កួតមកស្ទាក់មុខខ្ញុំនៅកណ្តាលចំណោមមនុស្សម្នាដែលដើរទៅមកខ្វាត់ខ្វែង ព្រមទាំងកញ្ឆក់ដៃខ្ញុំដោយការភករឿង ។

"រត់គេចបងធ្វើអី"

"អត់ទេ"

"អូនរត់គេចបងទៀតហើយ បីឆ្នាំ ១៥ថ្ងៃ និងអាបីម៉ោងដែលកន្លងផុតមិនបានធ្វើឱ្យអូនផ្លាស់ប្តូរទេឬយ៉ាងម៉េច"

គេដកដង្ហើមដង្ហក់ដោយកំហឹង ខ្សែភ្នែកសម្លឹងមកពេញដោយអាការៈដាច់ខាតដែលធ្វើឱ្យខ្ញុំស្រៀវពោះ ។

"ហើយរត់តាមខ្ញុំធ្វើអី ទៅនៅជាមួយស្នេហាថ្មីដែលខ្លួនឯងតាមរកទៅ"

@ amazingshelf.blogspot.com

"តើបងរកស្នេហាថ្មីមិនបានទើបបានជារត់តាមអូន បងជិតភ្លេចអូនបានហើយ ស្រីឆ្កួតអើយ!!!"

គ្រប់គ្នាឈរមើលយើង ហើយចាប់ផ្តើមខ្សឹបខ្សៀវពាក្យជាច្រើនដូចជាកំពុងទស្សនាប្តីប្រពន្ធឈ្លោះគ្នា ខ្ញុំមើលច្វេងស្តាំ ហើយនិយាយតិចៗ

ព្រោះខ្លាចមនុស្សមើលច្រើនដាង់នេះ ។

"ទៅនិយាយគ្នានៅកន្លែងផ្សេងទៅ"

"អូនទឹងគេចបង់ទៀត មានឱកាសក៏និយាយគ្នាត្រង់នេះហើយ"

"ខ្ញុំគ្មានអីនិយាយ"

"អូនច្បាស់ជាមាន អូនកំពុងតែប្រចណ្ឌ ហើយបង់កំពុងតែឆ្កួត ពេលបានជួបអូនដែលមិនស្មានថាបានជួប អូនក៏រត់គេចបង់ទៀត ធ្វើបាបបង់បីឆ្នាំ នេះអូនចង់ធ្វើបាបបង់ត្រឹមតែជួបគ្នាមួយភ្លែតទៀត ហើយឬ!"

"ឈប់ក្លាម"

"មិនឈប់"

"ខ្ញុំប្រាប់ឲ្យឈប់ក្លាម!" ខ្ញុំយកដៃដាល់ទ្រូងគេ តែ កូអឹន ក៏មិនបានគេច ទើបត្រូវមួយទំហឹង ស្រែកចាច "ខ្លួនឯងប្រាប់ថាគេគេច តែក៏ទៅមានអ្នកផ្សេងជារឿយៗ ហ៊ាននិយាយយ៉ាង់ម៉េចថាចាំគេ ហ៊ាន យ៉ាង់ម៉េច ហឺៗ"

"ព្រោះបង់មិនជួបអ្នកផ្សេងដែលដូចអូន មិនជួបអ្នកផ្សេងដែល បង់ស្រលាញ់បានខ្លាំង់ដូចដែលស្រលាញ់អូន តំបូង់បង់គិតថាខ្លួននៅ ក្មេងពេកទើបមានអារម្មណ៍ពាក់ព័ន្ធនឹងរឿងនេះខ្លាំង តែពេលបានជួប អូនម្តង់ទៀត" កូអឹន យកដៃក្តោបដើមទ្រូង់ខាង់ឆ្វេង់ខ្លួនឯង "បេះដូង បង់ក៏លោតញាប់ បង់នឹកអូន បង់ជិតឆ្កួតហើយ!"

"មិនបាច់ម៉ោនិយាយល្អទេ"

"ត្រូវឲ្យធ្វើម៉េចទើបអូនជឿ ត្រូវឲ្យបង់លុតជង្គង់អង្វរករមិនឲ្យអូន ទៅណាទើបជឿឬយ៉ាង់ម៉េច" គេយកអ្វីម្យ៉ាង់ចេញពីអាវ ហើយលើក បង្ហាញ "លុយក៏អូនមិនចង់បាន ស្នេហារបស់បង់ក៏អូនមិនចង់បាន តែ អូនម៉ោប្រចណ្ឌបង់ បង់គួរធ្វើយ៉ាង់ម៉េច បង់ស្រលាញ់អូនចង់ងាប់ទៅ ហើយ! ស្នេហារបស់អូន ត្រូវឲ្យបង់ទិញដោយស្អីទើបបានវ៉ាម៉ោ ហ៎ា!"

"..."

"បង់ជិតអស់កម្លាំង់ហើយ"

"បើខ្ញុំសុំឲ្យលោកទិញ..."

"ទិញ?"

"ទិញដោយអ្វីទាំងអស់ដែលលោកមាន លោកឱ្យបានទេ"

"ហើយអូនចង់យកស្អី"

"ស្រលាញ់គឺគ្រប់គ្រាន់ហើយ"

"អូនមិនចាំបាច់សុំទេ ស្រីឆ្កួត!"

កូអ៊ីន ទាញខ្ញុំទៅឱបនៅកណ្ដាលសម្លេងហៅានិងទះដៃ អ្នកដែលឈរមើល ខ្លះក៏ច្រល់ ហើយរត់ក្នុករកមើលម៉ាស៊ីនថត ព្រោះគិតថានេះគឺជាការថតកុន ។ ខ្ញុំឱប កូអ៊ីន វិញ ហើយសើច បិទ្ធាំកន្លងមកមើលទៅវាដូចជាខាតពេលទទេដែលយើងចាកចេញពីគ្នាទៅថ្ងៃ។ ដោយគ្មានអ្វីប្រសើរឡើង ក្រៅពីការនឹករលឹកដែលកើនទ្វេដង ។

"ចុះស្រីផ្សេង"

"បោះចោល!" កូអ៊ីន និយាយ ហើយសើច "ចុះអូនម៉ោរស់នៅទីនេះវិញអត់"

"ជំសមល្មមអាចចិញ្ចឹមខ្ញុំបាននៅ"

"សុំឲ្យតែប្រាប់ថាព្រមឲ្យចិញ្ចឹមមួយម៉ាត់ទៅបានហើយ"

តាំងពីថ្ងៃតំបូងដែលជួបគ្នារហូតមកដល់ថ្ងៃនេះគេនៅតែមិនប្ដូរផ្លាស់ ពេលនោះយើងជួបគ្នាអាចនឹងនៅក្មេង តែវាក៏ពិសោធតាមរយ:ពេលវេលាថា មិនថាយូរប៉ុណ្ណា ស្នេហានៅក្នុងវ័យក្មេងរបស់យើងក៏នៅតែខ្លាំងក្លានិងមានច្រើនឡើងទៅតាមកាលវេលា ។

"អី សំនួរចុងក្រោយ" កូអ៊ីន

"អីគេ"

"ស្នេហារបស់អូនថ្លៃប៉ុន្មាន"

កូអ៊ីន នៅតែមិនឈប់លេងដោយការលើកហៀកក្នុងដៃបង្ហាញទើបខ្ញុំញាក់ស្មា ហើយខ្សឹបក្បែរត្រចៀកគេតិចៗ នោះហើយដែលធ្វើឲ្យគេញញឹមបាន ។

"អនន្ត! គណនាមិនបាន"

The End